# អដ្ឋកថា ព្រះសុត្តន្តបិដក

## បបញ្ចសូទនី
## ទុតិយភាគ

## ភាគ ២១

ពុទ្ធសករាជ ២៥៥៣

# អដ្ឋកថា ព្រះសុត្តន្តបិដក

## មជ្ឈិមនិកាយ មូលបណ្ណាសក

## ទុតិយភាគ

## ភាគ ២១

ឈ្មោះ

# បបញ្ចសូទនី

ពុទ្ធសករាជ ២៥៥៣

អធិប្បាយ

**កកចូបមសូត្រ_អលគទ្ទូបមសូត្រ_វម្មិកសូត្រ_រថវីនិតសូត្រ_និវាបសូត្រ**

**បាសរាសិសូត្រ_ចុល្លហត្ថិបទោបមសូត្រ_មហាហត្ថិបទោបមសូត្រ_មហាសារោបមសូត្រ_ចុល្លសារោបមសូត្រ**

A

# Signes et accents.



# ស្រៈពេញតួ

## *Voyelles:*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូប Romain | *a* | *ā* | *i* | *i* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
## Consonnes:

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក | ខ | គ | ឃ | ង |
| [illegible] Romain | k | kh | g | gh | ṅ |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

D


Cambodgien
Romain
c
ch
j
jh
ñ
Siamois
Laotien
Cinghalais
Birman

E

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| រ៉ូម Romain | ṭ | ṭh | ḍ | ḍh | ṇ |
| សៀម Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| សិង្ហ Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

F

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| បាលី Pâli | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| លង្កា Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| រ៉ូម Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | ພ | ຠ | ມ |
| សិង្ហ Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

H


CAMBODGIEN
Romain
y r ḷ v s h ḷ ṃ ·/.
Siamois
Laotien
Cinghalais
Birman

# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

ឥតិវុត្តក គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភុតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភុតធម៌ទាំងអស់ ។

វេទល្ល គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី

រីករាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

> ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
> ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
> មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
> បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ **ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ** គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ **ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធសាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដកពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ  ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌  ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណី បាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បាន

បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយ-សង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើមក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទបណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធ-សាសនា បានសិក្សាសិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និង

បណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះ ឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថាឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថាព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្ដើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថា

ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កា-ទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយមានព្រះ សារីបុត្ត (ឈ្មោះដូចអគ្គសាវ័ក) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធ-ទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា មហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុដ: ) ខ្វះ ( សិរិកូដ្ឋ: ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិ អំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុងឬ ដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិ

ឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡ:មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោស:និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ: ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរ:នាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ:ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរីយ: ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡ: ដែលព្រះពុទ្ធឃោស:បានប្រែមកជាអដ្ឋ-

កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបោរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ភ្លាត ហ៊ិន

ឧបាសក ទុំ ទួន

ឧបាសក ជឹម ជនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ឹម វ៉ៃយ៉ា

ឧបាសក សំ ឆាយ

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសក នាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត និត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ិត

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

## ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នួវ បូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តវក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ឆុំ សាវឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុសារញ្ញាណោ | ស សត្ថា | ធម្មាចារ្យ |
| ព្រះភិក្ខុកល្យាណធម្មោ | យឿន កល្យាណ | វិនយាចារ្យ |

| | | |
|---|---|---|
| ព្រះភិក្ខុយន្តទិន្នោ | ផល សុភ័ណ | សមណសិស្ស សាលាសតិប្បដ្ឋាន |
| ព្រះភិក្ខុបវរធម្មោ | អ៊ុល សុធា | សមណសិស្ស សាលាសតិប្បដ្ឋាន |
| សាមណេរ អគ្គកាមោ | អ៊ុម សុជាន | សមណសិស្ស សាលាសតិប្បដ្ឋាន |
| សាមណេរ កោវិនោ | ឡោះ សូវៀត | សមណសិស្ស សាលាសតិប្បដ្ឋាន |
| សាមណេរ កោវិនោ | ចាន់ បូណា | សមណសិស្ស សាលាសតិប្បដ្ឋាន |

## ផ្នែកឧបាសក

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក ហាយ ចំរើន |
| ឧបាសក សន ម៉ារឌី | ឧបាសក អ៊ឹម រ៉ៃយ៉ា |
| ឧបាសក ទុំ ទូន | ឧបាសក ហុក សឹងហួត |

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធមិជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | ទំព័រ |
|---|---|
| **អដ្ឋកថា កកចូបមសូត្រ ទី១** | ១ |
| វេលាមាន ៣ | ២ |
| គន្លងនៃពាក្យ ៥ ប្រការ | ១៤ |
| កម្រាស់ផែនដី | ១៧ |
| ឧបមាទី ៣ | ១៩ |
| ឧបមាទី ៤ | ២០ |
| **អដ្ឋកថា អលគទ្ទូបមសូត្រ ទី២** | ២២ |
| ពាក្យថា សុតំ | ៣០ |
| បរិយត្តិ ៣ យ៉ាង | ៣៣ |
| ទិដ្ឋិ ៣ យ៉ាង | ៣៩ |
| **អដ្ឋកថា វម្មិកសូត្រ ទី ៣** | ៦៥ |
| ព្រះកុមារកស្សបៈ | ៦៥ |
| ព្រះធាតុព្រះមានព្រះភាគ | ៦៨ |
| បញ្ហា ១៥ ប្រការ | ៨១ |
| ដំបូក ៤ យ៉ាង | ៨៤ |
| **អដ្ឋកថា រថវិនិតសូត្រ ទី ៤** | ៩៩ |
| ក្រុងរាជគ្រឹះ | ៩៩ |
| ជាតិភូមិ | ១០១ |
| អ្នកបដិបត្តិ ៤ ប្រភេទ | ១០៨ |
| ការប្រាថ្នា ៤ យ៉ាង | ១១០ |

ការប្រាប្ឋាតិច ៤ យ៉ាង ១១៤
សន្តោស ១២ យ៉ាង ១១៧
វិវេក ៣ យ៉ាង ១២២
ការប្រឡូកប្រឡំ ៥ យ៉ាង ១២២
ព្រះនាមផ្សេងៗ របស់ព្រះបុណ្ណមន្តានីបុត្ត ១៣០
លាភ ៥ យ៉ាង ១៣២
ចារិករបស់ព្រះមានព្រះភាគ ២ យ៉ាង ១៣៤
មណ្ឌល ៣ យ៉ាង ១៣៧
ចារិកដោយហេតុ ៤ ប្រការ ១៤០
ចារិកដោយហេតុ ៨ ប្រការ ១៤១
ចារិក ២ យ៉ាង ១៤១
ឧបាទាន ២ យ៉ាង ១៥១
វិសុទ្ធិ ៧ ១៥៣
កថាវត្ថុ ១០ ១៥៥

**អដ្ឋកថា និវាបសូត្រ ទី ៥** ១៦០
ឧបមាចម្ការស្មៅ ១៦១

**អដ្ឋកថា ធាសរាសិសូត្រ ទី ៦** ១៦៩
ព្រះមានព្រះភាគប្រៀបដូចអសិរពិស..... ១៧០
វិហារព្រះមានព្រះភាគវិបស្សី ...... ១៧៤
អចលចេតិយ ៤ កន្លែង ១៧៥
ការស្វែងរករបស់ព្រះអរិយៈ ១៨២
អធិប្បាយ ឧរុវេលា ១៩០

ប្រវត្តិសហម្បតិព្រហ្ម ២០១
ឧបមាដូចផ្កាឈូក ៤ ប្រភេទ ២០៧
ដំណើរថ្ងៃចេញអភិនេស្រ្កមណ៍ ២១១
ទំនាយព្រះលក្ខណៈរបស់ព្រាហ្មណ៍ ៨ នាក់ ២២២
ប្រវត្តិសង្ខេបព្រះអញ្ញាកោណ្ឌញ្ញៈ ២២៤
រឿង ឧបកាជីវក ២២៨
ការត្រាស់ដឹងរបស់បញ្ចវគ្គិយ ២៣៤

**អដ្ឋកថា ចុល្លហត្ថិបទោបមសូត្រ ទី ៧ ២៣៨**
ព្រាហ្មណ៍ជាណុស្សោណិ ២៤០
ព្រះតថាគតឧប្បត្តិឡើងក្នុងលោក ២៥១
អធិប្បាយលម្អរបទដើម ជាដើម ២៥៦
បទថា សាត្ថៈ សព្យញ្ជនៈ ២៥៨
សីល និងសាជីវៈ ២៦៣
ពូជ ៥ យ៉ាង ២៧១
ស្រូវ ៧ ប្រភេទ ២៧៣
ឧបមាការទិញម្រឹគ ២៧៧
បរិក្ខារ ៨ ២៧៩
ពោលអំពីសេនាសនៈ ២៨៥

**អដ្ឋកថា មហាហត្ថិបទោបមសូត្រ ទី៨ ២៩៣**
សង្គហៈ ៤ ២៩៣
ប្រៀបអរិយសច្ចៈដូចស្នាមជើងដំរី ២៩៥
ឧបមាដូចជាងត្បាញផែង ២៩៦
បទថា បឋវីធាតុ ៣០៣

*បទថា អាបោធាតុ* ៣១៤
*បទថា តេជោធាតុ* ៣១៤
*បទថា វាយោធាតុ* ៣១៦

**អដ្ឋកថា មហារាហុលោវាទសូត្រ ទី ៩** ៣២៣

**អដ្ឋកថា ចូឡមាលុង្ក្យសូត្រ ទី ១០** ៣២៧
*អធិប្បាយ ក្រុមទាំង ៦* ៣២៨

# អដ្ឋកថា បបញ្ចសូទនី
## នៃព្រះសុត្តន្តបិដក
## មជ្ឈិមនិកាយ មូលបណ្ណាសកៈ
## ឱបម្មវគ្គសូត្រ
## ភាគ ២១

### កកចូបមសូត្រ ទី ១

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

(១) *កកចូបមសូត្រ មានពាក្យផ្តើមថា ខ្ញុំម្ចាស់បានស្តាប់មកយ៉ាងនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងកកចូបមសូត្រនោះ ដូចតទៅនេះ ។ ពាក្យថា* ***មោលិយផគ្គុន*** *នេះ ផ្នួងសក់លោកហៅថា* ***មោលី*** *។ ដូចលោកពោលទុកថា ៖*

ឆេត្វាន មោលី វរគន្ធវាសិតំ វេហាសយំ

ឧក្ខិបិ សាក្យបុង្គវោ រតនចង្កោដវរេន វាសវោ

សហស្សនេត្តោ សិរសា បដិគ្គហិ ។

*កំពូលសាក្យៈដ៏ប្រសើរបំផុត ទ្រង់កាត់ព្រះផ្នួង ( គឺផ្នួងសក់ ) ដែល*

អប់ដោយគ្រឿងក្រអូបយ៉ាងល្អ ហើយបោះឡើងទៅក្នុងអាកាស ស្ដេចវាសវសហស្សនេត្រ ទ្រង់យកប្រអប់កែវដ៏ប្រសើរ ទូលលើព្រះសិរសាទទួលទុក ដូច្នេះ ។ ក្នុងកាលដែលលោកនៅជាគ្រហស្ថ មានផ្ទះសក់ធំ ។ ព្រោះដូច្នោះ ទើបគេហៅលោកថា **មោលិយផគ្គុន** សូម្បីបួសហើយ ជនទាំងឡាយក៏នៅចាំឈ្មោះនោះបាន ។

បទថា **អតិវេលំ** ប្រែថា ហួសព្រំដែន ។ ក្នុងបទនេះ **អតិវេលំ** នោះ វេលាមានបី គឺ ៖

១ កាលវេលា ព្រំដែន គឺ វេលា

២ សីមវេលា ព្រំដែន គឺ ដែនខេត្ត

៣ សីលវេលា ព្រំដែន គឺ សីល

ពិតហើយ ក្នុងពាក្យថា ទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះ ដូច្នេះ វេលានេះ ឈ្មោះថា **កាលវេលា** ។ ក្នុងពាក្យថា ភិក្ខុដែលមានធម៌តាំងនៅហើយ ទីងមិនឈានកន្លងដែន ដូច្នេះ វេលានេះ ឈ្មោះថា **សីមវេលា** ។ ក្នុងពាក្យថា ការមិនកន្លងល្មើសវេលា គឺ ឈ្មោះ **សេតុឃាតវិរតិ** អរិយមគ្គដែលសម្លាប់នូវបាបធម៌ រាប់ចូលហើយក្នុងព្រះអរិយមគ្គ ឈ្មោះថា **សេតុ** និងក្នុងពាក្យថា ឈ្មោះថា **វេលា** ព្រោះ

អត្ថថា ការមិនកន្លងល្មើសនេះ ដូច្នេះ វេលានេះ ឈ្មោះថា **សីល-វេលា** ។

ព្រះមោលិយផគ្គុននោះ រមែងឈានកន្លងព្រំដែន តាមដែលពោលហើយនោះ សូម្បីទាំង ៣ កាល ។ ពិតហើយ កាលវេលាសម្រាប់ឲ្យឱវាទភិក្ខុនីទាំងឡាយនៅមាន ។ កាលណា ព្រះអាទិត្យអស្តង្គតហើយ ព្រះមោលិយផគ្គុននោះ ក៏នៅពោលប្រៀនប្រដៅ ទើបឈ្មោះថា ហួសវេលានោះ ។ ឈ្មោះថា ប្រមាណ ( ការកំណត់ ) ក្នុងការពោលប្រៀនប្រដៅភិក្ខុនីទាំងឡាយ ។ ឈ្មោះថា **សីមមរិយាទា** ប្រែថា **ព្រំដែន** ព្រះមោលិយផគ្គុននោះ ពោលប្រៀនប្រដៅ លើសពីប្រាំមួយម៉ាត់ឡើងទៅ ទើបឈ្មោះថា លើសសីមវេលានោះ ។ ក៏ព្រះមោលិយផគ្គុន កាលណានៅពោលធម៌ ក៏ធ្វើដូចលេង ( មានការនិយាយកំប្លែងជាដើម ) រមែងពោលពាក្យច្រើន ល្មមតែនឹងគ្រប់គ្រាន់ឲ្យត្រូវអាបត្តិបាន ។ ដោយអាការយ៉ាងនេះ ឈ្មោះថា **លើស** សូម្បីនូវសីលវេលា ។

(២) បទថា **សំសដ្ឋោ** គឺ ជាអ្នកនៅច្រឡូកច្រឡំរួមសុខរួមទុក្ខជាមួយគ្នា ។ បទថា **សម្មុខា** គឺ ខាងមុខ ។ បទថា **អវណ្ណំ ភាសតិ** សេចក្តីថា ភិក្ខុអង្គណា ៗ ឃើញពួកភិក្ខុនីទាំងនោះធ្វើកិច្ច មានការដាំបាយ

ជាដើម ក៏នឹងពោលរបស់ដែលមិនមែនគុណថា ភិក្ខុនីពួកនេះប្រព្រឹត្ត មិនល្អ លំបាកប្រដៅ ជាអ្នកធ្វើឫកគ្រាន់បើ គង់មិនត្រូវអាបត្តិ ដូច្នេះ ។

បទថា **អធិករណម្បិ ករោន្តិ** សេចក្តីថា ព្រះមោលិយផគ្គុន រមែងទាញអធិករណ៍ ( រឿងរ៉ាវ ) ដល់ភិក្ខុទាំងឡាយនេះថា ចាប់តាំងពីឃើញភិក្ខុនីទាំងឡាយនេះហើយ ទាស់ភ្នែក ការបូជាផ្កាឈើក្នុងវិហារនេះ ឬថា ការបាត់បែងផ្សេង ៗ មានការលាងសម្អាតអាសនៈ និងការព្រោះព្រំជាដើម រមែងធ្វើដោយភិក្ខុនីទាំងនេះ ភិក្ខុនីទាំងនេះ ជាកុលធីតា ជាអ្នកមានសេចក្តីខ្មាស់អៀន ពួកលោកម្ចាស់ពោលយ៉ាងនេះដល់ភិក្ខុនីទាំងនោះ ពួកលោកម្ចាស់មានអាបត្តិឈ្មោះនេះ ពួកលោកម្ចាស់ត្រូវមកសម្នាក់ ព្រះវិន័យធរ ហើយឲ្យវិនិច្ឆ័យដល់យើង ។ បទថា **មោលិយ-ផគ្គុនស្ស អវណ្ណំ ភាសតិ** សេចក្តីថា ភិក្ខុណា ៗ រមែងពោលរបស់ដែលមិនមែនគុណ ឈ្មោះថា អាបត្តិ រមែងមិនមានដល់ភិក្ខុនេះ ត្រង់បរិវេណរបស់ព្រះមោលិយផគ្គុននេះ មិនថា ភិក្ខុនីគ្រប់កាលជានិច្ច ដូច្នេះ ។ បទថា **អធិករណម្បិ ករោន្តិ** សេចក្តីថា រមែងទាញអធិករណ៍ដល់ភិក្ខុទាំងឡាយនោះថា ចាប់តាំងពីយើងឃើញព្រះមោលិយផគ្គុនត្មេរះហើយ រមែងទាស់ភ្នែក អ្នកណា ៗ ក៏មិនអាចសូម្បីតែក្រឡេកមើលកន្លែងនៅ

របស់ពួកភិក្ខុដទៃ ក្នុងវិហារនេះបាន ពួកភិក្ខុនី ដែលមកកាន់វិហារនេះ បានអាស្រ័យព្រះថេរៈ ( ព្រះមោលិយផគ្គុន ) មួយអន្លើពិត ៗ ទើបបាន ឱវាទខ្លះ ការស្វាគមន៍ខ្លះ បទឧទ្ទេសខ្លះ លោកជាបុត្ររបស់អ្នកមានត្រកូល មានសេចក្ដីអៀនខ្មាស់ មានសេចក្ដីរំខាន ពួកលោកបានពោលពាក្យសម្ដីយ៉ាងនេះៗ បែបនេះ ពួកលោកត្រូវមកឲ្យព្រះវិន័យធរ វិនិច្ឆ័យដល់យើង ដូច្នេះ ។ សេចក្ដីថា **សោ ភិក្ខុ ភគវន្តំ ឯតទវោច** សេចក្ដីថា បានក្រាបទូលដើម្បីប្រាថ្នាត្រូវការក៏ទេ តែឬប្រាថ្នាដើម្បីឲ្យគេបែកគ្នាក៏ទេ ដែលពិតដើម្បីស្វែងរកប្រយោជន៍ប៉ុណ្ណោះ ។

បានឮថា ភិក្ខុនោះគិតថា កាលណាភិក្ខុ ( មោលិយផគ្គុន ) នេះប្រឡូកប្រឡំយ៉ាងនេះ ការសាបសូន្យយសនឹងកើតឡើង របស់ដែលមិនមែនយសនេះ ជាទោស សូម្បីដល់ព្រះសាសនា ក៏មោលិយផគ្គុននេះត្រូវភិក្ខុដទៃជាស់តឿន ហើយក៏មិនព្រមវៀរចាក ព្រះមានជ័ព្រះភាគជាម្ចាស់ទ្រង់សម្ដែងធម៌ ឲ្យឱវាទហើយ នឹងវៀរចាក ដូច្នេះ ។ ព្រោះភិក្ខុនោះជាអ្នកស្វែងរកប្រយោជន៍ ទើបបានក្រាបទូលព្រះមានព្រះភាគជាម្ចាស់ថា **អាយស្មា ភន្តេ** ជាដើម ប្រែថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមោ-លិយផគ្គុននៅប្រឡូកប្រឡំជាមួយពួកភិក្ខុនីហួសវេលា ជាដើម ។ បទថា

**អាមន្តេសិ** គឺថា គួរឲ្យជ្រាប ។ បទថា **អាមន្តេតិ** ប្រែថា ត្រាស់ហៅ ។ បទថា **សទ្ធា** ប្រែថា ដោយសទ្ធា ។ បទថា **តស្មា** សេចក្តីថា ក៏ព្រោះហេតុដែលលោកជាបុត្រអ្នកមានត្រកូលជាអ្នកបួសដោយសទ្ធា ឬហេតុដែលលោកនៅស្និទ្ធស្នាលជាមួយភិក្ខុនីទាំងឡាយនោះ មនុស្សពួកណាជេរភិក្ខុនី ឬប្រហារភិក្ខុនី កើតសេចក្តីទោមនស្ស ទាស់ចិត្តក្នុងមនុស្សពួកនោះ កាលណាអ្នកលះបង់សេចក្តីស្និទ្ធស្នាលបានហើយ សេចក្តីទោមនស្សក៏នឹងមិនកើត ដូច្នេះ ។ បទថា **តត្រ** គឺថា ក្នុងការតិះដៀលនោះ ។ បទថា **គេហសិតា** គឺថា អាស្រ័យបញ្ចកាមគុណ ។ បទថា **ឆន្ទា** គឺថា ពេញចិត្តដោយតណ្ហាខ្លះ ពេញចិត្តដោយបដិឃៈខ្លះ ។ បទថា **វិបរិណតំ** សេចក្តីថា ចិត្តត្រេកអរដោយអំណាចតណ្ហា ក៏ប្រែប្រួលទាំងចិត្តដែលក្រោធ ទាំងចិត្តដែលវង្វេង ក៏ប្រែប្រួលជាដទៃ ។ តែក្នុងទីនេះ ចិត្តដែលត្រេកអរដោយសេចក្តីពេញចិត្តព្រោះអំណាចតណ្ហា ក៏គួរ សូម្បីចិត្តដែលក្រោធដោយសេចក្តីពេញចិត្ត ព្រោះអំណាចបដិឃៈ ក៏គួរ ។ បទថា **ហិតានុកម្បិ** បានដល់ អនុគ្រោះ គឺ ផ្សាយទៅដោយប្រយោជន៍ដ៏ក្រៃលែង ។ បទថា **ន ទោសន្តរោ** គឺថា យើងនឹង ជាអ្នកមិនមានទោសចិត្ត ។

(៣) ព្រោះហេតុអ្វី លោកផ្តើមពាក្យថា **អថខោ ភគវា** ជាដើម ។

បានឮថា សុម្បីការគិតថា យើងឲ្យឱវាទត្រឹមនេះហើយ នឹងវៀរចាកពីការប្រទូស្តប្រទូស្តជាមួយភិក្ខុនីទាំងឡាយ ដូច្នេះ របស់ព្រះមោលិយផគ្គុន មិនបានកើតឡើង ។ ក៏ព្រះមោលិយផគ្គុននោះ ជាអ្នកជំទាស់ជាមួយព្រះមានព្រះភាគជាម្ចាស់ ប្រៀបដូចជាគន្លឹះទ្វារសំពត់ដ៏ស្តើង ។ ក្នុងគ្រានោះ ព្រោះទ្រង់ឃើញភិក្ខុអ្នកទូន្មានបានដោយកម្រប៉ុណ្ណេះ ភាពជាភិក្ខុអ្នកប្រដៅងាយទាំងឡាយ ក្នុងបឋមពោធិកាលក៏មកប្រាកដដល់ ព្រះមានព្រះភាគជាម្ចាស់ ដូចបុគ្គលដែលឃ្លានប្រាថ្នាអាហារ អ្នកស្រេកទឹកប្រាថ្នាទឹកផឹក អ្នកប៉ះទង្គិចភាពរងា ប្រាថ្នាភាពក្តៅឧណ្ហ ។ អ្នកប្រទះនឹងទុក្ខប្រាថ្នាសុខ ដូច្នោះ ។ លំដាប់នោះ ទ្រង់មានបំណងនឹងសរសើរពួកភិក្ខុដែលប្រដៅងាយទាំងនោះ ទើបបានទេសនានេះ ។ បណ្តាបទទាំងនោះ បទថា **អារាធយឹសុ** ប្រែថា ឲ្យត្រេកអរ គឺ ឲ្យកាន់យក ។ បទថា **ឯកំ សមយំ** ប្រែថា សម័យមួយ ។ បទថា **ឯកាសនភោជនំ** បានដល់ ការឆាន់អាហារក្នុងវេលាបុរេភត្តតែមួយដង ។

ពិតហើយ តាំងតែពីព្រះអាទិត្យរះឡើងរហូតដល់ថ្ងៃត្រង់ សុម្បីភិក្ខុឆាន់អាហារ ១០ ដង លោកក៏ប្រាថ្នាយកក្នុងសេចក្តីថា ឆាន់អាហារមួយដង យ៉ាងនេះ ។ បទថា **អប្បាពាធតំ** គឺ ប្រាសចាកអាពាធ ។ បទថា

**អប្បាតង្កតំ** គឺ ប្រាសចាកទុក្ខ ។ បទថា **លហុដ្ឋានំ** បានដល់ មានរាង កាយរហ័សរហួន ។ បទថា **ពលំ** ប្រែថា មានកម្លាំងកាយ ។ បទថា **ផាសុវិហារំ** គឺ រាងកាយនៅជាសុខ ។

សួរថា ហេតុដូចម្តេច បានជាព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ទុកដោយសូត្រនេះ ។

ឆ្លើយថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ដល់កាលឲ្យលះការឆាន់អាហារក្នុងវេលាវិកាល នៅពេលថ្ងៃក្នុងសូត្រនេះ តែក្នុងកទ្ទាលិសូត្រ ទ្រង់ត្រាស់ឲ្យលះការឆាន់អាហារក្នុងវេលាវិកាល នៅពេលយប់ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់មិនបានឲ្យភិក្ខុលះការឆាន់អាហារក្នុងវេលាវិកាលទាំងពីរនេះព្រមគ្នាទេ ។

សួរថា ព្រោះហេតុអ្វី ។

ឆ្លើយថា ក៏ព្រោះអាហារក្នុងវេលាវិកាលទាំងពីរនេះ សត្វទាំងឡាយប្រព្រឹត្តរហូតដល់ធ្លាប់ក្នុងវដ្ដៈ ហើយកុលបុត្រសុខុមាលនៅមាន កុលបុត្រទាំងនោះ បើលះអាហារក្នុងវេលាវិកាលទាំងពីរនេះព្រមគ្នា រមែងលំបាក ព្រោះដូច្នោះ ទើបទ្រង់មិនឲ្យលះព្រមគ្នា គឺ ឲ្យលះការឆាន់អាហារនោះម្តងមួយពេល គឺ ឲ្យលះអាហារក្នុងវេលាវិកាល នៅវេលាថ្ងៃមួយពេល

និងឲ្យលះអាហារក្នុងវេលាវិកាលនៅពេលយប់មួយពេល ។ ក្នុងពីរពេលនោះ ក្នុងសូត្រនេះ ត្រាស់ឲ្យលះការឆាន់អាហារក្នុងវេលាវិកាលនៅពេលថ្ងៃត្រង់ ។ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់មិនមែនបង្ហាញភ័យ ឲ្យលះការឆាន់អាហារក្នុងវេលាវិកាលប៉ុណ្ណោះទេ តែទ្រង់សម្តែងអានិសង្ស ទើបឲ្យលះ ដោយហេតុនោះ សត្វទាំងឡាយទើបលះបានដោយងាយ ព្រោះដូច្នោះ កាលនឹងសម្តែងអានិសង្ស ទើបទ្រង់ត្រាស់គុណប្រយោជន៍ទាំងប្រាំនេះ ( គឺ មានអាពាធតិច មានការលំបាកតិចជាដើម ) ។

បទថា **អនុសាសនី ករណីយា** សេចក្តីថា ត្រូវប្រៀនប្រដៅរឿយៗថា ពួកលោកចូរធ្វើរបស់នេះ កុំធ្វើរបស់នេះ គឺ មានតែកិច្ចធ្វើឲ្យកើតសតិប៉ុណ្ណោះ និងទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រាបឋមពោធិកាលដោយហេតុត្រឹមតែប៉ុណ្ណោះ ភិក្ខុទាំងនោះ បានធ្វើរបស់ដែលគួរធ្វើ បានលះរបស់ដែលគួរលះ ភិក្ខុទាំងឡាយជាអ្នកប្រដៅងាយ ជឿស្តាប់ពាក្យឱវាទ ។

ឥឡូវនេះ កាលណាទ្រង់នាំឧបមា ដើម្បីទូន្មានដល់ភិក្ខុទាំងនោះដែលជាអ្នកប្រដៅងាយ ទើបទ្រង់ត្រាស់ពាក្យថា **សេយ្យថាបិ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **សុភូមិយំ** បានដល់ ផ្ទៃដីរាបស្មើ ដូចក្នុង

ប្រយោគថា បុគ្គលគប្បីសាបព្រោះពូជក្នុងផ្ទៃដីដែលល្អ ក្នុងស្រែល្អដែល ប្រាសចាកគល់ឈើជាដើម និងពាក្យក្នុងប្រយោគ ដែលមានមកក្នុង ប្រយោគថា ផ្ទៃដីដែលស្អាត ជាផ្ទៃដីដែលល្អជាដើម ។ បទថា **ចតុម្ម-ហាបថេ** បានដល់ ក្នុងផ្លូវធំបែកជាពីរ ធ្លងកាត់ទៅមក ។ បទថា **អាជញ្ញរថោ** បានដល់ រទេះទឹមដោយសេះ ដែលហ្វឹកហាត់ល្អហើយ ។ បទថា **ឱធស្តបតោទោ** សេចក្តីថា នាយសារថីដែលច្បាស់ឈានឡើងលើ រទេះហើយ អាចដើម្បីនឹងកាន់ខ្សែដែលដាក់ទទឹង ហើយសំយុងចុះ ។ បទថា **យោគ្គាចរិយោ** បានដល់ នាយសារថី ។ អ្នកណារមែងហ្វឹក ហាត់សេះ អ្នកនោះឈ្មោះថា **អស្សទម្មសារថិ** ។ បទថា **យេនិច្ឆកំ** គឺ រមែងប្រាថ្នាទៅផ្លូវណា ។ បទថា **យទិច្ឆកំ** គឺ រមែងត្រូវការ ចេញទៅទីណា ។ បទថា **សារេយ្យ** គឺ គប្បីទៅផ្លូវត្រង់ខាងមុខ ។ បទ ថា **បច្ចាសារេយ្យ** គឺ ឲ្យត្រឡប់ ។ បទថា **ឯវមេវ ខោ** សេចក្តីថា ដូចជានាយសារថីនោះ រមែងប្រាថ្នានឹងទៅផ្លូវណា ៗ សេះក៏នឹងឡើងទៅ ផ្លូវនោះ ៗ រមែងប្រាថ្នាដោយគតិណា ៗ ក៏កាន់យកគតិនោះ ៗ ឯងទៅ សេះទាញរទេះទៅ ក៏មិនហាម មិនវាយ តែសេះឈានជើងទៅលើផ្ទៃដី រាបស្មើដ៏ល្អ ប៉ុណ្ណោះ ។ ពាក្យដែលយើងគប្បីពោលដដែល ៗ ក្នុងកិច្ច

ទាំងឡាយនោះ មិនមានដោយអាការយ៉ាងនេះ ចូរធ្វើការនេះ កុំធ្វើការនេះ មានកិច្ចដែលគួរធ្វើ ក៏គ្រាន់តែជាស់សតិប៉ុណ្ណោះ ដូច្នេះ កិច្ចដែលគួរធ្វើ ក៏ជាការដែលភិក្ខុសូម្បីទាំងនោះ ធ្វើមកអំពីមុនហើយទាំងអស់ កិច្ចមិនគួរធ្វើលោកលះចេញហើយ ។ បទថា **តស្មា** សេចក្តីថា ពួកភិក្ខុអ្នកប្រដៅងាយ ប្រៀបធៀបដោយយានដែលទឹមដោយសេះអាជានេយ្យ ក៏លះអកុសលធម៌បាន ត្រឹមតែឲ្យកើតសតិប៉ុណ្ណោះ ព្រោះដូច្នោះ សូម្បីពួកអ្នក ក៏ត្រូវលះអកុសលធម៌ចេញ ។ បទថា **ឯលណ្ឌេហិ** សេចក្តីថា បានឮថា ដើមល្ហុងទាំងឡាយរមែងប្រទូស្ត និងដើមសាលៈ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ហើយយ៉ាងនោះ ។ បទថា **វិសោធេយ្យ** គឺ គប្បីកាប់ដើមល្ហុងទាំងឡាយ និងវល្លិ៍ដទៃចេញហើយ ក៏សំអាតដោយយកទៅចោលខាងក្រៅ ។ បទថា **សុជាតា** បានដល់ តាំងនៅដោយល្អ ។ បទថា **សម្មា បរិហរេយ្យ** គឺថា គប្បីបិទរបងធ្វើឲ្យចម្រើន មើលថែរក្សាឲ្យត្រឹមត្រូវ ដោយការស្រោចទឹកខ្លះ ជ្រួយដីពូនគល់តាមវេលាដ៏សមគួរខ្លះ កាត់វល្លិ៍ និងដង្កត់ឈើជាដើមខ្លះ យកសំបុកស្រមោចខ្មៅចេញខ្លះ យកសរសៃពីងពាង និងកំណាត់ឈើស្ងួតចេញខ្លះ ។ សេចក្តីចម្រើនជាដើម មានខ្លឹមសារដូចពោលទុកមកទាំងអស់ ។

(៤) ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលណាទ្រង់នឹងសម្តែងទោសនៃការមិនអត់ធន់ ទើបទ្រង់ត្រាស់ពាក្យថា **ភូតបុព្វំ** ជាដើម ។ បណ្តាពាក្យទាំងនោះ បទថា **វេទេហិកា** នេះ ជាឈ្មោះ កុលធីតាអ្នកអាស្រ័យនៅក្នុងវេទេហរដ្ឋ ។ ម្យ៉ាងទៀត លោកហៅបញ្ញាថា **វេទ** ។ អ្នកណារមែងទៅ រមែងប្រព្រឹត្តទៅដោយបញ្ញា ហេតុនោះ អ្នកនោះ ឈ្មោះថា **វេទេហិកា** អធិប្បាយថា បណ្ឌិត ។ បទថា **គហបតានី** គឺ ស្ត្រីមេ ផ្ទះ ។ បទថា **កិត្តិសទ្ទោ** គឺ កិត្តិស័ព្ទល្បី ។ បទថា **សោរតា** បានដល់អ្នកប្រកបដោយសេចក្តីស្ងប់ស្ងៀម ។ បទថា **និវាតា** គឺ ប្រព្រឹត្តបន្ទាបខ្លួន ។ បទថា **ឧបសន្តា** គឺ ជាអ្នកស្ងួតបូត ។ បទថា **ទក្ខា** បានដល់ជាអ្នកច្លាតក្នុងការងារទាំងឡាយ មានការដាំបាយ ក្រាលកន្ទេលដេក និងដុតភ្លើង ជាដើម ។ បទថា **អនលសា** គឺ ជាអ្នកក្រោកឡើង ( ឧស្សាហ៍ ) ។ បទថា **សុសំវិហិតកម្មន្តា** គឺ មានការងារដែលចាត់ចែងទុកហើយយ៉ាងល្អ ។ លោកសម្តែងថា ទាសីម្នាក់ខ្ជិលច្រអូសតែងចាប់ភាជនៈណាៗ ក៏ធ្វើឲ្យភាជនៈនោះៗ បែក ឬធែប , ទាសីនេះ មិនមែនដូច្នោះ ។ បទថា **ទិវា ឧដ្ឋាសិ** សេចក្តីថា ក្រោកឡើងក្នុងវេលាដែលព្រះអាទិត្យរះឡើងខ្ពស់ ហើយមិនធ្វើការងារ សូម្បីការរែកទឹកដោះ

គោជាដើម ដែលគួរធ្វើពីព្រលឹម ។ បទថា **ហេ ជេ កាឡិ** សេចក្តីថា យ៉ើ ! មេទាសី ព្រោះហេតុអ្វីបានជាហឯង ក្រោកឡើងយឺតម្ល៉េះ ឯង មិនសប្បាយ ឬអ្វី ។ បទថា **នោ វត រេ កិញ្ចិ** សេចក្តីថា កាលបើមិន បើមិនមានការឈឺក្បាល ឈឺខ្នងជាដើមទេ ហេតុនោះ ទើបនាងនោះពោល ថា យើស ! មីទាសីគម្រក់ ព្រោះហេតុអ្វី នាងឯងក្រោកឡើងថ្ងៃម្ល៉េះ យ៉ាងនេះ ហើយខឹងក្រោធ ទាស់ចិត្ត ជ្រួញចិញ្ចើម ។ បទថា **ទិវាតរំ ឧដ្ឋានសិ** គឺ ក្នុងថ្ងៃស្អែកឡើង ក៏ក្រោកឡើងថ្ងៃជាងមុន ។ បទថា **អនត្តមនំ វាចំ** មេផ្ទះនោះពោលថា អើ ! មេទាសីថោកទាប ហឯមិន ស្គាល់ប្រមាណរបស់ខ្លួនឯង សំគាល់ថារឹងណាស់ឬ ឥឡូវនេះ កាលនឹង ឲ្យនាងទាសីនោះដឹងកំហុសខ្លួន ទើបបន្ទឺសម្លេងរបស់មនុស្សខឹង ។ បទថា **បដិវិស្សកានំ** ប្រែថា អ្នកនៅផ្ទះជិតខាង ។ បទថា **ឧជ្ឈាបេសិ** គឺថា ដើរឃោសនាឲ្យគេមើលងាយ ។ បទថា **ចណ្ឌី** គឺ មិនស្ងប់ស្ងៀម ជា មនុស្សអាក្រក់ ។ អធិប្បាយគុណទាំងឡាយ មានត្រឹមប៉ុណ្ណេះដោយ អាការយ៉ាងនេះ តែទោសកើតឡើងជាទ្វេគុណ ច្រើនជាងគុណនោះ ។ ធម្មតាថា គុណទាំងឡាយ រមែងកើតឡើងសន្សឹម ៗ មក ។ តែទោស នោះ គ្រាន់តែមួយថ្ងៃក៏ផ្សាយទៅ ។ បទថា **សោរត សោរតោ** ប្រែថា

ជាមនុស្សស្លូតបូតយ៉ាងក្រៃលែង ។ ដល់គេពោលថា ជាព្រះសោតាបន្ន ឬហ្ន៎ ! ព្រះសកទាគាមី ព្រះអនាគាមី ព្រះអរហន្ត ឬហ្ន៎ ! ។ បទថា **ផុសន្តិ** បានដល់ គន្លងពាក្យសម្ដី ដែលប្រាកដមកពាល់ត្រូវ ប៉ះទង្គិច ពេលនោះទើបដឹងបានថា ភិក្ខុនោះជាអ្នកស្លូតបូត ។ មួយវិញទៀត ភិក្ខុអ្នកតាំងនៅក្នុងអធិវាសនខន្តី គប្បីជ្រាបថា ជាភិក្ខុអ្នកស្លូតបូត ។ បទថា **យោ ចីវរ ។បេ។ បរិក្ខារហេតុ** សេចក្ដីថា ភិក្ខុអង្គណា កាលបានបច្ច័យទាំងឡាយ មានចីវរជាដើម ដែលប្រណីត ៗ ទាំងនេះ រមែងធ្វើការប្រចបាច់ជើង ប្រចបាច់ខ្នងជាដើម ដោយនិយាយពាក្យមួយម៉ាត់ប៉ុណ្ណោះ ។ បទថា **អលភមានោ** គឺថា កាលណាមិនបាន ដូចដែលធ្លាប់បានមកពីមុន ។ បទថា **ធម្មំយេវ សក្ករោន្តោ** គឺថា កាលណាធ្វើសក្ការៈ គឺ ការដែលធ្វើឲ្យល្អចំពោះធម៌នោះឯង ។ បទថា **គរុករោន្តោ** គឺថា ធ្វើការគោរព គឺ ឲ្យជាភារៈ ។ បទថា **មានេន្តោ** គឺថា ធ្វើឲ្យជាទីស្រឡាញ់ ដោយសេចក្ដី ឱនលំទោន ។ បទថា **បូជេន្តោ** បានដល់ បូជាដោយបច្ច័យ ។ បទថា **អបចាយមានោ** បានដល់ ឱនលំទោន សម្ដែងសេចក្ដីកោតក្រែង បន្ទាបខ្លួនចំពោះធម៌នោះឯង ។

## គន្លងនៃពាក្យ ៥ ប្រការ

(៥) ព្រះមានព្រះភាគជាម្ចាស់ កាលបើទ្រង់សម្ដែងទោសនៃសេចក្ដីមិនអត់ធន់ យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់នឹងសម្ដែងគន្លងនៃពាក្យ ៥ ប្រការ ដោយព្រះតម្រាស់ថា ពួកជនរមែងអត់ទ្រាំយ៉ាងនេះ ហើយត្រាស់ពាក្យថា **បញ្ចិមេ ភិក្ខវេ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **កាលេន** ប្រែថា ដោយកាលវេលាដែលសមគួរ ។ បទថា **ភូតេន** ប្រែថា ដោយពាក្យដែលពិត ។ បទថា **សណ្ហេន** គឺថា ដោយពាក្យសម្ដីដែលសុភាព ។ បទថា **អត្ថសញ្ហិតេន** ដោយពាក្យដែលអាស្រ័យប្រយោជន៍ អាស្រ័យហេតុ ។ **អកាលេន** ជាដើម ប្រែថា ដោយកាលដែលមិនសមគួរ ជាដើម បណ្ឌិតគប្បីជ្រាបដោយអំណាចនៃធម៌ ដែលជាបដិបក្ខដល់ធម៌ទាំងនោះ ។ បទថា **មេត្តចិត្តា** គឺ កើតមេត្តាចិត្ត ។ បទថា **ទោសន្តរា** គឺ ចិត្តដែលទោសៈប្រទូសរ៉ាយហើយ គឺ កើតទោសៈឡើងហើយក្នុងខាងក្នុង ។ បទថា **តត្រាបិ** គឺ ក្នុងគន្លងនៃពាក្យទាំងនោះ ។ បទថា **ផរិត្វា** គឺ បង្ហោនទៅ ។ បទថា **តទារម្មណំ ច** គឺ ធ្វើពាក្យសម្ដីឲ្យជាអារម្មណ៍របស់ចិត្តនោះទូទៅក្នុងលោក ភិក្ខុធ្វើបុគ្គលអ្នកកាន់យកគន្លងនៃពាក្យ ៥ ប្រការមកហើយ មកជាអារម្មណ៍របស់មេត្តាចិត្ត កាលធ្វើសត្វដ៏សេសឲ្យជាអារម្មណ៍របស់មេត្តាចិត្តនោះឯងទៀត ទើបឈ្មោះថា ធ្វើឲ្យជាអារម្មណ៍របស់ចិត្ត

នោះទូទៅ ក្នុងលោក ។ ក្នុងសេចក្តីនោះ គប្បីជ្រាបសេចក្តីនៃពាក្យដូច្នេះ បទថា **តទារម្មណញ្ច** បានដល់ ធ្វើឲ្យជាអារម្មណ៍នៃមេត្តាចិត្តនោះ ។ បទថា **សព្វាវន្តំ** បានដល់ មានសត្វទាំងអស់ ។ បទថា **លោកំ** បានដល់ សត្វលោក ។ បទថា **វិបុលេន** បានដល់ មានសត្វមិនមែនតិចជាអារម្មណ៍ ។ បទថា **មហគ្គតេន** គឺ ប្រកបដោយចិត្តមហគ្គតភូមិ ។ បទថា **អប្បមាណេន** គឺ ចម្រើនល្អហើយ ។ បទថា **អវេរេន** គឺ មិនមានទោស ។ បទថា **អព្យាបជ្ឈេន** គឺ មិនមានទុក្ខ ។ បទថា **ផរិត្វា វិហរិស្សាម** សេចក្តីថា ពួកយើងបង្អោនដល់បុគ្គលនោះ និងសត្វលោកទាំងអស់ធ្វើឲ្យជាអារម្មណ៍របស់ចិត្តនោះ ដោយចិត្តដែលប្រកបដោយមេត្តាបែបនោះហើយ ។

(៦) ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់ឧបមាដែលបង្ហាញដល់អត្ថនោះ ទើបទ្រង់ត្រាស់ថា **សេយ្យថាបិ** ជាអាទិ៍ ។ បណ្តាបទទាំងនោះ បទថា **អបឋវឹ** បានដល់ នឹងធ្វើមិនឲ្យមានផែនដី អធិប្បាយថា នឹងឲ្យដល់ការមិនមានផែនដី ។ បទថា **តត្រ តត្រ** ប្រែថា ទីនោះៗ ។ បទថា **វិកិរេយ្យ** គឺ យកបន្តិលើកដីឡើងរោយដូចគ្រាប់ពូជទាំងឡាយ ។ បទថា **ឱដ្ឋុភេយ្យ** គឺ ស្តោះទឹកមាត់ ។ បទថា **អបឋវឹ ករេយ្យ** សេចក្តីថា អ្នកណាក៏ដោយ នឹងធ្វើសេចក្តីព្យាយាមដោយកាយវាចាយ៉ាងនេះ ក៏មិន

អាចធ្វើផែនដីដ៏ធំ មិនឲ្យជាផែនដីឡើយ ។

## ផែនដីកម្រាស់ ២៤០.០០០ យោជន៍

បទថា **គម្ភីរា** ប្រែថា ជ្រាលជ្រៅ គឺ ពោលដោយចំណែកដែលក្រាស់ជ្រៅ ( ពីរសែនបួនម៉ឺនយោជន៍ ) ។ បទថា **អប្បមេយ្យ** ប្រែថា រកប្រមាណមិនបាន គឺថា កំណត់មិនបានក្នុងផ្លូវទទឹង ។ បទថា **ឯវមេវ ខោ** នេះ ជាការប្រៀបធៀបដោយសេចក្ដីឧបមាក្នុងទីនេះ មេត្តាចិត្តគប្បីឃើញដូចផែនដី ។ បុគ្គលដែលកាន់យកគន្លងនៃពាក្យប្រាំយ៉ាងមកហើយ ដូចបុរសកាន់យកចបនិងបង្គីមកហើយ ។ បុរសនោះ មិនអាចធ្វើផែនដីដ៏ធំមិនឲ្យជាផែនដីបានដោយចប និងបង្គី យ៉ាងណា បុគ្គលកាន់យកគន្លងនៃពាក្យប្រាំយ៉ាងមកហើយ ក៏នឹងមិនអាចដើម្បីធ្វើមេត្តាចិត្តរបស់អ្នកទាំងឡាយឲ្យប្រែប្រួលបាន ដូច្នោះ ។

### គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមាទី ២ ដូចតទៅនេះ ៖

(៧) បទថា **ហលិទ្ទី** បានដល់ ពណ៌លឿងយ៉ាងណាមួយ ។ បទថា **នីលំ** បានដល់ ពណ៌ខៀវ សំរិទ្ធ ឬបៃតង ។ បទថា **អរូបី** ប្រែថា មិន

មិនមានរូប ។

សួរថា ក៏ **បរិច្ឆិន្នាកាស** ក្នុងចន្លោះនៃពួកឈើទាំងពីរ ឬដើមឈើ ឬកន្លែងដេក ឬសិលា ក៏ប្រាកដថា រូបមិនមែនឬ ? ព្រោះហេតុអ្វី ក្នុងទីនេះ ព្រះមានព្រះភាគជាម្ចាស់ទើបទ្រង់ត្រាស់ថា អាកាសជារបស់មិនមានរូប ដូច្នេះ ។

ឆ្លើយថា ព្រោះបដិសេធការឃើញរូប ។ ដោយហេតុនោះឯង ទើបទ្រង់ត្រាស់ពាក្យថា **អនិទស្សនោ** ប្រែថា ចក្ខុលឲ្យឃើញមិនបាន ។ ពិតណាស់ នរណា ៗ មិនអាចសរសេររូប សម្តែងរូបឲ្យប្រាកដក្នុងអាកាសនោះបាន ដូច្នោះ ទើបទ្រង់ត្រាស់ថា **អរូបី** ប្រែថា មិនមានរូប ដូច្នោះ ។ បទថា **អនិទស្សនោ** គឺ មិនមែនវិថីនៃចក្ខុវិញ្ញាណដែលធ្វើនាទីឃើញ ។ ក៏ក្នុងការប្រៀបធៀបឧបមា ក្នុងចំណុចទី ២ នេះ មេត្តាចិត្តប្រៀបដូចអាកាស , គន្លងពាក្យ ៥ យ៉ាង ប្រៀបដូចគ្រឿងសរសេរពណ៌ ៤ យ៉ាង មានជក់ជាទី ៥ ។ បុគ្គលដែលកាន់យកគន្លងនៃពាក្យ ៥ យ៉ាង ប្រៀបដូចបុរសដែលកាន់យកគ្រឿងសរសេរពណ៌ទាំងឡាយ មានជក់ជាទី ៥ មកហើយ ។ បុរសនោះ រមែងមិនអាចធ្វើរូបភាពឲ្យប្រាកដក្នុងអាកាសបានដោយគ្រឿងសរសេរពណ៌ទាំងឡាយ ដែលមានជក់ជាទី ៥ យ៉ាងណា បុគ្គលដែល

ធ្វើតាមគន្លងនៃពាក្យទាំង ៥ យ៉ាង ក៏មិនអាចធ្វើមេត្តាចិត្ត របស់លោកទាំងឡាយឲ្យប្រែប្រួល គឺ ឲ្យមានទោសៈកើតឡើងបាន ដូច្នោះ ។

## គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមាទី ៣ ដូចតទៅនេះ ៖

(៨) បទថា **អាទិត្តំ** គឺថា ភ្លើងឆេះឡើងសន្ធោសន្ធៅហើយ ។ បទថា **គម្ភីរា អប្បមេយ្យា** សេចក្តីថា ចំណែកដ៏ជ្រៅនៃស្ទឹងគង្គានេះ មាន ១ គាវុត ( មួយរយសែន ) ក៏មាន , កន្លះយោជន៍ក៏មាន , មួយយោជន៍ក៏មាន ។ ចំណែកទទឹងនៃស្ទឹងគង្គានេះ ក៏យ៉ាងនោះដូចគ្នា ។ តែដោយចំណែកបណ្តោយ ៥០០ យោជន៍ ។

សួរថា ចំណែកជម្រៅនោះ ប្រមាណមិនបាន ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះផ្ទាស់ប្តូរដោយការព្យាយាមនោះ មិនអាចធ្វើស្ទឹងនោះឲ្យក្តៅបាន ដូចទឹកដែលយកទៅតាំងលើចង្ក្រានភ្លើង ។ ក៏ទឹកប្រមាណ ១ អង្គុលី ឬ ៨ អង្គុលី អ្នកណាក៏អាចធ្វើវាឲ្យក្តៅបាន ដោយឧបាយបែបនេះខ្លះ តែស្ទឹងគង្គានេះ នរណា ៗ មិនអាចធ្វើឲ្យក្តៅបាន ព្រោះដូច្នោះព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ យ៉ាងនោះ ។ ក៏ការប្រៀបធៀបឧបមាក្នុងសេចក្តីនេះ មានដូច្នោះ មេត្តាចិត្ត ប្រៀបដូចស្ទឹងគង្គា ។ បុគ្គលដែល

កាន់យកគន្លងនៃវាចា ៥ យ៉ាងមកហើយ ប្រៀបដូចបុរស ដែលកាន់គប់ភ្លើងមកហើយ ។ បុរសនោះមិនអាចធ្វើស្ទឹងគង្គា ឲ្យក្តៅដោយគប់ភ្លើង យ៉ាងណា បុគ្គលដែលកាន់យកគន្លងនៃវាចា ៥ យ៉ាងមកហើយ ក៏នឹងមិនអាចធ្វើមេត្តាចិត្តឲ្យប្រែប្រួល ( គឺជាទោសៈ ) បានដូច្នោះ ។

## គប្បីជ្រាបវិនិច្ឆ័យឧបមាទី ៤ ដូចតទៅនេះ ៖

(៥) បទថា **វិឡារភស្តា** ប្រែថា សម្លៀកស្បែកខ្លាត្រី ។ បទថា **សុមទ្ទិតា** ប្រែថា ជំប្រចបាច់ល្អហើយ ។ បទថា **សុបរិមទ្ទិតា** គឺ ជំប្រចបាច់សម្លាប់ឲ្យទន់ដូចជាសំឡី រៀបរយហើយដោយជុំវិញ ទាំងខាងក្នុង និងខាងក្រៅ ។ បទថា **តូលិនី** គឺថា ជារបស់ស្មើនឹងសំឡីដើមរកា សំឡីវល្លិ៍ ។ បទថា **ឆិន្នសស្សរា** ប្រែថា មិនមានសំឡេងស្រួយ ។ បទថា **ឆិន្នបព្ភរា** ប្រែថា មិនមានសំឡេងស្រួយណែន ។ ក៏ការប្រៀបធៀប ឧបមាក្នុងចំណុចនេះ មានយ៉ាងនេះ គឺ មេត្តាចិត្តប្រៀបដូចសម្លៀកស្បែកខ្លាត្រី ។ បុគ្គលដែលកាន់យកគន្លងនៃពាក្យ ៥ យ៉ាងមកហើយ ប្រៀបដូច បុរសដែលកាន់យកឈើ ឬអំបែងក្បឿងមកហើយ ។ បុរសនោះមិនអាចយកឈើ ឬអំបែងក្បឿងវាយសម្លៀកស្បែកខ្លាត្រីឲ្យមានសំឡេងលាន់ស្រួយ យ៉ាងណា បុគ្គល

ដែលកាន់យកគន្លងនៃពាក្យ ៥ យ៉ាងមកហើយ ក៏មិនអាចធ្វើមេត្តាចិត្តឲ្យប្រែប្រួល គឺ ឲ្យប្រព្រឹត្តទៅតាមទោសៈបានដូច្នោះ យ៉ាងនោះ ។

(១០) បទថា **ឱចរា** គឺ ប្រព្រឹត្តបន្ទាប អធិប្បាយថា អ្នកធ្វើកម្មដ៏ថោកទាប ។ បទថា **យោ មនោ បទោសេយ្យ** សេចក្តីថា អ្នកណាមិនថា ភិក្ខុ ឬភិក្ខុនីញ៉ាំង ចិត្តឲ្យប្រទូស្ត អត់ធន់នឹងការអារដោយរណារនោះមិនបាន ។ បទថា **ន មេ សោ តេន សាសនករោ** សេចក្តីថា អ្នកនោះមិនឈ្មោះថាជាអ្នក ធ្វើតាមពាក្យប្រៀនប្រដៅរបស់តថាគត ព្រោះហេតុអត់ធន់មិនបាន ក៏ប៉ុន្តែថា អាបត្តិរមែងមិនមានដល់លោក ព្រោះអត់ធន់ចិត្តមិនបាននោះទេ ។

(១១) បទថា **អណុំ វា ថូលំ វា** ប្រែថា មានទោសតិច ឬថាមានទោសច្រើន ។ បទថា **យំ តុម្ហេ នាធិវាសេយ្យាថ** សេចក្តីថា បុគ្គលណាដែលគប្បីជាអ្នកដែលពួកលោកអត់សង្កត់ចិត្តមិនបាន ។ បទថា **នោ ហេតំ ភន្តេ** អធិប្បាយថា ពួកខ្ញុំព្រះអង្គមិនឃើញគន្លងនៃពាក្យដែលខ្ញុំព្រះអង្គអត់សង្កត់ចិត្តមិនបានក៏ទេ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់កាន់យកដល់ទីបំផុតព្រះអរហត្ត ទើបទេសនាទៅតាមលំដាប់អនុសន្ធិថា សេចក្តីនោះនឹងជាប្រយោជន៍ ឧបការៈ និងសេចក្តីសុខដល់អ្នកទាំងឡាយអស់កាលដ៏យូរ ដោយប្រការដូច្នេះឯង ។

( ចប់ អដ្ឋកថា កកចូបមសូត្រ ទី ១ )

# អដ្ឋកថា
# អលគទ្ទូបមសូត្រ ទី ២

(១២) អលគទ្ទូបមសូត្រផ្តើមថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងអលគទ្ទូបមសូត្រនោះ តទៅនេះ ៖

ជនទាំងឡាយពួកណា បៀតបៀនត្មាត ហេតុនោះ ជនពួកនោះឈ្មោះថា អ្នកបៀតបៀនត្មាត បុព្វបុរសដែលបៀតបៀនត្មាតរបស់អ្នកនោះមានហើយ ហេតុនោះ អ្នកនោះឈ្មោះថា បុព្វបុរសអ្នកបៀតបៀនត្មាត បុត្ររបស់ត្រកូលដែលធ្លាប់សម្លាប់ត្មាតនោះ អធិប្បាយថា អ្នកខ្វល់ខ្វាយចំពោះត្រកូលអ្នកសម្លាប់ត្មាត ។ ឈ្មោះថា អន្តរាយិកធម៌ ព្រោះធ្វើអន្តរាយចំពោះស្ថានសួគ៌ និងព្រះនិព្វាន ។ អន្តរាយិកធម៌ទាំងនោះមានប្រាំយ៉ាង គឺ កម្ម កិលេស វិបាក អរិយុបវាទៈ និងអាណាវីតិក្កមៈ , ក្នុងអន្តរាយិកធម៌ទាំងនោះ អនន្តរិយកម្ម ៥ ឈ្មោះថា **កម្មន្តរាយិកធម៌** ។ ភិក្ខុនីទូសកកម្ម ក៏ដូចគ្នា ។ តែភិក្ខុនីទូសកកម្មនោះ ធ្វើអន្តរាយចំពោះព្រះនិព្វានតែម្យ៉ាង មិនធ្វើអន្តរាយចំពោះស្ថានសួគ៌ឡើយ ។ ធម៌ គឺ និយតមិច្ឆាទិដ្ឋិ ឈ្មោះថា អន្តរាយិកធម៌ គឺ **កិលេស** ។ បដិសន្ធិធម៌របស់មនុស្សខ្ទើយ សត្វតិរច្ឆាន និងឧភតោព្យញ្ជនកៈឈ្មោះថា អន្តរាយិ-

កម្ម គឺ **វិបាក** ។ ធម៌ គឺ ការចូលទៅតិះដៀលព្រះអរិយៈឈ្មោះថា អន្តរាយិកធម៌ គឺ **ឧបវាទ** ។ តែឧបវាទន្តរាយិកធម៌ទាំងនោះ រមែងធ្វើអន្តរាយ រហូតពេលដែលនៅមិនទាន់ឲ្យព្រះអរិយៈទាំងឡាយ អត់ទោស បន្ទាប់ពីឲ្យព្រះអរិយៈ អត់ទោសហើយ មិនបានធ្វើអន្តរាយទេ ។ អាបត្តិ ៧ កង ដែលភិក្ខុតាំងចិត្តកន្លងល្មើសហើយ ឈ្មោះថា អន្តរាយិកធម៌ គឺ **អាណាវីតិក្កមៈ** ។ សូម្បីអាណាវីតិក្កមន្តរាយិកធម៌ទាំងនោះ រមែងធ្វើអន្តរាយដល់ភិក្ខុដែលត្រូវអាបត្តិហើយ នៅប្ដេជ្ញាខ្លួនថា ជាភិក្ខុក្ដី មិនទៅបរិវាសកម្មក្ដី មិនសម្ដែងអាបត្តិចេញក្ដី ក្រៅពីនោះមិនបានធ្វើអន្តរាយទេ ។

ក្នុងរឿងអន្តរាយិកធម៌នោះ ភិក្ខុជាពហុស្សូត ជាព្រះធម្មកថិក រមែងដឹងអន្តរាយិកធម៌ដ៏សេស តែអ្នកមិនឆ្លាតក្នុងព្រះវិន័យ ទើបមិនដឹងអន្តរាយិកធម៌ គឺ ការកន្លងល្មើសព្រះបញ្ញត្តិ ព្រោះដូច្នោះ ភិក្ខុដែលនៅក្នុងទីកំបាំង ទើបគិតយ៉ាងនេះថា គ្រហស្ថទាំងនេះ បរិភោគកាមគុណ ៥ ជាព្រះសោតាបន្នក៏មាន ព្រះសកទាគាមីក៏មាន ព្រះអនាគាមីក៏មាន ចំណែកពួកភិក្ខុ ពិចារណាឃើញរូបដែលគួរពេញចិត្ត គប្បីដឹងដោយចក្ខុ ពាល់ត្រូវផោដ្ឋព្វារម្មណ៍ដែលគប្បីដឹងដោយកាយ រមែងប្រើប្រាស់គ្រឿង

កម្រាល និងគ្រឿងស្មៀកដណ្ដប់ដ៏ទន់ សេចក្ដីនោះទាំងអស់ គួរ , ព្រោះហេតុអ្វី , រូប សម្លេង ក្លិន រស ផោដ្ឋព្វៈរបស់ស្ត្រីប៉ុណ្ណោះ មិនគួរ , ចំណែករូបជាដើមទាំងនេះទើបគួរ អរិដ្ឋភិក្ខុប្រៀបធៀប រស និងរស យ៉ាងនេះហើយ រួមការបរិភោគដោយអំណាចរាគៈដែលមានឆន្ទៈ និងការបរិភោគ ដោយអំណាចរាគៈដែលមិនមានឆន្ទៈ ហើយកើតទិដ្ឋិលាមក ប្រៀបប្រដូចសំពត់ដែលល្អិតក្រៃលែងជាមួយក្រចៅគ្រោតគ្រាត , ប្រៀបធៀបភ្នំសិនេរុ និងគ្រាប់ស្ពៃ ជំទាស់ជាមួយព្រះសព្វញ្ញុតញ្ញាណថា ហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ទ្រង់បញ្ញត្ត បឋមបារាជិកដោយព្រះឧស្សាហ៍យ៉ាងធំ ដូចជាឃាំងមហាសមុទ្រ ទោសក្នុងព្រះបញ្ញត្តិនោះមិនមាន ជំទាស់នឹងព្រះវេសារជ្ជញ្ញាណ ដាក់ដង្កត់ឈើ និងបន្ទាជាដើមចុះក្នុងព្រះអរិយ-មគ្គ ប្រហារអាណាចក្ររបស់ព្រះជិនស្រីជាម្ចាស់ថា ទោសក្នុងមេថុនធម្មមិនមាន ។ ដោយហេតុនោះ អរិដ្ឋភិក្ខុនោះទើបពោលថា **តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ** យើងដឹងទូទៅដល់ធម៌ដែល ព្រះមានព្រះភាគទ្រង់សម្ដែងហើយយ៉ាងនោះ ជាដើម ។ បទថា **ឯវំ ព្យាខោ** ស្មើនឹង **ឯវំ វិយខោ** ។ ក្នុងពាក្យថា **សមនុយុញ្ជន្តិ** ជាដើម ភិក្ខុទាំងឡាយ សួរថា លោកមានលទ្ធិអ្វី ទើបពោលលទ្ធិ ឈ្មោះថា សាកសួរ ។ លើកទិដ្ឋិឡើង

ឈ្មោះថា ប្រកាន់ទិដ្ឋិ ។ សាកសួរហេតុថា ព្រោះហេតុអ្វី ទើបលោក ពោលយ៉ាងនេះ ឈ្មោះថា **សមនុភាសន** ។ ក្នុងពាក្យថា **អដ្ឋិកង្ខលូបមា** ជាដើម ឧបមាដូចជាឆ្អឹងឆ្អឹង ព្រោះអត្ថថា មានការត្រេកអរតិច , ឧបមាដូចជាដុំសាច់ ព្រោះអត្ថថា ជារបស់ទូទៅដល់មនុស្សជាច្រើន , ឧបមាដូចជាគប់ភ្លើងស្មៅ ព្រោះអត្ថថា តាមដុត , ឧបមាដូចជារណ្ដៅរងើកភ្លើង ព្រោះអត្ថថា ធ្វើឲ្យក្ដៅក្រហាយច្រើន , ឧបមាដូចជាការយល់សប្ដិ ព្រោះអត្ថថា ប្រាកដបន្តិចបន្តួច , ឧបមាដូចជារបស់ដែលខ្ចីគេមក ព្រោះអត្ថថា ប្រព្រឹត្តមួយជួរខណៈ , ឧបមាដូចជាផ្លែឈើពុល ព្រោះអត្ថថា បំផ្លាញសព្វសរីរាង្គកាយ , ឧបមាដូចជាមុខកាំបិត ព្រោះអត្ថថា កាត់ផ្ដាច់ , ឧបមាដូចជាលំពែង និងស្នូ ព្រោះអត្ថថា ចាក់ដោត , ឧបមាដូចជាក្បាលពស់ ព្រោះអត្ថថា គួររង្កៀស និងមានភ័យចំពោះមុខ ។ បទថា **ថាមសា** បានដល់ ដោយកម្លាំងនៃទិដ្ឋិ ។ បទថា **បរាមាសា** បានដល់ ព្រោះស្ទាបអង្អែលដោយទិដ្ឋិ ។ បទថា **អភិនិវិស្ស វោហរតិ** បានដល់ ការតាំងចិត្ត ពោល ឬសម្ដែង ។

(១៣) បទថា **យតោ ខោ តេ ភិក្ខូ** បានដល់ គ្រាណា ភិក្ខុទាំងនោះ ។ អរិដ្ឋភិក្ខុនេះ សូម្បីអ្នកណានឹងពោលថា មិនមានយ៉ាងនេះ តាមអធ្យាស្រ័យ

របស់ខ្លួន ក៏ព្រមទទួលពាក្យនេះថា **ឯវំ ព្យាខោ អហំ ភន្តេ ភគវតា** ដោយអានុភាពរបស់ព្រះមានព្រះភាគជាម្ចាស់ ។ បានឮថា ឈ្មោះថា អ្នកដែលអាចពោលពាក្យពីរម៉ាត់ ចំពោះព្រះភក្ត្រព្រះមានព្រះភាគទាំងឡាយមិនមាន ។ បទថា **កស្ស ខោ នាម ត្វំ មោឃបុរិស** សេចក្តីថា ម្នាលមោឃបុរស អ្នកដឹងទូទៅដល់ធម៌ដែលតថាគតសម្តែងយ៉ាងនេះ ពីអ្នកណាក្សត្រ ឬព្រាហ្មណ៍ វេស្សៈ សូទ្រៈ គ្រហស្ថ ឬបព្វជិត ទេវតា ឬមនុស្ស ។ បទថា **អថ ខោ ភគវា ភិក្ខូ អាមន្តេសិ** នេះ ជាអនុសន្ធិមួយផ្នែកដោយចំពោះ ។ បានឮថា អរិដ្ឋភិក្ខុ គិតថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ហៅយើងថា មោឃបុរស តែលោកនឹងមិនមានធម៌ដែលជាឧបនិស្ស័យនៃមគ្គ និងផល ដោយហេតុត្រឹមតែត្រាស់ថា មោឃបុរសក៏ទេ ។ ពិតហើយព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ហៅឧបសេនវង្គន្តបុត្រ ដោយវាទៈថា **មោឃបុរិស** ម្នាលមោឃបុរស អ្នកជាអ្នកវិលមកដើម្បីសេចក្តីល្មោភច្រើនបន្ទាប់មកព្រះថេរៈ ឧស្សាហ៍ព្យាយាមធ្វើឲ្យច្បាស់នូវអភិញ្ញា ៦ ដោយគិតថាសូម្បីយើង ក៏នឹងផ្គងសេចក្តីព្យាយាមបែបនោះ ធ្វើមគ្គផលឲ្យកើត ។ លំដាប់នោះ ព្រះមានព្រះភាគ កាលណាទ្រង់សម្តែងដល់អរិដ្ឋភិក្ខុជាអ្នកមិនលូតលាស់ដូចស្លឹកឈើពណ៌លឿង ដែលជ្រុះចាកទង ទើបផ្តើមសម្តែងព្រះធម៌ទេសនា

នេះ ។

(១៤) បទថា **ឧស្មិកតោបិ** សេចក្ដីថា ភិក្ខុទាំងឡាយអ្នកសម្គាល់សេចក្ដីនោះយ៉ាងណា អរិដ្ឋភិក្ខុនោះ មានលទ្ធិយ៉ាងនេះ ជំទាស់នឹងសព្វញ្ញុតញ្ញាណ បដិសេធវេសារជ្ជញ្ញាណ ប្រហារអាណាចក្រព្រះតថាគត សូម្បីលោកក៏អប់រំបញ្ញាក្នុងធម៌វិន័យនេះបានខ្លះ លោកអាស្រ័យការអប់រំបញ្ញាសូម្បីមានប្រមាណតិច ក៏ព្យាយាមធ្វើមគ្គ-ផលឲ្យកើតឡើងបានខ្លះ ដូចគំនរភ្លើងធំដែលគប្បីមាន ព្រោះអាស្រ័យកម្ទេចភ្លើង សូម្បីមានប្រមាណប៉ុនអំពិលអំពែកក្នុងគំនរភ្លើងធំដែលបានរលត់ទៅហើយ ដូច្នោះ ។ បទថា **នោ ហេតំ ភន្តេ** សេចក្ដីថា ភិក្ខុទាំងឡាយពោលជំទាស់សេចក្ដីដែលអរិដ្ឋភិក្ខុ អប់រំបញ្ញាដើម្បីប្រយោជន៍ដល់មគ្គ-ផលដែលមានបច្ច័យស្មើគ្នាថា បពិត្រព្រះអង្គដ៏ចម្រើន អរិដ្ឋភិក្ខុមានលទ្ធិយ៉ាងនេះ នឹងអប់រំបញ្ញាដូច្នោះ បានមកពីណា ។

បទថា **មង្កុភូតោ** បានដល់ ជាអ្នកគ្មានអំណាច ។ បទថា **បត្តក្ខន្ធោ** បានដល់ ដាក់-កសំយុងចុះ ។ បទថា **អប្បដិភាណោ** បានដល់ មិនឃើញអ្វី ៗ ច្បាស់លាស់ គឺ ខ្វះបដិភាណ ។ អរិដ្ឋភិក្ខុពិចារណាដល់ភាពនៃខ្លួនជាអកព្វបុគ្គលថា បានឮថា យើងទទួលពាក្យប្រៀនប្រដៅ

ដែលនាំចេញចាកទុក្ខ បែបនេះហើយ នៅតែមិនទាន់លូតលាស់ល្អ យើងមានបច្ច័យត្រូវដកចេញហើយ ដូច្នោះ ក៏អង្គុយយកចុងម្រាមជើងឆ្កឹះដី ។

(១៥) បទថា **បញ្ញាយិស្សសិ ខោ** នេះ ក៏ជាអនុសន្ធិមួយផ្នែកដោយចំពោះ ។ បានឮថា អរិដ្ឋភិក្ខុគិតថា ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា យើងជាអ្នកខ្វះធម៌ដែលជាឧបនិស្ស័យនៃមគ្គ និងផល ក៏ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់មិនបានសម្តែងធម៌ចំពោះអ្នក ដែលមានឧបនិស្ស័យប៉ុណ្ណោះទេ ទ្រង់សម្តែងធម៌ដល់អ្នកដែលមិនមានឧបនិស្ស័យផង យើងបាននូវសុគតោវាទពីសំណាក់ព្រះសាស្តាហើយ នឹងធ្វើកុសលដែលអាចចូលដល់សម្បត្តិរបស់ខ្លួន ។ គ្រានោះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងរំងាប់ព្រះឱវាទ ទើបទ្រង់ត្រាស់ថា **បញ្ញាយិស្សសិ** ជាដើម ។ ពាក្យនោះ មានសេចក្តីថា ម្នាលមោឃបុរស អ្នកហ្នឹងឯង នឹងប្រាកដក្នុងនរកជាដើមដោយទិដ្ឋិដ៏អាក្រក់នេះ ដែលឈ្មោះថា **សុគតោវាទ** របស់អ្នក មិនមានពីសម្នាក់របស់តថាគត អ្នកមិនមានប្រយោជន៍សម្រាប់តថាគត តថាគតនឹងសាកសួរភិក្ខុទាំងឡាយក្នុងទីនេះ ។ សេចក្តីថា **អថ ខោ ភគវា** នេះ ជាអនុសន្ធិមួយផ្នែក ។ ពិតហើយ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជម្រះបរិស័ទក្នុងទីនេះ ទើបទ្រង់បណ្តេញព្រះអរិដ្ឋភិក្ខុចេញពីពួក ប្រសិនបើបណ្តាបរិស័ទទាំងឡាយ

ភិក្ខុអង្គខ្លះនឹងគប្បីគិតយ៉ាងនេះថា អរិដ្ឋៈនេះឬ នឹងអាចពោលពាក្យដែលព្រះមានព្រះភាគជាម្ចាស់មិនបានត្រាស់ កាលព្រះមានព្រះភាគជាម្ចាស់ទ្រង់ផ្តើមកថា ក៏ទ្រង់ត្រាស់ជាបន្ទាន់ក្នុងកណ្តាលចំណោមសង្ឃ ពាក្យដែលត្រាស់យ៉ាងនេះ ភិក្ខុអរិដ្ឋៈប៉ុណ្ណោះមិនស្តាប់ តែជាព្រះតម្រាស់ ដែលភិក្ខុដទៃស្តាប់ហើយដូច្នោះ , ភិក្ខុអង្គខ្លះនោះ គប្បីគិតថា ព្រះសាស្តាទ្រង់និគ្គហៈភិក្ខុអរិដ្ឋយ៉ាងណា គប្បីទ្រង់និគ្គហៈយើងដូច្នោះ សូម្បីស្តាប់ហើយក៏ត្រូវស្ងៀម មិនធ្វើការអ្វីៗ ទាំងអស់ ពាក្យដែលតថាគតមិនពោល អ្នកដទៃក៏មិនមានអ្វីស្តាប់ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ជម្រះលទ្ធិក្នុងបរិស័ទ ដោយព្រះតម្រាស់ថា **តុម្ហេបិ មេ ភិក្ខវេ** ជាដើម អរិដ្ឋភិក្ខុឈ្មោះថា ជាអ្នកដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់បណ្តេញឲ្យចេញពីគណៈ ដោយការជម្រះលទ្ធិក្នុងបរិស័ទហ្នឹងឯង ។

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់ប្រកាសលទ្ធិរបស់ភិក្ខុអរិដ្ឋៈ ទើបទ្រង់ត្រាស់ពាក្យជាដើមថា **សោ វត ភិក្ខវេ** ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យជាដើមថា **អញ្ញត្រេវ កាមេហិ** ក្នុងបាលីនោះដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមានលទ្ធិយ៉ាងនេះថា ធម៌ទាំងនោះមិនអាចធ្វើអន្តរាយដល់អ្នកសេពបានពិត ភិក្ខុនោះឯងនឹងសេពវត្ថុកាម

ទាំងឡាយ គឺ ប្រព្រឹត្តមេថុនសមាចារៈ វៀរកិលេសកាម និងសញ្ញាវិតក្កៈ ដែលប្រកបដោយកិលេសកាម លះធម៌ទាំងនោះ គឺ វៀរពីធម៌ទាំងនោះ ។ បទថា **នេតំ ឋានំ វិជ្ជតិ** សេចក្តីថា ឈ្មោះថា ដោយហេតុនេះមិនមាន គឺ ហេតុនេះមិនមែនជាឋានៈ មិនមែនជាឱកាស ។ ដោយប្រការដូច្នេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកាសលទ្ធិរបស់អរិដ្ឋៈថា អរិដ្ឋៈនេះ ប្រៀបដូចជាងជ្រលក់ កាន់យកសំពត់ដែលក្រអូបខ្លះ ស្អុយខ្លះ ចាស់ខ្លះ ថ្មីខ្លះ ស្អាតខ្លះ មិនស្អាតខ្លះ មកខ្ចប់ជាមួយគ្នា យ៉ាងណា លោកក៏ធ្វើការបរិភោគចីវរប្រណីតជាដើម ដែលមិនមានឆន្ទរាគៈសម្រាប់ភិក្ខុ , ធ្វើការបរិភោគដែលមានឆន្ទរាគៈនាំមកនូវអន្តរាយ , សម្រាប់គ្រហស្ថដែលមានសីលមិនប្រចាំ និងធ្វើការបរិភោគ ដែលមានឆន្ទរាគៈដែលធ្វើការ ការពារសម្រាប់ភិក្ខុដែលមានសីលប្រចាំ រួមជាមួយគ្នាទាំងអស់ ។ ឥឡូវនេះ កាលនឹងទ្រង់សម្តែងទោសរបស់ព្រះបរិយត្តិដែលរៀនមកមិនល្អ ទើបទ្រង់ត្រាស់ថា **ឥធ ភិក្ខវេ ឯកច្ចេ** ជាដើម ។

(១៦) បណ្តាបទទាំងនោះ បទថា **បរិយាបុណន្តិ** ប្រែថា រៀនសូត្រ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សុត្តំ** ជាដើម ឧភតោវិភង្គ និទ្ទេស ខន្ធកៈ និងបរិវារៈ មង្គលសូត្រ រតនសូត្រ នាឡកសូត្រ តុវដ្តកសូត្រ ក្នុងសុត្តនិបាត

និងតថាគតវចនៈសូម្បីដទៃ ដែលមានឈ្មោះថាសូត្រ គប្បីជ្រាបថា **សូត្រ** ។ សូត្រដែលមានគាថាទាំងអស់ គប្បីជ្រាបថា **គេយ្យៈ** ។ ដោយចំពោះយ៉ាងក្រៃលែង សគ្គាថវគ្គទាំងអស់ក្នុងសំយុត្តនិកាយ គប្បីជ្រាបថា **គេយ្យៈ** ។ អភិធម្មបិដកទាំងអស់ សូត្រដែលមិនមានគាថា និងពុទ្ធវចនៈសូម្បីដទៃ ដែលសង្គ្រោះដោយអង្គប្រាំបី គប្បីជ្រាបថា **វេយ្យាករណៈ** ។ ធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ដែលមិនឈ្មោះថា **សូត្រ** ក្នុងសុត្តនិបាត គប្បីជ្រាបថា **គាថា** ។ ព្រះសូត្រ ៨២ សូត្រ ដែលទាក់ទិនដោយគាថាដែលសម្រេចមកពីសោមនស្សញ្ញាណ គប្បីជ្រាបថា **ឧទាន** ។ ព្រះសូត្រ ១១០ សូត្រ ដែលប្រព្រឹត្តទៅជាដើមថា **វុត្តមិទំ ភគវតា** គប្បីជ្រាបថា **ឥតិវុត្តក** ។ ជាតក ៥៥០ រឿង មានអបណ្ណកជាតកជាដើម គប្បីជ្រាបថា **ជាតក** ។ ព្រះសូត្រទាក់ទិនដោយអច្ឆរិយព្ភូតធម៌ សូម្បីទាំងអស់ ដែលប្រព្រឹត្តទៅដោយន័យមានជាអាទិ៍ថា **ចត្តារោ មេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា អានន្ទេ** ដូច្នេះជាដើម គប្បីជ្រាបថា **អព្ភុតធម៌** ។ ព្រះសូត្រដែលត្រាស់សួរហើយនាំមកនូវការដឹង នាំមកនូវការត្រេកអរ ទាំងអស់ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហសូត្រ សង្ខារភាជនីយសូត្រ មហាបុណ្ណមសូត្រជាដើម គប្បីជ្រាបថា **វេទល្ល** ។

បទថា **អត្ថំ ន ឧបរិក្ខន្តិ** បានដល់ មិនឃើញ និងកំណត់មិនបាន ចំពោះអត្ថនៃសូត្រ ចំពោះអត្ថនៃហេតុ ។ បទថា **អនុបរិក្ខតំ** បានដល់ កំណត់មិនបាន ។ បទថា **ន និជ្ឈានំ ខមន្តិ** បានដល់ មិនប្រាកដ គឺ មិនមកប្រាកដ ។ អធិប្បាយថា នរណា ៗ មិនអាចនឹងដឹងយ៉ាងនេះថា សីល សមាធិ បញ្ញា មគ្គ ផល វដ្ដៈ ឬវិវដ្ដៈ ទ្រង់ត្រាស់ទុកហើយ ក្នុងទីនេះ ។ បទថា **តេ ឧបារម្ភានិសំសា ចេវ** សេចក្ដីថា កុលបុត្ត ទាំងនោះ ជាអ្នកមិនលើកទោសក្នុងវាទៈរបស់បុគ្គលពួកដទៃ ជាអានិ-សង្សនៃការរៀនសូត្រ ។ បទថា **ឥតិវាទប្បមោក្ខានិសំសា ច** បានដល់ មានការដោះចេញនូវវាទៈ យ៉ាងនេះ ជាអានិសង្សនៃការរៀនសូត្រ អធិប្បាយថា មិនរៀនសូត្រដោយហេតុនេះថា កាលណាអ្នកដទៃលើក ទោសវាទៈរបស់ខ្លួន យើងនឹងដោះចេញនូវទោសនោះ យ៉ាងនេះ ។ បទថា **តញ្ចស្ស អត្ថំ នានុភោន្តិ** សេចក្ដីថា កុលបុត្រទាំងឡាយ សិក្សាធម៌ដើម្បីប្រយោជន៍ មគ្គ ឬផលឯណា សិក្សាមិនល្អ រមែងមិន បានទទួលប្រយោជន៍នោះ របស់ធម៌នោះ មយ៉ាងទៀត សូម្បីកាលណា មិនអាចនឹងលើកទោសក្នុងវាទៈរបស់អ្នកដទៃ និងដោះចេញនូវវាទៈរបស់ ខ្លួន រមែងមិនបានទទួលប្រយោជន៍នោះ ដូចគ្នា ។

(១៧) បទថា **អលគទ្ទត្ថិកោ** បានដល់ អ្នកត្រូវការអសិរពិស ។ ពាក្យថា **គទ្ទោ** ជាឈ្មោះ របស់ ពិស ។ ពិសរបស់ពស់នោះមានគ្រប់ គឺ បរិបូណ៌ ហេតុនោះ អសិរពិសនោះ ទើបឈ្មោះថា **អលគទ្ទ** មានពិសពេញខ្លួន ។ បទថា **ភោគេ** បានដល់ ខ្លួន ។ សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ក៏កុលបុត្រពួកខ្លះក្នុងលោកនេះ សិក្សាធម៌ បានដល់ សិក្សាដោយអំណាចនិស្សរណបរិយត្តិ ។

ពិតហើយ បរិយត្តិមាន ៣ គឺ ៖

**អលគទ្ទូបរិយត្តិ , និស្សរណបរិយត្តិ , ភណ្ឌាគារិកបរិយត្តិ ។**

បណ្តាបរិយត្តិទាំង ៣ នោះ ភិក្ខុណាសិក្សាពុទ្ធវចនៈ ហេតុប្រាថ្នាលាភសក្ការៈថា យើងនឹងបានចីវរជាដើម ឬមនុស្សទាំងឡាយនឹងស្គាល់យើងក្នុងចំណោមកណ្តាលបរិស័ទទាំង ៤ នេះ បរិយត្តិនុ៎ះ របស់ភិក្ខុនោះឈ្មោះថា **អលគទ្ទូបរិយត្តិ** ។ ពិតហើយ ការមិនបានសិក្សានូវពុទ្ធវចនៈហើយដេកលក់ទៅ ល្អជាងការសិក្សាយ៉ាងដូច្នេះ ។ ចំណែកភិក្ខុណាសិក្សាដោយគិតថា សិក្សាពុទ្ធវចនៈបំពេញសីលក្នុងឋានៈដែលសីលមកដល់ហើយ ឲ្យកាន់យកបន្ទាប់ពីសមាធិក្នុងឋានៈដែលសមាធិមកដល់ហើយ ផ្តើមតាំងវិបស្សនាក្នុងឋានៈ ដែលវិបស្សនាមកដល់ហើយ ធ្វើមគ្គឲ្យកើត

ធ្វើផលឲ្យជាក់ច្បាស់ ក្នុងឋានៈដែលមគ្គ-ផលមកដល់ហើយ បរិយត្តិនុ៎ះ របស់ភិក្ខុនោះ ឈ្មោះថា **និស្សរណបរិយត្តិ** ។ បរិយត្តិរបស់ព្រះខី-ណាស្រព ឈ្មោះថា ភណ្ឌាគារិកបរិយត្តិ ។ ពិតហើយ ទុក្ខសច្ចៈដែលនៅមិនទាន់កំណត់ដឹង សមុទយសច្ចៈដែលនៅលះមិនទាន់បាន មគ្គសច្ចៈដែលនៅមិនទាន់បានចម្រើន ឬនិរោធសច្ចៈ ដែលនៅមិនទាន់ធ្វើឲ្យជាក់ច្បាស់ រមែងមិនមានដល់ព្រះខីណាស្រពនោះ ព្រោះថា ព្រះខីណាស្រពនោះ បានកំណត់ដឹងខន្ធហើយ លះកិលេសបានហើយ ចម្រើនមគ្គហើយ ធ្វើឲ្យជាក់ច្បាស់នូវផលហើយ ព្រោះដូច្នោះ លោកសិក្សាពុទ្ធវចនៈទើបសិក្សាជាអ្នកទ្រទ្រង់ទុក ជាបែបបទ រក្សាប្រពៃណី អនុរក្សវង្សដូច្នោះ បរិយត្តិរបស់លោកទើបឈ្មោះថា **ភណ្ឌាគារិកបរិយត្តិ** ។

សួរថា កាលណាពួកគន្ធធុរៈមិនអាចនឹងនៅក្នុងទីកន្លែងមួយ ព្រោះធាតុកក្ខ័យជាដើម បុថុជ្ជនណា កាលណាមិនលំបាកដោយភិក្ខាចារ ហើយសិក្សាដោយគិតថា សូមព្រះពុទ្ធវចនៈដែលពីរោះដ៏ក្រៃលែងកុំឲ្យសោះសូន្យទៅ យើងនឹងទ្រទ្រង់ទុកនូវបែបផែន និងរក្សាប្រពៃណីទុក បរិយត្តិរបស់បុថុជ្ជននោះ ជាភណ្ឌាគារិកបរិយត្តិ មិនមែនឬ ។

ឆ្លើយថា មិនមែន ។

សួរថា ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះខ្លួនមិនបានតាំងនៅក្នុងកន្លែងសិក្សា ។ ពិតហើយ ឈ្មោះថា បរិយត្តិរបស់បុថុជ្ជនជាអលគទ្ទូៈខ្លះ ជានិស្សរណៈខ្លះ , បរិយត្តិរបស់ព្រះសេក្ខៈទាំង ៧ ជានិស្សរណៈតែម្យ៉ាង , បរិយត្តិរបស់ព្រះខីណាស្រព ជាភណ្ឌាគារិកបរិយត្តិប៉ុណ្ណោះ ។ ប៉ុន្តែក្នុងទីនេះ លោកប្រាថ្នាយកនិស្សរណបរិយត្តិ ។

បទថា **និជ្ឈានំ ខមន្តិ** សេចក្តីថា ធម៌ទាំងឡាយរមែងមានប្រាកដក្នុងអាគតស្ថាននៃធម៌មានសីលជាដើមថា សីលទ្រង់ត្រាស់ទុកក្នុងទីនេះ សមាធិក្នុងទីនេះ វិបស្សនាក្នុងទីនេះ មគ្គក្នុងទីនេះ ផលក្នុងទីនេះ វដ្ដៈក្នុងទីនេះ វិវដ្ដៈក្នុងទីនេះ ។ បទថា **តេញ្ចស្ស អត្ថំ អនុភោន្តិ** សេចក្តីថា កុលបុត្រទាំងឡាយ រមែងសិក្សាដើម្បីមគ្គ-ផលណា កុលបុត្រពួកនោះអាស្រ័យបរិយត្តិដែលសិក្សាល្អហើយ ធ្វើមគ្គឲ្យកើត ធ្វើផលឲ្យជាក់ច្បាស់ ហើយទទួលប្រយោជន៍នោះ របស់ធម៌នោះ ។ សូម្បីមិនអាចនឹងលើកទោសក្នុងវាទៈរបស់អ្នកដទៃក្តី មិនអាចនឹង កាន់យកឋានៈដែលខ្លួនប្រាថ្នាហើយ ប្រាថ្នាទៀត ដោះចេញនូវទោសដែលគេលើក ក្នុងវាទៈរបស់ខ្លួនក្តី ឈ្មោះថា ទទួលប្រយោជន៍ដូចគ្នា ។ បទថា **ទីឃរត្តំ ហិតាយ សុខាយ**

**សំវត្តន្តិ** សេចក្តីថា កាលណាបំពេញសីលជាដើម ក្នុងឋានៈនៃសីលជាដើមមកហើយក្តី លើកទោសក្នុងវាទៈរបស់អ្នកដទៃដោយប្រពៃតាមធម៌ក្តី ដោះទោសចេញពីវាទៈរបស់ខ្លួនក្តី សម្រេចអរហត្តហើយសម្តែងធម៌ក្នុងកណ្តាលចំណោមបរិស័ទ ប្រើប្រាស់បច្ច័យបួនដែលមនុស្សអ្នកជ្រះថ្លាក្នុងព្រះធម៌ទេសនា បង្អោនចូលទៅថ្វាយក្តី ធម៌ទាំងនោះរមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខអស់កាលដ៏យូរ ។

កាលទ្រង់សម្តែងអានិសង្សក្នុងព្រះពុទ្ធវចនៈដែលសិក្សាល្អយ៉ាងនេះហើយ ឥឡូវនេះ កាលបើទ្រង់ប្រកបបរិស័ទទុកក្នុងពុទ្ធវចនៈនោះហើយ ទើបទ្រង់ត្រាស់ពាក្យជាដើមថា **តស្មា តិហ ភិក្ខវេ** យ៉ាងនេះ ។ បណ្តាបទទាំងនោះ បទថា **តស្មា** សេចក្តីថា ព្រោះហេតុបរិយត្តិដែលសិក្សាមកមិនល្អ រមែងប្រព្រឹត្តទៅដើម្បីរបស់មិនមែនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលយូរ ដូចចាប់អសិរពិសមិនល្អដូច្នោះ ចំណែកបរិយត្តិដែលរៀនមកល្អ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលដ៏យូរ ដូចអសិរពិសដែលចាប់ល្អហើយដូច្នោះ ។ បទថា **តថា នំ ធារេយ្យាថ** សេចក្តីថា គប្បីទ្រទ្រង់បរិយត្តិនុ៎ះ ទុកយ៉ាងនោះឯង គឺ

ទ្រទ្រង់ទុកដោយអត្ថនោះឯង ។ បទថា **យេ វា បនស្សុ ព្យត្តា ភិក្ខូ** សេចក្តីថា ឬក៏ថា គប្បីសាកសួរពួកភិក្ខុដែលឈ្លាសជាបណ្ឌិត មានព្រះសារីបុត្រ ព្រះមោគ្គល្លាន ព្រះមហាកស្សបៈ និងព្រះមហាកច្ចានៈជាដើម តែភិក្ខុមិនគប្បីដូចជាអរិដ្ឋភិក្ខុ ដាក់កក់ ឬសរសៃពីងពាងក្នុងសាសនារបស់តថាគត ។ បទថា **កុល្លូបមំ** ប្រែថា ដូចផែ ឬ ក្បូន ។ បទថា **និត្ថរណត្ថាយ** បានដល់ ដើម្បីប្រយោជន៍ដល់ការឆ្លងឱឃៈ ៤ ។

(១៨) បទថា **ឧទកណ្ណវំ** សេចក្តីថា ទឹកណាជ្រៅតែមិនធំ ឬធំតែមិនជ្រៅ ទឹកនោះ លោកមិនហៅថា **អណ្ណព** ចំណែកទឹកណាទាំងជ្រៅ ទាំងធំ ទឹកនោះលោក ហៅថា **អណ្ណព** ព្រោះដូច្នោះ អត្ថក្នុងបទថា **មហន្តំ ឧទកណ្ណវំ** នេះ ទើបមានសេចក្តីយ៉ាងនេះថា ទឹកធំ គឺ ទូលំទូលាយ ជ្រៅ ។ ទីណា មានឱកាសដែលចោរឈរ អង្គុយ ដេក ប្រាកដហើយ ទីនោះឈ្មោះថា **សាសង្កំ** គួរសង្ស័យ ។ ទីណាមានពួកមនុស្សត្រូវពួកចោរមកប្ចន់ វាយដណ្តើម ប្រាកដហើយ ទីនោះឈ្មោះថា **សប្បដិភយ** មានភ័យប្រាកដចំពោះមុខ ។ ស្ពានដែលគេចង ទុកខាងលើអន្លង់ទឹកឈ្មោះថា **ឧត្តរសេតុ** ប្រែថា ស្ពានឆ្លង ។ បទថា **កុល្លំ ពន្ធិត្វា** សេចក្តីថា គំនរឈើជាដើមដែលគេចងជាបាច់ដើម្បីប្រយោជន៍ ដល់ការឆ្លងទឹកឈ្មោះថា **ក្បូន** , ចំណែក

គំនរឈើជាដើមដែលគេចងផ្តុំឲ្យធំ លោកហៅថា **ផែ** ។ បទថា **ឧស្សា-បេត្វា** ប្រែថា តាំងទុក ។ បទថា **កិច្ចការី** សេចក្តីថា ធ្វើកិច្ចដែលដល់ហើយ ធ្វើកិច្ចដែលគួរ ធ្វើកិច្ចដែលសមគួរ ។ ក្នុងពាក្យថា **ធម្មាបិ វោ បទាតព្វា** នេះ ធម៌ទាំងឡាយឈ្មោះថា សមថៈ និងវិបស្សនា ។

ពិតហើយ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ឲ្យលះឆន្ទរាគៈទាំងក្នុងសមថៈ ទាំងក្នុងវិបស្សនា ។ ទ្រង់ឲ្យលះឆន្ទរាគៈទុកក្នុងទីណា ។ ទ្រង់ឲ្យលះឆន្ទរាគៈទុកក្នុងទីនេះថា ម្នាលឧទាយី ព្រោះហេតុនេះឯង តថាគតពោលការលះសូម្បី នេវសញ្ញានាសញ្ញាយតនៈ ម្នាលឧទាយី អ្នកមិនឃើញសំយោជនៈដែលល្អិត ឬគ្រោតគ្រាត ដែលយើងមិនបានពោលដល់ការលះទុក ។ ទ្រង់ឲ្យលះឆន្ទរាគៈ ទុកក្នុងវិបស្សនាក្នុងទីនេះថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកអ្នកមិនតោង មិនចាប់ មិនកាន់ ទិដ្ឋិនេះរមែងបរិសុទ្ធ ផូរផង់យ៉ាងនេះ ។ តែក្នុងទីនេះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់ឲ្យលះឆន្ទរាគៈក្នុងសមថៈ និងវិបស្សនា ទាំង ២ ទើបទ្រង់ត្រាស់ថា សូម្បីធម៌ទាំងឡាយ ក៏ពួកអ្នកគប្បីលះ នឹងពោលថ្វីដល់អធម៌ទាំងឡាយ ។ ក្នុងចំណុចនោះ មានអធិប្បាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលការលះឆន្ទរាគៈក្នុងធម៌ទាំងឡាយដ៏ស្ងប់ និងប្រណីតបែបនេះ ចាំបាច់

ពោលថា ក្នុងអសទ្ធម្មនេះ ដែលជារបស់អ្នកស្រុក ជារបស់ថោកទាប ជាធម៌គ្រោតគ្រាត អាក្រក់ ជាធម៌ផ្តេសផ្តាស ដែលអរិដ្ឋមោឃបុរសនេះ សម្គាល់ថា មិនមានទោស ពោលធទូរាគៈក្នុងកាមគុណទាំង ៥ ថាជាធម៌មិនអាច ធ្វើអន្តរាយបាន ពួកអ្នកមិនគប្បីជួចជាអរិដ្ឋភិក្ខុ ដាក់កក់ ឬសរសៃពីងពាងចុះក្នុងសាសនារបស់តថាគតឡើយ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់និគ្គហៈអរិដ្ឋភិក្ខុម្នាក់ដោយឱវាទនេះ ដោយប្រការដូច្នេះ , ឥឡូវនេះ កាលណាទ្រង់សម្តែងថា ៖

អ្នកណាប្រកាន់ថា យើង របស់យើង ដោយ
អំណាចការប្រកាន់ ៣ យ៉ាង ក្នុងខន្ធប្រាំ អ្នក
នោះ ឈ្មោះថា ដាក់កក់ ឬសំរាមទៅក្នុង
សាសនារបស់តថាគត ។

(១៩) ដូចអរិដ្ឋភិក្ខុនេះ ទើបទ្រង់ត្រាស់ថា **ឆយិមានិ ភិក្ខវេ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **ទិដ្ឋិដ្ឋានានិ** សេចក្តីថា សូម្បីទិដ្ឋិក៏ឈ្មោះថា ទីតាំងនៃទិដ្ឋិ ទាំងអារម្មណ៍របស់ទិដ្ឋិ ទាំងបច្ច័យរបស់ទិដ្ឋិ ក៏ឈ្មោះថា ទីតាំងរបស់ទិដ្ឋិ , ក្នុងបទថា **រូបំ ឯតំ មម** ជាដើម ការប្រកាន់ថា " នុ៎ះរបស់យើង " **ជាតណ្ហាគាហៈ** , ការប្រកាន់ថា " នុ៎ះជាយើង " ជា

**មានគាហៈ** , ការប្រកាន់ថា " នុ៎ះ ជាខ្លួនរបស់យើង " ជា **ទិដ្ឋិគាហៈ** ។

ការសម្តែង តណ្ហា មានះ ទិដ្ឋិ ដែលមានរូបជាអារម្មណ៍ដោយប្រការដូច្នេះ ។ រូបមិនគួរពោលថា ជាអត្តា ។ សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។ រូបាយតនៈ ឈ្មោះថា ទិដ្ឋៈ , សទ្ទាយតនៈ ឈ្មោះថា សុតៈ , គន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈ ឈ្មោះថា មុតៈ , គន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈនោះ លោកពោលថា មុតៈ ព្រោះជួបហើយចាប់ទុក , អាយតនៈ ៧ ដ៏សេស ឈ្មោះថា វិញ្ញាតៈ ។ បទថា **បត្តំ** បានដល់ ការស្វះស្វែងរកក្តី មិនស្វះស្វែងរកក្តី ជួបប្រទះហើយ ។ បទថា **បរិយេសិតំ** បានដល់ ដែលជួប ឬមិនជួប ក៏ស្វែងរកហើយ ។ បទថា **អនុវិចរិតំ មនសា** បានដល់ ជាប់តាមដោយចិត្ត ។ ពិតហើយ របស់ក្នុងលោក ដែលស្វែងរកហើយជួបក៏មាន ស្វែងរកហើយមិនជួបក៏មាន , មិនស្វែងរកហើយជួបក៏មាន មិនស្វែងរកហើយមិនជួបក៏មាន ។ ក្នុងទីតាំងនៃសេចក្តីឃើញនោះ របស់ដែលស្វែងរកហើយជួបឈ្មោះថា **បត្ត** , របស់ដែលស្វែងរកហើយមិនជួប ឈ្មោះថា **បរិយេសិត** , របស់ដែលមិនស្វែងរកហើយជួប និងរបស់ដែលមិនស្វែងរកហើយមិនជួប ឈ្មោះថា **មនសានុចរិត** ។ ន័យម្យ៉ាងទៀត របស់ដែលស្វែងរកហើយ

ជួបក្តី របស់ដែលមិនស្វែងរកមិនជួបក្តី ឈ្មោះថា **បត្ត** ព្រោះអត្ថថា ជួបហើយ ។ របស់ដែលស្វែងរកមិនជួបតែម្យ៉ាង ឈ្មោះថា **បរិយេសិត** , របស់ដែលមិនស្វែងរកហើយជួប និងរបស់ដែលមិនស្វែងរកហើយមិនជួប ឈ្មោះថា **មនសានុចរិត** ។ ឬថា របស់ទាំងអស់នោះឈ្មោះថា **មនសានុ-ចរិត** ព្រោះជារបស់ជាប់តាមជាមួយចិត្ត , តណ្ហា មានះ ទិដ្ឋិ ដែលមានវិញ្ញាណជាអារម្មណ៍ ត្រាស់ដោយបទនេះ , វិញ្ញាណត្រាស់ដោយអំណាចទិដ្ឋិជាដើម ជាអារម្មណ៍ក្នុងកាលមុន ដោយអំណាចការផ្លាស់ប្តូរនៃទេសនា ។ បទថា **យម្បិ តំ ទិដ្ឋិដ្ឋានំ** បានដល់ ទីតាំងនៃទិដ្ឋិដែលប្រព្រឹត្តទៅ ដោយន័យមានជាអាទិ៍ថា ជាខ្លួន ដោយប្រកាន់ថា ជាលោក ជាអត្តា លោកសំដៅយកទិដ្ឋិនោះ ទើបពោលទុកយ៉ាងនេះ ។ បទថា **សោ បេច្ចភវិស្សាមិ** សេចក្តីថា យើងនឹងទៅបរលោក ហើយនឹងតាំងនៅជានិច្ចទៀងទាត់ យឺនយូរ មានការមិនប្រែប្រួលជាធម្មតា នឹងតាំងនៅជានិច្ចដោយសេចក្តីទៀងទាត់ ដូចភ្នំសិនេរុ មហាប្រឹថពី និងមហាសមុទ្រជាដើម ដូច្នោះ ដូចគ្នា ។ បទថា **តម្បិ នេតំ មម** សេចក្តីថា រមែងតាមឃើញថា ទស្សនៈនោះថា នុ៎ះរបស់យើង នុ៎ះជាយើង នុ៎ះជាខ្លួនរបស់យើង ។ តណ្ហា មានះ ទិដ្ឋិ ដែលមានទិដ្ឋិជាអារម្មណ៍ ទ្រង់ត្រាស់ដោយបទនេះ ។

វេលាប្រកាន់ដោយទិដ្ឋិជាដំបូង បានដោយទិដ្ឋិជាខាងក្រោយយ៉ាងនេះ ដូច វេលាដែលឃើញច្បាស់ដោយវិបស្សនា ។ ក្នុងសុក្កបក្ខ " ផ្នែកខាងស " ទ្រង់ជំទាស់ការប្រកាន់ដោយតណ្ហា មានះ ទិដ្ឋិ ក្នុងរូបថា នុ៎ះមិនមែនរូប របស់យើង ជាដើម ។ សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។ ក៏បទ នេះថា **សមនុបស្សតិ** សេចក្តីថា សមនុបស្សនាមាន ៤ គឺ ៖

**តណ្ហាសមនុបស្សនា មានសមនុបស្សនា**

**ទិដ្ឋិសមនុបស្សនា ញាណសមនុបស្សនា ។**

កាពនៃសមនុបស្សនាទាំងនោះគប្បីជ្រាបដោយអំណាចសមនុបស្សនា ៣ នៅក្នុងកណ្ហបក្ខ , ញាណសមនុបស្សនា នៅក្នុងសុក្កបក្ខ ។ បទថា **អសតិ ន បរិតស្សតិ** សេចក្តីថា កាលបើសេចក្តីប្រកាន់មិនមាន អ្នក រមែងមិនភ្ញាក់ផ្អើល ដោយសេចក្តីភ្ញាក់ផ្អើល គឺ ភ័យ ដោយសេចក្តីភ្ញាក់ ផ្អើល គឺ តណ្ហា ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងដល់ព្រះខី- ណាស្រព អ្នកមិនភ្ញាក់ផ្អើល ព្រោះសេចក្តីវិនាសខន្ធខាងក្នុង ទើបទ្រង់ បញ្ចប់ធម៌ទេសនា ដោយបទនេះ ។

(២០) បទថា **ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ** សេចក្តីថា កាលព្រះមានព្រះ ភាគជាម្ចាស់ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុដែលឆ្លាតក្នុងអនុសន្ធិ មួយ

អន្តគិតថា ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងដល់ព្រះវីណាស្រេព អ្នកមិនភ្ញាក់ផ្អើល ព្រោះសេចក្ដីវិនាសនៃខន្ធខាងក្នុង ទ្រង់បានបញ្ចប់ទេសនា ក៏កាលបើព្រះវីណាស្រេពមិនភ្ញាក់ផ្អើលខាងក្នុង , ភិក្ខុដែលភ្ញាក់ផ្អើលខាងក្រៅ ភិក្ខុដែលភ្ញាក់ផ្អើលខាងក្នុង ភិក្ខុដែលភ្ញាក់ផ្អើល ព្រោះសេចក្ដីវិនាសក្នុងបរិក្ខារ សូម្បីអ្នកដែលមិនភ្ញាក់ផ្អើល គប្បីមាន យើងនឹងសួរបញ្ហានេះ ដោយហេតុបួនប្រការ ដូចពោលមកហើយ ទើបធ្វើចីវរឆៀងស្មាម្ខាង ផ្គងអញ្ជលី ក្រាបទូលព្រះមានព្រះភាគជាម្ចាស់យ៉ាងនេះ ។ បទថា **ពហិទ្ធា អសតិ** បានដល់ ក្នុងខាងក្រៅ គឺ ព្រោះការវិនាសនៃបរិក្ខារ ។ បទថា **អហុ វត មេ** សេចក្ដីថា របស់របរ យាន ពាហនៈ ប្រាក់ មាស របស់យើងមានហើយហ្ន៎ ។ បទថា **តំ វត មេ នត្ថិ** សេចក្ដីថា ឥឡូវនេះ របស់របរនោះហ្ន៎ ជារបស់យើងមិនមាន គឺ ត្រូវព្រះរាជារឹបអូសយកខ្លះ ពួកចោរលួចយកខ្លះ ភ្លើងឆេះខ្លះ ត្រូវទឹកបន្សាត់នាំទៅខ្លះ ទ្រុឌទ្រោម ព្រោះប្រើប្រាស់ខ្លះ ។ បទថា **សិយា វត មេ** សេចក្ដីថា យាន ពាហនៈ ប្រាក់ មាស ស្រូវសាលី ស្រូវជំណើប ស្រូវលះម៉ាន ( ស្រូវព្រៃមួយប្រភេទ ឬស្មៅមួយប្រភេទ ) របស់យើងមានហ្ន៎ ។ បទថា **តំ វតាហំ ន លភាមិ** មានន័យថា សោកសៅថា យើងកាលណាមិនបានរបស់នោះ

ឥឡូវនេះយើង ក៏មិនបាន ព្រោះមិនធ្វើការដែលសមគួរដល់ទ្រព្យនោះ នោះឯងឈ្មោះថា ការសោកសៅរបស់អ្នកគ្រប់គ្រងផ្ទះ ( គ្រហស្ថ ) ។ សេចក្តីសោកសៅអ្នកមិនគ្រប់គ្រងផ្ទះ (បព្វជិត) គប្បីជ្រាបដោយអំណាចបាត្រ និងចីវរជាដើម ។

គប្បីជ្រាបក្នុង **អបរិតស្សនាការៈ** ដូចតទៅនេះ បទថា **ន ឯវំ ហោតិ** មានន័យថា សេចក្តីភ្ញាក់ផ្អើលគប្បីមានយ៉ាងនេះ ព្រោះកិលេសពួកណា រមែងមិនមានយ៉ាងនេះ ព្រោះកិលេសទាំងនេះបានលះហើយ ។ បទថា **ទិដ្ឋិដ្ឋានាធិដ្ឋានបរិយុដ្ឋានាភិនិវេសានុសយានំ** សេចក្តីថា ចំពោះទិដ្ឋិ ទីតាំងទិដ្ឋិ ទីតាំងមាំនៃទិដ្ឋិ ការរួបរឹតនៃទិដ្ឋិ និងទីដេកត្រាំនៃសេចក្តីប្រកាន់មាំ ។ បទថា **សព្វសង្ខារសមថាយ** បានដល់ ដើម្បីប្រយោជន៍ដល់សេចក្តីរំលត់ ។ ពិតហើយ ការញាប់ញ័រ ការកម្រើក ការប្រែប្រួលនៃសង្ខារទាំងពួង មកដល់ព្រះនិព្វាន រមែងស្ងប់រំងាប់ទៅ ព្រោះដូច្នោះ ព្រះនិព្វាននោះ ទើបលោកហៅថា ជាទីរំងាប់នៃសង្ខារទាំងពួង ។ មយ៉ាងទៀត ឧបធិទាំងនេះ ឧបធិ គឺ ខន្ធ , ឧបធិ គឺ កិលេស ឧបធិ គឺ អភិសង្ខារ , ឧបធិ គឺ កាមគុណ ៥ មកដល់ព្រះនិព្វាននោះ ហើយក៏រលត់ទៅ តណ្ហាក៏អស់ទៅ ក៏ធូរស្រាល ក៏រលត់ ព្រោះដូច្នោះ

ព្រះនិព្វាននោះ លោកទើបហៅថា **សព្វុបធិប្បដិនិស្សគ្គ** ជាទីរលាស់ចេញនូវឧបធិទាំងពួង **តណ្ហក្ខយ** ជាទីអស់ទៅនៃតណ្ហា , **វិរាគ** ការខ្ជាក់ចោលនូវរាគៈ , **និរោធ** រលត់ ។ ស័ព្ទថា **និព្វានាយ** នេះ ជានិទ្ទេសសរុបនៃព្រះនិព្វាននោះ ។ ដូច្នោះ លោកសម្តែងសេចក្តីនេះថា កាលបើទ្រង់សម្តែងធម៌ដើម្បីប្រយោជន៍ ដល់ការធ្វើឲ្យជីងព្រះនិព្វាន ដោយបទទាំងនេះទាំងអស់តែម្តង ។ បទថា **តស្សេវំ ហោតិ** សេចក្តីថា ភិក្ខុដែលមានទិដ្ឋិនោះ រមែងមានការគិតយ៉ាងនេះថា យើងនឹងដាច់សូន្យ យើងនឹងវិនាស យើងនឹងមិនមាន ។ ពិតហើយ ភិក្ខុដែលមានទិដ្ឋិ ស្តាប់ធម៌ដែលទ្រង់លើកឡើងដល់ត្រៃលក្ខណ៍ សម្តែងឲ្យទាក់ទិនដោយសុញ្ញតា ក៏កើតសេចក្តីភ្ញាក់ព្រើត ដូចពាក្យដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនបានស្តាប់ រមែងមានការតក់ស្លុតយ៉ាងនេះថា យើងមាន និងយើងមិនមាន ។

ដោយការត្រាស់សម្តែងមានប្រមាណប៉ុណ្ណេះ ទ្រង់ត្រាស់សុញ្ញតាមាន ៤ កង ដោយអំណាចនៃភិក្ខុទាំងនេះ គឺ ភិក្ខុដែលស្លុត និងមិនស្លុតព្រោះការវិនាសនៃបរិក្ខារខាងក្រៅមួយគូ និងភិក្ខុដែលស្លុត និងមិនស្លុតព្រោះការវិនាសនៃខន្ធខាងក្នុងមួយគូ ។

(២១) ឥឡូវនេះ ដើម្បីទ្រង់សម្ដែងសុញ្ញតា ៣ កង គឺ ចាត់បរិក្ខារខាងក្រៅ ឲ្យឈ្មោះថា **ទិដ្ឋិបរិគ្គហ** , ចាត់សក្កាយទិដ្ឋិ ដែលមានវត្ថុ ២០ ឲ្យឈ្មោះថា **អត្តវាទុបាទាន** , ចាត់ទិដ្ឋិ ៦២ ដែលមានសក្កាយទិដ្ឋិជាប្រធាន ឲ្យឈ្មោះថា **ទិដ្ឋិនិស្សយ** , ទើបទ្រង់ត្រាស់ថា **ភិក្ខវេ បរិគ្គហំ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **បរិគ្គហំ** បានដល់ សបរិក្ខារខាងក្រៅ ។ បទថា **បរិគ្គណ្ហេយ្យ** សេចក្ដីថា វិញ្ញូជនគប្បីកំណត់កាន់យក ។ ដោយបទថា **អហំបិ ខោ តំ ភិក្ខវេ** ទ្រង់សម្ដែងថា ម្នាលភិក្ខុទាំងឡាយ សូម្បីពួកអ្នក ក៏មិនឃើញ សូម្បីតថាគតក៏មិនឃើញ ដូច្នោះ ការកំណត់នូវសភាពបែបនោះ ក៏មិនមាន ។ គប្បីជ្រាបខ្លឹមសារក្នុងបទទាំងពួងដោយប្រការដូច្នេះ ។

(២២) ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងសុញ្ញតា ៣ កង យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្ដែង ២ កង គឺ អត្តាក្នុងខន្ធខាងក្នុង និងការជាប់ជំពាក់ដោយខ្លួនក្នុងបរិក្ខារខាងក្រៅ ទើបទ្រង់ត្រាស់ពាក្យជាអាទិ៍ថា **អត្តនិ វា ភិក្ខវេ សតិ** ។ ក្នុងពាក្យនោះ មានសេចក្ដីសង្ខេបយ៉ាងនេះថា កាលណាខ្លួននៅមាន បរិក្ខាររបស់យើងនេះ ក៏ជាប់ជំពាក់ក្នុងខ្លួន ឬថា កាលបរិក្ខារដែលជាប់ជំពាក់នឹងខ្លួនមានហើយ អត្តារបស់

យើងនេះ ក៏ជាម្ចាស់របស់បរិក្ខារនេះ យើងក៏ដូចគ្នា បានសេចក្តីថា កាលវត្ថុនៅមាន របស់យើងក៏មាន យើងក៏មានយ៉ាងនេះ ។ បទថា **សច្ចតោ** ប្រែថា ដោយសភាពដ៏ពិត ។ បទថា **ឋិតតោ** ប្រែថា មានដោយពិតឬតាំងនៅ ។ ឥឡូវនេះ កាលដែលទ្រង់មិនប្រកាន់បញ្ចក្ខន្ធដោយបរិវដ្តៈ ៣ យ៉ាងនេះ គឺ **អនិច្ចំ ទុក្ខំ អនត្តា** កាលទ្រង់សម្តែងថា ភិក្ខុនេះ ក៏ដូចអរិដ្ឋភិក្ខុជាក់ កក់ល្បាប់ សំបុកពីងពាង ចុះក្នុងសាសនារបស់តថាគត ទើបទ្រង់ត្រាស់ថា **តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា** ជាដើម ។ បទថា **អនិច្ចំ ភន្តេ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុដែលរូបនោះមានហើយត្រឡប់ជាមិនមាន ដូច្នេះ រូបទើបមិនទៀង ដែលឈ្មោះថាមិនទៀង ព្រោះហេតុ ៤ ប្រការ គឺ ព្រោះកើតហើយក៏អស់ទៅ ឬព្រោះអត្ថថា ប្រែប្រួល ប្រព្រឹត្តទៅជាបណ្តោះអាសន្ន និងបដិសេធការទៀង ។ បទថា **ទុក្ខំ ភន្តេ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន រូបឈ្មោះថា ទុក្ខ ដោយអាការ គឺ បៀតបៀន ឈ្មោះថា ជាទុក្ខ ដោយហេតុ ៤ យ៉ាង គឺ ព្រោះអត្ថថា ធ្វើឲ្យក្តៅ រោលរាល អត់ទ្រាំបានដោយលំបាក ជាទីតាំងនៃទុក្ខ និងបដិសេធសេចក្តីសុខ ។ បទថា **វិបរិណាមធម្មំ** សេចក្តីថា មានការឈានចុះ និងចូលដល់ភពជាសភាវៈ គឺ មានការលះ

បង់ភាពប្រក្រតីជាសការៈ ។ បទថា **កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តា** សេចក្តីថា សមគួរឬ ដែលមកប្រកាន់នូវរូបនោះ យ៉ាងនេះថា យើង , របស់យើង ដោយអំណាចការប្រកាន់នៃតណ្ហា មានះ និងទិដ្ឋិ ទាំង ៣ នេះ ។ ដោយបទនេះថា **នោ ហេតំ ភន្តេ** ភិក្ខុទាំងនោះរមែងប្តេជ្ញាថា រូបជាអនត្តា ព្រះអង្គដោយអាការមិនប្រព្រឹត្តទៅក្នុងអំណាច , រូបឈ្មោះថា ជាអនត្តា ដោយហេតុ ៤ គឺ ដោយអត្ថថា ជារបស់សូន្យ មិនមានម្ចាស់ មិនជាធំ និងបដិសេធអត្តា ។ ពិតហើយព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងភាពជាអនត្តាដោយអំណាចជារបស់មិនទៀង ទុកក្នុងទីណា , ដោយអំណាចភាពជាទុក្ខ ទុកក្នុងទីណា , ដោយអំណាចភាព ជារបស់មិនទៀង និងភាពជាទុក្ខ ទុកក្នុងទីណា ។ ពិតហើយ ទ្រង់សម្តែង ភាពជាអនត្តា ដោយអំណាចការមិនទៀង ទុកក្នុងឆក្កសូត្រនេះថា អ្នកណាគប្បីពោលថា ចក្ខុជាអត្តា ចក្ខុរបស់អ្នកនោះរមែងមិនកើត ទាំងការកើត ទាំងការអស់ទៅរបស់ចក្ខុ រមែងប្រាកដ ប៉ុន្តែទាំងការកើត ការអស់ទៅរបស់ចក្ខុណា រមែងប្រាកដ ចក្ខុនោះ រមែងមានមកយ៉ាងនេះថា អត្តារបស់យើងកើត និងវិនាសទៅ ព្រោះដូច្នោះ ចក្ខុនោះទើបមិនកើត ។ អ្នកណាគប្បីពោលថា ចក្ខុជាអនត្តា ដូច្នោះ ចក្ខុ

ទើបជាអនត្តា ដូច្នេះ ។ ទ្រង់សម្តែងភាពជាអនត្តា ដោយអំណាចភាពជាទុក្ខ ទុកក្នុងអនត្តលក្ខណសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ បើរូបនេះជាអត្តា រូបនេះ មិនគប្បីប្រព្រឹត្តដើម្បីអាពាធ នឹងគប្បីបានក្នុងរូបថា រូបរបស់យើងចូរជាយ៉ាងនេះ រូបរបស់យើងកុំជាយ៉ាងនោះឡើយ ម្នាលភិក្ខុទាំងឡាយ ក៏ព្រោះរូបជាអនត្តាដូច្នោះ រូប ទើបប្រពឹត្តទៅដើម្បីអាពាធ ទាំងមិនបានក្នុងរូបថា សូមរូបរបស់យើងចូរជាយ៉ាងនេះ រូបរបស់យើងកុំជាយ៉ាងនេះឡើយ ដូច្នេះ ។ ទ្រង់សម្តែងភាពជាអនត្តា ដោយអំណាចសេចក្តីមិនទៀង និងជាទុក្ខ ទាំងពីរ ទុកក្នុងអរហត្តសូត្រ នេះថា ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង រូបណាមិនទៀង រូបនោះក៏ជាទុក្ខ រូបណាជាទុក្ខ រូបនោះក៏ជាអនត្តា រូបណាជាអនត្តា រូបនោះក៏មិនមែនរបស់យើង , មិនមែនជាយើង , មិនមែនខ្លួនយើង គប្បីឃើញរូបនោះ ដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិតដូចពោលមកនេះ ។ ព្រោះហេតុអ្វី ។ ព្រោះអនិច្ចំ និងទុក្ខំ ប្រាកដហើយ អនត្តានៅមិនទាន់ប្រាកដ ។ ពិតហើយ កាលណាភាជនៈដាក់វត្ថុបរិភោគជាដើម បែកទៅ មនុស្សទាំងឡាយ ក៏ពោលថា **អហោ អនិច្ចំ ឱ !** មិនទៀងហ្ន៎ មិនមានអ្នកណាពោលថា អនត្តា ។ ឬកាលណាគំរង់ខ្ទាចទាំងឡាយកើតឡើងនៅជាប់រាងកាយ ឬអ្នកត្រូវបន្ទា

មុត ក៏ពោលថា **អហោ ទុក្ខំ ឱ !** ទុក្ខហ្ន៎ តែមិនមានអ្នកពោលថា **អហោ អនត្តា** មិនមែនអត្តាហ្ន៎ ។ ព្រោះហេតុអ្វី ។ ព្រោះឈ្មោះថា អនត្តលក្ខណៈនេះ មិនច្បាស់ ឃើញលំបាក ដឹងដោយលំបាក ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់សម្ដែងភាពជាអនត្តានោះ ដោយអំណាចមិនទៀងខ្លះ ទុក្ខខ្លះ ទាំងមិនទៀង ទាំងទុក្ខ ទាំងពីរខ្លះ , រូបនេះ លោកសម្ដែងដោយអំណាចមិនទៀង ជាទុក្ខប៉ុណ្ណោះ ក្នុងបរិវដ្ដៈ ៣ នេះ ។ សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **តស្មា តិហ ភិក្ខវេ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ព្រោះរូបមិនទៀង ជាទុក្ខ ជាអនត្តា ទាំងក្នុងឥឡូវនេះ ទាំងក្នុងកាលដទៃ ៗ ។ ពាក្យថា **យំ កិញ្ចិ រូបំ** ជាដើម ពោលទុកពិស្ដារហើយក្នុងខន្ធនិទ្ទេសនៃគម្ពីរវិសុទ្ធិមគ្គ ។

(២៣) បទថា **និព្វិន្ទតិ** ប្រែថា នឿយណាយ ។ ក្នុងពាក្យថា **និព្វិន្ទតិ** ក្នុងបាលីនេះ លោកប្រាថ្នា យកវុដ្ឋានគាមិនីវិបស្សនា ( វិបស្សនាដែលដល់នូវការចេញពីការប្រកាន់ដោយតណ្ហា ) ។ ការពិត វុដ្ឋានគាមិនីវិបស្សនា មានច្រើនឈ្មោះ កន្លែងខ្លះហៅថា **សញ្ញគ្គៈ** កន្លែងខ្លះថា **ធម្មដ្ឋិតិញ្ញាណ** កន្លែងខ្លះថា **បរិសុទ្ធិបធានិយង្គៈ** កន្លែងខ្លះថា **បដិបទាញាណទស្សនវិសុទ្ធិ** កន្លែងខ្លះថា **តម្មយបរិយាទានៈ** កន្លែងខ្លះក៏មាន ៣ ឈ្មោះ

កន្លែងខ្លះក៏មាន ២ ឈ្មោះ ។ បណ្ដាអាគតស្ថានទាំងនោះ ក្នុងបោដ្ឋបាទ-សូត្រ ទ្រង់ត្រាស់ហៅថា **សញ្ញគ្គ** យ៉ាងនេះថា ម្នាលបោដ្ឋបាទ សញ្ញាកើតឡើងមុន ក្រោយមកញាណទើបកើតឡើងយ៉ាងនេះ ។ ក្នុងសុសិមសូត្រ ទ្រង់ត្រាស់ហៅថា ធម្មដ្ឋិតិញ្ញាណ យ៉ាងនេះថា ម្នាលសុសិមៈ ធម្មដ្ឋិតិ-ញ្ញាណមានមុន ក្រោយមកញាណក្នុងនិព្វានទើបមាន យ៉ាងនេះ ។ ក្នុងទសុត្តរសូត្រ ទ្រង់ត្រាស់ហៅថា បរិសុទ្ធិបធានិយង្គៈថា បដិបទាញាណ-ទស្សនវិសុទ្ធិបធានិយង្គៈ យ៉ាងនេះ ។ ក្នុងរថវិនីតសូត្រ លោកហៅថា បដិបទាញាណទស្សនវិសុទ្ធិ យ៉ាងនេះថា ម្នាលអ្នកដ៏មានអាយុ អ្នកប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមានព្រះភាគជាម្ចាស់ ដើម្បីបដិបទាញាណទស្ស-នវិសុទ្ធិឬ ដូច្នេះ ។ ក្នុងសឡាយតនវិភង្គសូត្រ លោកហៅថា តម្មយ-បរិយាទានៈ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ឧបេក្ខានេះ គប្បីនាំមកការមិនមានតណ្ហា អាស្រ័យការមិនមានតណ្ហា មានអារម្មណ៍តែ ១ អាស្រ័យអារម្មណ៍តែ ១ ពួកអ្នកត្រូវលះឧបេក្ខានោះចេញ ត្រូវឈានកន្លងឧបេក្ខានោះចេញ ការលះឧបេក្ខានោះ មានយ៉ាងនេះ ការឈានកន្លងឧបេក្ខានោះមានយ៉ាងនេះ ដូច្នេះ ។ ក្នុងបដិសម្ភិទាមគ្គ លោកបញ្ជាក់ទុក ៣ ឈ្មោះយ៉ាងនេះថា ធម៌ទាំងនេះ គឺ **មុញ្ចិតុកម្យតា បដិសង្ខានុបស្សនា និងសង្ខារុ-**

**បេក្ខា** មានអត្ថតែមួយ ខុសតែព្យញ្ជនៈប៉ុណ្ណោះ ។ ក្នុងគម្ពីរបដ្ឋាន លោកបញ្ជាក់ទុក ២ ឈ្មោះ យ៉ាងនេះ គឺ អនុលោមញ្ញាណជាបច្ច័យនៃគោត្រ-ភូញាណ ដោយអនន្តរប្បច្ច័យ អនុលោមញ្ញាណជាបច្ច័យនៃវោទានៈ (មគ្គចិត្តផលចិត្ត) ដោយអនន្តរប្បច្ច័យ ។ ចំណែកក្នុងអលគទ្ទូបមសូត្រនេះ វុដ្ឋានគាមិនីវិបស្សនា មកដោយឈ្មោះថា **និព្វិទា** ក្នុងបទថា **និព្វិន្ទតិ** ។ មគ្គឈ្មោះថា **វិរាគ** ក្នុងបទនេះថា **និព្វិន្ទន្តោ វិរជ្ជតិ** ។ ក្នុងបទថា **វិរាគា វិមុច្ចតិ** នេះ លោកពោលផលថា រមែងរួចផុតព្រោះវិរាគៈ គឺ មគ្គ ។ ក្នុងទីនេះ លោកពោលបច្ចវេក្ខណញ្ញាណទុកថា កាលបើរួចផុត ក៏មានញ្ញាណដឹងថា យើងរួចផុតស្រឡះហើយ ។

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងព្រះមហាខីណាស្រពដែលមានចិត្តរួចផុតយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់បញ្ជាក់ឈ្មោះរបស់ព្រះមហាខីណាស្រពនោះ ដោយហេតុ ៥ ប្រការ តាមការពិត ទើបទ្រង់ត្រាស់ថា **អយំ វុច្ចតិ ភិក្ខវេ** ជាដើម ។ បទថា **អវិជ្ជា** បានដល់ អវិជ្ជាមានវដ្តៈជាមូល ។ ពិតហើយ អវិជ្ជានេះ លោកហៅថា **បលិឃ** ព្រោះអត្ថថា លើកឡើងបានដោយលំបាក ។ ដោយហេតុនោះ ភិក្ខុនេះ លោកទើបហៅថា **ឧក្ខិត្តបលិឃៈ** ព្រោះអវិជ្ជានោះ ត្រូវលើកឡើង ។ បទថា

**តាលាវត្ថុកតា** បានដល់ ធ្វើឲ្យដូចដើមត្នោតកំបុត-ក អធិប្បាយថា ឬ ដកដើមត្នោតព្រមទាំងឫស ធ្វើឲ្យលែងមានបែបភាព គឺ នាំទៅឲ្យដល់ការមិនមានបញ្ញត្តិទៀត ដូចដើមត្នោតនោះ មិនប្រាកដកន្លែងនៃទីតាំង ។ បទថា **បោនោព្ភវិកោ** បានដល់ ឲ្យនូវភពថ្មី ។ បទថា **ជាតិសំសារោ** បានដល់ អភិសង្ខារ គឺ កម្ម ដែលជាបច្ច័យនៃខន្ធក្នុងភពថ្មី ដែលបានឈ្មោះយ៉ាងនេះ ដោយការកើត និងត្រាច់ទៅក្នុងជាតិទាំងឡាយ ។ ពិតហើយ អភិសង្ខារ គឺ កម្មនោះ លោកហៅថា បរិក្ខា ព្រោះរួបរឹតទុក ម ដោយការធ្វើឲ្យកើតរឿយ ៗ ដោយហេតុនោះ ភិក្ខុនោះហៅថា **សង្កិណ្ណ-បរិក្ខៈ** ព្រោះអវិជ្ជានោះ ខ្ចាត់ខ្ចាយហើយ ។ បទថា **តណ្ហា** បានដល់ តណ្ហាដែលមានវដ្តៈជាមូល ។ ពិតហើយ តណ្ហានេះ លោកហៅថា **ឯសិកា** ព្រោះអត្ថថា តាមទៅដោយជ្រាលជ្រៅ ។ ដោយហេតុនោះ ភិក្ខុនោះ លោកហៅថា **អព្ពុឡ្ហេសិកៈ** ព្រោះតណ្ហាគេលើកចោល គឺ ព្រោះគេកាត់ចោល ។ បទថា **ឱរម្ភាគិយានិ** បានដល់ ឲ្យកើតជាចំណែកខាងក្រោម គឺ ជាបច្ច័យឲ្យកើតក្នុងកាមភព ។ ពិតហើយ សំយោជនៈទាំងនោះ លោកហៅថា **អគ្គឡ** ព្រោះបិទបាំងចិត្ត ដូចសន្លឹកទ្វារបិទទ្វារនគរ ។ ព្រោះហេតុនោះ ភិក្ខុនោះ លោកហៅថា **និរគ្គឡ** ព្រោះសំយោជនៈទាំងនោះ

ដែលលោកធ្វើឲ្យមិនមាន គឺ បំផ្លាញហើយ ។ បទថា **អរិយោ** បានដល់ អ្នកមិនមានកិលេស គឺ អ្នកបរិសុទ្ធ ។ បទថា **បន្នទ្ធជោ** បានដល់ មានទង់ គឺ មានះ ដែលបានដាក់ចុះហើយ ។ បទថា **បន្នភារោ** វិគ្រោះថា ឈ្មោះថា **បន្នភារះ** ព្រោះភិក្ខុនោះមានភារះ គឺ ខន្ធ , កិលេស , អភិសង្ខារ និងកាមគុណ ៥ ធ្លាក់ចុះហើយ គឺ ដាក់ចុះហើយ ។ ន័យមួយទៀតក្នុងទីនេះ លោកបំណងថា **បន្នភារះ** ព្រោះដាក់ភារះ គឺ មានះប៉ុណ្ណោះ ។ បទថា **វិសំយុត្តោ** បានដល់ ប្រាសចេញចាកហើយ ពីយោគៈ ៤ និងកិលេសទាំងអស់ ។ តែក្នុងទីនេះ លោកបំណងថា **វិសំយុត្តៈ** ព្រោះប្រាសចាកសំយោជនៈ គឺ មានះតែម្យ៉ាង ។ បទថា **អស្មិមានោ** បានដល់ មានមានះថា យើងមានក្នុងរូប , មានមានះថា យើងមានក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងកាលរបស់ព្រះខីណាស្រព ដែលធ្វើកិលេសឲ្យអស់ទៅ ដោយមគ្គនៅលើទីដេក គឺ និរោធដ៏ប្រសើរ ចូលផលសមាបត្តិ ដែលមាននិព្វានជាអារម្មណ៍ ។ ប្រៀបដូចនគរពីរ គឺ នគរចោរ ១ , នគរក្សេម ១ កាលបើដូច្នោះ អ្នកចម្បាំងធំម្នាក់ គប្បីគិតយ៉ាងនេះថា នគរចោរនេះ តាំងនៅដរាបណា នគរក្សេមក៏មិនផុតភ័យ

ជរាបនោះ យើងនឹងធ្វើនគរចោរ មិនឲ្យទៅជានគរ ទើបពាក់ក្រោះ កាន់ព្រះខ័ន កាប់សសរបង់ ដែលលើកឡើងនៅជិតទ្វារនគរ បំផ្លាញសន្ទឹកទ្វារព្រមទាំងក្របទ្វារ ហើយលើកគន្លឹះឡើង បំផ្លាញកំផែង រើបន្ទាយរំលំទង់ដែលលើកឡើង ដើម្បីសេចក្ដីលំអរបស់នគរ យកភ្លើងដុតនគរ ហើយចូលនគរក្សេម ឡើងប្រាសាទដែលហែហមដោយពួកញាតិ បរិភោគភោជនមានរសជាតិឆ្ងាញ់ យ៉ាងណា សេចក្ដីនេះក៏ដូច្នោះ សក្កាយៈប្រៀបដូចជានគរចោរ និព្វានប្រៀបដូចជានគរក្សេម ព្រះយោគាវចរប្រៀបដូចជាអ្នកចម្បាំងធំ ព្រះយោគាវចរនោះ មានការគិតយ៉ាងនេះថា ការវិលវល់នៃសក្កាយៈនៅប្រព្រឹត្តទៅជរាបណា ការរួចផុតពីកម្មករណ៍ ៣២ រោគ ៩៨ មហាភ័យ ២៥ មិនបានជរាបនោះ ព្រះយោគាវចរប្រៀបដូចជាអ្នកចម្បាំងធំ ពាក់ក្រោះ គឺ សីល , ចាប់ព្រះខ័ន គឺ បញ្ញា យកព្រះអរហត្តមគ្គ កាប់សសរបង់ គឺ តណ្ហា ដូចជាចាប់ព្រះខ័នកាប់សសរបង់ ព្រះយោគាវចរនោះ លើកគន្លឹះ គឺ សំយោជនៈខាងក្រោម ៥ ដូចអ្នកចម្បាំងលើកទ្វារនគរ ព្រមទាំងក្របទ្វារ ព្រះយោគាវចរនោះលើកគន្លឹះ គឺ អវិជ្ជា ដូចអ្នកចម្បាំងលើកគន្លឹះ ព្រះយោគាវចរបំផ្លាញអភិសង្ខារ គឺ កម្មរុះរើបន្ទាយ ប្រឡាយ គឺ ជាតិសង្សារ ដូចអ្នកចម្បាំង បំផ្លាញកំផែង

រុះរើបន្ទាយ ប្រឡាយ , ព្រះយោគាវចរផ្ដួលទង់ គឺ មានះ ដុតនគរ គឺ សក្កាយៈ ដូចអ្នកចម្បាំង រំលំទង់ដែលលើកឡើង ដើម្បីធ្វើនគរឲ្យស្អាតល្អ , ព្រះយោគាចវរចូលនគរ គឺ កិលេសនិព្វាន សោយសុខដែលកើតពីផលសមាបត្តិដែល មានអមតនិរោធជាអារម្មណ៍ ញុំាំងកាលឲ្យកន្លងទៅ ដូចអ្នកចម្បាំងបរិភោគភោជនមានរសល្អ ក្នុងប្រាសាទជាន់លើ ក្នុងនគរក្សេម ។

(២៤) ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលណាទ្រង់សម្ដែងភាពដែលព្រះខីណាស្រពមានចិត្តរួចផុតយ៉ាងនេះ ជាអ្នកមានវិញ្ញាណដែលអ្នកដទៃរកជួបមិនបាន ទើបទ្រង់ត្រាស់ថា **ឯវំ វិមុត្តចិត្តំ ខោ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **អន្វេសន្តា** បានដល់ ស្វះស្វែងរក ។ បទថា **ឥទំ និស្សិតំ** បានដល់ អាស្រ័យវត្ថុនេះ ។ សូម្បីសត្វលោក ក៏ប្រាថ្នាថា តថាគត ក្នុងពាក្យថា **តថាគតស្ស** នេះ ។ សូម្បីព្រះខីណាស្រព ក៏ជាបុគ្គលខ្ពស់បំផុត ។ បទថា **អននុវេជ្ជោ** ប្រែថា អ្នកមិនមាន ឬអ្នកដែលអ្នកណាមិនជួបប្រទះ ។ ពិតហើយ កាលណាប្រកាន់ថា សត្វ ជាតថាគតក៏គួរ មានសេចក្ដីថា មិនមាន ។ កាលណាប្រកាន់ថា ព្រះខីណាស្រពក៏គួរមានសេចក្ដីថា មិនមាន ។ កាលណាប្រកាន់ថា ព្រះខីណាស្រព ក៏គួរ

មានសេចក្ដីថា អ្នកណាជួបប្រទះមិនបាន ។ ក្នុងន័យទាំងពីរនោះ ន័យមុន មានអធិប្បាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនបញ្ញត្តព្រះខីណាស្រព ដែលមានជីវិតក្នុងបច្ចុប្បន្នប៉ុណ្ណោះថា តថាគត សត្វ បុគ្គល តើតថាគតបញ្ញត្តព្រះខីណាស្រពដែលបរិនិព្វានហើយ មិនមានបដិសន្ធិថា សត្វ ឬបុគ្គលបានយ៉ាងណា អធិប្បាយថា តថាគតមិនមាន , ពិតហើយ ពោលដោយបរមត្ថ ឈ្មោះថា សត្វណាៗ មិនមាន កាលសត្វនោះមិនមាន ទេវតាទាំងឡាយ សូម្បីស្វែងរកនូវវិញ្ញាណអាស្រ័យអ្វី នឹងជួបប្រសព្វបានយ៉ាងណា គឺ នឹងជួបបានយ៉ាងណា ។ ក្នុងន័យទី ២ អធិប្បាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ព្រះខីណាស្រពដែលនៅមានជីវិតក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះ ដែលទេវតាទាំងឡាយ មានព្រះឥន្ទជាដើម ជួបមិនបានដោយវិញ្ញាណ , ពិតហើយ ទេវតាទាំងឡាយព្រមទាំងព្រះឥន្ទ ព្រមទាំងព្រះព្រហ្ម ព្រមទាំងបជាបតី សូម្បីស្វះស្វែងរក ក៏មិនអាចនឹងដឹងវិបស្សនាចិត្ត មគ្គចិត្ត ឬផលចិត្តរបស់ព្រះខីណាស្រពថា អាស្រ័យអារម្មណ៍ឈ្មោះនេះប្រព្រឹត្តទៅ ទេវតាទាំងនោះ នឹងដឹងអ្វីរបស់ព្រះខីណាស្រពដែលបរិនិព្វានហើយ មិនមានបដិសន្ធិ ។ បទថា **អសតា** ប្រែថា មិនមាន ។ បទថា **តុច្ឆា** ប្រែថា សោះសូន្យ ។ បទថា **មុសា**

ប្រែថា និយាយមិនពិត ។ បទថា **អភូតេន** ប្រែថា ដោយរឿងដែលមិនមាន ។ បទថា **អព្ភាចិក្ខន្តិ** បានដល់ មួលបង្កាច់ ពោលបន្ទំ ។ បទថា **វេនយិកោ** សេចក្តីថា ឈ្មោះថា វិន័យ ព្រោះកម្ចាត់ ធ្វើឲ្យវិនាសវិន័យនោះហើយឈ្មោះថា **វេនយិក** អធិប្បាយថា អ្នកធ្វើសត្វឲ្យវិនាស ។ បទថា **យថា ចាហំ ភិក្ខវេ នេ** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនជាអ្នកធ្វើសត្វឲ្យវិនាសដោយហេតុណា ។ បទថា **យថា ចាហំ ន វទាមិ** សេចក្តីថា តថាគតមិនបញ្ញត្តការធ្វើសត្វឲ្យវិនាសដោយហេតុណា ។ លោកអធិប្បាយទុកថា តថាគតមិនធ្វើសត្វឲ្យវិនាសដោយប្រការណា និងមិនបញ្ញត្តការធ្វើសត្វឲ្យវិនាសដោយប្រការណា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ពោលចោទតថាគតថា ព្រះសមណគោតមជាអ្នកកម្ចាត់ និងពោលចោទថា ព្រះសមណគោតមធ្វើសត្វឲ្យវិនាស ថាតថាគតបញ្ញត្តសេចក្តីដាច់សូន្យ សេចក្តីវិនាស សេចក្តីមិនមាននៃសត្វដែលមានហើយ ទាំងពោលបន្ទំនូវរឿងដែលមិនមានថា សូន្យ មិនពិត និងមិនមានការពិតថា តថាគតបញ្ញត្តសេចក្តីវិនាសនៃសត្វ ។ បទថា **បុព្វេ ច** បានដល់ ក្នុងកាលមុន គឺ ក្នុងគ្រាដែលទ្រង់ត្រាស់ដឹង នៅមហាពោធិមណ្ឌលស្ថាន ។ បទថា **ឯតរហិ ច** បានដល់ ក្នុងកាលឥឡូវនេះ គឺ ក្នុងវេលាដែលសម្តែង

ព្រះធម៌ ។

បទថា **ទុក្ខំ ចេវ** (១) **បញ្ញាបេមិ** (២) **ទុក្ខស្ស ច និរោធំ** សេចក្ដីថា តថាគតនៅត្រង់ពោធិមណ្ឌលស្ថាន មិនទាន់បានប្រកាសព្រះធម្មចក្រក្ដី សម្ដែងព្រះធម៌ព្រមទាំងប្រកាសព្រះធម្មចក្រក្ដី រមែងបញ្ញត្តសច្ចៈ ៤ ប៉ុណ្ណោះ ។ ពិតហើយ ក្នុងសច្ចៈ ៤ នោះ សមុទយៈ ដែលជាមូលនៃសេចក្ដីទុក្ខនោះ គប្បីជ្រាបថា ទ្រង់កាន់យកដោយ **ទុក្ខ** ស័ព្ទ ចំណែកមគ្គដែលធ្វើឲ្យដល់និរោធនោះ គប្បីជ្រាបថា ទ្រង់កាន់យកដោយ **និរោធ** ស័ព្ទ ។ បទថា **តត្រ ចេ** បានដល់ ក្នុងសច្ចៈ ៤ នោះ ។ បទថា **បរេ** បានដល់ បុគ្គលដែលមិនអាចត្រាស់ដឹង ចាក់ធ្លុះសច្ចៈទាំងឡាយ ។ បទថា **អក្កោសន្តិ** បានដល់ ជេរដោយអក្កោសវត្ថុ ១០ យ៉ាង ។ បទថា **បរិភាសន្តិ** បរិភាសដោយវាចា ។ បទថា **រោសេន្តិ វិហេសេន្តិ** បានដល់ ប្រាថ្នាថា យើងនឹងក្រោធខឹង នឹងបៀតបៀន ។ បទថា **ឃដ្ដេន្តិ** បានដល់ ឲ្យជួបប្រសព្វទុក្ខ ។ បទថា **តត្រ** បានដល់ ក្នុងការជេរជាដើមទាំងនោះ ឬក្នុងបុគ្គលដទៃទាំងនោះ ។ បទថា **អាឃាតោ** បានដល់ សេចក្ដីក្រោធ ។ បទថា

(១) ពាក្យថា **ទុក្ខំ ចេវ** មាននៅក្នុងអដ្ឋកថាថៃ , ក្នុងព្រះត្រៃបិដកខ្មែរជា **ទុក្ខញ្ចេវ** ។

(២) ពាក្យថា **បញ្ញាបេមិ** មាននៅក្នុងអដ្ឋកថាថៃ , ក្នុងព្រះត្រៃបិដកខ្មែរជា **បញ្ញាបេមិ** ។

**អប្បច្ចយោ** បានដល់ ការខូចចិត្ត ។ បទថា **អនភិនន្ទិ** បានដល់ ការមិនត្រេកអរ ។ បទថា **តត្រ វេ** បានដល់ ក្នុងការប្រកាសសច្ចៈ ៤ នោះឯង ។ បទថា **បរេ** បានដល់ បុគ្គលដែលត្រាស់ដឹង ចាក់ធ្លុះក្នុងសច្ចៈ ៤ ។ បទថា **អានន្ទោ** បានដល់ ការជាប់ចិត្តដោយសេចក្តីត្រេកអរ ។ បទថា **ឧព្វិលា វិតត្តំ** បានដល់ ការជាប់ចិត្តដោយអំណាចនៃសេចក្តីរីករាយ ។ បទថា **តត្រ វេ** បានដល់ ការប្រកាសសច្ចៈ ៤ នោះឯង ។ បទថា **តត្រ** បានដល់ ក្នុងសក្ការៈជាដើម ។ បទថា **យំ ខោ ឥទំ បុព្វេ បរិញ្ញាតំ** សេចក្តីថា ខន្ធបញ្ចកៈនេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់កំណត់ដឹងហើយដោយបរិញ្ញា ៣ នៅពោធិមណ្ឌលស្ថានមុន ។ បទថា **តត្ថ មេ** ប្រែថា សក្ការៈទាំងនេះ ដែលគេធ្វើទុកក្នុងខន្ធបញ្ចកៈនោះ ។ លោកអធិប្បាយទុកយ៉ាងណា ។ លោកអធិប្បាយទុកថា ការគិតថា សក្ការៈទាំងនេះនឹងមានក្នុងព្រះតថាគត ឬថា តថាគតនឹងសោយនូវសក្ការៈទាំងនេះ មិនមានដល់ព្រះតថាគតក្នុងខន្ធបញ្ចកៈនោះ ឬមានការត្រិះរិះប៉ុណ្ណោះថា តថាគតរមែងសោយសក្ការៈរបស់ខន្ធបញ្ចកៈ ដែលកំណត់ដឹងហើយពីមុននោះ និងខន្ធបញ្ចកៈ រមែងសោយសក្ការៈទាំងនោះ ។

(២៥) បទថា **តស្មា** សេចក្តីថា ក៏ព្រោះហេតុដែលសមណព្រាហ្មណ៍

ពួកជនទៃមិនអាចចាក់ដុះសច្ចៈទាំងឡាយ ទើបនាំគ្នាជេរជល់តថាគត ដូច្នោះ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យ ដែលបានពោលមកហើយនោះឯង ។

បទថា **តស្មាតិហ ភិក្ខវេ យំ ន តុម្ហាកំ** សេចក្តីថា ការលះឆន្ទរាគៈ សូម្បីរបស់ដែលមិនទាក់ទិនជាមួយខ្លួន ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលយូរ ព្រោះដូច្នោះ ពួកអ្នកត្រូវលះរបស់ដែលមិនមែនជារបស់ពួកអ្នកចេញទៅ ។ បទថា **យថាបច្ចយំ វា ករេយ្យ** សេចក្តីថា អ្នកប្រាថ្នាដោយប្រការណា ៗ គប្បីធ្វើដោយប្រការនោះៗ ។ បទថា **ន ហិ នោ ឯតំ ភន្តេ អត្តា វា** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន សមណព្រាហ្មណ៍ទាំងឡាយពោល ស្មៅ ឈើ មែកឈើ និងស្លឹកឈើនោះថា មិនមែនខ្លួនរបស់យើង មិនមែនរូបរបស់យើង មិនមែនវិញ្ញាណរបស់យើង ។ បទថា **អត្តនិយំ វា** សេចក្តីថា សូម្បីបរិក្ខារ មានចីវរជាដើម មិនមែនជារបស់យើង ។ បទថា **ឯវមេវ ខោ ភិក្ខវេ យំ ន តុម្ហាកំ តំ បជហថ** សេចក្តីថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងខន្ធបញ្ចកៈនោះថា មិនមែនរបស់អ្នក ទើបទ្រង់ឲ្យលះចេញ តែក៏មិនមែនឲ្យដកហូតចេញ ឬកាត់ខន្ធបញ្ចកៈ តែឲ្យលះចេញ ដោយការកម្ចាត់ឆន្ទរាគៈ ។

(២៦) គប្បីជ្រាប វិនិច្ឆ័យក្នុងពាក្យថា **ឯវំ ស្វាក្ខាតោ** នេះ ដូច្នេះ

សូម្បីទីងទាំមកនូវបរិវដ្ដ: ៣ ទើបដល់ឋាន:នេះ ក៏គួរដោយបដិលោម និង ថយត្រឡប់មកតាំងពី **បេមមត្តសត្តបរាយន:** រហូតដល់ឋាន:នេះ ក៏គួរ ។ បទថា **ស្វាក្ខាតោ** សេចក្ដីថា ទ្រង់ត្រាស់ទុក ល្អហើយ គឺ ងាយ បើក បង្ហាញ ប្រកាសហើយ ព្រោះជាធម៌ដែលទ្រង់ត្រាស់ទុកល្អហើយ ។ សំពត់ រហែក ដាច់ដាច ដែលគេដេរធ្វើជាចំណាងទុកក្នុងទីនោះ ៗ សំពត់ប្រឡាក់ ដោយមន្ទិល លោកហៅថា សំពត់ចាស់ ក្នុងពាក្យថា **ឆិន្នបិលោតិកោ** អ្នកណាមិនមានសំពត់ចាស់នោះ អ្នកនោះស្លៀកសំពត់ថ្មី ៨ ហត្ថខ្លះ ៩ ហត្ថខ្លះ ឈ្មោះថា អ្នកខ្វះខាតសំពត់ចាស់ ។ សូម្បីធម៌នេះ ក៏ដូច្នោះ , ក៏ក្នុងពាក្យនេះ មិនមានការ: ដូចសំពត់ដែលដាច់ ដែលរហែក ដែលដេរ ធ្វើជាចំណាងដោយការបញ្ឆោតជាដើម ។ម្យ៉ាងទៀត សំរាម លោកហៅថា **បិលោតិក** តែដែលឈ្មោះថា សមណ:សំរាម នៅក្នុងសាសនានេះមិនបាន ។

ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា ៖

ពួកអ្នកត្រូវកម្ចាត់សមណ:សំរាម ត្រូវបោសសមណ:
គំនរសំរាមត្រូវបណ្ដេតសមណ:អន្ធាម ដែលមិនមែនជា
សមណ: តែសម្គាល់ថា ជាសមណ: ចេញពីសាសនា
កាលបើកម្ចាត់សមណ: ដែលមានសេចក្ដីប្រាថ្នាលាមក

ដែលមានអាចារៈ និងគោចរដ៏ល្អមក គប្បីរស់នៅបរិសុទ្ធ នៅរួមជាមួយអ្នកបរិសុទ្ធ មានសតិចំពោះមុខ តពីនោះមាន សេចក្តីព្រមព្រៀងគ្នា មានបញ្ញារក្សាខ្លួន នឹងធ្វើទីបំផុត ទុក្ខបាន ។

ធម៌នេះរមែងឈ្មោះថា ខ្វះសំពត់ចាស់ ព្រោះខ្វះសមណៈសម្រាម ដោយប្រការដូច្នេះ ។ បទថា វដ្តន្តេសំ នត្ថិ បញ្ញាបនាយ សេចក្តីថា វដ្តៈរបស់ភិក្ខុទាំងនោះ ដល់នូវការមិនមានបញ្ញត្តិ រកបញ្ញត្តិមិនបាន ។ ព្រះមហាខីណាស្រពបែបនោះ រមែងកើតឡើងក្នុងសាសនា ដែលព្រះមាន- ព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ទុកល្អហើយយ៉ាងនេះ ប៉ុណ្ណោះ ។ ក៏ព្រះ ខីណាស្រពដូចម្តេច ព្រះអរិយបុគ្គល មានព្រះអនាគាជាដើម ក៏ដូច្នោះ ។ បណ្តាព្រះអរិយបុគ្គលទាំងនោះ ព្រះអរិយបុគ្គលពីរនេះ គឺ ធម្មានុសារី សទ្ធានុសារី រមែងជាអ្នកតាំងនៅក្នុងសោតាបត្តិមគ្គ ។ ដូចដែលលោក ពោលទុកថា ធម្មានុសារីបុគ្គលយ៉ាងណា បញ្ញិន្ទ្រិយ៍របស់បុគ្គលណាដែល បដិបត្តិដើម្បីធ្វើឲ្យត្រាស់ដឹងសោតាបត្តិផល មានប្រមាណដ៏ក្រៃលែង រមែង ចម្រើនអរិយមគ្គ មានបញ្ញាជាគ្រឿងនាំ មានបញ្ញាជាប្រធាន បុគ្គលនេះ លោកហៅថា ធម្មានុសារី , បុគ្គលដែលបដិបត្តិដើម្បីធ្វើឲ្យបានសម្រេច

សោតាបត្តិផល ជាធម្មានុសារី ដែលតាំងនៅក្នុងផល ឈ្មោះថា ទិដ្ឋិប្បត្ត , ក៏សទ្ធានុសារីបុគ្គល តើដូចម្តេច សទ្ធិន្ទ្រិយ៍របស់បុគ្គលណា ដែលបដិបត្តិ ដើម្បីធ្វើឲ្យបានសោតាបត្តិផល មានប្រមាណដ៏ក្រៃលែង ចម្រើនអរិយមគ្គ មានសទ្ធាជាធំ មានសទ្ធាជាប្រធាន បុគ្គលនេះលោកហៅថា សទ្ធានុសារី , បុគ្គលដែលបដិបត្តិ ដើម្បីធ្វើឲ្យបានសោតាបត្តិផលជាសទ្ធានុសារី បុគ្គល ដែលតាំងនៅក្នុងផល ដែលបង្អោនទៅដោយសទ្ធា ។ ដោយពាក្យថា **យេសំ មយិសទ្ធាមត្តំ បេមមត្តំ** នេះ លោកសំដៅយកពួកបុគ្គលដែល ចម្រើនវិបស្សនាដែលមិនមាន អរិយធម៌យ៉ាងដទៃ មានត្រឹមតែការជឿ ត្រឹមតែការស្រឡាញ់ក្នុងព្រះតថាគតប៉ុណ្ណោះ ។ ពិតហើយ ពួកភិក្ខុដែល អង្គុយផ្តើមវិបស្សនា កើតការជឿម្យ៉ាង ការស្រឡាញ់ម្យ៉ាង ក្នុងព្រះ ទសពល អ្នកដែលមានសេចក្តីជឿនោះ សេចក្តីស្រឡាញ់នោះ ដូចចាប់ ដៃដាក់ទុកក្នុងស្ថានសួគ៌ ។ ន័យថា ភិក្ខុទាំងនោះ មានគតិទៀង ។ ចំណែក ពួកព្រះថេរៈដែលចាស់ ៗ ហៅភិក្ខុទាំងនោះថា **ព្រះចូឡសោតាបន្ន** ។ ពាក្យដ៏សេស ក្នុងទីគ្រប់កន្លែងងាយទាំងអស់ ។

( ចប់អដ្ឋកថា អលគទ្ទូបមសូត្រទី២ )

# អដ្ឋកថា
## វម្មិកសូត្រ ទី៣

(២៧) វម្មិកសូត្រ មានពាក្យផ្តើមថា ខ្ញុំម្ចាស់បានស្តាប់មកហើយយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវម្មិកសូត្រនោះ ពាក្យថា **អាយស្មា** នេះ ជាពាក្យពោលសម្តែងដល់កាពដែលគួរជាទីស្រឡាញ់ ។

(២៨) ពាក្យថា **កុមារកស្សបោ** ជាឈ្មោះរបស់លោក ។ ពីព្រោះលោកបួសនៅក្នុងវ័យក្មេង កាលដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា ចូរហៅកស្សបៈមក ចូរឲ្យផ្លែឈើ ឬវត្ថុទំពាស៊ីនេះដល់កស្សបៈ ព្រោះភិក្ខុទាំងឡាយបានសង្ស័យថា កស្សបៈអង្គណា ទើបដាក់ឈ្មោះលោកយ៉ាងនេះថា **កុមារកស្សប** តាំងពីនោះមក ក្នុងពេលដែលលោកមានវ័យចាស់ ក៏នៅហៅថា **កុមារកស្សប** យ៉ាងនេះឯង ។ម្យ៉ាងទៀតមនុស្សទាំងឡាយសម្គាល់លោកថា **កុមារកស្សប** ព្រោះជាបុត្តចិញ្ចឹមរបស់ព្រះរាជា ។ នឹងពោលឲ្យជាក់ច្បាស់ដល់បុព្វប្រយោគរបស់លោក ដូចតទៅនេះ ។

ដូចបានស្តាប់មក ព្រះថេរៈជាបុត្តសេដ្ឋីក្នុងសម័យព្រះពុទ្ធជាម្ចាស់ព្រះនាមថា **បទុមុត្តរ** តមកថ្ងៃមួយ ព្រះថេរៈឃើញព្រះមានព្រះភាគជាម្ចាស់

ទ្រង់ស្តាបនាសាវករបស់ព្រះអង្គ មួយអង្គ ជាអ្នកពោលធម៌ដ៏វិចិត្រ ទុកក្នុងលំដាប់ឋានន្តរៈ ទើបធ្វើការថ្វាយទាន ៧ ថ្ងៃ ដល់ព្រះមានព្រះភាគជាម្ចាស់ ធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ សូម្បីខ្ញុំព្រះអង្គក៏គប្បីជាសាវកអ្នកពោលធម៌ដ៏វិចិត្រដូចព្រះថេរៈអង្គនេះ របស់ព្រះពុទ្ធជាម្ចាស់មួយព្រះអង្គក្នុងអនាគតកាល យ៉ាងនេះ ហើយធ្វើបុណ្យទាំងឡាយ បួសក្នុងព្រះសាសនារបស់ព្រះមានព្រះភាគជាម្ចាស់ព្រះនាមថា **កស្សប** តែមិនអាចធ្វើគុណវិសេសឲ្យកើតបាន ។ បានឮថា គ្រានោះ កាលព្រះសាសនារបស់ព្រះដ៏មានព្រះភាគជាម្ចាស់ ស្តេចបរិនិព្វានហើយ សាសនាព្រះជិនស្រីក៏មានសភាពអន់ថយចុះ ភិក្ខុចំនួនប្រាំអង្គបានចងជណ្តើរឡើងភ្នំ ធ្វើសមណធម៌ ។ ព្រះសង្ឃត្ថេរៈ បានសម្រេចព្រះអរហត្តនៅថ្ងៃទី ៣ ។ ព្រះអនុថេរៈ ជាព្រះអនាគាមីនៅថ្ងៃទី ៤ ។ ចំណែកព្រះថេរៈ ៣ អង្គ ទៀតមិនអាចធ្វើគុណវិសេសឲ្យកើត ក៏ទៅកើតក្នុងទេវលោក ។ កាលទេពទាំងនោះ សោយសម្បត្តិក្នុងទេវតា និងមនុស្សអស់មួយចន្លោះព្រះពុទ្ធមួយអង្គ ក៏ទៅកើតក្នុងរាជត្រកូល ក្រុងតក្កសីលា ជាព្រះរាជាព្រះនាមថា **បុក្កុសាតិ** បួសឧទ្ទិសដល់ព្រះមានព្រះភាគជាម្ចាស់ មកកាន់ក្រុងរាជគ្រឹះ ស្តាប់ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគជាម្ចាស់ ត្រង់រោងស្មូនឆ្នាំងរួចសម្រេចអនា-

គាមិផល ។ មួយអន្លើ កើតក្នុងត្រកូលជិតកំពង់ផែនៃសុប្បារកៈ ។ ឡើងសំពៅទៅរកស៊ី សំពៅលិច ស្នៀកសំបកឈើជំនួសសំពត់ បានលាភសម្បត្តិ កើតការគិតឡើងថា អញជាព្រះអរហន្ត ត្រូវទេវតាដែលមានបំណងល្អដាស់តឿនថា អ្នកមិនមែនជាព្រះអរហន្តទេ គប្បីទៅទូលសួរបញ្ហានឹងព្រះសាស្តាចុះ បានធ្វើដូចយ៉ាងនោះ រួចក៏សម្រេចអរហត្តផល ។ មួយអន្លើទៀត កើតក្នុងផ្ទៃនៃស្ត្រីដែលមានត្រកូលក្នុងក្រុងរាជគ្រឹះ ។ នាងបានសុំអង្វរមាតាបិតា កាលមិនបានបព្វជ្ជា ក៏រៀបការ មិនដឹងថាខ្លួនមានគភ៌ បានអង្វរ-កស្វាមី ស្វាមីក៏អនុញ្ញាត ទើបបានបួសក្នុងសម្នាក់ភិក្ខុនី ភិក្ខុនីទាំងឡាយឃើញនាងមានគភ៌ ទើបសួរព្រះទេវទត្ត ។ ព្រះទេវទត្តឆ្លើយថា នាងមិនមែនសមណៈឡើយ ។ ពួកភិក្ខុនីបានទៅក្រាបទូលសួរព្រះទសពល ។ ព្រះសាស្តាប្រោសឲ្យ ព្រះឧបាលិទទួលរឿងទុកពិចារណា ព្រះថេរៈ ឲ្យអញ្ជើញត្រកូលអ្នកនគរសាវត្ថី និងព្រះនាងវិសាខាឧបាសិកា ឲ្យជួយដោះស្រាយគ្នា ( ដឹងការខុសត្រូវហើយ ) ទើបពោលថា នាងមានគភ៌មកអំពីមុនបព្វជ្ជា ទើបមិនខូចបព្វជ្ជា ។ ព្រះសាស្តាប្រទានសាធុការដល់ ព្រះថេរៈថា ឧបាលិវិនិច្ឆ័យអធិករណ៍ល្អហើយ ។ ភិក្ខុនីនោះ ប្រសូតបុត្ត មានសភាពដូចពិម្ព-មាស (ខ្នើយមាស) ។ ព្រះបាទបសេនទិកោសល ទ្រង់ទទួលក្មេងនោះមក

ចិញ្ចឹម ។ ប្រទានទាមក្មេងនោះថា **កស្សប** តមកទ្រង់ចិញ្ចឹមចម្រើនវ័យ ហើយ បាននាំទៅសម្នាក់ព្រះសាស្តាដើម្បីបព្វជ្ជា ។ ដូច្នោះ មនុស្សទាំងឡាយ ទើបសម្គាល់ឈ្មោះក្មេងនោះថា **កុមារកស្សប** ព្រោះជាបុត្តចិញ្ចឹមរបស់ព្រះរាជានោះឯង ។ បទថា **អន្ធវនេ** បានដល់ ព្រៃមានឈ្មោះយ៉ាងនេះ ។ គេថា ព្រៃនោះមានឈ្មោះយ៉ាងនេះ ក្នុងសម័យព្រះពុទ្ធជាម្ចាស់ ២ ព្រះអង្គ ប្រាកដឈ្មោះថា អន្ធវ័ននោះឯង ។ ក្នុងព្រៃអន្ធវ័ននោះ នឹងធ្វើឲ្យមានរឿងរ៉ាវជាក់ច្បាស់ដូចតទៅនេះ ៖

ពិតហើយ សរីរធាតុរបស់ព្រះពុទ្ធជាម្ចាស់ ដែលព្រះអង្គមានជន្មាយុតិច មិនទៅផ្តុំគ្នាតែមួយដុំ រមែងខ្ចាត់ខ្ចាយទៅ ដោយអានុភាពនៃការអធិដ្ឋាន ។ ដោយហេតុនោះឯង ព្រះមានព្រះភាគជាម្ចាស់របស់យើងទាំងឡាយ ទ្រង់អធិដ្ឋានថា តថាគតស្ថិតនៅបានមិនយឺនយូរ ពួកសត្វមានចំនួនតិច នឹងបានឃើញតថាគត អ្នកមិនបានឃើញតថាគតមានចំនួនច្រើនជាងសត្វទាំងនោះ កាន់យកធាតុរបស់តថាគត បូជានៅក្នុងទីនោះ នឹងបានស្ថានសួគ៌នៅខាងមុខ ព្រោះដូច្នោះ សម័យបរិនិព្វានសូមសរីរធាតុរបស់តថាគត ចូរខ្ចាត់ខ្ចាយទៅ ។ ចំណែកព្រះពុទ្ធជាម្ចាស់ ដែលមានព្រះជន្មាយុវែង ព្រះសរីរធាតុតាំងនៅមួយកន្លែងជាមួយគ្នា ដូចដុំមាស ។ សូម្បី

ព្រះសរីរធាតុរបស់ព្រះមានព្រះភាគជាម្ចាស់ ព្រះនាមថា **កស្សប** ក៏តាំងនៅយ៉ាងនោះដូចគ្នា ។ តាំងពីនោះ មហាជនក៏ប្រជុំប្រឹក្សាគ្នាថា យើងមិនអាចបំបែកដុំព្រះធាតុនោះបាន ពួកយើងនឹងធ្វើយ៉ាងណា ទើបសម្រេចគ្នាថា យើងនឹងធ្វើព្រះធាតុមួយដុំនោះឯង ឲ្យទៅជាព្រះចេតិយ៍ នឹងមានទំហំប៉ុនណា ។ មួយពួកនិយាយថា យក ៧ យោជន៍ តែយល់ព្រមគ្នាថានោះធំហួសពេក អ្នកណា ៗ មិនអាចនឹងថែរក្សាបាន ក្នុងអនាគតកាល យក ៦ យោជន៍ ៥ យោជន៍ ៤ យោជន៍ ៣ យោជន៍ ២ យោជន៍ ១ យោជន៍ ប្រឹក្សាគ្នាថា នឹងប្រើឥដ្ឋដូចម្តេច សម្រេចគ្នាថា ខាងក្រៅជាឥដ្ឋមួយដុំ ៗ ធ្វើដោយមាសពណ៌ក្រហម មានតម្លៃ ១០០.០០០ , ខាងក្នុងមានតម្លៃ ៥០.០០០ លាបដោយហរិតាល[១] និងមនោសិលាជំនួសដី លាបដោយប្រេងជំនួសទឹក បែកចេញជាបួនមុខ មួយមុខ ៗ ជាបួនទៀត ។ ព្រះរាជាទ្រង់ទទួលមុខមួយ , បដ្ឋវិនធរកុមាររាជបុត្តទទួលមុខមួយ , សេនាបតីប្រធានអាមាត្យទទួលមុខមួយ , សេដ្ឋីមេស្រុកជនបទទទួលមុខ

---

១ ពាក្យថា « ហរិតាល » ប្រែថា វត្ថុមួយប្រភេទស្មើរជាថ្ម តែសាច់ទន់សម្បុរលឿងខ្ចី ដុស ឬកិនយកផង់ប្រើការធ្វើពណ៌លឿងជាដើម [តាមវចនានុក្រមខ្មែរ ] ។

មួយ ។ បណ្ដាជនទាំងនោះ ព្រោះជាអ្នកសម្បូណ៌ដោយទ្រព្យ ។ ព្រះរាជា បានឲ្យជញ្ជូនមាសមក ទ្រង់ផ្ដើមកិច្ចការងារត្រង់មុខដែលព្រះអង្គទទួល ទាំងឧបរាជ ទាំងសេនាបតី ក៏ដូចគ្នា ។ ចំណែកការងារត្រង់មុខដែល សេដ្ឋីទទួល ក៏ស្រួតទៅ ។ គ្រានោះឧបាសកម្នាក់ឈ្មោះ **យសោធរ** ជា អរិយសាវកថ្នាក់អនាគាមី ទ្រទ្រង់ព្រះត្រៃបិដកដឹងថា សេដ្ឋីនោះធ្វើការ ស្រួតទៅ ទើបឲ្យទឹមរទេះចំនួនប្រាំរយ ទៅកាន់ជនបទ បបួលមនុស្ស ទាំងឡាយថា ព្រះកស្សបសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ព្រះជន្ម ២ ម៉ឺនឆ្នាំ បរិនិព្វានយូរហើយ ពួកយើងនឹងធ្វើរតនចេតីយ៍មួយយោជន៍ ថ្វាយចំពោះ ព្រះអង្គ អ្នកណានឹងឲ្យវត្ថុអ្វី ជាមាស ឬជាប្រាក់ កែវ ៧ ប្រការ ហរិតាល ឬមនោសិលាក៏ដោយ អ្នកនោះចូរឲ្យវត្ថុនោះចុះ ។ អ្នកស្រុក ទាំងឡាយ បានឲ្យប្រាក់ និងមាសជាដើម តាមកម្លាំងរបស់ខ្លួន ។ កាល មិនអាចនឹងឲ្យបាន ក៏ឲ្យប្រេង និងអង្ករជាដើមប៉ុណ្ណោះ ។ ឧបាសកជូន ប្រេង និងអង្ករជាដើម ដើម្បីជាអាហារប្រចាំថ្ងៃដល់កម្មករទាំងឡាយ ដ៏សេស ក៏បំណងនឹងឲ្យមាស ។ បានឃោសនាទូទៅក្នុងជម្ពូទ្វីប ដោយអាការយ៉ាង នេះ ។

ការងារព្រះចេតីយ៍ស្រេចហើយ ព្រោះដូច្នោះ ពួកគេបញ្ជូនសំបុត្រ

ទៅអំពីចេតិយស្ថានថា ការងាររួចស្រេចហើយ សូមអាចារ្យចូលមកថ្វាយបង្គំព្រះចេតីយ៍ ។ សូម្បីអាចារ្យក៏បានផ្ញើសំបុត្រទៅថា យើងបានបបួលអ្នកជម្ពូទ្វីបទូទៅហើយ វត្ថុអ្វីដែលមាន ចូរកាន់យកវត្ថុនោះធ្វើការងារឲ្យសម្រេច ។ សំបុត្រពីរច្បាប់នោះ ក៏បានជួបគ្នាក្នុងវវាងផ្លូវ ឯសំបុត្រពីចេតិយស្ថាន បានទៅដល់ដៃរបស់អាចារ្យ មុនសំបុត្ររបស់អាចារ្យ ។ អាចារ្យនោះមើលសំបុត្រហើយក៏គិតថា នឹងទៅថ្វាយបង្គំព្រះចេតីយ៍ ក៏ចេញទៅតែម្នាក់ឯង ។ នៅក្នុងវវាងផ្លូវ ចោរ ៥០០ រយ ក៏ប្រាកដឡើងក្នុងព្រៃក្រាស់ ។ បណ្តាចោរទាំងនោះ ពួកខ្លះឃើញអាចារ្យនោះ គិតថា មនុស្សនេះប្រមូលប្រាក់ និងមាសពីជម្ពូទ្វីបទាំងអស់ ។ មនុស្សទាំងឡាយដែលរក្សាទ្រព្យនឹងមកជាមួយ ទើបប្រាប់ដល់ចោរដែលនៅសល់ ឲ្យចាប់អាចារ្យនោះ ។ អាចារ្យសួរថា អ្នកអើយ ហេតុអ្វីពួកអ្នកមកចាប់យើង ។ ពួកចោរឆ្លើយថា អ្នកប្រមូលប្រាក់ និងមាសទាំងអស់ពីជម្ពូទ្វីប អ្នកត្រូវឲ្យទ្រព្យបន្តិចបន្តួចដល់ពួកយើងមក ។ អាចារ្យសួរថា ពួកលោកមិនដឹងទេឬថា ព្រះពុទ្ធជាម្ចាស់ព្រះនាម **កស្សប** បរិនិព្វានហើយ ពួកយើងកំពុងកសាងព្រះរតនចេតីយ៍មួយយោជន៍ ថ្វាយព្រះអង្គ ក៏យើងបបែបបួលគ្នាដើម្បីប្រយោជន៍នោះ មិនមែនដើម្បីប្រយោជន៍របស់ខ្លួន ដូច្នោះចាំបាច់ត្រូវ

នាំវត្ថុដែលបានរក្សាទុកហើយទៅកាន់ទីនោះឯង ។ ចំណែកក្រៅពីសំពត់ដែលស្លៀកពាក់មក ក៏មិនមានអ្វីដទៃ សូម្បីត្រឹមតែមួយកាកណិក ។ ចោរមួយពួកទៀតពោលថា សេចក្តីនោះពិតយ៉ាងនោះ អ្នកចូរដោះលែងអាចារ្យនោះទៅ ។ ចោរមួយពួកពោលថា អាចារ្យនេះ ព្រះរាជាក៏បូជា អាមាត្យក៏បូជា បើឃើញបុគ្គលខ្លះនៃពួកយើងនៅតាមផ្លូវព្រះនគរ គេនឹងប្រាប់ព្រះរាជា និងមហាមាត្យរបស់ព្រះរាជាជាដើម នឹងធ្វើឲ្យពួកយើងដល់នូវសេចក្តីវិនាសបាន ។ ឧបាសកពោលថា អ្នកអើយ ខ្ញុំមិនធ្វើយ៉ាងនោះទេ ក៏ពេលនោះ មានតែសេចក្តីករុណាក្នុងចោរទាំងនោះ មិនមានសេចក្តីស្រឡាញ់ សូម្បីក្នុងជីវិតរបស់ខ្លួន ។ កាលបើយ៉ាងនោះ បណ្តាចោរទាំងនោះ ដែលកំពុងជជែកគ្នាថា គួរចាប់ទុក គួរលែងទៅ ពួកចោរដែលមានការយល់ថា គួរចាប់ មានចំនួនច្រើនជាង ក៏សម្លាប់អាចារ្យនោះទៅ ។ កែវភ្នែករបស់ចោរទាំងនោះ ក៏អន្តរធានទៅ ដូចប្រទីបរលត់ ព្រោះធ្វើខុសចំពោះព្រះអរិយសាវក ដែលមានគុណច្រើន ។ ចោរទាំងនោះរៀបរាប់ថា កែវភ្នែកនៅឯណា កែវភ្នែកនៅឯណា ។ ពួកខ្លះញាតិក៏នាំត្រឡប់ទៅស្រុក ពួកខ្លះមិនមានញាតិ ក៏ទៅជាមនុស្សអនាថា ។ ព្រោះដូច្នោះទើបអាស្រ័យនៅក្នុងបណ្ណសាលាទៀបគល់ឈើក្នុងព្រៃទុំៈឯង ។ ពួកមនុស្ស

ដែលមកក្នុងព្រៃ ក៏ឲ្យអង្ករខ្លះ បាយកញ្ចប់ខ្លះ ស្បៀងខ្លះ ដល់ចោរទាំងនោះ ដោយសេចក្ដីករុណា ។ ពួកមនុស្សដែលទៅរកឈើ និងស្លឹកឈើជាដើម ត្រឡប់មកវិញហើយ កាលបើត្រូវគេសួរថា ពួកអ្នកទៅណាហ្នឹង ក៏ឆ្លើយថា ពួកយើងទៅព្រៃមនុស្សខ្វាក់ ។ ព្រៃនោះ ប្រាកដឈ្មោះថា **អន្ធវន** ក្នុងសម័យព្រះពុទ្ធជាម្ចាស់ ២ ព្រះអង្គ ដោយប្រការដូច្នេះ ។

ក៏ព្រៃនោះ សម័យព្រះពុទ្ធជាម្ចាស់ព្រះនាមថា **កស្សប** បានក្លាយទៅជាព្រៃ ក្នុងជនបទដែលបាត់បង់ទៅ ។ លុះដល់សម័យព្រះមានព្រះភាគជាម្ចាស់របស់យើង បានក្លាយទៅជាទីកន្លែងសម្រាប់ធ្វើសេចក្ដីព្យាយាមជាស្ថានទីនៅរបស់ពួកកុលបុត្ត ដែលត្រូវការសេចក្ដីស្ងប់ នៅក្រោយវត្តជេតវនមិនឆ្ងាយពីក្រុងសាវត្ថី ។ សម័យនោះ ព្រះកុមារកស្សបៈ បានបំពេញសេក្ខបដិបទានៅក្នុងព្រៃអន្ធវននោះ ។ ព្រោះដូច្នោះ ទើបលោកពោលថា **អន្ធវនេ វិហរតិ** ។

បទថា **អញ្ញតរា ទេវតា** បានដល់ ទេវតាមួយអង្គមិនប្រាកដនាមនិងគោត្រ ។ សូម្បីសក្កទេវរាជ ដែលដឹងច្បាស់លាស់ លោកក៏ហៅថា **អញ្ញតរោ** ក្នុងបាលីនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជ្រាប ឬមិនជ្រាប ព្រះអង្គបានត្រាស់ថា **តណ្ហា សង្ខយ វិមុត្តិ**

ដោយសន្ទេបដល់យក្ស ដែលមានសក្តិធំមួយនាក់ ។ សូម្បីពាក្យថា ទេវតា នេះ ជាពាក្យហៅទូទៅសម្រាប់ទេវតាទាំងឡាយ ។ តែក្នុងទីនេះ លោកសំដៅយក **ទេព** ក្នុងពាក្យថា ទេវតានោះ ។ **អភិក្កន្ត** ស័ព្ទ ក្នុងពាក្យថា **អភិក្កន្តាយ រត្តិយា** ប្រាកដក្នុងអត្ថទាំងឡាយមាន អស់ទៅ ល្អ ស្អាត និងសេចក្តីត្រេកអរក្រៃលែងជាដើម ។ ក្នុងអត្ថទាំងនោះ **អភិក្កន្ត** ស័ព្ទ ប្រាកដអត្ថថា **អស់ទៅ** បានក្នុងពាក្យជាដើម យ៉ាងនេះថា រាត្រីអស់ទៅហើយ បឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ សូមព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រោសសម្តែងបាតិមោក្ខដល់ភិក្ខុទាំងឡាយចុះ ។

ប្រាកដក្នុងអត្ថថា **ល្អ** បានក្នុងពាក្យជាដើមយ៉ាងនេះថា អ្នកនេះល្អជាង ប្រណីតជាង បុគ្គល ៤ ជំពូកនេះ ។ ប្រាកដក្នុងអត្ថថា **ស្អាត** បានក្នុងពាក្យជាដើមយ៉ាងនេះថា ៖

អ្នកណារុងរឿងដោយឫទ្ធិ យស មានវណ្ណៈស្រស់ល្អ
ធ្វើទិសទាំងពួងឲ្យភ្លឺស្វាង មកថ្វាយបង្គំព្រះបាទាទាំង
២ របស់តថាគត ។

ប្រាកដក្នុងអត្ថថា **ត្រេកអរយ៉ាងក្រៃលែង** បានក្នុងពាក្យជាដើម យ៉ាងនេះថា ព្រះគោតមដ៏ចម្រើនគួរត្រេកអរពិតៗ ។ តែក្នុងទីនេះ **អភិក្កន្ត**

ស័ព្ទ ប្រាកដក្នុង អត្ថថា អស់ទៅ ។ ព្រោះហេតុនោះ បទថា **អភិក្កន្តាយ រត្តិយា** លោកទើប អធិប្បាយថា កាលនៃរាត្រីអស់ទៅហើយ ។ ក្នុងសេចក្ដីនោះគប្បីជ្រាបថា ទេវបុត្រនេះ មកក្នុងចន្លោះមជ្ឈិមយាម ។ **អភិក្កន្ត** ស័ព្ទ ក្នុងបទថា **អភិក្កន្តវណ្ណា** នេះ ប្រាកដក្នុងអត្ថថា **ស្រស់** , ចំណែក **វណ្ណ** ស័ព្ទ ប្រាកដក្នុងអត្ថមានជាអាទិ៍ថា ពណ៌សម្បុរគួរពីកកាយ ពួកត្រកូល ហេតុ ទ្រង់ទ្រាយ ប្រមាណ និងរូបាយតនៈ ។ ក្នុងអត្ថទាំងនោះ **អភិក្កន្ត** ស័ព្ទ ប្រាកដក្នុងអត្ថថា **ពណ៌សម្បុរ** បានក្នុងពាក្យជាដើមយ៉ាងនេះថា បពិត្រព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គមានវណ្ណៈដូចមាស ។ ប្រាកដក្នុងអត្ថថា **គួរសរសើរ** បានក្នុងពាក្យជាជីមយ៉ាងនេះថា ម្នាលគហបតិក្នុងកាលណាវណ្ណៈរបស់ព្រះសមណគោតម ដែលលោកគួរសរសើរ។ ប្រាកដក្នុងអត្ថថា **ពួកត្រកូល** ក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ត្រកូល ៤ ពួកនេះ ។ ប្រាកដក្នុងអត្ថថា **ហេតុ** បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា កាលបើដូច្នោះ ព្រោះហេតុអ្វីហ្ន៎ លោកទើបពោលថា លួចក្លិន ។ ប្រាកដក្នុងអត្ថថា ទ្រង់ទ្រាយ បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា និមិត្តរូបរាងស្ដេចដំរីធំ ។ ប្រាកដក្នុងអត្ថថា ប្រមាណ បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា បាត្រ ៣ ខ្នាត ។ ប្រាកដ

ក្នុង *រូបាយតនៈ* បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា *រូបាយតនៈ គន្ធា-យតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈ* ។

**អភិក្កន្តស្ត** សព្ទនោះ គប្បីឃើញថា ចុះក្នុងអត្ថថា **ពណ៌សម្បុរ** ក្នុងទីនេះ ។ ដោយហេតុនោះ បទថា **អភិក្កន្តវណ្ណា** លោកអធិប្បាយទុកថា មានពណ៌សម្បុរស្អាត មានសម្បុរគួរប្រាថ្នា គួរពេញចិត្ត ។ ពិតហើយ ទេវតាទាំងឡាយ កាលមកកាន់មនុស្សលោក លះបង់ពណ៌សម្បុរយ៉ាងធម្មតា ឫទ្ធិធម្មតា ធ្វើអត្តភាពឲ្យគ្រោតគ្រាត និមិត្តសម្បុរលើសប្រក្រតី ឫទ្ធិលើសប្រក្រតី មកដោយកាយដែលតុបតែងហើយ ដូចមនុស្សទៅកាន់ទីប្រជុំក្រុមរបាំជាដើម ។ ទេវបុត្តនេះ ក៏មកដោយអាការយ៉ាងនោះឯង ។ ហេតុនោះ លោកពោលថា **អភិក្កន្តវណ្ណា** ។

**កេវល** សព្ទ ក្នុងពាក្យថា **កេវលកប្បំ** នេះ មានអត្ថជាអនេកដូចមិនមានចំណែកសល់ដោយច្រើន **មិនផ្សំ មិនលើស ណែនណាន់ មិនប្រកប** ជាដើម ។ ពិតយ៉ាងនោះ **កេវល** សព្ទនោះ មានអត្ថថាមិនសល់ បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា ព្រហ្មចរិយៈបរិសុទ្ធបរិបូរដោយមិនសល់ ។ អត្ថដោយច្រើន បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា ដោយច្រើនអ្នកដែនអង្គៈ និងមគធៈ កាន់របស់ទំពារបស់ស៊ីជាច្រើន ចូល

ទៅគាល់ ។ មានអត្ថថា **មិនផ្សំ** បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា កងទុក្ខសុទ្ធៗ រមែងកើតឡើង ។ មានអត្ថថា **មិនលើស** បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា ពិតមែន លោកនោះ មានសទ្ធាតែម្យ៉ាង ។ មានអត្ថថា **ណែនណាន់** បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា សទ្ធិវិហារិករបស់ព្រះអនុរុទ្ធ ឈ្មោះថា ពាហិកៈ តាំងនៅក្នុងសង្ឃភេទអស់មួយថ្ងៃពិតមែន ។ មានអត្ថថា **មិនប្រកប** បានក្នុងពាក្យមាន ជាអាទិ៍យ៉ាងនេះថា អ្នកនៅចប់ព្រហ្មចរិយៈស្រេចហើយ លោកហៅថា បុរសខ្ពស់បំផុត ។ តែក្នុងទីនេះ លោកមានបំណងយកថា ដោយអត្ថ **មិនសល់** ។

ចំណែក **កប្ប** ស័ព្ទនេះ មានអត្ថជាអនេក ដូចជា ជឿយ៉ាងក្រៃលែង វោហារ កាល បញ្ញត្តិ កាត់ វិកប្ប ឧបាយកល ដោយជុំវិញ ។ ពិតយ៉ាងនោះ **កប្ប** ស័ព្ទនោះ មានអត្ថថា **គួរជឿយ៉ាងក្រៃលែង** ក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា ពាក្យនេះរបស់ព្រះគោតម ដែលជាព្រះអរហន្តសម្មាសម្ពុទ្ធ គួរជឿពិតមែន ។ មានអត្ថថា **វោហារ** បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ យើងអនុញ្ញាតឲ្យឆាន់ផ្លែឈើដោយសមណវោហារ ៥ យ៉ាង ។ មានអត្ថថា **កាល** បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា បានឮថា ដោយហេតុដែលយើងនៅអស់កាលជានិច្ច ។

មានអត្ថថា **បញ្ញត្តិ** បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា លោកបញ្ញត្ត យ៉ាងនេះ ។ មានអត្ថថា **កាត់** បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា តែងខ្លួនកាត់សក់ និងពុកមាត់ ។ មានអត្ថថា **វិកប្ប** បានក្នុងពាក្យមាន ជាអាទិ៍យ៉ាងនេះថា វិកប្ប ២ អង្គុលី គួរ ។ មានអត្ថថា **ឧបាយកល** បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា មានឧបាយកលដើម្បីនឹងដេក ។ មាន អត្ថថា **ដោយជុំវិញ** បានក្នុងពាក្យមានជាអាទិ៍យ៉ាងនេះថា ធ្វើឲ្យភ្លឺដោយ ជុំវិញវត្តជេតពន តែក្នុងទីនេះ លោកមានបំណងយក **កប្ប** សព្ទនោះថា ដោយអត្ថថា **ដោយជុំវិញ** ។ ព្រោះដូច្នោះ ក្នុងពាក្យថា **កេវលកប្បំ អន្ធវនំ** នេះ គប្បីឃើញខ្លឹមសារយ៉ាងនេះថា ដោយជុំវិញអន្ធវន មិនមាន ចំណែកសល់ ។ បទថា **ឱភាសេត្វា** សេចក្តីថា ផ្សាយទៅដោយរស្មីដែល កើតឡើងពីសរីរៈ ប្រដាប់ដោយសំពត់ ធ្វើឲ្យមានឱភាសតែមួយដូចព្រះច័ន្ទ និងព្រះអាទិត្យ ។ បទថា **ឯកមន្តំ អដ្ឋាសិ** បានដល់ ឈរនៅក្នុងទីមួយ ដ៏សមគួរ គឺ ក្នុងឱកាសមួយ ។ បទថា **ឯតទវោច** បានដល់ ពោលជា មួយភិក្ខុនោះថា ភិក្ខុ ភិក្ខុ យ៉ាងនេះជាដើម ។

សួរថា ក៏ព្រោះហេតុអ្វី បានជាទេវតានេះមិនថ្វាយបង្គំ ពោលដោយ សមណវោហារតែម្យ៉ាង ។

ឆ្លើយថា ដោយការហៅជាសមណសញ្ញា ។ បានឮថា ទេវបុត្ត មានការគិតយ៉ាងនេះថា អ្នកនេះនៅក្នុងរវាងកាមាវចរភូមិ ចំណែកយើង ជាព្រហ្មចារី តាំងតែពីកាលនោះ ក្នុងវេលានោះ ។ សូម្បីសមណសញ្ញា របស់ទេវបុត្តនោះ នៅប្រាកដ ព្រោះដូច្នោះ ទេវបុត្តនោះទើបមិនថ្វាយបង្គំ ពោលដោយសមណវោហារ តែម្យ៉ាង ។

សួរថា បានឮថា ទេវបុត្តនោះ ជាសម្លាញ់ដំបូងរបស់ព្រះថេរៈតាំង ពីកាលណា ។

ឆ្លើយថា តាំងពីសម័យនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះនាមកស្សបៈ។

ពិតហើយ បណ្តាសម្លាញ់ទាំង ៥ ដែលមកក្នុងគ្រាមុន សម្លាញ់ នោះណា ដែលលោកពោលថា ព្រះអនុថេរៈ បានជាព្រះអនាគាមីក្នុងថ្ងៃ ទីបួន សម្លាញ់នោះ ក៏គឺ អ្នកនេះ ។ បានឮថា គ្រានោះបណ្តាព្រះថេរៈ ទាំងនោះ អភិញ្ញាព្រមជាមួយព្រះអរហត្តនោះឯង សម្រេចដល់សង្ឃត្ថេរៈ ។ ព្រះសង្ឃត្ថេរនោះគិតថា កិច្ចរបស់យើងដល់ទីបំផុតហើយ ទើបហោះទៅ កាន់នភាកាស ខ្មាមាត់នៅឯស្រះអនោត្តៈ ទទួលបិណ្ឌបាតអំពីឧត្តរកុរុទើប ត្រឡប់មក ហើយពោលថា អ្នកដ៏មានអាយុ ចូរឆាន់បិណ្ឌបាតនេះកុំប្រមាទ ហើយធ្វើសមណធម៌ ។ ពួកភិក្ខុក្រៅពីនេះ ពោលថា អ្នកដ៏មានអាយុ

ពួកយើងមិនមានកតិកាយ៉ាងនេះថា អ្នកណាធ្វើឲ្យសម្រេចគុណវិសេសមុន ក៏នាំបិណ្ឌបាតមក ពួកដ៏សេសឆាន់បិណ្ឌបាតដែលអ្នកនោះនាំមក ហើយធ្វើសមណធម៌ ពួកលោកសម្រេចទីបំផុតកិច្ចដោយឧបនិស្ស័យរបស់ខ្លួន បើពួកយើងនឹងមានឧបនិស្ស័យ ក៏នឹងសម្រេចកិច្ចទីបំផុត នោះជាការយឺតយូររបស់ពួកយើង ពួកលោកចូរទៅចុះ ។ សង្ឃត្ថេរនោះ ទៅដោយសេចក្ដីជាសុខ ហើយក៏បរិនិព្វានក្នុងកាលដែលអស់អាយុ ។ ព្រឹកស្អែកឡើង ព្រះអនុថេរៈ ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល អភិញ្ញាទាំងឡាយក៏កើតព្រមដល់លោក ។ សូម្បីលោក ក៏នាំបិណ្ឌបាតមកយ៉ាងនោះដូចគ្នា ត្រូវភិក្ខុទាំងនោះបដិសេធ ក៏ទៅតាមសេចក្ដីសប្បាយ កាលបើអស់អាយុក៏ទៅបដិសន្ធិក្នុងសុទ្ធាវាសព្រហ្ម ។

ព្រះអនុថេរៈនោះ កាលតាំងនៅក្នុងសុទ្ធាវាសព្រហ្មហើយ បានពិចារណាមើលសម្លាញ់ទាំងនោះ ក៏ឃើញថា សម្លាញ់ម្នាក់បរិនិព្វានក្នុងកាលនោះឯង ម្នាក់ទៀត សម្រេចអរិយភូមិក្នុងសម្នាក់ព្រះមានព្រះភាគដោយមិនយូរ ម្នាក់ទៀតអាស្រ័យលាភសក្ការៈ កើតការគិតឡើងថា យើងជាព្រះអរហន្ត នៅត្រង់កំពង់ទឹកឈ្មោះ សុប្បារកៈនោះឯង ហើយចូលទៅរកគេ បញ្ជូនគេទៅ ដោយពោលថា អ្នកមិនមែនជាព្រះអរហន្តទេ បដិបត្តិ

នៅមិនទាន់ដល់ព្រះអរហត្តមគ្គ ចូរទៅគាល់ព្រះមានព្រះភាគ ហើយស្តាប់ធម៌ចុះ ។ សូម្បីសម្ពាញ់ម្នាក់នោះ ទូលសូមឱវាទពីព្រះមានព្រះភាគក្នុងលង្វែកស្រុក ព្រះមានព្រះភាគ ទ្រង់ឲ្យឱវាទដោយសង្ខេបថា ពាហិយៈ ព្រោះហេតុដូច្នោះឯង អ្នកគប្បីសិក្សាក្នុងរបស់ដែលអ្នកបានឃើញហើយថា ត្រឹមតែឃើញ ក៏សម្រេចអរិយភូមិ ។ សម្ពាញ់ម្នាក់ក្រៅពីនោះ " នៅមាន " ក៏ពិចារណារកមើលថា នៅទីណា ក៏ឃើញថា កំពុងបំពេញសេក្ខបដិបទា នៅក្នុងអន្ទរវ័ន ទើបគិតថា យើងនឹងទៅកាន់សម្នាក់សម្ពាញ់របស់យើង តែកាលទៅ មិនទៅដោយដៃទទេ គួរនឹងកាន់យកគ្រឿងបណ្ណាការខ្លះទៅផង តែសម្ពាញ់របស់យើងមិនមានអាមិស នៅលើកំពូលភ្នំ សម្ពាញ់នោះ នឹងមិនធាន់សូម្បីបិណ្ឌបាត ដែលយើងឈរនៅទីលំហអាកាសថ្វាយបានធ្វើសមណធម៌ ឥឡូវនេះលោកនឹងទទួលអាមិសបណ្ណាការឬ ចាំយើងកាន់យកធម្មបណ្ណាការទៅ ហើយស្ថិតនៅព្រហ្មលោកនោះឯង ។ ចំណែកបញ្ហា ១៥ ( ៦ ) ដូចជា បណ្តាកម្រងរតនៈ កម្រងកែវ កាន់យកធម្ម-បណ្ណាការនោះមកឈរនៅក្នុងទីជិតសម្ពាញ់ មិនអភិវាទព្រះថេរៈនោះ ដោយពោលសមណសញ្ញា ហៅថា ភិក្ខុ ភិក្ខុ ទើបពោលថា **អយំ វម្មិកោ** ជាដើម ។ ក្នុងពាក្យនោះ គប្បីជ្រាបពាក្យដែលលោកពោលដដែល ៗ ថា

ភិក្ខុ ភិក្ខុ ដោយហៅផ្ទួន ៗ ។ មុខស្ងួត រមែងមិនស្រស់ ដោយការប្រោះដោយម្សៅមួយកន្លែងប៉ុណ្ណោះ លុះកាលប្រោះម្សៅកន្លែងដទៃ ៗ ជុំវិញកន្លែងនោះ ទើបនឹងស្រស់ស្អាត ដូចប្រដាប់ដោយផ្កាឈើដែលរីក យ៉ាងណា ពាក្យនឹងមិនស្រស់ល្អ ដោយបទតែមួយប៉ុណ្ណោះ ។ លុះដោយមានបទហែហម ទើបនឹងស្រស់ល្អ ដូចការតុបតែងដោយផ្កាឈើដែលរីកដូច្នោះ ព្រោះដូច្នោះ ទេវបុត្តនោះ ធ្វើពាក្យដោយមានបទហែហមនោះ ឲ្យដូចជាការតុបតែងផ្កាឈើដែលរីក ទើបពោលយ៉ាងនេះ ។ ឈ្មោះថា **ជំបូក** ដែលតាំងនៅត្រង់ចំពោះមុខមិនមាន តែទេវបុត្តសម្តែងដូចមានជំបូកដែលតាំងនៅចំពោះមុខ ដោយអំណាចទេសនាវិធី ទើបពោលថា **អយំ** ក្នុងបទថា **អយំ វម្មិកោ** ។

បទថា **បលិង្គ** សេចក្តីថា កាន់យកសស្ត្រាជីក ក៏ឃើញសន្ទះទ្វារកង់ ។

បទថា **ឧក្ខិប បលិង្គំ**(១) **អភិក្ខន សុមេធ** បានដល់ បណ្ឌិត ។

ឈ្មោះថា សន្ទះទ្វារកង់ , ពេលយប់ហុយផ្សែង ពេលថ្ងៃឆេះជាភ្លើង

---

(១) បលិង្គំ និង ឧក្ខិប បលិង្គំ អភិក្ខន សុមេធ ពាក្យនេះមាននៅក្នុងបិដកខ្មែរ នៅក្នុងអដ្ឋកថាថៃដាក់ថា លង្គី ត្រូវគ្នានឹងអ៊ីរ៉ុបដែលមានពាក្យថា លង្គី ឬ លឹង្គី យកតាមបិដកខ្មែរ ។

កាលលើកយកសន្ទះទ្វារកង់ឡើងជីកតទៅទៀត គប្បីឃើញសេចក្ដីក្នុងបទគ្រប់យ៉ាង ដូចពោលមកនេះ ។

បទថា **ឧទ្ធុមាយិកំ** បានដល់ សត្វហ៊ឹង ។

បទថា **បន្ថវារំ** បានដល់ សំពត់តម្រងក្បុង ។

បទថា **កុម្មំ** បានដល់ សត្វអណ្ដើក ។

បទថា **អសិសូនំ** បានដល់ កាំបិត និង ជ្រញ់ ។

បទថា **មំសបេសឹ** បានដល់ ដុំសាច់ស្រស់ប៉ុនត្បាល់កិន ។

បទថា **នាគំ** បានដល់ បានឃើញស្ដេចនាគហែហមដោយផ្កាច័ន្ទ ៣ ផ្កា មានពពារធំ ដូចក្ដាំងផ្កាម្លិះ ។

បទថា **មា នាគំ ឃដ្ដេសិ** បានដល់ កុំប្រើចុងឈើ ចុងវល្លិ ឬបាចធូលីទៅប៉ះពាល់នាគ ។

បទថា **នមោ ករោហិ នាគស្ស** សេចក្ដីថា ចូរជៀសអំពីខាងលើខ្យល់ ស្លៀកដណ្ដប់សំពត់ស្អាត ហើយនមស្ការស្ដេចនាគ ដែលឈ្មោះថា ទ្រព្យរបស់ស្ដេចនាគគ្រប់គ្រងប្រើប្រាស់ ៧ ត្រកូលក៏មិនអស់ ស្ដេចនាគនឹងឲ្យទ្រព្យដែលខ្លួនគ្រប់គ្រងដល់អ្នក ព្រោះដូច្នោះ អ្នកចូរធ្វើការនមស្ការដល់ស្ដេចនាគ ។

បទថា **ឥតោ វា បន សុត្វា** សេចក្ដីថា អស់សេចក្ដីសង្ស័យក្នុងកង្ខាអំពីសម្នាក់យើងនេះ ព្រោះដូច្នោះ ទើបឈ្មោះថា អស់សេចក្ដីសង្ស័យក្នុងសាសនា យ៉ាងណា ក្នុងទីនេះមិនដូច្នោះទេ តែក្នុងទីនេះអស់សង្ស័យព្រោះទេវបុត្ត ព្រោះដូច្នោះក្នុងសេចក្ដីនេះ ទើបមានខ្លឹមសារដូច្នេះថា បទថា **ឥតោ វា បន** បានដល់ ឬថា ព្រោះស្ដាប់អំពីសម្នាក់របស់យើង ។

(២៩) បទថា **ចាតុម្មហាភូតិកស្ស** បានដល់ សម្រេចដោយមហាភូតរូបទាំងបួន ។

បទថា **កាយស្ស អធិវចនំ** ប្រែថា ជាឈ្មោះរបស់សរីរៈ ។ បានសេចក្ដីថា កាយខាងក្រៅ លោកហៅថា **វម្មិក** ព្រោះហេតុ ៤ យ៉ាង គឺ ដំបូករមែងខ្ជាក់ចេញ ១ , អ្នកខ្ជាក់ចេញ ១ , អ្នកខ្ជាក់ចេញនូវរាងកាយដែលប្រជុំធាតុបួន ១ , អ្នកខ្ជាក់ចេញនូវសេចក្ដីសម្ពន្ធដោយស្នេហា ១ ។

ពិតណាស់ ដំបូកនោះ រមែងខ្ជាក់ចេញនូវសត្វល្អិត ៗ មានប្រការផ្សេង ៗ ដូចសត្វពស់ សត្វស្ការ សត្វកណ្ដុរ សត្វពស់ថ្លាន់ជាដើម ព្រោះដូច្នោះ កាយនោះឈ្មោះថា **វម្មិក** ។

កាយ ដែលកណ្ដៀរខ្ជាក់ចេញហើយ ហេតុនោះទើបឈ្មោះថា **វម្មិក** ។

កាយ ដែលកណ្ដៀរ-កពូនឡើងដោយផង់ធូលី ដែលកណ្ដៀរ-កពូនឡើងដោយមាត់ មានប្រមាណត្រឹមចង្កេះខ្លះ មួយជួរបុរសខ្លះ ព្រោះដូច្នោះទើបឈ្មោះថា **វម្មិក** ។

កាយ កាលបើភ្លៀងធ្លាក់ ៧ សប្ដាហ៍ សត្វកណ្ដៀរចែកគ្នាជញ្ជូនដីព្រមទាំងបញ្ចេញទឹកមាត់ដ៏ស្អិតពូនជាជំពូក សូម្បីក្នុងរដូវរាំងស្ងួតក៏ផ្ដិតយកធូលីពីទីនោះ ធ្វើឲ្យទៅជាដុំយ៉ាងស្អិតជាប់គ្នា ហេតុនោះទើបឈ្មោះថា **វម្មិក** ។

សូម្បីកាយនេះ ក៏ឈ្មោះថា **វម្មិក** ព្រោះក្អែរចេញនូវរបស់មិនស្អាតជារបស់មានទោស និងមន្ទិលដោយប្រការផ្សេង ៗ ដោយន័យជាដើមថា អាចម៍ភ្នែកចេញពីភ្នែកជាដើម និងឈ្មោះថា **វម្មិក** ព្រោះព្រះអរិយៈខ្ជាក់ចោលហើយ ហេតុនោះ ព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រព លះបង់អត្តភាពទៅ ព្រោះអស់ការជាប់ជំពាក់ក្នុងអត្តភាពនេះ ។

ឈ្មោះថា **វម្មិក** នេះ ព្រោះខ្ជាក់ចេញទាំងអស់នូវទីតាំងប្រជុំធាតុ ៤ ហេតុដែលព្រះអរិយៈខ្ជាក់ចេញទាំងអស់នូវឆ្អឹង ៣០០ កំណាត់ ចងរឹតដោយសរសៃ បូកលាបដោយសាច់ បិទបាំងដោយស្បែក ជ្រលក់លាបដោយពណ៌ បោកបញ្ឆោតសត្វទាំងឡាយ ។

ឈ្មោះថា វម្មិក ព្រោះចង់ដោយសេចក្ដីស្នេហានូវកាយនេះ ចង់ដោយចំណង់ គឺ តណ្ហា ដែលព្រះអរិយៈទាំងឡាយខ្ពាក់ចេញហើយ ព្រោះតណ្ហាបង្កឲ្យកើតឡើង តាមព្រះបាលីយ៉ាងនេះថា តណ្ហាធ្វើបុរសឲ្យកើតឡើង ចិត្តរបស់បុរសនោះរមែងស្ទុះទៅ ។

មួយ៉ាងទៀត សត្វតូចៗ មានប្រការផ្សេងៗ នៅខាងក្នុងដំបូក រមែងកើតឡើង បន្ទោបង់ឧច្ចារបស្សាវៈ ដេក ឈឺ រមែងស្លាប់ធ្លាក់ទៅក្នុងដំបូកនោះឯង ។ ដូច្នោះ ដំបូកនោះទើបថា ជាផ្ទះកើត ជាបង្គន់ ជារោងព្យាបាល និងជាទីសុខសាន្តនៃសត្វតូចៗ ទាំងនោះ យ៉ាងណា កាយសូម្បីរបស់ក្សត្រមហាសាលជាដើម ក៏ដូច្នោះដែរ ។ ពួកសត្វដែលអាស្រ័យស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង មិនបានគិតថា កាយនេះត្រូវគ្រប់គ្រងរក្សាហើយ ប្រដាប់តុបតែងហើយ ជាកាយរបស់អ្នកមានអានុភាពធំ , រួមសេចក្ដីថា ពួកជន្លូវ ដោយការរាប់ត្រកូលប្រមាណ ៨០.០០០ ត្រកូល រមែងកើតឡើង រមែងបន្ទោបង់ឧច្ចារបស្សាវៈ ដេក ស្លាប់សោប់សោល់ ព្រោះសេចក្ដីឈឺចាប់ ស្លាប់ណែនណាន់តាន់តាប់នៅក្នុងកាយនេះឯង ហេតុនោះ ទើបរាប់បានជាដំបូក ព្រោះជាផ្ទះប្រសូត ជាបង្គន់ ជារោងព្យាបាល និងជាព្រៃស្មសាននៃសត្វពួកនោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគ

*ទើបត្រាស់ថា ម្នាលភិក្ខុ ពាក្យថា **វម្មិក** នេះ ជាឈ្មោះរបស់កាយនេះ ដែលកើតអំពីមហាភូតរូប ៤ ។*

*បទថា **មាតាបេត្តិកសម្ភវស្ស** មានន័យថា ដែលកើតព្រមព្រោះទឹកសុក្កៈរបស់មាតាបិតា ទើបឈ្មោះ **មាតាបេត្តិកៈ** ។ បទថា **ឱទនកុម្មាសូបចយស្ស**[១] សេចក្តីថា ធំធាត់ឡើងដោយបាយ និងនំកុម្មាស ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មស្ស** ដូចតទៅនេះ កាយនេះ ឈ្មោះថា មានការមិនទៀងជាធម្មតា ព្រោះអត្ថថាមានហើយត្រឡប់ជាមិនមានវិញ ឈ្មោះថា មានការបូកលាបជាធម្មតា ព្រោះបូកលាបដោយស្បែកខ្ទះ ដើម្បីប្រយោជន៍ដល់ការកម្ចាត់ក្លិនស្អុយ , ឈ្មោះថា មានការគក់ប្របាច់ជាធម្មតា ព្រោះមានការគក់ ប្របាច់រឿយ ៗ ដើម្បីប្រយោជន៍ដល់ការបន្ទោបង់ការឈឺចាប់តាមអវយវៈតូចធំ , ម្យ៉ាងទៀត ឈ្មោះថា មានការបីបម ឱបក្រសោបជាធម្មតា ដោយការបន្តក់ថ្នាំភ្នែក និងគក់ប្របាច់ជាដើម ដើម្បីភាពសម្បូណ៌នៃទ្រង់ទ្រាយនូវអវយវៈទាំងនោះដែលតាំងនៅមិនល្អដោយឲ្យដេកនៅលើទ្រូង ឲ្យដេកតែក្នុងបន្ទប់ក្នុងកាល*

---

[១] ពាក្យថា ឱទនកុម្មាសូបចយស្ស មាននៅក្នុងបិដកខ្មែរ , អដ្ឋកថាថៃសរសេរថា ឱទកម្មាសូបច្ចយស្ស យកតាមបិដកខ្មែរ ។

នៅក្នុង អធិប្បាយថា សូម្បីទីងត្រូវបីបម ឱបក្រសោបយ៉ាងនេះ ក៏នៅមានការបែកធ្លាយ ខ្ចាត់ខ្ចាយទៅជាធម្មតា កាយ មានសភាពយ៉ាងនេះ ។ លោកពោល កាយ ដែលតាំងឡើងដោយបទ គឺ **មាតាបេត្តិកសម្ភវ ឱទន កុម្មាសឧបចយ ឧច្ឆាទន** និង **បរិមទ្ទន** ក្នុងពាក្យនោះ ។ លោកពោលការលេត់ដោយបទ គឺ **អនិច្ច ឧច្ឆាទន ភេទន វិទ្ធំសន** ការៈដែលខ្ពស់ទាប សេចក្តីចម្រើន សេចក្តីសាបសូន្យ ការកើត និងការលេត់នៃកាយ ដែលកើតពីមហាភូតទាំង ៤ គប្បីជ្រាបថា លោកពោលទុកដោយបទទាំង ៧ យ៉ាង ដោយប្រការដូច្នេះ ។

បទថា **ទិវា កម្មន្តេ** បានដល់ ការងារដែលគប្បីធ្វើក្នុងពេលថ្ងៃ ។ **ធូម** សព្ទនេះ ក្នុងបទថា **ធូមាយនា** នេះ ប្រព្រឹត្តទៅក្នុងអត្ថទាំងនេះ គឺ សេចក្តីក្រោធ តណ្ហា វិតក្កៈ កាមគុណ ៥ ធម្មទេសនា ផ្សែងតាមប្រក្រតី ។

ពិតណាស់ **ធូម** សព្ទ ប្រព្រឹត្តទៅក្នុងសេចក្តីក្រោធក្នុងពាក្យនេះថា សេចក្តីក្រោធ ដូចជាផ្សែងភ្លើង ទោសនៃចោរកម្ម ដូចជាផេះ ។ ប្រព្រឹត្តទៅក្នុងតណ្ហា ក្នុងពាក្យនេះថា សត្វទាំងឡាយមានតណ្ហា ដូចផ្សែងភ្លើង ។ ប្រព្រឹត្តទៅក្នុងវិតក្កៈ មានក្នុងពាក្យនេះថា សម័យនោះ ភិក្ខុមួយអង្គអង្គុយត្រិះរិះដូចផ្សែងភ្លើងក្នុងទីមិនឆ្ងាយពីព្រះមានព្រះភាគ ។ ប្រព្រឹត្ត

ទៅក្នុងកាមគុណ ៥ មានក្នុងពាក្យនេះថា ៖

កាមដូចជាភក់ កាមដូចជាផ្លូវអែម និងជាភ័យ ភ័យនោះ

តថាគតពោលថា មានមូល ៣ ថាគតប្រកាសកិលេស

ដូចជាធូលី និងដូចជាផ្សែងភ្លើង ម្នាលព្រហ្មទត្ត សូម

ព្រះអង្គមេត្តាលះវាចេញ ហើយទ្រង់ផ្នួសចុះ ។

ប្រព្រឹត្តទៅក្នុងធម្មទេសនាបានក្នុងពាក្យនេះថា ជាអ្នកធ្វើធម៌ដូចជាផ្សែង ។ ប្រព្រឹត្តទៅក្នុងផ្សែងតាមប្រក្រតី មានក្នុងពាក្យនេះថា ទង់ជាគ្រឿងសម្គាល់នៃរថ ផ្សែងជាគ្រឿងសម្គាល់របស់ភ្លើង ។

តែក្នុងទីនេះ ធូម ស័ព្ទនេះ លោកបំណងថា ប្រព្រឹត្តទៅក្នុងវិតក្កៈ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា នេះជាការហុយផ្សែងក្នុងពេលយប់ ។

បទថា **តថាគតស្សេតំ អធិវចនំ** សេចក្តីថា ព្រះតថាគតឈ្មោះថាព្រាហ្មណ៍ ព្រោះទ្រង់បន្សាត់បង់ធម៌ទាំង ៧ បានហើយ ។ ធម៌ទាំង ៧ គឺអ្វី គឺ រាគៈ ទោសៈ មោហៈ មានះ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ភិក្ខុដែលឈ្មោះថា ព្រាហ្មណ៍ ព្រោះបន្សាត់បង់ធម៌ទាំង ៧ នេះ បានហើយ ។

បទថា **សុមេធោ** ប្រែថា អ្នកមានបញ្ញាល្អ ។ ក្នុងបទថា **សេក្ខស្ស** នេះ ឈ្មោះថា **សេក្ខ** ព្រោះនៅសិក្សា ។ ដូចដែលលោកពោលទុកថា ម្នាលភិក្ខុ ភិក្ខុនៅសិក្សា ព្រោះហេតុដូច្នោះ លោកទើបហៅថា **សេក្ខ** សិក្សាអ្វីទៅ សិក្សាអធិសីលខ្លះ សិក្សាអធិចិត្តខ្លះ សិក្សាអធិប្បញ្ញាខ្លះ ។ បទថា **បញ្ញាយេតំ** គឺ ពាក្យនេះ ជាឈ្មោះរបស់បញ្ញាដែលជាលោកិយៈ និងលោកុត្តរៈ មិនមែនជាឈ្មោះរបស់អាវុធ និងសស្ត្រា ។ បទថា **វិរិយារម្ភស្ស** បានដល់ សេចក្ដីព្យាយាមផ្លូវកាយ និងចិត្ត ។ សេចក្ដីព្យាយាមនោះ រមែងជាគតិនៃបញ្ញានោះឯង ព្យាយាមដែលជាគតិនៃលោកិយប្បញ្ញា ចាត់ជាលោកិយៈ , គតិនៃលោកុត្តរប្បញ្ញា ចាត់ជា លោកុត្តរៈ ។ ក្នុងសេចក្ដីនេះ នឹងបង្ហាញសេចក្ដីដូច្នេះ ។

តំណាលមកថា ព្រាហ្មណ៍ជនបទម្នាក់ ចេញអំពីស្រុកពីព្រលឹមព្រមដោយពួកមាណព ពេលថ្ងៃបង្រៀនមន្តក្នុងព្រៃ ពេលរសៀលក៏ត្រឡប់ចូលស្រុក ។ ក្នុងចន្លោះផ្លូវ មានដំបូកមួយ ដំបូកនោះ ពេលយប់ហុយផ្សែង ពេលថ្ងៃឆេះចេញជាអណ្ដាតភ្លើង ព្រាហ្មណ៍ទើបនិយាយជាមួយសុមេធមាណពថា បាអើយ ! ដំបូកនេះ ពេលយប់ហុយផ្សែង ពេលថ្ងៃឆេះចេញជាអណ្ដាតភ្លើង យើងឃើញសភាពខុសប្រក្រតីរបស់ដំបូកនោះ

ឯងចូរបំបែកវាជាបួនចំណែក បោះចោលទៅ ។ សិស្សនោះក៏ទទួលពាក្យហើយ ចាប់ចប ជើងទាំងពីរឈរលើផែនដីយ៉ាងស៊ប់ ហើយធ្វើយ៉ាងនោះ ។ ក្នុងបណ្តាមនុស្សទាំងពីរនាក់ គឺ អាចារ្យ និងសិស្សនោះ ព្រះមានព្រះភាគប្រៀបធៀប ព្រាហ្មណ៍ដូចជាអាចារ្យ សេក្ខភិក្ខុ ប្រៀបដូចសុមេធមាណពដែលជាសិស្ស , កាយ ប្រៀបដូចជាដំបូក ពេលដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ចូរអ្នកបែងចែកកាយដែលកើតពីមហាភូតរូបទាំងបួនជាចំណែក កំណត់កាន់យកជាអារម្មណ៍ ក៏ប្រៀបដូចពេលដែលព្រាហ្មណ៍ជាអាចារ្យពោលថា បាអើយ ! ដំបូកនេះ ពេលយប់ហុយផ្សែង ពេលថ្ងៃឆេះចេញជាអណ្តាតភ្លើង យើងនឹងឃើញសភាពខុសប្រក្រតីរបស់ដំបូកនោះ ឯងចូរបំបែកវា បែងជាបួនចំណែក ហើយបោះចោលទៅ ។ គប្បីជ្រាបការកំណត់កាយសម្រាប់សេក្ខភិក្ខុ ដោយកំណត់ធាតុ ៤ ជាអារម្មណ៍យ៉ាងនេះ គឺ កាយជារបស់រឹងមាន ២០ ចំណែក ចាត់ជាបឋវីធាតុ , កាយដែលសើមជ្រួតជ្រាប ១២ ចំណែក ចាត់ជាអាបោធាតុ , កាយដែលអប់ឧណ្ហ ៤ ចំណែក ចាត់ជាតេជោធាតុ , កាយដែលតឹង កម្រើក ៦ ចំណែក ចាត់ជាវាយោធាតុ ប្រៀបដូចជាសុមេធមាណព ដែលជាសិស្សទទួលពាក្យហើយ ចាប់ចបធ្វើយ៉ាងនោះ ។

សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្តែងអវិជ្ជា ឈ្មោះថា សន្ទះទ្វារកង់ក្នុងពាក្យថា **លង្គីតិ ខោ ភិក្ខុ** ។

ឆ្លើយថា ការបិទទ្វារព្រះនគរ ដាក់គន្លឹះ មហាជនក៏មិនបានចូលទៅ ពួកជនដែលនៅក្នុងព្រះនគរ ក៏គង់នៅខាងក្នុងនោះឯង , ពួកដែលនៅខាងក្រៅព្រះនគរក៏នៅខាងក្រៅ យ៉ាងណា សន្ទះទ្វារកង់ គឺ អវិជ្ជាធ្លាក់ទៅក្នុងមាត់ គឺ ញាណរបស់អ្នកណា ការទៅ គឺ ញាណដែលឲ្យទៅដល់ព្រះនិព្វានរបស់អ្នកនោះ ក៏ដាច់ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងអវិជ្ជាឲ្យដូចជាសន្ទះទ្វារកង់ ក្នុងពាក្យថា **បជហ អវិជ្ជំ** នេះ លោកពោលការលះអវិជ្ជា ដោយអំណាចការរៀន និងការសាកសួរកម្មដ្ឋាន ។

ក្នុងបទថា **ឧទ្ធុមាយិកាតិ ខោ ភិក្ខុ** នេះ ឈ្មោះថា សត្វហ៊ឹងដែលប៉ោងឡើងមិនធំ ប្រមាណប៉ុនខ្នងក្រចក នៅក្នុងចន្លោះស្លឹកឈើចាស់ ៗ ក្នុងចន្លោះគុម្ពឈើ ឬចន្លោះវល្លិ៍ កាលប៉ះពាល់ត្រូវដោយចុងឈើ ចុងវល្លិ៍ ឬលំអងធូលី ក៏ពង្រីកខ្លួនមានបរិមណ្ឌលធំប៉ុនផ្លែត្នោត ដើងទាំងបួនកម្រើកខ្ញៃ ៗ ក្នុងអាកាស ដាច់ការទៅមក ( ដើរមិនបាន ) ធ្លាក់ទៅក្នុងអំណាចរបស់សត្រូវ ជាចំណីរបស់សត្វក្អែក និងសត្វមៀមជាដើម យ៉ាងណាមិញ

សេចក្តីក្រោធនេះ ក៏ដូច្នោះដូចគ្នា កាលណាកើតឡើងគ្រាដំបូង ក៏គ្រាន់តែជាសេចក្តីសៅហ្មងរបស់ចិត្តប៉ុណ្ណោះ បើមិនបានលះបង់ក្នុងខណៈនោះទេ ក៏ពង្រីកឲ្យដល់ការជ្រួញចិញ្ចើម បើមិនបានលះបង់ក្នុងពេលនោះទេ ក៏ឲ្យដល់ការញ័រថ្គាម បើមិនគ្របសង្កត់ក្នុងពេលនោះទេ នាំឲ្យមានការបញ្ចេញវាចាគ្រោតគ្រាត បើមិនគ្របសង្កត់ក្នុងពេលនោះ ក៏ឲ្យដល់ការក្រឡេកមើលមិនឃើញទិស បើមិនគ្របសង្កត់ក្នុងពេលនោះទេ នាំឲ្យដល់ការទាញទៅ-ទាញមក បើមិនគ្របសង្កត់ក្នុងពេលនោះទេ ក៏ឲ្យដល់ការកម្រើកដៃចាប់ដុំដី ដំបង និងសស្ត្រា បើមិនគ្របសង្កត់ក្នុងពេលនោះទេ ក៏ឲ្យដល់ការប្រហារដោយដំបង និងសស្ត្រា បើមិនគ្របសង្កត់ក្នុងពេលនោះទេ នាំឲ្យមានការសម្លាប់អ្នកដទៃខ្លះ សម្លាប់ខ្លួនឯងខ្លះ ។

សមដូចពាក្យដែលលោកពោលទុកថា សេចក្តីក្រោធនេះ សម្លាប់អ្នកដទៃ ហើយសម្លាប់ខ្លួនឯងប៉ុនណា សេចក្តីក្រោធត្រឹមនេះ ក៏នឹងក្រៃលែងឡើង គឺ កម្រើកយ៉ាងក្រៃលែង ។

ក្នុងសេចក្តីនោះ កាលជើងទាំងបួនរបស់សត្វហ៊ីងខ្វែៗ ក្នុងអាកាសក៏ដាច់ការទៅមក ដើរមិនបាន ។ ហ៊ីងក៏ធ្លាក់ទៅក្នុងអំណាចនៃសត្រូវជាចំណីរបស់សត្វ មានសត្វក្អែកជាដើម យ៉ាងណា បុគ្គលដែលធ្លាក់នៅ

ក្នុងអំណាចរបស់សេចក្ដីក្រោធ ក៏ដូច្នោះដូចគ្នា មិនអាចកំណត់កម្មដ្ឋានឲ្យចម្រើនទៅបាន នឹងធ្លាក់ទៅក្នុងអំណាចរបស់សត្រូវ ដែលជាបក្សពួកមារ ៗ គប្បីធ្វើបានតាមសេចក្ដីប្រាថ្នា ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ពាក្យថា **ឧទ្ធុមាយិកា** នេះ ជាឈ្មោះរបស់សេចក្ដីក្រោធ និងសេចក្ដីចង្អៀតចង្អល់ចិត្ត ។ ក្នុងសេចក្ដីនោះ សេចក្ដីក្រោធខ្លាំង ឈ្មោះថា ឈឺចិត្ត ដោយអំណាចសេចក្ដីក្រោធ លោកពោលការលះដោយការពិចារណា ក្នុងពាក្យថា **បជហ កោធបយាសំ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ទ្វេធាបថោ** ដូចតទៅនេះ បុរសដែលមានភោគទ្រព្យ ធ្វើដំណើរឆ្ងាយ ផ្លូវកន្ដារ ដល់ផ្លូវបំបែកជាពីរ មិនអាចសម្រេចចិត្តថា គួរទៅផ្លូវនេះ ឬមិនគួរទៅផ្លូវនេះ ឈប់នៅក្នុងទីនោះឯង កាលបើដូច្នោះ ពួកចោរ បានប្រាកដឡើងមក ក៏នឹងធ្វើអ្នកនោះឲ្យដល់សេចក្ដីវិនាស យ៉ាងណា ភិក្ខុដែលអង្គុយកំណត់កម្មដ្ឋានខាងដើម ក៏ដូច្នោះឯង ។ កាលណាកើតសេចក្ដីសង្ស័យក្នុងព្រះពុទ្ធជាម្ចាស់ជាដើម ក៏មិនអាចចម្រើនកម្មដ្ឋានបាន ។ កាលបើដូច្នោះ ពួកមារ មានកិលេសមារជាដើម រមែងធ្វើភិក្ខុនោះ ឲ្យដល់សេចក្ដីវិនាស **វិចិកិច្ឆា** ទើបស្មើដោយផ្លូវបំបែកជាពីរ ដោយប្រការដូច្នោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគជា

ម្ចាស់ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ពាក្យថា ផ្លូវបែកជាពីរនោះ ជាឈ្មោះរបស់វិចិកិច្ឆា ។ ក្នុងពាក្យថា **បជហ វិចិកិច្ឆំ** នេះ លោកពោលការលះវិចិកិច្ឆា ដោយការរៀន និងការសាកសួរកម្មដ្ឋាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **បន្កវារំ** ដូចតទៅនេះ កាលជាងជ្រលក់ ចាក់ទឹកជ្រលក់ក្នុងតម្រងក្បុង ទឹក ១ ឆ្នាំងខ្លះ ២ ឆ្នាំងខ្លះ ១០ ឆ្នាំងខ្លះ ២០ ឆ្នាំងខ្លះ ១០០ ឆ្នាំងខ្លះ ក៏ហូរចេញ ទឹកសូម្បីជួស ១ ទូកដៃក៏មិនដក់នៅ យ៉ាងណា កុសលធម៌ខាងក្នុងរបស់បុគ្គលដែលប្រកបដោយនីវរណៈ រមែងមិនតាំងនៅដូច្នោះដូចគ្នា ។ ដោយហេតុនោះ ព្រះមាន-ព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ពាក្យថា ឆ្នាំងតម្រងក្បុងនេះ ជាឈ្មោះរបស់នីវរណៈទាំង ៥ ។ ក្នុងពាក្យថា **បជហ បញ្ចនីវរណេ** នេះ ត្រាស់ការលះនីវរណៈ ដោយវិក្ខម្ភនប្បហាន និងតទង្គប្បហាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **កុម្មោ** ដូចតទៅនេះ អណ្ដើកមានអវយវៈ ៥ គឺ ជើងបួន ក្បាលមួយ យ៉ាងណា សង្ខតធម៌ទាំងអស់ កាលរួបរួម ក៏មានខន្ធ ៥ ប៉ុណ្ណោះ ដូច្នោះដូចគ្នា ដោយហេតុនោះ ព្រះមាន-ព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ពាក្យថា អណ្ដើកនេះ ជាឈ្មោះរបស់ឧបាទានក្ខន្ធ ៥ ។

ក្នុងពាក្យថា **បជហ បញ្ចុបាទានក្ខន្ធេ** នេះ ទ្រង់ត្រាស់ការលះសេចក្ដីស្រឡាញ់ ដោយអំណាចសេចក្ដីពេញចិត្តក្នុងខន្ធ ៥ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អសិសូនា** ដូចតទៅនេះ យកសាច់ដាក់លើជ្រញ់ យកកាំបិតចិញ្ច្រាំ យ៉ាងណា ពួកសត្វនេះ កាលណាត្រូវកាមកិលេសប៉ះពាល់ ដើម្បីប្រយោជន៍ដល់ការធ្វើទុកលើវត្ថុកាម ត្រូវកិលេសកាមកាប់ចិញ្ច្រាំ ក៏ដូច្នោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ពាក្យថា ជ្រញ់ កាំបិត នេះ ជាឈ្មោះរបស់កាមគុណទាំង ៥ ។

ក្នុងពាក្យថា **បជហ បញ្ចកាមគុណេ** នេះ ទ្រង់ត្រាស់ដល់ការលះតម្រេក ដោយអំណាចសេចក្ដីពេញចិត្តក្នុងកាមគុណ ៥ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **មំសបេសីតិ ខោ ភិក្ខុ** ដូចតទៅនេះ ដែលឈ្មោះថា ដុំសាច់ នេះ មនុស្សជាច្រើនប្រាថ្នាហើយ ទាំងពួកមនុស្សមានក្សត្រជាដើម ទាំងសត្វតិរច្ឆាន មានក្អែកជាដើម ម្នាក់ ៗ ប្រាថ្នាដុំសាច់នោះ ។ ពួកសត្វនេះ ប្រកបដោយអវិជ្ជា អាស្រ័យសេចក្ដីត្រេកអរ ដោយអំណាចសេចក្ដីភ្លើតភ្លើន ម្នាក់ ៗ ក៏ប្រាថ្នាវត្ថុ: ដុំសាច់រមែងជាប់នៅក្នុងទីដាក់ យ៉ាងណា សត្វពួកនេះ ត្រូវសេចក្ដីត្រេកអរដោយអំណាចនៃសេចក្ដី

សប្បាយចង់ទុក ក៏ជាប់នៅក្នុងវដ្តៈ សូម្បីជួបនឹងទុក្ខ ក៏មិននឿយណាយ ដូច្នោះ សេចក្តីស្រឡាញ់ដោយអំណាចសេចក្តីសប្បាយ រមែងប្រដូចជា ជុំសាច់ ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុ ពាក្យថា ជុំសាច់នេះ ជាឈ្មោះរបស់សេចក្តី ត្រេកអរ ដោយអំណាចសេចក្តីភ្លើតភ្លើន ។ ក្នុងពាក្យថា **បជហ នន្ទិរាគំ** នេះ ទ្រង់ត្រាស់ការលះសេចក្តីត្រេកអរ ដោយអំណាចសេចក្តីភ្លើតភ្លើន ដោយមគ្គ ទី ៤ ។

ក្នុងពាក្យថា ម្នាលភិក្ខុ ពាក្យថា នាគនេះ ជាឈ្មោះរបស់ព្រះខី-ណាស្រព ព្រះខីណាស្រពលោកហៅថា **នាគ** ដោយអត្ថណា អត្ថនោះ លោកប្រកាសទុកនៅក្នុងអនង្គណសូត្រ ។ ក្នុងពាក្យថា **នមោ ករោហិ នាគស្ស** នេះ មានសេចក្តីដូច្នេះ គឺ អ្នកត្រូវធ្វើការនមស្ការព្រះពុទ្ធនាគ ដែលជាព្រះខីណាស្រពថា ព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គត្រាស់ដឹង ហើយ រមែងសម្តែងធម៌ដើម្បីការដឹង , ព្រះមានព្រះភាគជាម្ចាស់ ព្រះអង្គ ទ្រង់ហ្វឹកហាត់ហើយ ទ្រង់សម្តែងធម៌ដើម្បីហ្វឹកហាត់ , ព្រះមានព្រះភាគ ជាម្ចាស់ ព្រះអង្គស្ងប់ហើយ ទ្រង់សម្តែងធម៌ដើម្បីការស្ងប់ , ព្រះមាន ព្រះភាគជាម្ចាស់ ព្រះអង្គទ្រង់ឆ្លងហើយ ទ្រង់សម្តែងធម៌ដើម្បីឆ្លង , ព្រះ

មានព្រះភាគជាម្ចាស់ ព្រះអង្គទ្រង់រំលត់ស្មិទ្ធហើយ ទ្រង់សម្តែងធម៌ដើម្បីរំលត់ស្មិទ្ធ ។

ព្រះសូត្រនេះ បានជាកម្មដ្ឋានរបស់ព្រះថេរៈ ដោយប្រការដូច្នេះ ចំណែកព្រះថេរៈ ធ្វើព្រះសូត្រនេះឯងឲ្យជាកម្មដ្ឋាន ចម្រើនវិបស្សនាសម្រេចព្រះអរហត្ត ។

បទថា **អយមេ តស្ស អត្ថោ**[១] មានន័យថា នេះជាសេចក្តីអធិប្បាយក្នុងពាក្យនោះ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់កាន់យកកំពូលមណីក្នុងនគររតនៈ ទ្រង់បញ្ចប់ទេសនាតាមលំដាប់អនុសន្ធិ ដោយប្រការដូច្នេះឯង ។

" ចប់ អដ្ឋកថាវម្មិកសូត្រ ទី ៣ "

---

១ ក្នុងអដ្ឋកថាថៃសរសេរថា អយមេវ តស្ស អត្ថោ, ក្នុងបិដកខ្មែរជា អយមេតស្ស អត្ថោ យកតាមបិដកខ្មែរ .

# អដ្ឋកថា

## រថវិនីតសូត្រ ទី ៤

(៣០) *រថវិនីតសូត្រចាប់ផ្ដើមថា ខ្ញុំម្ចាស់បានស្ដាប់មកហើយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងរថវិនីតសូត្រនោះ យ៉ាងនេះ ៖*

*បទថា* ***រាជគហេ*** *បានដល់ នគរមានឈ្មោះយ៉ាងនេះ ។ ពិតហើយ នគរនោះ លោកហៅថា* ***រាជគ្រឹះ*** *ព្រោះព្រះបាទមន្ធាតុរាជ និងមហាគោវិន្ទសាស្ដាជាដើម គ្រប់គ្រងរក្សា ។ តែអាចារ្យពួកដទៃ ពណ៌នាទុកច្រើនប្រការក្នុងពាក្យនេះ ។ លោកពណ៌នាទុកយ៉ាងណា លោកពណ៌នាទុកថា ពាក្យនេះ ជាឈ្មោះរបស់នគរនោះ ក៏ក្រុងរាជគ្រឹះនោះ ជានគរទាំងក្នុងកាលនៃព្រះពុទ្ធជាម្ចាស់ ទាំងក្នុងកាលនៃព្រះបាទចក្រពត្តិ ក្នុងពេលក្រៅពីនោះ ក៏ជានគរដែលបោះបង់ចោល មានតែខ្មោចហ្លួងហែងរក្សា ក្លាយទៅជាព្រៃ ជាទីនៅរបស់ពួកខ្មោចនោះទៅ ។ ពាក្យថា* ***វេឡុវនេ*** *ក្នុងពាក្យថា* ***វេឡុវនេ កលន្ទកនិវាបេ*** *ជាឈ្មោះរបស់ឧទ្យាននោះ ។ សេចក្ដីថា ឧទ្យាននោះ មានដើមឫស្សីព័ទ្ធជុំវិញ មានកំផែងកម្ពស់ ១៨ ហត្ថ ប្រកបដោយខ្លោងទ្វារ និងបន្ទាយ មានពណ៌ខៀវស្រស់ថ្លាគួរជាទីមនោរម្យ*

ទើបលោកហៅថា **វេឡុវន** ។ មយ៉ាងទៀត មនុស្សទាំងឡាយ បានឲ្យចំណី ដល់ពួកសត្វកង្ហែនក្នុងវេឡុវនេនោះ ដោយហេតុនោះ ទើបលោកហៅថា **កលន្ទកនិវាប** ជាទីឲ្យចំណីដល់សត្វកង្ហែន ។

បានឮមកថា កាលវេលាដើម ព្រះរាជាមួយព្រះអង្គស្តេចមកដើម្បីទ្រង់កម្សាន្តក្នុងព្រះរាជឧទ្យាននោះ តែទ្រង់ស្រវឹងដោយទឹកចន្ទន៍ ក៏ផ្ទំលក់ទៅក្នុងពេលថ្ងៃ ។ សូម្បីជនដែលនៅជិតខាងព្រះរាជា ដឹងថា ព្រះរាជាផ្ទំលក់ហើយ ក៏ស្រវាយកផ្កាឈើ ផ្លែឈើជាដើម ម្នាក់ ៗ បំបែកគ្នាទៅកាន់ទីផ្សេងៗ ។ គ្រានោះ ពស់វែកមួយក្បាលធុំក្លិនសុរា ក៏លូនចេញមកពីប្រហោងឈើមួយដើម បែរមុខមករកព្រះរាជា ។ រុក្ខទេវតាឃើញពស់វែកនោះហើយ ក៏ក្លែងភេទជាសត្វកង្ហែន ប្រាថ្នាទឹងជួយជីវិតព្រះរាជា មកបញ្ចេញសំឡេងជិតព្រះកាណ៌ ។ ព្រះរាជាក៏ភ្ញាក់ពីបន្ទំ ។ ពស់វែកក៏លូនត្រឡប់ទៅ ។ ព្រះរាជាទតព្រះនេត្រឃើញសត្វកង្ហែននោះ ក៏ទ្រង់ជ្រាបថា សត្វកង្ហែននេះជួយជីវិតយើង ទ្រង់ក៏ដាក់ចំណីទុកក្នុងព្រះរាជឧទ្យាននោះ សម្រាប់កង្ហែនទាំងឡាយ ហើយត្រាស់បង្គាប់ឲ្យប្រទានអភ័យដល់កង្ហែនទាំងឡាយ ព្រោះដូច្នោះ តាំងពីនោះមក ព្រះរាជឧទ្យាននោះ ទើបបានឈ្មោះថា **កលន្ទកនិវាប** ជាទីប្រទានចំណីដល់សត្វកង្ហែន ។ ពាក្យថា

*កលន្ទក ជាឈ្មោះ របស់សត្វកន្ធែនទាំងឡាយ ។*

*បទថា **ជាតិភូមិកា**[១] បានដល់ អ្នកនៅក្នុងជាតិភូមិ ។ ក្នុងពាក្យថា **ជាតិភូមិ** ប្រែថា ទីកើត ។ ក៏ទីកើតនោះ មិនមែនទីកើតរបស់ព្រះបាទកោសលមហារាជជាដើម មិនមែនជាទីកើតរបស់ចង្កីព្រាហ្មណ៍ជាដើម មិនមែនជាទីកើតរបស់សក្កទេវរាជ ស្តេចសុយាមៈ និងស្តេចសន្តុសិតជាដើម មិនមែនជាទីកើតរបស់ព្រះអសីតិមហាសាវកជាដើម មិនមែនជាទីកើតរបស់សត្វពួកដទៃ ដែលហៅថា **ជាតិភូមិ** ។ តែក្នុងថ្ងៃដែលព្រះសព្វញ្ញូពោធិ-សត្វជាម្ចាស់ ព្រះអង្គណាកើតហើយ មួយម៉ឺនលោកធាតុជេរជាសជោយទង់ និងផ្កាឈើជាមួយគ្នា ក្រអូបដោយក្លិនផ្កាឈើ និងអប់ដោយលំអិតរុងរឿងដូចនន្ទវ័ន ដែលមានផ្កាឈើរីកស្គុសស្គាយទូទៅ បានកម្រើកដូចដំណក់ទឹកលើស្លឹកឈូក បាដិហារិយ៍ជាច្រើន ដូចជាមនុស្សខ្វាក់ ក៏បានឃើញរូបជាដើម ប្រព្រឹត្តទៅហើយ ទីកន្លែងកើតព្រះសព្វញ្ញូពោធិសត្វ ជា*

---

[១] ពាក្យ **ជាតិភូមិកា** មានក្នុងបិដកខ្មែរ ។ ក្នុងពាក្យ **ជាតិភូមិ** បិដកខ្មែរបានយោងពីអដ្ឋកថា ថា ស្រុកកំណើតរបស់ខ្លួន គឺ ស្រុកជាមួយសព្វញ្ញូពោធិសត្វ ។ មានក្នុងច្បាប់អ៊ីរ៉ុបនិងច្បាប់ភូមាសរសេរថា **ជាតិភូមកា** ។ ក្នុងអដ្ឋកថាថៃសរសេរ **ជាតិភូមិ ៣** ។ យកតាមច្បាប់បិដកខ្មែរ ។

ម្ចាស់នោះ គឺ ក្រុងកបិលពស្តុ សក្កជនបទនោះឯង ហៅថា **ជាតិភូមិ** ។

បទថា **វស្សំ វុដ្ឋា** បានដល់ នៅចាំវស្សា ៣ ខែ បវារណាហើយ ។

បទថា **ភគវា ឯតទវោច** បានសេចក្តីថា ព្រះមានព្រះភាគជាម្ចាស់ត្រាស់ព្រះពុទ្ធវចនៈថា **កោ នុ ខោ ភិក្ខវេ** យ៉ាងនេះជាដើមនោះ ទ្រង់ធ្វើបដិសណ្ឋារៈទទួលអាគន្តុកៈ ដោយព្រះតម្រាស់ជាដើមថា **កច្ចិ ភិក្ខវេ ខមនីយំ** ។

បានឮថា ភិក្ខុពួកនោះត្រូវ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សួរដោយការបដិសណ្ឋារៈថា ម្នាលភិក្ខុទាំងឡាយ អ្នកអត់ធន់បានទេ អ្នកអាចប្រព្រឹត្តទៅបានទេ ពួកអ្នកមកពីឆ្ងាយមិនលំបាកទេឬ មិនលំបាកដោយបិណ្ឌបាត ឬពួកអ្នកមកអំពីទីណា ទើបក្រាបទូលថា បពិត្រព្រះមាន-ព្រះភាគជាម្ចាស់ ពួកខ្ញុំព្រះអង្គ មកពីជាតិភូមិ គឺ កបិលពស្តុសក្កជនបទ ។ លំដាប់នោះ ព្រះមានព្រះភាគជាម្ចាស់ មិនត្រាស់សួរដល់ការមិនមានរោគរបស់ព្រះបាទសុទ្ធោទនៈមហារាជ របស់ព្រះបាទសុក្កោទនៈ របស់ព្រះបាទសក្កោទនៈ របស់ព្រះបាទធោទនៈ របស់ព្រះបាទអមិតោទនៈ របស់ព្រះនាងអមិតាទេវី របស់ព្រះនាងមហាបជាបតី របស់វង្សសក្យៈទាំងអស់ឡើយ ។ ការពិត កាលត្រាស់សួរ ក៏សួរដល់ភិក្ខុដែលបានកថាវត្ថុ ១០

ដោយខ្លួនឯង និងអ្នកដទៃ ដែលដឹកនាំក្នុងវត្តបដិបត្តិនោះ ជាអ្នកសម្បូរដោយ (ខ) បដិបត្តិ ទើបទ្រង់ត្រាស់ព្រះពុទ្ធវចនៈនេះថា **កោ នុ ខោ ភិក្ខវេ** ជាដើម ។ ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ ទើបមិនត្រាស់សួរការមិនមានរោគរបស់ព្រះបាទសុទ្ធោទនៈជាដើម ត្រាស់សួរចំពោះភិក្ខុបែបនោះប៉ុណ្ណោះ ព្រោះជាទីស្រឡាញ់ ។ ពិតហើយ ភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ជាអ្នកបដិបត្តិ រមែងជាទីស្រឡាញ់ ជាទីពេញព្រះហឫទ័យរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ។ ព្រោះហេតុអ្វី ។ ព្រោះទ្រង់ជាអ្នកធ្ងន់ក្នុងធម៌ ។ ពិតហើយ ព្រះតថាគតទាំងឡាយ ព្រះអង្គធ្ងន់ក្នុងធម៌ ។ ក៏ភាវៈដែលព្រះតថាគតទាំងឡាយទ្រង់ធ្ងន់ក្នុងធម៌នោះ គប្បីជ្រាបដោយអធ្យាស្រ័យ ដែលកើតនៅជិតគល់នៃអជបាលនិគ្រោធនេះថា អ្នកមិនមានសេចក្តីគោរព អ្នកមិនមានសេចក្តីកោតក្រែង រស់នៅជាទុក្ខ ។ ពិតហើយ ព្រោះភាពជាអ្នកធ្ងន់ក្នុងធម៌ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ធ្វើការក្រោកទទួល ក្នុងថ្ងៃចេញបួសរបស់ព្រះមហាកស្សបត្ថេរៈ ស្តេចបានយាងទៅរហូតចម្ងាយផ្លូវប្រមាណ ៣ គាវុត ។ ស្តេចធ្វើដំណើរជាង ៣០០ យោជន៍ សម្តែងធម៌នៅត្រង់ឆ្នេរស្ទឹងគង្គា ស្ថាបនាព្រះមហាកបិនព្រមទាំងបរិស័ទទុកក្នុងព្រះអរហត្ត ។ ខាងក្រោយភត្ត សម័យមួយស្តេចយាងទៅអស់ផ្លូវ

៤៥ យោជន៍ ត្រាស់សម្ដែងធម៌អស់យាមទាំង ៣ នៅឯលំនៅនៃស្មូនឆ្នាំង ទ្រង់ស្ដាបនា បុក្កុសាតិកុលបុត្តទុកក្នុងអនាគាមិផល ។ ស្ដេចយាងទៅចម្ងាយផ្លូវ ២០០០ យោជន៍ ទ្រង់អនុគ្រោះសាមណេរដែលនៅព្រៃ ។ ស្ដេចយាងទៅចម្ងាយផ្លូវ ៦០ យោជន៍ សម្ដែងធម៌ប្រោសព្រះខទិរវនិយត្ថេរៈ ។ ទ្រង់ជ្រាបថា ព្រះអនុរុទ្ធត្ថេរៈអង្គុយនៅឯបាចិនវង្សទាយវ័ន ត្រិះរិះដល់មហាបុរិសវិតក្កៈ ហើយហោះទៅក្នុងទីនោះ និងស្ដេចចុះខាងមុខនៃព្រះថេរៈប្រទានសាធុការ ។ ឲ្យក្រាលសេនាសនៈក្នុងព្រះគន្ធកុដិជាមួយគ្នាសម្រាប់ព្រះកុដិកណ្ណសោណត្ថេរៈ ក្នុងពេលជិតភ្លឺ អារាធនាសម្ដែងធម៌ ក្នុងវេលាចប់សរភញ្ញ បានប្រទានសាធុការ ។ ស្ដេច ពុទ្ធដំណើរ ៣ គាវុត ត្រាស់អានិសង្សសាមគ្គីរស នៅឯគោសិង្គសាលវ័ន ជាទីនៅរបស់កុលបុត្ត ៣ នាក់ ។ ចំណែកព្រះមានព្រះភាគជាម្ចាស់ ព្រះនាមថា **កស្សប** កើតសេចក្ដីស្និទ្ធស្នាលថា ព្រះអរិយសាវ័កនេះ តាំងនៅក្នុងអនាគាមិផល ស្ដេចយាងទៅលំនៅរបស់នាយស្មូនឆ្នាំងឈ្មោះថា ឃដិការ ទទួលអាមិសដោយព្រះហស្ថរបស់ព្រះអង្គ ហើយសោយ ។ ព្រះមានព្រះភាគជាម្ចាស់របស់យើងទាំងឡាយ កាលណាជិតចូលវស្សា ភិក្ខុសង្ឃហែហមស្ដេចចេញចារិកពីវត្តជេតពន ។ ព្រះបាទកោសលមហារាជ និងអនាថបិណ្ឌិកសេដ្ឋី

ជាដើម មិនអាចនឹងធ្វើឲ្យស្ដេចត្រឡប់បាន ។ អនាថបិណ្ឌិកសេដ្ឋីត្រឡប់មកផ្ទះ ហើយក៏អង្គុយអស់សង្ឃឹម ។ ទាសីឈ្មោះថា បុណ្ណា ពោលនឹងអនាថបិណ្ឌិកសេដ្ឋីថា លោកម្ចាស់ខូចចិត្តឬ ។ អនាថបិណ្ឌិកសេដ្ឋីឆ្លើយថា អើ ! យើងមិនអាចធ្វើឲ្យព្រះសាស្ដាត្រឡប់មកវិញបាន កាលបើយ៉ាងនោះ យើងក៏គិតថា យើងក៏គង់នឹងមិនបានស្ដាប់ធម៌ ថ្វាយទានតាមសេចក្ដីប្រាថ្នាអស់រយៈ ៣ ខែនេះ ។ នាងបុណ្ណាទាសីពោលថា នាងខ្ញុំនឹងអាភពនានាំព្រះសាស្ដាត្រឡប់មកបាន ។ សេដ្ឋីនិយាយថា បើឯងអាចអាភពនានាំព្រះសាស្ដាត្រឡប់មកបាន ឯងនឹងបានជាអ្នកជា ។ នាងទៅក្រាបចុះទៀបព្រះយុគលបាទរបស់ព្រះទសពល ហើយទូលថា បពិត្រព្រះមានព្រះភាគជាម្ចាស់ សូមព្រះអង្គស្ដេចប្រោសយាងត្រឡប់វិញចុះ ។ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា បុណ្ណា នាងជាអ្នកអាស្រ័យគេចិញ្ចឹមជីវិត នឹងធ្វើអ្វីដល់យើងបាន ។ នាងក្រាបទូលថា បពិត្រព្រះមានព្រះភាគជាម្ចាស់ ខ្ញុំព្រះអង្គ មិនមានទេយ្យធម៌ទេ សូម្បីព្រះអង្គក៏ទ្រង់ជ្រាប តែព្រោះព្រះអង្គទ្រង់ស្ដេចយាងត្រឡប់ជាហេតុ ខ្ញុំព្រះអង្គនឹងតាំងនៅក្នុងសរណៈ ៣ សីល ៥ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ឲ្យសាធុការថា ល្អហើយបុណ្ណា ហើយស្ដេចយាងត្រឡប់ចូលកាន់វត្តជេតពន នោះឯង ។ រឿងនេះប្រាកដ

ច្បាស់ហើយ ។ សេដ្ឋីស្តាប់ហើយគិតថា គេថា ព្រះមានព្រះភាគជាម្ចាស់ ស្តេចត្រឡប់ព្រោះនាងបុណ្ណា ទើបឲ្យនាងបុណ្ណាជាអ្នកជា ហើយតាំងនាងក្នុងឋានៈជាធីតា ។ នាងសុំបួស ហើយក៏បួស លុះបួស ហើយក៏ផ្តើមវិបស្សនា ។ លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបថា នាងផ្តើមវិបស្សនាហើយ ទ្រង់បញ្ចេញឱភាស និងត្រាស់គាថានេះថា ៖

បុណ្ណេ បូរេសិ សទ្ធម្មំ ចន្ទោ បណ្ណរសោ យថា
បរិបុណ្ណាយ បញ្ញាយ ទុក្ខស្សន្តំ ករិស្សសិ
ម្នាលនាងបុណ្ណា នាងបំពេញព្រះសទ្ធម្មឲ្យពេញដូច
ព្រះច័ន្ទក្នុងថ្ងៃពេញបូរមី នឹងធ្វើទីបំផុតទុក្ខ ដោយ
បញ្ញាដែលបរិបូរបាន ។

កាលបើចប់គាថា នាងក៏សម្រេចព្រះអរហត្ត បានជាព្រះសាវិកាដែលមានឈ្មោះបោះសំឡេង ។ ព្រះតថាគតទាំងឡាយ ជាអ្នកជូន់ក្នុងធម៌ដោយប្រការដូច្នេះ ។ កាលបើព្រះនន្ទត្ថេរសម្តែងធម៌ នៅក្នុងរោងធាន់ព្រះមានព្រះភាគជាម្ចាស់ មិននាំអ្វីទៅ ប្រថាប់ឈរស្តាប់ធម្មកថារហូតយាម ៣ កាលចប់ទេសនាបានប្រទានសាធុការ ។ ព្រះថេរៈមកថ្វាយបង្គំ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គយាងមកក្នុងពេលណា ព្រះមាន-

ព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា តាំងពីអ្នកបានផ្ដើមព្រះសូត្រ ។ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គធ្វើកិច្ចដែលធ្វើបានដោយលំបាក ព្រះអង្គទ្រង់ប្រកបដោយសុខមាលជាតិ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា នន្ទ បើអ្នកអាចសម្ដែងរហូតអស់កប្ប តថាគតក៏នៅឈរស្ដាប់រហូតអស់កប្ប ។ ព្រះតថាគតទាំងឡាយ ធ្ងន់ក្នុងធម៌យ៉ាងនេះ ។ អ្នកបដិបត្តិទាំងឡាយ រមែងជាទីស្រឡាញ់របស់តថាគតទាំងនោះ ព្រោះទ្រង់ជាអ្នកធ្ងន់ក្នុងធម៌ ព្រោះដូច្នោះ ទើបត្រាស់សួរអ្នកបដិបត្តិទាំងឡាយ ។

ដែលឈ្មោះថា អ្នកបដិបត្តិមាន ៤ ប្រភេទ គឺ ៖

-អ្នកបដិបត្តិដើម្បីប្រយោជន៍ខ្លួន មិនបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១
-អ្នកបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ មិនបដិបត្តិដើម្បីប្រយោជន៍ខ្លួន ១
-អ្នកបដិបត្តិដើម្បីប្រយោជន៍ខ្លួន ទាំងដើម្បីប្រយោជន៍អ្នកដទៃ ១
-មិនបដិបត្តិទាំងដើម្បីប្រយោជន៍ខ្លួន ទាំងមិនបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១

បណ្ដាអ្នកបដិបត្តិទាំងនោះ អ្នកណាបាននូវកថាវត្ថុ ១០ ដោយខ្លួនឯង មិនពោល មិនបង្រៀន មិនប្រដៅអ្នកដទៃក្នុងកថាវត្ថុ ១០ នោះ ដូចជាព្រះពាកុលៈ អ្នកនេះឈ្មោះថា បដិបត្តិដើម្បីប្រយោជន៍ខ្លួន មិនបដិបត្តិ

ដើម្បីប្រយោជន៍ដល់អ្នកដទៃ ។ ព្រះមានព្រះភាគជាម្ចាស់ មិនសួរភិក្ខុបែបនេះ ។ ព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះ មិនតាំងនៅក្នុងចំណែកចម្រើននៃសាសនារបស់ព្រះតថាគត ។ ចំណែកអ្នកមិនបានកថាវត្ថុ ១០ បង្រៀនភិក្ខុដទៃដោយកថាវត្ថុ ១០ នោះ ដើម្បីត្រេកអរ វត្តដែលភិក្ខុនោះធ្វើហើយ ដូចព្រះឧបនន្ទសក្យបុត្ត អ្នកនេះឈ្មោះថា បដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ មិនបដិបត្តិដើម្បីប្រយោជន៍ខ្លួន ។ ព្រះមានព្រះភាគជាម្ចាស់ មិនត្រាស់សួរសួម្បីភិក្ខុដូច្នោះ ។ ព្រោះហេតុអ្វី ។ ព្រោះភិក្ខុនោះលះតណ្ហាមិនបាន ដូចថង់ធំ ។ អ្នកណាមិនបានទូវកថាវត្ថុ ១០ ដោយខ្លួនឯង មិនបបួល មិនបង្រៀនអ្នកដទៃ ដោយកថាវត្ថុ ១០ នោះ ដូចព្រះលោឡុទាយីឈ្មោះថា មិនបដិបត្តិដើម្បីប្រយោជន៍ខ្លួន និងមិនបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ។ ទ្រង់មិនត្រាស់សួរដល់ភិក្ខុ ដែលមានសភាពបែបនោះ ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះកិលេសទាំងឡាយខាងក្នុងរបស់លោកមានច្រើន ដូចត្រូវកាត់ចោលដោយពូថៅ ។

ចំណែកភិក្ខុណា ខ្លួនឯងបានកថាវត្ថុ ១០ ទាំងបង្រៀនអ្នកដទៃដោយកថាវត្ថុ ១០ នោះ ភិក្ខុនេះឈ្មោះថា បដិបត្តិដើម្បីប្រយោជន៍ខ្លួន និងប្រយោជន៍ដល់អ្នកដទៃ ដូចព្រះអសីតិមហាថេរៈ មានព្រះសារីបុត្ត

ព្រះមោគ្គល្លាន និងព្រះមហាកស្សបជាដើម ។ ទ្រង់ត្រាស់សួរដល់ភិក្ខុ ដែលមានសភាពបែបនោះ ។

សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះភិក្ខុនោះ តាំងនៅក្នុង សេចក្ដីចម្រើននៃសាសនារបស់ព្រះតថាគត ។ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងសួរដល់ភិក្ខុមានសភាពបែបនោះ សូម្បីក្នុងទីនេះ ទើបត្រាស់ថា ***កោ នុ ខោ ភិក្ខវេ*** ជាដើម ។

ភិក្ខុទាំងនោះ កាលបើព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សួរ យ៉ាងនេះហើយ ក៏ព្រះអង្គទ្រង់ត្រាស់សួរចំពោះភិក្ខុដែលបានកថាវត្ថុ ១០ ជាអ្នកបដិបត្តិដើម្បីប្រយោជន៍ទាំងពីរចំណែក ក្នុងជាតិភូមិរបស់ខ្លួន ។ មាន ការគិត ឬប្រឹក្សាគ្នានិងគ្នាថា ក្នុងភិក្ខុទាំងនោះ អង្គណា នឹងជាដូច្នោះ ។ ព្រោះហេតុអ្វី ។ ព្រោះព្រះមន្តាណីបុត្ត ប្រាកដមានឈ្មោះបោះសំឡេង ក្នុងជនបទនោះ ដូចព្រះច័ន្ទ និងព្រះអាទិត្យ ដែលអណ្ដែតនៅកណ្ដាល អាកាស ។ ព្រោះដូច្នោះ ភិក្ខុទាំងនោះដូចជាហ្វូងសត្វក្ងោក បានស្ដាប់ សំឡេងផ្គរ ក៏ផ្ដុំប្រជុំគ្នា និងដូចភិក្ខុដែលផ្ដើមធ្វើគណៈសាធ្យាយ កាល នឹងក្រាបទូលពីព្រះបុណ្ណត្ថេរៈ ដែលជាអាចារ្យរបស់ខ្លួន ដល់ព្រះមានព្រះ-ភាគជាម្ចាស់ សូម្បីមានមាត់ ក៏មិនល្មមក្នុងការពោលសរសើរគុណរបស់

ព្រះថេរៈ ទើបបានពោលជាសំឡេងដូចគ្នាថា **បុណ្ណោ នាម ភន្តេ អាយស្មា** ជាដើម ។

បណ្តាបទទាំងនោះ ពាក្យថា **បុណ្ណោ** ជាឈ្មោះរបស់ព្រះថេរៈនោះ ក៏ព្រោះលោកជាបុត្តរបស់មន្តាណីព្រាហ្មណី ដូច្នោះទើបហៅថា មន្តាណី-បុត្ត ។

បទថា **សម្ភាវិតោ** បានដល់ លើកតម្កើងដោយពោលសរសើរគុណ ។ បទថា **អប្បិច្ឆោ** បានដល់ ប្រាសចាកសេចក្តីប្រាថ្នា អស់ចំណង់ អស់តណ្ហា ។ ក៏ក្នុងពាក្យនេះ ដូចនៅសល់តែព្យញ្ជនៈ ចំណែកខ្លឹមសារ មិនមានសល់ឡើយ ។ ក៏ព្រះបុណ្ណមន្តាណីបុត្តនោះ មិនមានសេចក្តីប្រាថ្នាសល់នៅឡើយសូម្បីបន្តិចបន្តួច ព្រោះលោកជាព្រះខីណាស្រព លះតណ្ហាបានដោយប្រការទាំងពួង ។

ម្យ៉ាងទៀត ក្នុងពាក្យថា **អប្បិច្ឆោ** នេះ គប្បីជ្រាបសេចក្តីផ្សេងគ្នាយ៉ាងនេះថា ៖

ភាពជាអ្នកប្រាថ្នាគ្មានព្រំដែន

ភាពជាអ្នកប្រាថ្នាលាមក

ភាពជាអ្នកប្រាថ្នាច្រើន

ភាពជាអ្នកប្រាថ្នាតិច

ក្នុង ៤ ប្រភេទនោះ អ្នកមិនឆ្អែតក្នុងលាភរបស់ខ្លួន បំណងរកលាភរបស់អ្នកដទៃឈ្មោះថា ភាពជាអ្នកប្រាថ្នាគ្មានព្រំដែន ។ អ្នកដែលប្រកបដោយសេចក្តីប្រាថ្នាមិនមានព្រំដែន រមែងមើលឃើញនំ ដែលឆ្អិនហើយក្នុងភាជន៍តែមួយ ដែលធ្លាក់ចុះក្នុងបាត្ររបស់ខ្លួនថា ដូចជាមិនទាន់ឆ្អិន និងជារបស់បន្តិចបន្តួច របស់តែម្យ៉ាងនោះឯង ដែលគេដាក់ក្នុងបាត្ររបស់អ្នកដទៃ រមែងមើលឃើញថា ដូចជារបស់ឆ្អិនល្អ និងជារបស់ច្រើន ។

ម្យ៉ាងទៀត ការអួតអាងគុណដែលមិនមាន និងការមិនស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា ភាពជាអ្នកប្រាថ្នាលាមក ។ សេចក្តីនោះ មានហើយក្នុងអភិធម្ម ដោយន័យជាដើមថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា រមែងប្រាថ្នាថា សូមជនចូរដឹងថា យើងមានសទ្ធា ។ បុគ្គលជាអ្នកប្រកបដោយការប្រាថ្នាលាមកនោះ រមែងតាំងនៅក្នុងឋានៈជាមនុស្សបោកប្រាស់ ។

ចំណែកការពោលសរសើរគុណ ដែលមានក្តី និងការមិនស្គាល់ប្រមាណក្នុងការទទួលក្តី ឈ្មោះថា ភាពជាអ្នកប្រាថ្នាច្រើន ។ សូម្បីភាពជាអ្នកប្រាថ្នាច្រើននោះ ក៏មានមកហើយដោយន័យជាដើមថា បុគ្គលខ្លះក្នុង

លោកនេះ ជាអ្នកមានសទ្ធា រមែងប្រាថ្នាថា សូមជនចូរដឹងថា យើងមាន
សទ្ធា ជាអ្នកមានសីល ។ បុគ្គលដែលប្រកបដោយការប្រាថ្នាច្រើននោះ
រមែងជាទីស្រឡាញ់របស់មនុស្សអាក្រក់ ។ សូម្បីមាតាអ្នកបង្កើត ក៏មិន
អាចយកចិត្តគេបាន ។ ដោយហេតុនោះ លោកទើបពោលពាក្យទុកថា ៖

អគ្គិក្ខន្ធោ សមុទ្ទោ ច មហិច្ឆោ ចាបិ បុគ្គលោ
សកដេន បច្ចយំ ទេតុ តយោ ចេតេ អតប្បិយា
គំនរភ្លើងមួយ សមុទ្រមួយ អ្នកប្រាថ្នាច្រើនមួយ ទាំង ៣ ប្រភេទ
នេះ សូម្បីនឹងឲ្យវត្ថុពេញមួយរទេះ ក៏មិនធ្វើឲ្យឆ្អែតបាន ។

ចំណែកការបិទបាំងគុណដែលមាន និងភាពជាអ្នកស្គាល់ប្រមាណ
ក្នុងការទទួល ឈ្មោះថា ភាពជាអ្នកប្រាថ្នាតិច ។ បុគ្គលដែលប្រកបដោយ
សេចក្តីប្រាថ្នាតិចនោះ ព្រោះបំណងនឹងបិទបាំងគុណ សូម្បីដែលមាននៅ
ក្នុងខ្លួនយ៉ាងសម្បូរដោយសទ្ធា ក៏មិនប្រាថ្នានឹងឲ្យមនុស្សដឹងថា យើងមាន
សទ្ធា ជាអ្នកមានសីល ជាអ្នកស្ងាត់ ជាពហុស្សូត ជាអ្នកប្រារព្ធសេចក្តី
ព្យាយាម សម្បូរដោយសមាធិ មានបញ្ញា ជាព្រះខីណាស្រព ក៏មិនប្រាថ្នា
នឹងឲ្យមនុស្សដឹងថា យើងជាព្រះខីណាស្រព ដូចជាព្រះមជ្ឈន្តិកត្ថេរៈ ដូច្នោះ ។

តំណាលមកថា ព្រះថេរៈជាព្រះខីណាស្រព ។ ក៏បាត្រចីវររបស់

លោកមានតម្លៃត្រឹមតែ ១ បាទប៉ុណ្ណោះ ។ លោកបានជាប្រធានសង្ឃក្នុងថ្ងៃឆ្លងវិហាររបស់ព្រះបាទធម្មាសោករាជ ។ គ្រានោះ មនុស្សទាំងឡាយឃើញលោកមានចីវរសៅហ្មងហួសពេក ទើបពោលថា សូមលោកចូររង់ចាំនៅខាងក្រៅមួយភ្លែតចុះ លោកម្ចាស់ ។ ព្រះថេរៈគិតថា កាលព្រះខីណាស្រពដូចជាយើង មិនសង្គ្រោះព្រះរាជា អ្នកដទៃណានឹងសង្គ្រោះបាន ទើបមុជចុះទៅក្នុងផែនដី ហើយផុសឡើងទទួលអាហារ ដែលគេរៀបទុកសម្រាប់ព្រះថេរៈជាប្រធានសង្ឃ ។ សូម្បីលោកជាព្រះខីណាស្រពយ៉ាងនេះ ក៏មិនទាន់ប្រាថ្នាថា សូមឲ្យជនានុជនចូរដឹងយើងថា ជាព្រះខីណា-ស្រព ។ ចំណែកភិក្ខុដែលប្រាថ្នាតិច រមែងញុាំងលាភដែលមិនទាន់កើតឲ្យកើតឡើង រមែងធ្វើលាភដែលកើតឡើងហើយ ឲ្យចម្រើនឡើងថែមទៀត ធ្វើចិត្តរបស់ពួកទាយកឲ្យត្រេកអរដោយប្រការដូច្នេះ ។ ពិតណាស់ ភិក្ខុដែលមានសេចក្តីប្រាថ្នាតិចនោះ រមែងទទួលយកតែបន្តិចបន្តួច ព្រោះខ្លួនជាអ្នកប្រាថ្នាតិច ដោយប្រការណាៗ ពួកមនុស្សអ្នកជ្រះថ្លាក្នុងវត្តរបស់លោក រមែងថ្វាយច្រើន ដោយប្រការនោះៗ ។

ន័យមួយទៀត ភិក្ខុដែលប្រាថ្នាតិចមាន ៤ ប្រភេទ គឺ ៖

ភិក្ខុអ្នកប្រាថ្នាតិចក្នុងបច្ច័យ ១ , ភិក្ខុអ្នកប្រាថ្នាតិចក្នុងធុតង្គ ១ ,

ភិក្ខុអ្នក ប្រាថ្នាតិចក្នុងបរិយត្តិ ១ , ភិក្ខុអ្នកប្រាថ្នាតិចក្នុងអធិគម ១ ។

ក្នុង ៤ ប្រភេទនោះ ភិក្ខុអ្នកប្រាថ្នាតិចក្នុងបច្ច័យ ៤ ឈ្មោះថា អ្នកប្រាថ្នាតិចក្នុងបច្ច័យ ។ ភិក្ខុអ្នកប្រាថ្នាតិចក្នុងបច្ច័យនោះ រមែងដឹង អំណាចរបស់ទាយក រមែងដឹងប្រមាណក្នុងទេយ្យធម៌ រមែងដឹងកម្លាំង របស់ខ្លួន ។ ក៏ប្រសិនបើថា ទេយ្យធម៌មានច្រើន តែទាយកត្រូវការថ្វាយ តិច ក៏ទទួលតែបន្តិចតាមសេចក្តីជ្រះថ្លារបស់ទាយក , ទេយ្យធម៌មានតិច ទាយកត្រូវការនឹងថ្វាយច្រើន ក៏ទទួលយកតែ បន្តិចតាមចំនួនរបស់ទេយ្យ-ធម៌ , ទាំងទេយ្យធម៌ក៏មានច្រើន ទាំងទាយកក៏ត្រូវការនឹងថ្វាយច្រើន ក៏ ដឹងកម្លាំងរបស់ខ្លួន ទទួលយកតែល្មមប្រមាណ ។ ភិក្ខុដែលមានសេចក្តី ប្រាថ្នាតិច មិនត្រូវការនឹងឲ្យគេដឹងថា ខ្លួនសមាទានធុតង្គៈ ឈ្មោះថា អ្នក ប្រាថ្នាតិចក្នុងធុតង្គៈ ។ ដើម្បីនឹងធ្វើសេចក្តីក្នុងប្រការនោះ ឲ្យជាក់ច្បាស់ មានរឿងទាំងនេះជាឧទាហរណ៍ ។

បានឮមកថា ព្រះមហាសុមត្ថេរៈ អ្នកកាន់សោសានិកង្គធុតង្គនៅ ក្នុងព្រៃស្មសានមក ៦០ ឆ្នាំ សូម្បីតែភិក្ខុត្រឹមតែមួយអង្គដទៃក៏មិនដឹង ។ ដោយហេតុនោះ លោកទើបពោលថា ៖

សុសានេ សដ្ឋិវស្សានិ អព្ពោកិណ្ណោ វសាមហំ

*ទុតិយោ មំ ន ជានេយ្យ អហោ សោសានិកុត្តមោ*

*យើងនៅតែម្នាក់ឯងក្នុងព្រៃស្មសានអស់៦០ឆ្នាំ សព្រហ្មចារីក៏*

*មិនដឹងយើង, ឱ! កំពូលបុរសអ្នករក្សា សោសានិកង្គធុតង្គ ។*

*ព្រះថេរៈ ២ អង្គ បងប្អូន នៅក្នុងចេតិយបព៌ត ។ ព្រះថេរៈប្អូន ទទួលកំណាត់អំពៅដែលឧបដ្ឋាកនាំមក បានទៅកាន់សម្នាក់ព្រះថេរៈបង និយាយថា បងឆាន់ទៅ ។ ជាពេលដែលព្រះថេរៈឆាន់ហើយខ្ពុរមាត់ ។ ព្រះថេរៈបងពោលថា បានហើយប្អូន ។ ព្រះថេរៈប្អូនសួរថា បងសមាទាន ឯកាសនិកង្គធុតង្គឬ ។ ព្រះថេរៈ បងពោលថា អ្នកនាំកំណាត់អំពៅមក សូម្បីជាអ្នកកាន់ឯកាសនិកង្គធុតង្គមកអស់ ៥០ ឆ្នាំក៏បិទបាំងធុតង្គទុក ឆាន់ ហើយខ្ពុរមាត់ អធិដ្ឋានធុតង្គថ្មីហើយទៅ ។ ចំណែកភិក្ខុដែលប្រាថ្នាតិច អង្គណាមិនប្រាថ្នានឹងឲ្យគេដឹងសេចក្ដីដែលខ្លួនជាពហុស្សូត ដូចព្រះសា-កេតកតិស្សត្ថេរៈ ភិក្ខុនេះ ឈ្មោះថា អ្នកប្រាថ្នាតិចក្នុងព្រះបរិយត្តិ ។*

*បានឮមកថា ព្រះថេរៈមិនធ្វើឱកាសក្នុងឧទ្ទេស និងបរិបុច្ឆាថា មិនមានពេលត្រូវតិះដៀលថា លោកគង់នឹងមានតែវេលាស្លាប់ លះពួកហើយ ទៅកាន់វិហារជិតសមុទ្រដែលមានខ្សាច់ដូចជាផ្កាកណ្ណិការ ជាអ្នកឧបការៈ ពួកភិក្ខុថ្នាក់ថេរៈ នវកៈ និងមជ្ឈិមៈ រហូតវស្សា ញុំាងប្រជុំជនឲ្យញាប់*

ញ័រ ដោយធម្មកថាក្នុងថ្ងៃបវារណា ថ្ងៃឧបោសថ ហើយទៅ ។

ចំណែកភិក្ខុដែលប្រាថ្នាតិចអង្គណា ជាព្រះអរិយបុគ្គលមួយអង្គក្នុងបណ្តាព្រះអរិយបុគ្គលជាសោតាបន្នៈជាដើម រមែងមិនប្រាថ្នាឲ្យដឹងភាពជាព្រះសោតាបន្នៈជាដើម ភិក្ខុដែលប្រាថ្នាតិចរូបនេះ ឈ្មោះថា អ្នកប្រាថ្នាតិចក្នុងអធិគម ដូចកុលបុត្ត ៣ នាក់ និងដូចស្មូនឆ្នាំងឈ្មោះថា ឃដិការ ។ ចំណែកព្រះបុណ្ណៈ លះសេចក្តីប្រាថ្នាហួសព្រំដែន សេចក្តីប្រាថ្នាលាមក និងសេចក្តីប្រាថ្នាច្រើន បានឈ្មោះថា ជាអ្នកប្រាថ្នាតិចព្រោះជាអ្នកប្រកបដោយសេចក្តីប្រាថ្នាតិចដ៏បរិសុទ្ធ ពោលគឺ ការមិនលោភដែលជាបដិបក្ខចំពោះការប្រាថ្នាដោយប្រការទាំងពួង ។

ព្រះបុណ្ណៈសម្តែងទោសក្នុងធម៌ទាំងនេះថា អ្នកដ៏មានអាយុ ធម៌ទាំងនេះ គឺ សេចក្តីប្រាថ្នាហួសព្រំដែន សេចក្តីប្រាថ្នាលាមក ភាពជាអ្នកប្រាថ្នាច្រើន ដែលភិក្ខុគួរលះ យ៉ាងនេះហើយ ទើបពោលអប្បិច្ឆកថាដល់ភិក្ខុទាំងឡាយថា ភិក្ខុគួរសមាទាន ប្រព្រឹត្តភាពជាអ្នកប្រាថ្នាតិចបែបនេះ ។ ដោយហេតុនេះ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ថា ភិក្ខុដែលប្រាថ្នាតិចដោយខ្លួនឯង ហើយទូន្មាន ការប្រាថ្នាតិចដល់ភិក្ខុទាំងឡាយ ។

ឥឡូវនេះ ខ្ញុំម្ចាស់នឹងសម្តែងអត្ថដ៏វិសេសក្នុងពាក្យថា **អត្តនាវ**

**សន្តុដ្ឋោ** ជាដើម ។ តែគប្បីជ្រាបការប្រកបសេចក្តីដោយន័យដូចពោលមកហើយ ។ បទថា **សន្តុដ្ឋោ** បានដល់ អ្នកដែលប្រកបដោយសេចក្តីសន្តោសក្នុងបច្ច័យតាមមាន តាមបាន ។

ក៏សន្តោសនេះមាន ១២ យ៉ាង គឺអ្វីខ្លះ ? លំដាប់ដំបូង ក្នុងចីវរមាន ៣ យ៉ាង គឺ យថាលាភសន្តោស , យថាពលសន្តោស និងយថាសារុប្បសន្តោស ។

ក្នុងបិណ្ឌបាតជាដើម ក៏ដូចគ្នា ។ ក្នុងការពណ៌នាប្រភេទបច្ច័យ គឺ ចីវរយ៉ាងនេះ ភិក្ខុក្នុងសាសនានេះបានចីវរ មិនថាល្អ ឬមិនល្អ ក៏ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរនោះប៉ុណ្ណោះ មិនប្រាថ្នាចីវរដទៃ ទោះបីបានក៏មិនទទួល នេះឈ្មោះថា យថាលាភសន្តោស ក្នុងចីវររបស់ភិក្ខុនោះ ។ ម្យ៉ាងទៀត ភិក្ខុណា ទុព្វលភាពដោយធម្មតា ឬត្រូវមានជម្ងឺ ឬជរាគ្របសង្កត់ គ្រងចីវរធ្ងន់ក៏លំបាក ភិក្ខុនោះប្តូរចីវរជាមួយភិក្ខុដែលស្រឡាញ់គ្នា ហើយញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរស្រាល ក៏ជាអ្នកសន្តោសដូចគ្នា នេះឈ្មោះថា យថាពលសន្តោស ក្នុងចីវររបស់ភិក្ខុនោះ ។ ភិក្ខុមួយអង្គទៀត បានបច្ច័យដ៏ប្រណីត លោកបានចីវរមានតម្លៃច្រើន ១ ផ្ទាំង បណ្តាចីវរព្រៃជាដើម ឬក៏ថា បានចីវរច្រើនជាដើម គិតថា ចីវរនេះសមគួរ

ដល់ព្រះថេរៈជាអ្នកបួសយូរ ទាំងនេះសមគួរដល់ភិក្ខុ ដែលជាពហុស្សូត ទាំងនេះសមគួរដល់ភិក្ខុដែលមានជម្ងឺ ទាំងនេះសមគួរដល់ភិក្ខុ ដែលមានលាភតិច ថ្វាយហើយ រើសចីវរចាស់ៗ បណ្ដាសំពត់ទាំងនោះ សូម្បីគ្រងក៏ជាអ្នកសន្ដោសនោះឯង នេះឈ្មោះថា យថាសារុប្បសន្ដោស ក្នុងចីវររបស់ភិក្ខុនោះ ។ មយ៉ាងទៀត ភិក្ខុក្នុងសាសនានេះ បានបិណ្ឌបាតមក មិនថា ថោកទាប ឬប្រណីត លោកញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌ-បាតនោះ ប៉ុណ្ណោះ មិនប្រាថ្នាបិណ្ឌបាតដទៃ ទោះបានក៏មិនទទួល នេះឈ្មោះថា យថាលាភសន្ដោស ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។ តែភិក្ខុណា បានបិណ្ឌបាត ដែលសម្ដែងដល់ការធម្មតារបស់ខ្លួន ឬសម្ដែងដល់រោគដែលលោកឆាន់ហើយមិនជាសុខ ភិក្ខុនោះ ថ្វាយបិណ្ឌបាតនោះ ដល់ភិក្ខុដែលត្រូវគ្នា ឆាន់ភោជនដែលស្អាតពីដៃរបស់ភិក្ខុនោះ សូម្បីធ្វើសមណធម៌ ក៏នៅឈ្មោះថា អ្នកសន្ដោស នេះឈ្មោះថា យថាពលសន្ដោស ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។ ភិក្ខុមួយអង្គទៀត បានបិណ្ឌបាតប្រណីតជាច្រើន លោកថ្វាយបិណ្ឌបាតនោះដល់ភិក្ខុអ្នកបួសយូរ ជាពហុស្សូត អ្នកមានលាភតិច និងភិក្ខុឈឺ ( ដូចគ្នានឹងចីវរ ) សូម្បីឆាន់បិណ្ឌបាតដែលសល់របស់ភិក្ខុទាំងនោះ ឬដើរបិណ្ឌបាត ហើយឆាន់អាហារលាយឡំគ្នា ក៏នៅមានឈ្មោះ

ថា អ្នកសន្តោស នេះឈ្មោះថា យថាសារុប្បសន្តោស ក្នុងបិណ្ឌបាតរបស់ភិក្ខុនេះ ។ មយ៉ាងទៀត ភិក្ខុក្នុងសាសនានេះ បានសេនាសនៈមិនថា គួរពេញចិត្ត ឬមិនគួរពេញចិត្ត លោកមិនសោមនស្ស មិនកើតបដិឃៈ ដោយសេនាសនៈនោះ ត្រេកអរដោយសេនាសនៈតាមដែលបាន ដោយទីបំផុតសូម្បីគ្រឿងកម្រាលធ្វើដោយស្មៅ នេះឈ្មោះថា យថាលាភសន្តោស ក្នុងសេនាសនៈនោះ ។ មយ៉ាងទៀត ភិក្ខុណា បានសេនាសនៈដែលទាស់ចិត្តដោយធម្មតារបស់ខ្លួន ឬទាស់ដល់រោគ កាលនៅ ក៏មិនបានសេចក្តីសុខភិក្ខុនោះថ្វាយសេនាសនៈនោះ ដល់ភិក្ខុដែលស្រឡាញ់គ្នា សូម្បីនៅក្នុងសេនាសនៈដែលជាសប្បាយ ជាចំណែករបស់លោក ក៏នៅមានឈ្មោះថាអ្នកសន្តោស នេះឈ្មោះថា យថាពលសន្តោស ក្នុងទីសេនាសនៈរបស់ភិក្ខុនោះ ។ ភិក្ខុមួយអង្គទៀត មានបុណ្យច្រើន បានសេនាសនៈច្រើនមានទីពួនសំងំ មណ្ឌប និងផ្ទះកំពូលជាដើម លោកថ្វាយសេនាសនៈទាំងនោះដល់ភិក្ខុបួសយូរ អ្នកជាពហុស្សូត អ្នកមានលាភតិច និងភិក្ខុឈឺ ( ដូចគ្នានឹងចីវរ ) សូម្បីនៅក្នុងទីណាមួយ ក៏នៅឈ្មោះថា អ្នកសន្តោស នេះឈ្មោះថា យថាសារុប្បសន្តោស ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។ សូម្បីភិក្ខុណាពិចារណាថា សេនាសនៈដ៏ឧត្តម ជាទីតាំងនៃសេចក្តីប្រមាទ កាល

ណាអន្ទុយក្នុងទីនោះ រមែងងងុយងោកងក់ កាលដេកលក់ហើយភ្ញាក់ឡើង វិតក្កៈដ៏លាមកក៏ប្រាកដ គប្បីមិនទទួលសេនាសនៈនោះ សូម្បីមកដល់ហើយ លោកបដិសេធន៍ហើយ សូម្បីការនៅកណ្តាលវាល គល់ឈើជាដើម ក៏នៅឈ្មោះថា អ្នកសន្តោស នេះឈ្មោះថា យថាសារុប្បសន្តោសក្នុងសេនាសនៈ ។ មួយ៉ាងទៀត ភិក្ខុនៅក្នុងព្រះសាសនានេះ បានភេសជ្ជៈមិនថា ថោកទាប ឬប្រណីត លោកត្រេកអរដោយភេសជ្ជៈដែលបាន មិនប្រាថ្នាភេសជ្ជៈសូម្បីយ៉ាងដទៃ ទោះបានក៏មិនទទួល នេះឈ្មោះថា យថា-លាភសន្តោស ក្នុងគិលានប្បច្ច័យរបស់លោក ។ មួយ៉ាងទៀត ភិក្ខុណាត្រូវការប្រេង តែបានទឹកអំពៅ លោកថ្វាយទឹកអំពៅនោះដល់ភិក្ខុដែលស្រឡាញ់គ្នា កាន់យកប្រេងពីដៃរបស់ភិក្ខុនោះ ឬស្វែងរកយ៉ាងដទៃ សូម្បីធ្វើភេសជ្ជៈដោយបច្ច័យទាំងនោះ ក៏នៅឈ្មោះថា ជាអ្នកសន្តោស នេះឈ្មោះថា យថាពលសន្តោស ក្នុងគិលានប្បច្ច័យរបស់លោក ។ ភិក្ខុមួយអន្លេទៀត មានបុណ្យច្រើន បានភេសជ្ជៈប្រណីត មានប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើមជាច្រើន លោកថ្វាយភេសជ្ជៈនោះដល់ភិក្ខុបួសយូរ ពហុស្សូតមានលាភតិច និងភិក្ខុឈឺ (ដូចគ្នានឹងចីវរ) សូម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភេសជ្ជៈណាមួយ ដែលបានមកពីគិលានប្បច្ច័យទាំងនោះ ក៏នៅ

ឈ្មោះថា ជាអ្នកសន្តោស ។ ភិក្ខុណា ដែលភិក្ខុទាំងឡាយយកផ្លែសម៉ត្រាំទុកក្នុងភាជនៈមួយ ដាក់របស់មានរសឆ្ងាញ់ ៤ យ៉ាង ទុកក្នុងភាជនៈមួយ ហើយពោលថា និមន្តកាន់យករបស់ដែលត្រូវយកចុះ បើថា រោគរបស់លោកនឹងរំងាប់ទៅដោយរបស់ឯណានីមួយ ក្នុងរបស់ទាំងនោះ កាលបើដូច្នោះ លោកក៏ហាមថា ឈ្មោះសម៉ត្រាំ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរ ហើយធ្វើភេសជ្ជៈដោយផ្លែសម៉ត្រាំតែប៉ុណ្ណោះ ឈ្មោះថា ជាអ្នកសន្តោសយ៉ាងក្រៃលែង នេះឈ្មោះថា យថាសារុប្បសន្តោស ក្នុងគិលានបច្ច័យ ។ ក៏យថាសារុប្បសន្តោស ជាកំពូលជាងសន្តោសទាំង ៣ ក្នុងបច្ច័យតែមួយៗ ទាំងនេះ ព្រះបុណ្ណៈ ជាអ្នកសន្តោសដោយសន្តោសសូម្បីទាំង ៣ នេះ ក្នុងបច្ច័យតែម្យ៉ាង ។

បទថា **សន្តុដ្ឋិកថញ្ច** បានដល់ ទូន្មានរឿងសន្តោសនេះដល់ភិក្ខុទាំងឡាយ ។ បទថា **បវិវិត្តោ** បានដល់ អ្នកប្រកបដោយវិវេក ៣ ទាំងនេះ គឺ **កាយវិវេក** , **ចិត្តវិវេក** , **ឧបធិវិវេក** ។

ក្នុងវិវេកទាំង ៣ នោះ ភិក្ខុដើរមួយអង្គ ឈរមួយអង្គ អង្គុយមួយអង្គ សឹងមួយអង្គ បិណ្ឌបាតមួយអង្គ ត្រឡប់វិញមួយអង្គ ចង្ក្រមមួយអង្គ ត្រាច់ទៅមួយអង្គ គង់នៅមួយអង្គ នេះឈ្មោះថា **កាយវិវេក** ។

ចំណែកសមាបត្តិ ៨ ឈ្មោះថា **ចិត្តវិវេក** ។

និព្វាន ឈ្មោះថា **ឧបធិវិវេក** ។

សមដូចដែលលោកពោលទុកថា **កាយវិវេក** ចំពោះបុគ្គលដែលជាអ្នកមានកាយត្រេកអរក្នុងនេក្ខម្ម: , **ចិត្តវិវេក** ចំពោះបុគ្គលដែលមានចិត្តបរិសុទ្ធ មានចិត្តផូរផង់យ៉ាងក្រៃលែង និង **ឧបធិវិវេក** ចំពោះបុគ្គលដែលប្រាសចាកឧបធិ ជាអ្នកដល់វិសង្ខារ ។ បទថា **បវិវេកកថំ** បានដល់ទូន្មានរឿងវិវេកនេះ ដល់ភិក្ខុទាំងឡាយ ។ បទថា **អសំសគ្គោ** បានដល់វៀរចាកការប្រឡូកប្រឡំ ៥ យ៉ាង ។

ការប្រឡូកប្រឡំ ៥ យ៉ាង គឺ

១ សវនសំសគ្គ:

២ ទស្សនសំសគ្គ:

៣ សមុល្លាបសំសគ្គ:

៤ សម្ភោគសំសគ្គ:

៥ កាយសំសគ្គ:

ការប្រឡូកប្រឡំ ៥ យ៉ាងនោះ ភិក្ខុក្នុងធម្មវិន័យនេះ ឮថា ស្ត្រី ឬស្រីក្រមុំ ក្នុងស្រុក ឬក្នុងតំបន់នោះស្អាត គួររីករាយ ស្រស់ស្អាត មាន

ពណ៌សម្បុរស្អាតក្រៃលែង ស្តាប់រឿងនោះហើយ រសាប់រសល់ មិនអាចបន្តព្រហ្មចរិយៈតទៅបាន មិនលាសិក្ខាឡើយ កាលណាលោកស្តាប់អ្នកដទៃគេនិយាយដល់រូបសម្បត្តិជាដើម ឬសំឡេងសើច នាំឲ្យកើតរាគៈដោយសោតវិញ្ញាណវិថី ឈ្មោះថា **សវនសំសគ្គ** , សវនសំសគ្គៈនោះ គប្បីជ្រាបដោយអំណាចព្រះពោធិសត្វ ដែលមិនធ្លាប់ហិតក្លិនរបស់ស្ត្រី និងព្រះតិស្សៈកំលោះ ដែលនៅក្នុងល្អាងបញ្ចគ្គឡៈ ។ បានឮថា ភិក្ខុកម្លោះហោះទៅ បានឮសំឡេងកូនក្រមុំជាងមាស ដែលជាអ្នកស្រុកគិរិគ្រាមទៅកាន់ស្រះបទុមជាមួយស្រីក្រមុំ ៥ នាក់ ងូតទឹកប្រដាប់ផ្កាឈូក ច្រៀងដោយសម្លេងដ៏ពីរោះ ត្រូវកាមរាគៈគ្របសង្កត់ ដាច់ឈានដល់នូវសេចក្តីវិនាស ។

ភិក្ខុក្នុងធម្មវិន័យនេះ មិនបានឮសំឡេងឡើយ តែខ្លួនឯងឃើញមនុស្សស្រី ឬស្រីក្រមុំដែលស្អាតគួរសរសើរ ស្រស់ស្អាត មានពណ៌សម្បុរស្អាតក្រៃលែង លោកឃើញហើយ រសាប់រសល់ មិនអាចបន្តព្រហ្មចរិយៈតទៅបាន មិនលាសិក្ខា មិនសឹកឡើយ កាលលោកមើលឃើញរូបដែលជាសត្រូវយ៉ាងនេះ កើតរាគៈដោយចក្ខុវិញ្ញាណវិថី ឈ្មោះថា **ទស្សនសំសគ្គ** ។ ទស្សនសំសគ្គៈនោះ គប្បីជ្រាបយ៉ាងនេះ ។ គេថា ភិក្ខុកំលោះ

មួយរូប ទៅកាន់ទូរវិហារជិតបឹងកាលទីយៈ ដើម្បីរៀនឧទ្ទេស ។ អាចារ្យ ឃើញអន្តរាយរបស់លោក ក៏មិនឲ្យឱកាស លោកក៏ព្យាយាមជាប់តាម ទៅ ។ អាចារ្យពោលថា បើអ្នកមិនត្រាច់ទៅក្នុងស្រុក យើងនឹងបង្រៀន ឧទ្ទេសដល់អ្នក ។ លោកទទួលពាក្យហើយ កាលរៀនឧទ្ទេសចប់ ក៏ថ្វាយ បង្គំលាអាចារ្យទៅ គិតថា អាចារ្យមិនឲ្យយើងត្រាច់ទៅក្នុងស្រុកនេះ យ៉ាង ដូម្តេចហ្ន៎ ក៏ឃ្លុំចីវរចូលស្រុក ។ កុលធីតាម្នាក់ ស្លៀកសំពត់ពណ៌លឿង ឈរនៅត្រង់ផ្ទះ ឃើញភិក្ខុកំលោះ ក៏កើតរាគៈ យកវែកដួសយាគូមក ដាក់បាត្រ ហើយត្រឡប់ទៅដេកលើគ្រែ ។ ពេលនោះ មាតាបិតាសួរថា យ៉ាងដូចម្តេច ! កូន ។ កុលធីតានោះ ឆ្លើយថា កាលខ្ញុំបានភិក្ខុកំលោះ ដែលទៅតាមទ្វារ ទើបនឹងមានជីវិតនៅបាន កាលមិនបាន ខ្ញុំនឹងស្លាប់ ។ មាតាបិតាប្រញាប់ទៅជួបភិក្ខុកំលោះនៅឯមាត់របងផ្ទះ ថ្វាយបង្គំ ហើយ ប្រាប់ថា ត្រឡប់មកវិញចុះលោកម្ចាស់ មេត្តាទទួលភិក្ខា ។ ភិក្ខុកំលោះ ប្រាប់ថា ល្មមហើយញោម ។ មាតាបិតាអង្វរថា រឿងរ៉ាវជាយ៉ាងនេះ លោកម្ចាស់ ក្នុងផ្ទះរបស់ខ្ញុំម្ចាស់មានទ្រព្យប៉ុណ្ណេះ ខ្ញុំម្ចាស់មានកូនក្រមុំតែ មួយប៉ុណ្ណោះ លោកម្ចាស់ចូរមកជាកូនថ្លៃរបស់ខ្ញុំម្ចាស់ចុះ អាចនៅបាន យ៉ាងសប្បាយ ។ ភិក្ខុកំលោះឆ្លើយថា អាត្មាមិនត្រូវការកង្វល់យ៉ាងនេះ

អាត្មាមិនជាប់ជំពាក់ ហើយក៏និមន្តចេញទៅ ។ មាតាបិតាទៅប្រាប់កូនស្រីថា ពុកម៉ែ មិនអាចនឹងនាំភិក្ខុកំលោះត្រឡប់មកបានទេ រើសរកស្វាមីដទៃដែលឯងត្រូវការចុះ ចូរក្រោកឡើងស៊ីបាយ ផឹកទឹកទៅ ។ កុលធីតានោះក៏មិនប្រាថ្នា នាងអត់បាយ ៧ ថ្ងៃ ហើយក៏ស្លាប់ ។ មាតាបិតាធ្វើឈាបនកិច្ចនាងហើយ ថ្វាយសំពត់ពណ៌លឿងផ្ទាំងនោះ ដល់ភិក្ខុសង្ឃក្នុងទូរវិហារ ។ ភិក្ខុទាំងឡាយ ក៏ហែកជាចំរៀកតូចៗ ចែកគ្នា ។ ភិក្ខុចាស់មួយអង្គទទួលចំណែករបស់ខ្លួន ហើយមកកាន់កល្យាណវិហារ ។ ភិក្ខុកំលោះនោះ សូម្បីគិតនឹងទៅថ្វាយបង្គំព្រះចេតិយ៍ ក៏ទៅកាន់កល្យាណវិហារនោះអង្គុយក្នុងទីសម្រាកពេលថ្ងៃ ។ ភិក្ខុចាស់ទាញផ្ទាំងសំពត់នោះមក ហើយប្រាប់ភិក្ខុកំលោះថា លោកមេត្តាទទួលប្រើសំពត់ផ្ទាំងនេះរបស់ខ្ញុំ ធ្វើជាសំពត់ត្រងទឹកចុះ ។ ភិក្ខុកំលោះសួរថា បពិត្រមហាថេរៈ បានមកពីណាលោកម្ចាស់ ។ ភិក្ខុចាស់ក៏និយាយរឿងនោះទាំងអស់ ។ ភិក្ខុកំលោះស្តាប់រឿងនោះហើយ គិតថា យើងមិនបាននៅរួមជាមួយ ស្រីនេះត្រូវភ្លើងរាគៈដុតរហូតមរណៈក្នុងទីនោះឯង ។ ចំណែករាគៈ ដែលកើតដោយការសន្ទនា ប្រាស្រ័យគ្នានិងគ្នា ឈ្មោះថា **សមុល្លាបសំសគ្គ** រាគៈដែលកើតដោយភិក្ខុទទួលវត្ថុរបស់ភិក្ខុនី ឬភិក្ខុនីទទួលវត្ថុរបស់ភិក្ខុ ហើយបរិភោគ

ឈ្មោះថា សម្ភោគសំសគ្គ សម្ភោគសំសគ្គៈនោះ គប្បីយ៉ាងនេះ ។

តំណាលថា ក្នុងគ្រាឆ្លងមរិចិវត្តិយវិហារ មានភិក្ខុ ១ សែនអង្គ ភិក្ខុនី ៩ ម៉ឺនអង្គ ។ សាមណេរ ១ អង្គ ទទួលយាគូក្តៅ ក៏ទុកត្រង់ជាយចីវរម្តង នៅលើផ្ទៃដីម្តង ។ សាមណេរី ១ អង្គឃើញ ថ្វាយស្រោមបាត្រ ដោយពោលថា ដាក់បាត្រទុកក្នុងទីនេះហើយ ចាំទៅ ។ ក្រោយមក កាលកើតភ័យឡើង ទាំងពីរអង្គ ក៏ទៅកាន់សរសមុទ្ទវិហារ ។ ទាំងពីរអង្គនោះ ភិក្ខុនីទៅមុន ។ ភិក្ខុនីនោះ បានឮថា ភិក្ខុអ្នកសីហឡមួយអង្គមក ក៏ទៅកាន់សម្នាក់ព្រះថេរៈ ធ្វើបដិណ្ឋារៈ ហើយអង្គុយ សួរថា លោកម្ចាស់កាលឆ្លងមរិចិវត្តិយវិហារ លោកវស្សាប៉ុន្មាន ។ ព្រះថេរៈឆ្លើយថា កាលណោះខ្ញុំជាសាមណេរអាយុ ៧ ខួប ចុះអ្នកប៉ុន្មានវស្សា ។ ភិក្ខុនីឆ្លើយថា កាលណោះនាងខ្ញុំក៏ជាសាមណេរីអាយុ ៧ ខួបដូចគ្នា នាងខ្ញុំ បានថ្វាយស្រោមបាត្រដល់សាមណេរមួយអង្គ ដែលទទួលយាគូក្តៅដើម្បីដាក់បាត្រ ។ ព្រះថេរៈប្រាប់ថា សាមណេរអង្គនោះគឺ ខ្ញុំករុណា រួចនាំស្រោមបាត្រចេញមកបង្ហាញ ។ សំសគ្គៈនេះឯង សូម្បីលោកទាំងពីរ ក៏មិនអាចបន្តព្រហ្មចរិយៈតទៅបាន សឹកក្នុងវេលាមានអាយុ ៦០ ឆ្នាំ ។

ក៏ភគៈ ដែលកើតឡើងដោយការចាប់ដៃជាដើម ឈ្មោះថា កាយ-

សំសគ្គៈ ។ ក្នុងសេចក្ដីនោះ មានរឿងនេះជាឧទាហរណ៍ គេថា នៅឯ **មហាចេតិយង្គណ** ពួកភិក្ខុកំលោះធ្វើការស្វាធ្យាយ ពួកភិក្ខុនីក្រមុំស្ដាប់ធម៌នៅខាងក្រោយភិក្ខុកំលោះទាំងនោះ ក្នុងភិក្ខុកំលោះទាំងនោះ ភិក្ខុកំលោះមួយអង្គ លាដៃចេញទៅត្រូវកាយភិក្ខុនីក្រមុំមួយអង្គ ។ ភិក្ខុនីក្រមុំចាប់ដៃយកមកដាក់ទុកនៅទីធំដើមទ្រូងរបស់ខ្លួន ។ ដោយសំសគ្គៈនោះ សូម្បីទាំងពីរអង្គក៏សឹកជាគ្រហស្ថ ។

ក៏ក្នុងសំសគ្គៈ ៥ យ៉ាងនោះ ការស្ដាប់ ការឃើញ ការចរចា ការរួម ការប៉ះពាល់កាយរបស់ភិក្ខុជាមួយភិក្ខុទាំងឡាយ រមែងមានជានិច្ច វៀរកាយសំសគ្គៈ កាយសំសគ្គៈដ៏សេសជាមួយភិក្ខុនីទាំងឡាយ រមែងមានមួយជំនួយកាល ។ សំសគ្គៈ សូម្បីទាំងអស់ជាមួយឧបាសកឧបាសិកាទាំងឡាយ ក៏មានមួយជំនួយកាលដូចគ្នា ។ គប្បីរក្សាចិត្តពីការកើតកិលេសក្នុងសំសគ្គៈទាំងនោះ ។ ភិក្ខុមួយអង្គជាគាហគាហកៈ មួយអង្គជាគាហមុត្តកៈ មួយអង្គជាមុត្តគាហកៈ មួយអង្គជាមុត្តមុត្តកៈ ។ ក្នុងភិក្ខុទាំងនោះ ពួកមនុស្សចូលទៅរកភិក្ខុដោយការយកចំណីបញ្ចោតដើម្បីចាប់ទុកក្ដី ភិក្ខុចូលទៅរកមនុស្សដោយការយកផ្កាឈើ ផ្លែឈើជាដើម បញ្ចោតចាប់ទុកក្ដី នេះឈ្មោះថា **គាហគាហក** ម្នាក់ ៗ ចាប់គ្នា រៀង ៗ ខ្លួន ។

ចំណែកមនុស្សចូលទៅរកភិក្ខុ ដោយន័យដែលពោលហើយ ភិក្ខុចូលទៅរកដោយជាទក្ខិណេយ្យបុគ្គល នេះឈ្មោះថា **គាហមុត្តក** ផុតពីអ្នកចាប់ ។ មនុស្សទាំងឡាយថ្វាយបច្ច័យ ៤ ដោយជាទក្ខិណេយ្យបុគ្គល ចំណែកភិក្ខុចូលទៅរក ដោយយកផ្កាឈើ ផ្លែឈើជាដើម បញ្ឆោតចាប់ទុក នេះឈ្មោះថា **មុត្តគាហក** ចាប់មិនជាប់ ។ មនុស្សទាំងឡាយ ថ្វាយបច្ច័យ ៤ ដោយជាទក្ខិណេយ្យបុគ្គលក្តី ភិក្ខុបរិភោគដោយជាទក្ខិណេយ្យបុគ្គល ដូចព្រះចុល្លបិណ្ឌបាតិយតិស្សត្ថេរៈក្តី នេះឈ្មោះថា **មុត្តមុត្តក** ម្នាក់ៗ ព្រលែងរៀងៗ ខ្លួន ។

ឮថា ឧបាសិកាម្នាក់ឧបដ្ឋាកព្រះថេរៈមក ១២ ឆ្នាំ ថ្ងៃមួយភ្លើងឆេះផ្ទះនៅភូមិនោះ ។ ភិក្ខុប្រចាំត្រកូលរបស់អ្នកដទៃៗ ក៏មកសួរថា ឧបាសិកាភ្លើងអាចធ្វើវត្ថុអ្វី ៗ មិនឲ្យខូចខាតមានខ្លះឬ ។ មនុស្សទាំងឡាយពោលថា ព្រះថេរៈប្រចាំត្រកូលមាតារបស់យើងនឹងមកក្នុងវេលាឆាន់ប៉ុណ្ណោះ ។ ព្រឹកឡើង សូម្បីព្រះថេរៈកំណត់វេលាភិក្ខាចារហើយក៏មក ។ ឧបាសិកានិមន្តឲ្យអង្គុយត្រង់ម្លប់ជង្រុកស្រូវ ចាត់ភិក្ខាថ្វាយ ។ កាលព្រះថេរៈឆាន់រួចហើយក៏ទៅ អ្នកទាំងឡាយក៏និយាយថា ព្រះថេរៈប្រចាំត្រកូលមាតារបស់យើង មកតែក្នុងវេលាឆាន់ប៉ុណ្ណោះ ។ ឧបាសិកាពោលថា លោក

ប្រចាំត្រកូលរបស់ពួកលោក ក៏សមដល់ពួកលោកប៉ុណ្ណោះ ។ ព្រះថេរៈរបស់យើង ក៏សមដល់យើងប៉ុណ្ណោះ ។ ក៏ព្រះមន្តាណីបុត្ត មិនស្និទ្ធ-ស្នាលជាមួយបរិស័ទបួន ដោយសំសគ្គៈ ៥ យ៉ាងនេះ ទើបទាំងជាគាហ-មុត្តកៈ ទាំងមុត្តមុត្តកៈ លោកមិនស្និទ្ធស្នាលខ្លួនឯងយ៉ាងណា ក៏បានអប់រំរឿងការមិនស្និទ្ធស្នាលសូម្បីដល់ភិក្ខុទាំងឡាយ ដូច្នោះ ។

បទថា **អារទ្ធវិរិយោ** បានដល់ ផ្គងសេចក្ដីព្យាយាម អធិប្បាយថា មានសេចក្ដីព្យាយាមផ្លូវកាយ និងផ្លូវចិត្តបរិបូរ ។ ពិតហើយ ភិក្ខុណាដែលកិលេសកើតឡើងក្នុងខណៈដើរ ក៏មិនព្រមឈរ ( ឈប់ ) កិលេសកើតឡើងក្នុងខណៈឈរ ក៏មិនព្រមអង្គុយ កិលេសកើតឡើងក្នុងខណៈអង្គុយ ក៏មិនព្រមដេក រមែងដើរទៅ ដូចពស់វែកដែលមន្តបង្គាប់ ចាប់ទុក និងដូចជាន់-កសត្រូវ ភិក្ខុនេះ ឈ្មោះថា អ្នកប្រារព្ធសេចក្ដីព្យាយាម ។ ព្រះថេរៈក៏ដូច្នោះ បង្រៀនរឿងប្រារព្ធសេចក្ដីព្យាយាមដល់ភិក្ខុទាំងឡាយ យ៉ាងនោះ ដូចគ្នា ។

ចតុប្បារិសុទ្ធិសីល ឈ្មោះថា សីល ក្នុងពាក្យថា សីលសម្បន្នោ ជាដើម ។

សមាបត្តិ ៨ ជាបាទរបស់វិបស្សនាឈ្មោះថា សមាធិ ។ ញាណ

ដែលជាលោកិយៈ និងលោកុត្តរៈ ឈ្មោះថា បញ្ញា ។ **វិមុត្តិ** ដែលជា អរិយផល ឈ្មោះថា វិមុត្តិ ។ បច្ចវេក្ខណញ្ញាណ ១៩ ឈ្មោះថា ញាណ-ទស្សនៈ ។

ព្រះថេរៈបរិបូរដោយសីលជាដើម បង្រៀនអំពីសីលជាដើម ដល់ភិក្ខុទាំងឡាយ ។ ព្រះមន្តាណីបុត្តនេះ ឈ្មោះថា **ឱវាទកៈ** ព្រោះឱវាទ ដោយកថាវត្ថុ ១០ ភិក្ខុមួយអន្លើ រមែងទូន្មានខ្លួនបានតែម្យ៉ាង មិនអាចនឹង ជម្រាបវិម្ពិសារ ដែលល្អិតឲ្យអ្នកដទៃដឹងបានយ៉ាងណា ព្រះថេរៈក៏មិន ដូច្នោះ ។ តែព្រះថេរៈឈ្មោះថា **វិញ្ញាបក** ព្រោះធ្វើអ្នកដទៃឲ្យដឹងនូវ កថាវត្ថុ ១០ ទាំងអស់នោះផង ។ ភិក្ខុមួយអន្លើ អាចធ្វើឲ្យអ្នកដទៃដឹង តែមិនអាចនឹងសម្តែងហេតុបាន ។ ព្រះថេរៈឈ្មោះថា **សន្ទស្សក** ព្រោះ សម្តែងហេតុបាន ។ ភិក្ខុមួយអន្លើ សម្តែងហេតុដែលមានហើយ តែមិន អាចឲ្យគេកាន់យកបាន ។ ព្រះថេរៈឈ្មោះថា **សមាទបក** ព្រោះអាចឲ្យ គេកាន់យកបាន ។ ក៏ព្រះថេរៈឈ្មោះថា **សមុត្តេជក** ព្រោះកាលបើបបួល គេយ៉ាងនោះហើយ ធ្វើភិក្ខុទាំងឡាយឲ្យអាចហ៊ាន ដោយធ្វើឲ្យកើតឧស្សាហៈ ក្នុងកថាវត្ថុទាំងនោះ ។ ឈ្មោះថា **សម្បហំសក** ព្រោះសរសើរភិក្ខុដែល កើតឧស្សាហៈហើយ ធ្វើឲ្យសប្បាយ ។

(៣១) បទថា **សុលទ្ធលាភា** បានដល់ រមែងឈ្មោះថា បានគុណមានអត្តភាពជាមនុស្ស និងបព្វជ្ជាជាដើម របស់ភិក្ខុសព្រហ្មចារីក្រុមដទៃ អធិប្បាយថា គុណធម៌ទាំងនេះ ជាលាភយ៉ាងល្អរបស់ព្រះបុណ្ណៈ ដែលមានឈ្មោះបោះសំឡេងខ្ចរខ្ចារទៅយ៉ាងនេះ ចំពោះព្រះភក្ត្ររបស់ព្រះសាស្តា ។ ម្យ៉ាងទៀត ការពោលសរសើរដល់អ្នកមិនមែនបណ្ឌិត មិនមែនជាលាភ ចំណែកការសរសើរដោយបណ្ឌិតជាលាភ ម្យ៉ាងទៀត ការសរសើរដោយគ្រហស្ថក៏មិនមែនជាលាភ ។ ក៏គ្រហស្ថគិតថា យើងនឹងសរសើរ កំពុងពោលថាលោកម្ចាស់របស់យើង ជាអ្នកមានវាចាទន់ភ្លន់ មានវាចាគួរសេពគប់ជាសម្លាញ់ មានវាចាពីរោះ សង្គ្រោះអ្នកដែលមកកាន់វិហារ ដោយបបរបាយ និងទឹកអំពៅជាដើម ស្មើនឹងការនិយាយតិះដៀលនុ៎ះឯង ។ គ្រហស្ថគិតថា យើងនឹងតិះដៀល និយាយថា ព្រះថេរៈនេះដូចជាមនុស្សប្រញាប់ទន់ ដូចជាមនុស្សមិនមានកម្លាំងកំហែង ដូចជាមនុស្សតក់ក្រហល់ មិនមានការជ្រាប់ស្គាល់ព្រះថេរៈនេះ ស្មើនឹងការសរសើរនុ៎ះឯង ។

សព្រហ្មចារី និយាយសរសើរពីក្រោយខ្នងព្រះសាស្តា ក៏មិនជាលាភ ចំណែកអ្នកសរសើរចំពោះព្រះភក្ត្រព្រះសាស្តា ជាលាភដ៏ក្រៃលែង ព្រះមានព្រះភាគ ទ្រង់អាស្រ័យនូវប្រយោជន៍ដូចពោលមក

ដូច្នេះ ទើបត្រាស់ថា **សុលទ្ធលាភោ** ដូច្នេះ ។ បទថា **អនុមស្ស អនុមស្ស** បានដល់ កំណត់សំដៅយកកថាវត្ថុ ១០ ។ បទថា **តញ្ច សត្ថា អព្ភ-នុមោទតិ** សេចក្តីថា ព្រះសាស្តា ទ្រង់អនុមោទនាគុណរបស់ភិក្ខុនោះៗ គឺ គុណនោះ យ៉ាងនេះថា ភិក្ខុនោះជាអ្នកប្រាថ្នាតិច និងជាអ្នកសន្តោស ។

លោកសំដៅយកលាភ ៥ យ៉ាង នេះគឺ ៖

-ការដែលសប្បុរសសរសើរ ជាលាភមួយយ៉ាង ។

-ការដែលសព្រហ្មចារីសរសើរ ជាលាភមួយយ៉ាង ។

-ការដែលសព្រហ្មចារីសរសើរ ចំពោះព្រះភក្ត្រព្រះសាស្តា ជាលាភមួយយ៉ាង ។

-ការកំណត់សំដៅយកកថាវត្ថុ ១០ ជាលាភមួយយ៉ាង ។

-ការដែលព្រះសាស្តាទ្រង់អនុមោទនា ជាលាភមួយយ៉ាង ។

ទើបពោលថា **សុលទ្ធលាភា** យ៉ាងនេះ ដោយប្រការដូច្នេះ ។ បទថា **កទាចិ** គឺ ក្នុងគ្រាខ្លះ ។ បទថា **ករហចិ** ជាវេវចនៈរបស់បទថា **កទាចិ** នោះឯង ។ បទថា **អប្បេវ នាម សិយា កោចិទេវ កថា-សល្លាបោ** បានដល់ តើដូចម្តេចហ្ន៎ សូម្បីការចរចាអួតអាងខ្លះ នឹងគប្បីមាន ។ គេថាព្រះថេរៈ មិនធ្លាប់ឃើញព្រះបុណ្ណៈមកឡើយ មិនធ្លាប់

ស្តាប់ធម្មកថារបស់លោក ដូច្នោះ ទើបលោកប្រាថ្នានឹងឃើញព្រះបុណ្ណៈខ្វះ ការពោលធម៌របស់លោកខ្វះ ទើបពោលយ៉ាងនេះ ។

(៣២) បទថា **យថាភិរន្តំ** បានដល់ ប្រថាប់នៅតាមព្រះអធ្យាស្រ័យ ។ ពិតណាស់ ព្រះពុទ្ធទាំងឡាយ កាលណាប្រថាប់នៅកន្លែងណាមួយ ឈ្មោះថា មិនមានការមិនត្រេកអរ ព្រោះអាស្រ័យការវិបត្តិដោយម្ហូប និងទឹកជាដើម សេនាសនៈមិនជាសុខ ឬការមិនមានសទ្ធាជាដើម របស់ពួកមនុស្ស មិនមាន សូម្បីសេចក្តីត្រេកអរថា យើងនឹងនៅជាសុខក្នុងទីនេះយូរ ៗ ហេតុតែវត្ថុទាំងនោះមានគ្រប់គ្រាន់ ។ កាលព្រះតថាគតប្រថាប់នៅក្នុងទីណា សត្វទាំងឡាយក៏តាំងនៅក្នុងសរណៈ សមាទានសីល ឬបព្វជ្ជា ឬក្រៃលែងជាងនោះ សត្វទាំងនោះ មានឧបនិស្ស័យនៃសោតាបត្តិមគ្គជាដើម ។ ព្រះពុទ្ធទាំងឡាយ រមែងប្រថាប់នៅក្នុងទីនោះតាមអធ្យាស្រ័យ ដែលទ្រង់ស្គាបនាសត្វទាំងនោះ ទុកក្នុងសម្បត្តិទាំងនោះ ព្រោះមិនមានសត្វពួកនោះ ទើបស្តេចយាងចៀសចេញទៅ ។ ដោយហេតុនោះ ទើបលោកពោលថា **យថាអជ្ឈាសយំ វិហរិត្វា** ។

បទថា **ចារិកញ្ចរមានោ** សេចក្តីថា ស្តេចពុទ្ធដំណើរផ្លូវឆ្ងាយ ។ ក៏ឈ្មោះថា ការចារិករបស់ព្រះមានព្រះភាគជាម្ចាស់នេះមាន ២ យ៉ាងគឺ ៖

## ចារិកប្រញាប់ ១ , ចារិកមិនប្រញាប់ ១

បណ្តាចារិកទាំង ២ នោះ ការដែលទ្រង់ឃើញបុគ្គលអ្នកគួរត្រាស់ដឹង សូម្បីក្នុងទីឆ្ងាយ ស្តេចប្រញាប់ទៅដើម្បីប្រោសឲ្យគេត្រាស់ដឹង ឈ្មោះថា **ចារិកប្រញាប់** ។ ការចារិកប្រញាប់នោះ គប្បីឃើញដូចជាស្តេចចេញទទួលព្រះមហាកស្សបៈជាដើម ។ ពិតណាស់ ព្រះមានព្រះភាគជាម្ចាស់ កាលស្តេចក្រោកទទួលព្រះមហាកស្សបៈ ស្តេចទ្រង់យាងចម្ងាយផ្លូវ ៣ គាវុត តែមួយភ្លែត ។ ស្តេចទ្រង់យាង ៣០ យោជន៍ ដើម្បីប្រោសអាឡវកយក្ស ប្រោសអង្គុលិមាលក៏ដូចគ្នា តែប្រោសបុក្កុសាតិ ៤៥ យោជន៍ ប្រោសព្រះបាទមហាកប្បិន ២០០០ យោជន៍ ប្រោសខទិរវនិយត្ថេរៈ ៧០០ យោជន៍ ប្រោសវនវាសីតិស្សសាមណេរ ជាសទ្ធិវិហារិករបស់ព្រះធម្មសេនាបតី ២០០០ យោជន៍ និង ៣ គាវុត ។ បានឮថា ថ្ងៃមួយព្រះថេរៈទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅសម្លាក់តិស្សសាមណេរ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា សូម្បីតថាគតក៏នឹងទៅ ហើយទ្រង់ត្រាស់នឹងព្រះអានន្ទថា អានន្ទ អ្នកចូរប្រាប់ភិក្ខុដែលបានអភិញ្ញាប្រាំមួយ ២០.០០០ អង្គថា តថាគតនឹងទៅសម្លាក់វនវាសីតិស្សសាមណេរ ។ ថ្ងៃស្អែកឡើង ព្រះមានព្រះភាគជា

ម្ចាស់ មានព្រះទីណាស្រេច ២០.០០០ អន្ទ ហែហមហោះទៅតាមអាកាស ស្តេចចុះជិតទ្វារគោចរគាមរបស់តិស្សសាមណេរនោះ ផុតផ្លូវ ២.០០០ យោជន៍ ទ្រង់ឃ្មុំចីវរ ។ ពួកមនុស្សទៅធ្វើការងារបានឃើញ ក៏ពោលថា អ្នកដ៏ចម្រើន ព្រះសាស្តាស្តេចយាងមក ពួកអ្នកមកធ្វើការងារហើយ ជួយគ្នាក្រាលអាសនៈ ថ្វាយយាគូ ធ្វើទានវត្ត ហើយសួរភិក្ខុកំលោះទាំងឡាយថា លោកម្ចាស់ ព្រះមានព្រះភាគជាម្ចាស់ ស្តេចយាងទៅណា ។ ឧបាសកទាំងឡាយ ព្រះមានព្រះភាគជាម្ចាស់ ស្តេចមិនទៅទីដទៃទេ ស្តេចមកសួរសុខទុក្ខតិស្សសាមណេរក្នុងទីនេះឯង ។ អ្នកស្រុកទាំងនោះ កើតសោមនស្សថា បានឮថា ព្រះសាស្តាស្តេចមកសួរសុខទុក្ខព្រះថេរៈ ប្រចាំត្រកូលរបស់ពួកយើង ព្រះថេរៈរបស់ពួកយើង មិនមែនថោកថយឡើយហ្ន៎ ។ លំដាប់នោះ កាលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ធ្វើភត្តកិច្ចរួចហើយ សាមណេរក៏ចូលភូមិដើម្បីបិណ្ឌបាត ក៏សួរថា មានភិក្ខុសង្ឃពួកជំឬ ។ គ្រានោះ ឧបាសកទាំងឡាយ បានប្រាប់ដល់សាមណេរថា លោកម្ចាស់ ព្រះសាស្តាស្តេចយាងមកហើយ ។ សាមណេរនោះចូលគាល់ព្រះមានព្រះភាគជាម្ចាស់ អើពើដោយអាហារបិណ្ឌបាត ។ ព្រះសាស្តាយកព្រះហស្តចាប់បាត្រ ហើយទ្រង់ត្រាស់ថា បានហើយសាមណេរ តថាគត

រួចភត្តកិច្ចហើយ ។ តមក សាមណេរនិមន្តព្រះឧបជ្ឈាយ៍គង់លើអាសនៈដែលគួរដល់ខ្លួន ហើយធ្វើភត្តកិច្ច ។ កាលបើសាមណេររួចភត្តកិច្ចហើយ ព្រះសាស្តាទ្រង់ត្រាស់មង្គល ហើយស្តេចចេញទៅប្រថាប់ឈរជិតខ្លោងទ្វារស្រុក ទ្រង់ត្រាស់សួរថា តិស្សៈ ផ្លូវទៅកន្លែងនៅរបស់អ្នក ផ្លូវណា ។ សាមណេរក្រាបទូលថា ផ្លូវនេះព្រះអង្គ ។ ទ្រង់ត្រាស់ថា តិស្សៈ អ្នកចូរចង្អុលផ្លូវដើរទៅខាងមុខ ។ បានឮថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងផ្លូវដល់លោក ព្រមទាំងទេវលោក តែទ្រង់ធ្វើសាមណេរនោះឲ្យជាមគ្គុទ្ទេសក៍ដោយពុទ្ធបំណងថា នឹងបានឃើញសាមណេររហូតអស់ផ្លូវ ៣ គាវុត ។ សាមណេរទៅដល់កន្លែងនៅរបស់ខ្លួន បានធ្វើវត្តដល់ព្រះមានព្រះភាគជាម្ចាស់ ។ គ្រានោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សួរសាមណេរនោះថា តិស្សៈ ទីចង្ក្រមត្រង់ណា ហើយស្តេចយាងទៅកាន់ចង្ក្រមនោះ ប្រថាប់គង់លើថ្មសម្រាប់អង្គុយរបស់សាមណេរ ហើយត្រាស់សួរថា តិស្សៈ អ្នកនៅជាសុខក្នុងទីនេះឬ ។ សាមណេរទូលថា ករុណាព្រះអង្គ ខ្ញុំព្រះអង្គនៅក្នុងទីនេះ បានឮសំឡេងរាជសីហ៍ ខ្លា ដំរី ម្រឹគ និងក្ងោកជាដើម ក៏កើតអរញ្ញសញ្ញាថា យើងនឹងនៅជាសុខដោយសញ្ញានោះ ។ គ្រានោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់បង្គាប់

សាមណេរនោះថា តិស្សៈ អ្នកចូរឲ្យភិក្ខុសង្ឃប្រជុំគ្នា តថាគតនឹងឲ្យ តំណែងពុទ្ធទាយាទដល់អ្នក ទ្រង់ឲ្យភិក្ខុសង្ឃប្រជុំគ្នាកន្លះយោជន៍ ឲ្យសាមណេរឧបសម្បទហើយ បានស្ដេចយាងទៅកាន់ទីនោះ ដោយព្រះអង្គឯង ហេតុនោះ ចារិកនេះ ទើបឈ្មោះថា ចារិកប្រញាប់ ។

ចំណែកការយាងរបស់ព្រះមានព្រះភាគជាម្ចាស់ ទ្រង់អនុគ្រោះលោក ដោយស្ដេចយាងបិណ្ឌបាតជាដើម ដោយផ្លូវ ១ យោជន៍ និងកន្លះយោជន៍ រាល់ ៗ ថ្ងៃ តាមលំដាប់ តាមនិគម ឈ្មោះថា ចារិកមិនប្រញាប់ ។ ក៏គឺ ព្រះមានព្រះភាគជាម្ចាស់ ស្ដេចចារិកយ៉ាងនេះ រមែងស្ដេចចារិកទៅក្នុងមណ្ឌល ៣ មណ្ឌល ណាមួយយ៉ាងនេះ គឺ មហាមណ្ឌល មជ្ឈិមមណ្ឌល អន្តិមមណ្ឌល ។ ក្នុងមណ្ឌលទាំង ៣ នោះ ទី ៩០០ យោជន៍ ចាត់ជាមហាមណ្ឌល , ទី ៦០០ យោជន៍ ចាត់ជាមជ្ឈមមណ្ឌល , ទី ៣០០ យោជន៍ ចាត់ជាអន្តិមមណ្ឌល ។ គ្រាណាមានព្រះពុទ្ធបំណងស្ដេចនឹងចារិកទៅក្នុងមហាមណ្ឌល ទ្រង់បវារណាក្នុងថ្ងៃមហាបវារណាហើយ ក្នុងថ្ងៃបាដិបទ មានភិក្ខុក្រុមធំជាបរិវារ ស្ដេចចេញទៅ បានកើតកោលាហលជាមួយគ្នា មានផ្ទៃដី ១០០ យោជន៍ ដោយជុំវិញ ។ ពួកដែលមកមុនៗ បាននិមន្តឲ្យត្រឡប់វិញ ។ ក្នុងមណ្ឌល

២ ក្រៅពីនេះ សក្ការៈរមែងរួមចុះក្នុងមហាមណ្ឌល ។ បើក្នុងទីនោះ ព្រះមានព្រះភាគជាម្ចាស់ប្រថាប់នៅ ១ ថ្ងៃ ២ ថ្ងៃ ក្នុងគាមនិគមនោះៗ ទ្រង់អនុគ្រោះមហាជនដោយទ្រង់ទទួលអាមិសទាន ទ្រង់នឹងចម្រើនកុសល ដែលជាចំណែកអាស្រ័យវិវដ្ដៈ ដោយការប្រទានធម៌ដល់មហាជននោះ ៩ ខែ ទើបស្ដេចចារិក ។ បើខាងក្នុងវស្សា ភិក្ខុទាំងឡាយមានសមថៈ-វិបស្សនានៅខ្ចី ក៏ទ្រង់មិនបវារណាក្នុងថ្ងៃមហាបវារណា តែទ្រង់នឹងពន្យាបវារណាចេញ ទៅបវារណាក្នុងថ្ងៃបវារណាកណ្ដាលខែកត្ដិក (ខែ ១២ ) ថ្ងៃដំបូងនៃខែមិគសិរ (ខែ ០១) មានភិក្ខុក្រុមធំជាបរិវារ ស្ដេចចេញដំណើរទៅរហូតដល់មជ្ឈិមមណ្ឌល ។ កាលណា ទ្រង់មានព្រះពុទ្ធបំណងចារិកក្នុងមជ្ឈិមមណ្ឌល ដោយហេតុសូម្បីដទៃ ក៏ប្រថាប់នៅ ៤ ខែ ហើយស្ដេចទើបចេញទៅ ។ ក្នុងមណ្ឌលទាំងពីរក្រៅពីនេះ លាភសក្ការៈរមែងរួមចុះក្នុងមជ្ឈិមមណ្ឌល ដូចន័យដែលពោលហើយនោះឯង ។

ព្រះមានព្រះភាគជាម្ចាស់ទ្រង់អនុគ្រោះលោក ដោយន័យខាងដើម ៨ ខែ ទើបស្ដេចចារិក ។ កាលណាព្រះមានព្រះភាគជាម្ចាស់នៅប្រចាំ ៤ ខែហើយ ពួកវេនេយ្យសត្វមានឥន្ទ្រីយ៍មិនទាន់ចាស់ក្លា ក៏ទ្រង់រង់ចាំឥន្ទ្រីយ៍របស់វេនេយ្យសត្វទាំងនោះចាស់ក្លា នឹងប្រថាប់នៅក្នុងទីនោះឯង ១ ខែខ្លះ

២-៣ ខែខ្លះ ហើយទ្រង់មានភិក្ខុពួកធំជាបរិវារ ស្តេចចេញទៅក្នុងមណ្ឌល ២ ក្រៅពីនេះ លោកសក្ការៈរមែងរួមចុះក្នុងអន្តិមមណ្ឌល ដូចន័យដែលពោលហើយនោះឯង ។

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់អនុគ្រោះសត្វលោក ដោយន័យខាងដើម ៧ ខែខ្លះ ៦ ខែខ្លះ ៥ ខែខ្លះ ៤ ខែខ្លះ ទើបស្តេចចារិក ។ ដូច្នោះ កាលណាទ្រង់ចារិកក្នុងមណ្ឌល ៣ មណ្ឌល ណានីមួយ ព្រះអង្គមិនចារិកទៅ ព្រោះហេតុនៃបច្ច័យ មានចីវរជាដើម ។ ការពិត ស្តេចចារិកទៅដើម្បីទ្រង់អនុគ្រោះ ដោយព្រះពុទ្ធបំណងយ៉ាងនេះថា មនុស្សពួកណាជាទុគ៌ត ជាពាល ជាមនុស្សចាស់ ជាមនុស្ស មានជម្ងឺ គ្រាណាមនុស្សពួកនោះ នឹងមកឃើញតថាគត ក៏កាលណាតថាគតចារិកទៅមហាជនក៏នឹងបានឃើញតថាគតក្នុងទីនោះ មនុស្សពួកខ្លះក៏នឹងធ្វើចិត្តឲ្យជ្រះថ្លា ពួកខ្លះក៏នឹងបូជាដោយផ្កាជាដើម ពួកខ្លះក៏នឹងថ្វាយភិក្ខាមួយវែក ពួកខ្លះក៏នឹងលះសេចក្តីឃើញខុស ជាសម្មាទិដ្ឋិ សេចក្តីនោះនឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏ឧត្តម ដើម្បីសេចក្តីសុខដល់មនុស្សពួកនោះ អស់កាលយូរ ។

មួយវិញទៀត ព្រះមានព្រះភាគជាម្ចាស់ទាំងឡាយ រមែងស្តេចចារិក

ដោយហេតុ ៤ ប្រការ គឺ ៖

-ដើម្បីប្រយោជន៍ដល់សេចក្តីសុខនៃសរីរៈ ដោយការឈប់សម្រាកដៃជើង ១

-ដើម្បីប្រយោជន៍ គឺ រង់ចាំការកើតអត្ថុប្បត្តិ (កើតរឿងជាហេតុឲ្យត្រាស់ធម្មទេសនា) ១ ។

-ដើម្បីប្រយោន៍ដល់ការបញ្ញត្តិសិក្ខាបទសម្រាប់ភិក្ខុទាំងឡាយ ១ ។

-ដើម្បីប្រយោជន៍ដល់សត្វដែលគួរត្រាស់ដឹង និងអ្នកមានឥន្ទ្រិយ៍ចាស់ក្លាហើយក្នុងទីនោះៗ ឲ្យត្រាស់ដឹង ១ ។

ព្រះមានព្រះភាគជាម្ចាស់ រមែងស្តេចចារិកដោយហេតុ ៤ ប្រការយ៉ាងដទៃទៀត គឺ ៖

-សត្វទាំងឡាយនឹងដល់ព្រះពុទ្ធជាម្ចាស់ ជាសរណៈខ្លះ

-ដល់ព្រះធម៌ជាសរណៈខ្លះ

-ដល់ព្រះសង្ឃជាសរណៈខ្លះ

តថាគត នឹងធ្វើបរិស័ទ ៤ ឲ្យឆ្អែតឆ្អន់ ដោយការស្តាប់ធម៌ អស់កាលដ៏យូរ ។

ព្រះមានព្រះភាគជាម្ចាស់ទាំងឡាយ រមែងស្តេចចារិកដោយហេតុ

៥ ប្រការ យ៉ាងដទៃ គឺ ៖ ពួកសត្វនឹងវៀរចាកបាណាតិបាតខ្លះ វៀរចាក អទិន្នាទានខ្លះ វៀរចាកកាមេសុមិច្ឆាចារខ្លះ វៀរចាកមុសាវាទខ្លះ វៀរចាក សុរាមេរយមជ្ជប្បមាទដ្ឋានខ្លះ ។

ព្រះមានព្រះភាគជាម្ចាស់ រមែងស្តេចចារិកដោយហេតុ ៨ ប្រការ យ៉ាងដទៃ គឺ ៖ គេនឹងបានបឋមជ្ឈានខ្លះ ទុតិយជ្ឈានខ្លះ ។ល។ នេវ-សញ្ញានាសញ្ញាសមាបត្តិខ្លះ ។

ព្រះមានព្រះភាគជាម្ចាស់ រមែងស្តេចចារិកដោយហេតុ ៨ ប្រការ យ៉ាងដទៃទៀតគឺ ៖ គេនឹងសម្រេចសោតាបត្តិមគ្គខ្លះ សោតាបត្តិផលខ្លះ ។ល។ និងធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តផលខ្លះ ។ នេះឈ្មោះថា **អតុរិតចារិក** ចារិកមិនប្រញាប់ លោកបំណងយកក្នុងទីនេះ ។

***ចារិកនោះមាន ២ យ៉ាង គឺ ៖**

និពទ្ធចារិក ១ ( ការចារិកដោយសេចក្តីចងសម្ព័ន្ធ ) , អនិពទ្ធ-ចារិក ១ ( ការចារិកដោយមិនមានការចងសម្ព័ន្ធ ) ។

ក្នុងចារិក ២ យ៉ាងនេះ កាលដែលព្រះមានព្រះភាគជាម្ចាស់ស្តេច យាងទៅប្រោសសត្វ ដែលគួរត្រាស់ដឹងសូម្បីម្នាក់ប៉ុណ្ណោះ ឈ្មោះថា **និពទ្ធចារិក** ។

ការដែលព្រះមានព្រះភាគជាម្ចាស់ ស្តេចចារិកទៅតាមលំដាប់គាម និគម នគរ ឈ្មោះថា **អនិពទ្ធចារិក** អនិពទ្ធចារិកនេះ លោកបំណងយក ក្នុងទីនេះ ។

បទថា **សេនាសនំ សំសាមេត្វា** ប្រែថា ទុកដាក់សេនាសនៈ ។ ព្រះថេរៈ កាលទុកដាក់សេនាសនៈ ក៏យកបាត្រតូច-បាត្រធំ ស្រោមបាត្រ តូច-ធំ ចីវរព្រៃ និងចីវរសំពត់សម្បកឈើជាដើម វេចខ្ចប់ទុក , ប្រក ទឹកដោះថ្លា និងប្រេងជាដើមពេញថ្នាំង ទុកដាក់ក្នុងបន្ទប់បិទទ្វារ ចាក់សោ ( រនុកទ្វារ ) រាយត្រាទុកដាក់ដោយត្រឹមតែ **អាបុច្ឆា** ពោលប្រាប់ភិក្ខុ ម្ចាស់កន្លែង តាមព្រះបាលីថា បើមិនមានភិក្ខុ ឬសាមណេរ ញោមវត្ត ឬ ម្ចាស់វិហារទេ ក៏យកគ្រែត្រួតលើគ្រែ យកតាំងត្រួតលើតាំង ដាក់ទុក លើថ្មបួនជុំ ធ្វាយខ្សែស្នួហាលចីវរ ឬខ្សែព្យួរចីវរដាក់ទុកខាងលើ បិទ ទ្វារបង្អួច ហើយចេញទៅ ។

បទថា **យេន សាវត្ថី តេន ចារិកំ បក្កាមិ** សេចក្តីថា ព្រះបុណ្ណ-មន្តាណីបុត្តបំណងនឹងគាល់ព្រះសាស្តា ទើបចេញកាន់ទិសដែលទៅក្រុង សាវត្ថី គង់នៅទីនោះ ។ ក៏ការចេញទៅ លោកឲ្យដំណឹងដល់ព្រះបាទ សុទ្ធោទនមហារាជ ឲ្យទ្រង់ទទួលទឹកដោះថ្លា ប្រេង ទឹកឃ្មុំ និងទឹកអំពៅ

ជាដើម ហើយកាលចេញទៅ ក៏យកត្រឹមតែបាត្រ ចីវរ ចេញទៅតែម្នាក់ឯង ដូចដំរីចុះប្រេងលះបង់ហ្វូង ដូចរាជសីហ៍មិនមានកិច្ចដោយមិត្រ ។ សួរថា ព្រោះហេតុអ្វី លោកមកក្រុងរាជគ្រឹះ ព្រមជាមួយអន្តេវាសិករបស់ខ្លួន ៥០០ អង្គ តែឥឡូវនេះ បានចេញទៅតែម្នាក់ឯង ។ ឆ្លើយថា ក្រុងរាជគ្រឹះឆ្ងាយពីក្រុងកបិលព័ស្តុ ៦០ យោជន៍ ចំណែកក្រុងសាវត្ថី ចម្ងាយ ៥០ យោជន៍ ព្រះសាស្តាស្តេចយាងមកពីក្រុងរាជគ្រឹះ ៤៥ យោជន៍ ប្រថាប់នៅនាក្រុងសាវត្ថី លោកបានឮថា ឥឡូវនេះព្រះសាស្តាជិតចូលមកដល់ហើយ យើងនឹងចេញទៅម្នាក់ឯង ដូច្នេះ សេចក្តីនេះ ទើបមិនជាហេតុ ។ ការពិត កាលលោកទៅកាន់សម្នាក់ព្រះពុទ្ធទាំងឡាយ គប្បីទៅអស់ផ្លូវ ១.០០០ យោជន៍ តែក្នុងគ្រានេះ លោកមិនអាចបានទូវកាយវិវេក ព្រោះត្រូវទៅជាមួយគ្នាច្រើន កាលណាពោលថា យើងនឹងទៅម្នាក់ឯង ក៏ពោលបានថា យើងនឹងនៅក្នុងទីនេះតែម្នាក់ឯង , កាលនិយាយថា យើងនឹងនៅម្នាក់ឯង ក៏និយាយថា យើងនឹងទៅម្នាក់ឯង ព្រោះដូច្នោះ លោកមិនអាចនឹងអង្គុយចូលសមាបត្តិក្នុងខណៈដែលប្រាថ្នាហើយប្រាថ្នាទៀត ឬបានទូវកាយវិវេកក្នុងសេនាសនៈដែលជាសុខ តែកាលនៅម្នាក់ឯង ក៏នឹងបានរបស់ទាំងអស់នោះដោយងាយ ដូច្នោះទើបលោកមិនទៅក្នុងគ្រានោះ ក៏

បេញទៅក្នុងពេលនេះ ។ ក្នុងពាក្យថា **ចារិកំ ចរមានោ** នេះ ឈ្មោះថា **ចារិក** នេះ រមែងបានដល់ព្រះពុទ្ធជាម្ចាស់ទាំងឡាយប៉ុណ្ណោះ ដើម្បីសង្គ្រោះមហាជន ការពិត ចារិកនោះ ក៏គួរដល់សាវកទាំងឡាយផង ។ ស័ព្ទពង្រីកសេចក្ដីចំពោះព្រះពុទ្ធទាំងឡាយ ដូចផ្ចិតស្លឹកត្នោត ដែលដោយកន្ទេលស្លឹកត្នោតជាដើម ។ បទថា **យេន ភគវា** សេចក្ដីថា ព្រះមន្តាណីបុត្តត្រាច់បិណ្ឌបាតក្នុងស្រុកមួយកន្លែងទៀបក្រុងសាវត្ថី ធ្វើភត្តកិច្ចហើយ ចូលទៅកាន់ព្រះជេតពន ទៅដល់ទីនៅរបស់ព្រះសារីបុត្តត្ថេរៈ ឬរបស់ព្រះមហាមោគ្គល្លានត្ថេរៈ លាងជើងហើយ លាបប្រេង ឆាន់ទឹក ឬទឹកបានៈ សម្រាកបន្តិច មិនកើតចិត្តគិតថា នឹងទៅគាល់ព្រះសាស្ដា តែក៏ដើរឆ្ពោះទៅកាន់បរិវេណព្រះគន្ធកុដិ ។ ព្រោះថា ព្រះថេរៈប្រាថ្នានឹងគាល់ព្រះសាស្ដា តែមិនមានកិច្ចជាមួយភិក្ខុដទៃ ព្រោះដូច្នោះ ទើបលោកមិនមានចិត្តគិតសូម្បីយ៉ាងនេះថា យើងនឹងនាំព្រះរាហុល ឬព្រះអានន្ទ ឲ្យធ្វើឱកាសដើម្បីបានគាល់ព្រះសាស្ដា ។ ពិតហើយ ព្រះថេរៈជាអ្នកស្និទ្ធស្នាលក្នុងព្រះពុទ្ធ-សាសនាខ្លួនឯងតែម្យ៉ាង ដូចអ្នកចម្បាំងធំ ដែលមានជ័យជម្នះក្នុងសង្គ្រាមរបស់ព្រះរាជា ។ ដូចជាអ្នកចម្បាំង ដូច្នោះ ប្រាថ្នានឹងគាល់ព្រះរាជាឈ្មោះថា មិនមានកិច្ចនឹងជួបអ្នកដទៃ , គាល់ព្រះរាជា រមែងគាល់បានតែ

ម្យ៉ាង ព្រោះជាអ្នកស្និទ្ធស្នាល យ៉ាងណា សូម្បីព្រះថេរៈក៏ដូច្នោះ ។ ជាអ្នកស្និទ្ធស្នាលក្នុងព្រះពុទ្ធសាសនា លោកក៏មិនមានកិច្ចដែលនឹងពឹងកិច្ចដទៃ ហើយគាល់ព្រះសាស្តា ព្រោះដូច្នោះ លោកលាងជើងហើយ ជូតជើងចូលគាល់ព្រះមានព្រះភាគជាម្ចាស់ ។ សូម្បីព្រះមានព្រះភាគជាម្ចាស់ ស្តេចពិចារណាថា វេលាព្រឹកឡើងមន្តាណីបុត្តនឹងមក ព្រោះដូច្នោះ ទើបស្តេចចូលទៅក្នុងព្រះគន្ធកុដិមិនដាក់គន្លឹះ រំងាប់ការក្រវល់ក្រវាយ តើនឡើងប្រថាប់គង់ ។ ព្រះថេរៈបើកទ្វារចូលទៅក្នុងព្រះគន្ធកុដិ ថ្វាយបង្គំព្រះមានព្រះភាគជាម្ចាស់ ហើយអង្គុយក្នុងទីដ៏សមគួរមួយ ។ បទថា **ធម្មិយាកថាយ** សេចក្តីថា ព្រះមានព្រះភាគជាម្ចាស់ កាលត្រាស់ធម្មីកថា ត្រាស់អានិសង្សសាមគ្គីរសដល់កុលបុត្ត ៣ នាក់ ក្នុងចុល្លគោសិង្គសូត្រ ត្រាស់អានិសង្សអំពីការថ្វាយទីសម្រាកក្នុងសេក្ខសូត្រ ត្រាស់កថាដែលទាក់ទងដោយបុព្វេនិវាសានុស្សតិញ្ញាណ ដែលធ្វើឲ្យបានសតិក្នុងឃដិការសូត្រ ត្រាស់ធម្មទេស ៤ ក្នុងរដ្ឋបាលសូត្រ ត្រាស់រឿងអានិសង្សថ្វាយទឹកផឹក ក្នុងសេលសូត្រ កាលត្រាស់ធម្មកថា ត្រាស់អានិសង្សក្នុងភាពជាអ្នកនៅម្នាក់ឯងដល់ព្រះភគុត្ថេរៈ ក្នុងសង្កិលេសិយសូត្រ ។ តែក្នុងរថវិនីតសូត្រនេះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ដល់ព្រះបុណ្ណៈ ទ្រង់សម្តែងរឿងកថាឈ្មោះ

**អនន្តន័យ** ដែលជាទីអាស្រ័យរបស់កថាវត្ថុ ១០ ថា ម្នាលបុណ្ណៈ សូម្បីនេះ ក៏ឈ្មោះថា **អប្បិច្ឆកថា សន្តោសកថា** ដូចគ្នា ប្រៀបដូចព្រះអង្គប្រថាប់ឈរនៅទីបំផុតព្រំដែន លាតព្រះហស្តទៅក្នុងមហាសមុទ្រ ដល់ព្រះសាវ័កដែលសម្រេចបដិសម្ភិទា ។ បទថា **យេន អន្ធវនំ** សេចក្តីថា បានឮថា គ្រានោះ វេលាក្រោយអាហារ វត្តជេតពនដេរដាសដោយមនុស្សជាច្រើន មានក្សត្រិយ៍ ព្រាហ្មណ៍ជាដើម ចូលមកកាន់វត្តជេតពន ដូចស្ថានទីរបស់ស្តេចចក្រពត្តិ ភិក្ខុមិនអាចបាននូវការស្ងប់ស្ងាត់ ចំណែកអន្ធវ័នមានសភាពស្ងប់ស្ងាត់ ប្រៀបដូចផ្ទះ ដែលសម្រាប់ធ្វើសេចក្តីព្យាយាម ព្រោះដូច្នោះ ព្រះបុណ្ណមន្តាណីបុត្ត ទើបចូលទៅកាន់អន្ធវ័ន ។ ក៏ព្រោះហេតុអ្វី លោកទើបមិនឃើញពួកមហាថេរៈ ។ គេថា ព្រោះលោកគិតយ៉ាងនេះថា យើងមកវេលាល្ងាចនឹងឃើញពួកមហាថេរៈ ហើយនឹងគាល់ព្រះទសពលទៀត ការប្រតិបត្តិព្រះមហាថេរៈយ៉ាងនេះ ក៏នឹងមានមួយដងតែសម្រាប់ព្រះសាស្តានឹងមានពីរដង ប៉ុន្តែយើងថ្វាយបង្គំព្រះសាស្តាហើយនឹងត្រឡប់ទៅកាន់ទីនៅរបស់យើងវិញ ។

(៣៣) បទថា **អភិណ្ហំ កិត្តយមានោ អហោសិ** បានដល់ សរសើររឿយៗ ។

បានឮថា ព្រះថេរៈគិតថា គេថា បុត្ត នាងមន្តាណី ឈ្មោះបុណ្ណៈ មិនប្រឡូកប្រឡំជាមួយបរិស័ទ ៤ លោកនឹងមកគាល់ព្រះទសពល លោកមិនទាន់ជួបយើង ក៏នឹងទៅហើយឬហ្ន៎ ហើយសរសើរព្រះបុណ្ណៈក្នុងចំណោមសង្ឃរាល់ ៗ ថ្ងៃ តាំងពីនោះមក កាលដាស់តឿនសតិដល់ព្រះថេរៈ ព្រះនវក និងព្រះមជ្ឈិម ។ បានឮថា លោកមានសេចក្តីគិតយ៉ាងនេះថា ធម្មតាថា ភិក្ខុចាស់ៗ មិននៅខាងក្នុងវិហារគ្រប់ពេល សូម្បីកាលយើងពោលគុណរបស់លោក ក៏អ្នកណានឹងឃើញភិក្ខុនោះ អ្នកនោះក៏នឹងមកប្រាប់ ។ គ្រានោះ សទ្ធិវិហារិករបស់ព្រះថេរៈនោះ បានឃើញព្រះបុណ្ណមន្តាណីបុត្តកំពុងកាន់បាត្រ ចីវរ ចូលទៅដល់ព្រះគន្ធកុដិ ។ សួរថា ក៏លោកបានស្គាល់ព្រះបុណ្ណមន្តាណីបុត្តនោះ យ៉ាងណា ។ ឆ្លើយថា ភិក្ខុអង្គនោះបានដឹងទូទៅដល់ព្រះធម្មកថារបស់ព្រះមានព្រះភាគជាម្ចាស់ ដែលរំលឹកដល់ឈ្មោះ បុណ្ណៈ បុណ្ណៈ ថា ព្រះថេរៈដែលព្រះឧបជ្ឈាយ៍របស់យើងសរសើររឿយ ៗ គឺ អង្គនេះឯង ដូច្នោះ ភិក្ខុអង្គនោះទើបមកប្រាប់ដល់ព្រះថេរៈ ។ បទថា **និសីទនំ អាទាយ** បានដល់ ត្បាញសំពត់ដែលមានជាយ លោកហៅថា និសីទនៈ ។ ក៏ព្រះថេរៈកាន់បន្ទះស្បែកទៅ ។ បទថា **បិដ្ឋិតោ បិដ្ឋិតោ** ប្រែថា ខាងក្រោយ ៗ ។ បទថា **សីលានុលោកិ**

សេចក្តីថា ភិក្ខុណាដើរទៅ ឃើញខ្នងក្នុងទីទួល ឃើញសិរសាក្នុងទីទាប ភិក្ខុនោះ ឈ្មោះថា មើលឃើញសិរសា គឺ ភិក្ខុនោះតាមជាប់ទៅ ។ ព្រះថេរៈ សូម្បីដើរទៅជិត ដោយមានស្នូរជំហានជើង ក្នុងជំហានដ៏រួសរាន់ ប៉ុន្តែលោកដឹងថា នេះមិនមែនជាវេលា ដែលនឹងសម្តែងការស្និទ្ធស្នាលគ្នា ទើបមិនទៅជិត ធម្មតាអន្ធវ័នជាព្រៃធំ មនុស្សរមែងមើលមិនឃើញមនុស្ស ដែលអង្គុយនៅក្នុងទីកន្ទែងមួយ ត្រូវធ្វើសម្លេងដែលមិនជាសុខ ( ស្រែក ) ថា អ្នកដ៏មានអាយុបុណ្ណៈ បុណ្ណៈ ព្រោះដូច្នោះ ព្រះថេរៈទើបមិននៅឆ្ងាយពេក ដើម្បីបានដឹងស្ថានទីដែលលោកគង់ ទើបដើរទៅល្មមមើលឃើញសិរសា ។

បទថា **ទិវាវិហារម និសីទិ** បានដល់ អង្គុយដើម្បីប្រយោជន៍ដល់ការសម្រាកពេលថ្ងៃ ។ លោកទាំងពីរអង្គនោះ ទាំងព្រះបុណ្ណៈ ទាំងព្រះសារីបុត្តត្ថេរៈ ក៏ជាជាតិនៃឧទិច្ចព្រាហ្មណ៍ ទាំងព្រះបុណ្ណត្ថេរៈ ទាំងព្រះសារីបុត្តត្ថេរៈ ក៏មានវណ្ណៈដូចមាស ទាំងព្រះបុណ្ណត្ថេរៈ ទាំងព្រះសារី-បុត្តត្ថេរៈ ក៏ដល់ព្រមដោយសមាបត្តិសម្បយុត្តដោយព្រះអរហត្តផល ទាំងព្រះបុណ្ណត្ថេរៈ ក៏ដល់ព្រមដោយអភិនីហារមួយសែនកប្ប ទាំងព្រះសារី-បុត្តត្ថេរៈ ក៏ដល់ព្រមដោយអភិនីហារមួយអសង្ខេយ្យមួយសែនកប្ប ទាំង

ព្រះបុណ្ណត្ថេរៈ ទាំងព្រះសារីបុត្តត្ថេរៈ ក៏ជាព្រះមហាខីណាស្រព ដែលសម្រេចបដិសម្ភិទា ៗ ដូច្នោះ ទើបដូចជារាជសីហ៍ពីរចូលទៅកាន់ល្អាងមាស ១ ជាមួយគ្នា ដូចខ្លាដំបងពីរ ចុះត្រោះទៅកន្លែងរលាស់ស្នងជើងរលាស់ជើងកន្លែងមួយជាមួយគ្នា ដូចស្ដេចដំរីឆទ្ទន្តពីរ ចូលទៅកាន់សាលវ័ន ដែលមានផ្ការីកល្អហើយក្នុងកន្លែងតែមួយជាមួយគ្នា ដូចស្ដេចសុប័ណ្ណៈពីរចូលទៅកាន់ធិមពលីវ័នកន្លែងតែមួយ ដូចស្ដេចវេស្សវ័ណពីរអង្គប្រថាប់រាជរថពាហនៈជាមួយគ្នា ដូចស្ដេចសកទេវរាជពីរអង្គប្រថាប់រួមក្នុងផ្ទាំងបណ្ឌុកម្ពលជាមួយគ្នា ដូចស្ដេចហារិតមហាព្រហ្មពីរអង្គ ប្រថាប់នៅក្នុងវិមានជាមួយគ្នា ព្រះមហាថេរៈនោះ ជាជាតិព្រាហ្មណ៍ទាំងពីរអង្គ មានវណ្ណៈដូចមាសទាំងពីរអង្គ បានសមាបត្តិទាំងពីរអង្គ ដល់ព្រមដោយអភិនីហារទាំងពីរអង្គ ជាព្រះមហាខីណាស្រព ដែលសម្រេចបដិសម្ភិទាទាំងពីរអង្គចូលទៅព្រៃសណ្ឌៈ (ដងព្រៃ) ជាមួយគ្នា ធ្វើដងព្រៃនោះឲ្យរុងរឿង ៗ

(៣៤) បទថា ***ភគវតិ នោ អាវុសោ ព្រហ្មចរិយំ វុស្សតិ*** បានសេចក្ដីថា ព្រះសារីបុត្តធ្លាប់ដឹងមកថា ព្រះបុណ្ណមន្តាណីបុត្តនោះ ប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមានព្រះភាគជាម្ចាស់ ក៏សួរដើម្បីផ្ដើមរឿងឡើងយ៉ាងនេះថា លោកដ៏មានអាយុ លោកប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ព្រះមានព្រះ-

ភាគជាម្ចាស់របស់ពួកយើងឬ ។ ពិតហើយ កាលកថាដំបូងមិនទាន់តាំងឡើង កថាក្រោយក៏កើតមិនបាន ព្រោះដូច្នោះ ព្រះថេរៈទើបសួរយ៉ាងនេះ ។ ព្រះថេរៈក៏ពោលបណ្តោយតាមថា យ៉ាងនោះហើយ លោកដ៏មានអាយុ ។ គ្រានោះ ព្រះសារីបុត្តប្រាថ្នានឹងស្តាប់ពាក្យឆ្លើយបញ្ហារបស់ព្រះបុណ្ណមន្តាណីបុត្តនោះ ទើបសួរវិសុទ្ធិ ៧ តាមលំដាប់ថា លោកដ៏មានអាយុ លោកប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់ព្រះមានព្រះភាគជាម្ចាស់ ដើម្បីសីលវិសុទ្ធិឬ ។ រឿងពិស្តាររបស់វិសុទ្ធិ ៧ នោះ បានពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ ក៏ព្រោះហេតុ ដែលប្រព្រឹត្តព្រហ្មចរិយៈរបស់អ្នកសូម្បីតាំងនៅក្នុងចតុប្បារិសុទ្ធិសីលជាដើម ក៏នៅមិនទាន់ដល់ទីបំផុត ដូច្នោះ ព្រះបុណ្ណៈទើបបដិសេធទាំងអស់ថា មិនមែនត្រឹមតែប៉ុណ្ណឹងទេ លោកដ៏មានអាយុ ។

បទថា **កិមត្ថំ ចរហាវុសោ**[១] សេចក្តីថា ព្រះសារីបុត្តសួរថា បើលោកមិនប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីប្រយោជន៍ដល់សីលវិសុទ្ធិជាដើម បើដូច្នោះលោក ប្រព្រឹត្តព្រហ្មចរិយៈដើម្បីអ្វីទៅ ។ បរិនិព្វានដែលរកបច្ច័យ

[១] ក្នុងបិដកខ្មែរសរសេរ **កិន្នុ ខោ អាវុសោ សីលវិសុទ្ធំ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ** ប្រែ / ម្នាលអាវុសោ លោកដ៏មានអាយុ ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ព្រះមានព្រះភាគ ដើម្បីបរិសុទ្ធិនៃសីល) ។ នៅក្នុងអដ្ឋកថាថៃសរសេរថា **កិមត្ថំ ចរហាវុសោ** យកតាមអដ្ឋកថាភាសាថៃ ។

មិនបាន ឈ្មោះថា អនុបាទាបរិនិព្វាន ក្នុងពាក្យថា **អនុប្បាទា បរិនិព្វានត្ថំ ខោ អាវុសោ** នេះ ។

ឧបាទានមានពីរចំណែក គឺ **គហណុបាទាន** ១ , **បច្ចយុបាទាន** ១ ។

ឧបាទាន ៤ យ៉ាងមាន **កាមុបាទាន** ជាដើម ឈ្មោះថា **គហណុបាទាន** ។ បច្ច័យដែលពោលហើយយ៉ាងនេះថា សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ឈ្មោះថា **បច្ចយុបាទាន** ។ បណ្តាឧបាទានទាំងនោះ អាចារ្យទាំងឡាយដែលប្រកាន់គហណុបាទាន ហៅអរហត្តផល ដែលមិនប្រកាន់ធម៌អ្វី ៗ សូម្បីដោយឧបាទាន ៤ យ៉ាង ណាមួយ ប្រព្រឹត្តទៅថា អនុបាទាបរិនិព្វាន ក្នុងពាក្យថា **អនុបាទាបរិនិព្វានំ** ។ ពិតហើយ ព្រះអរហត្តផលនោះ មិនប្រកបដោយឧបាទាន ប្រកាន់ធម៌អ្វីទេ ហើយលោកពោលថា បរិនិព្វាន ព្រោះកើតក្នុងទីបំផុតនៃកិលេសបរិនិព្វាន ។ ចំណែកអាចារ្យដែលកាន់បច្ចយុបាទាន ហៅបរិនិព្វាន ដែលរកបច្ច័យមិនបាន ដែលមិនកើតឡើងដោយបច្ច័យ ដែលបច្ច័យតាក់តែងមិនបាន បានដល់ អមតធាតុនោះឯងថា អនុបាទាបរិនិព្វាន ក្នុងពាក្យថា **អនុបាទាបរិនិព្វាន** ។ នេះជាទីបំផុត នេះជាខាងចុង នេះជាទីបញ្ចប់ ដោយថា ការបញ្ចប់ព្រហ្មចរិយៈរបស់អ្នកកាន់អបច្ចយបរិនិព្វាន រមែងឈ្មោះថា ដល់ទីបំផុត ព្រោះដូច្នោះ

ព្រះថេរៈទើបពោលថា អនុបាទាបរិនិព្វាន ។

(៣៥) លំដាប់នោះ ព្រះសារីបុត្តអ្នកប្រកបរឿយៗ នូវអនុបាទាបរិនិព្វាន នោះ ទើបផ្ដើមសួរទៀតថា លោកដ៏មានអាយុ សីលវិសុទ្ធិឬ ឈ្មោះថា អនុបាទាបរិនិព្វាន ។ ចំណែកព្រះថេរៈ បានបដិសេធពាក្យនោះទាំងអស់ ក្នុងបរិវដ្ដៈ គឺ ដោយជុំវិញ កាលបើសម្ដែងទោសក្នុងទីបំផុត ទើបពោលពាក្យមានជាអាទិ៍ថា **សីលវិសុទ្ធិព្ហោ អាវុសោ** ។

បណ្ដាបទទាំងនោះ បទថា **បញ្ញាបេស្យ**[១] ប្រែថា បើគប្បីបញ្ញត្ត ។ បទថា **សឧបាទានំយេវ**[២] សមានំ អនុបាទាបរិនិព្វានំ បញ្ញាបេស្យ សេចក្ដីថា គប្បីបញ្ញត្តចំពោះសគហណធម៌ថា និគហណធម៌ គប្បីបញ្ញត្ត សប្បច្ចយធម៌ថា អប្បច្ចយធម៌ ចំពោះសង្ខតធម៌ថា អសង្ខតធម៌ ។ ក៏ គប្បីកាន់យកខ្លឹមសារក្នុងញាណទស្សនវិសុទ្ធិយ៉ាងនេះថា គប្បីបញ្ញត្តចំពោះ សប្បច្ចធម៌ថា អប្បច្ចយធម៌ , គប្បីបញ្ញត្តចំពោះសង្ខតធម៌ថា អសង្ខត-ធម៌ ។ គប្បីឃើញលោកិយៈ ពាលបុថុជ្ជនអ្នកដើរទៅតាមវដ្ដៈ ក្នុងពាក្យ

---

១ **បញ្ញាបេស្ស** មាននៅក្នុងបិដកខ្មែរ អដ្ឋកថាថៃជា **បញ្ញបេយ្យ** , ភូមាជា **បញ្ញបេយ្យ** ។

២ **សឧបាទានញ្ញេវ** មាននៅក្នុងបិដកខ្មែរ អដ្ឋកថាថៃជា **សឧបាទានំយេវ** , អ៊ឺរ៉ុប និងភូមាក៏ជា **សឧបាទានំយេវ** ។

ថា **បុថុជ្ជនោ ហាវុសោ** នេះ ។ ពិតហើយ បុថុជ្ជននោះ វៀរចាកនូវធម៌ទាំងនេះ ដោយប្រការទាំងពួង ព្រោះសូម្បីគ្រាន់តែចតុប្បារិសុទ្ធិសីលក៏មិនមាន ។ បទថា **តេនហិ** សេចក្តីថា បណ្ឌិតពួកខ្លះ រមែងដឹងនូវទៅដល់អត្ថបានដោយឧបមា ដោយហេតុណា ហេតុនោះ យើងទើបឧបមាដល់លោក ។

(៣៦) បទថា **សត្ត រថវិនីតានិ** បានដល់ រថប្រាំពីរដែលទឹមដោយសេះអាជានេយ្យ បានហ្វឹកហាត់ល្អហើយ ។

បទថា **យាវទេវ ចិត្តវិសុទ្ធត្ថា** សេចក្តីថា លោកដ៏មានអាយុឈ្មោះថា សីលវិសុទ្ធិនេះ រមែងមានត្រឹមតែជាប្រយោជន៍ដល់ចិត្តវិសុទ្ធិ ។ បទថា **ចិត្តវិសុទ្ធត្ថា** នេះ ជាបញ្ចមីវិភត្តិ ។ ក៏ក្នុងសេចក្តីនេះ មានខ្លឹមសារដូចតទៅនេះ ប្រយោជន៍ពោល គឺ ចិត្តវិសុទ្ធិមាននៅត្រឹមណា ឈ្មោះថា សីលវិសុទ្ធិនេះ ក៏គប្បីប្រាថ្នាត្រឹមនោះ , ក៏ចិត្តវិសុទ្ធិនេះ ជាប្រយោជន៍របស់សីលវិសុទ្ធិ នេះជាទីបំផុត នេះជាខាងចុង ។ ពិតហើយ អ្នកតាំងនៅក្នុងចិត្តវិសុទ្ធិ រមែងឈ្មោះថា ធ្វើកិច្ចនៃសីលវិសុទ្ធិ ។ ក្នុងបទទាំងពួង ក៏ន័យនេះ ។ ក្នុងសេចក្តីនេះ មានសេចក្តីប្រៀបធៀប ឧបមាដូចតទៅនេះ ព្រះយោគាវចរអ្នកតក់ស្លុតខ្លាចចំពោះជរា និងមរណៈ គប្បីឃើញ

ដូចព្រះបាទបសេនទិកោសល , សក្កាយនគរ គប្បីឃើញដូចសាវត្ថីនគរ , នគរ គឺ ព្រះនិព្វាន គប្បីឃើញដូចនគរសាកេត , វេលាដែលព្រះយោគី កើត គឺ ការត្រាស់ដឹងអរិយសច្ចៈ ៤ ដែលនៅមិនទាន់ដឹង គប្បីឃើញ ដូចវេលាព្រះរាជាអ្នកនាំសេចក្តីចម្រើន កិច្ចប្រញាប់ប្រញាល់ដែលនឹងគប្បី ប្រញាប់ទៅកាន់ក្រុងសាកេត , វិសុទ្ធិ ៧ គប្បីឃើញដូចរថ ៧ , វេលា ដែលតាំងនៅក្នុងសីលវិសុទ្ធិ គប្បីឃើញដូចវេលាឡើងរថ ទី ១ , វេលា ដែលតាំងនៅក្នុងចិត្តវិសុទ្ធិជាដើម ដោយសីលវិសុទ្ធិជាដើម គប្បីឃើញ ដូចវេលាដែលដល់រថទី ២ ដោយរថទី ១ ជាដើម , វេលាដែលព្រះយោ- គាវចរធ្វើកិលេសទាំងពួងឲ្យអស់ទៅ ដោយញាណទស្សនវិសុទ្ធិ ហើយ ឡើងទៅលើប្រាសាទ គឺ ធម៌ប្រសើរ អ្នកមានកុសលធម៌ ៥០ នៅខាង មុខជាបរិវារ ចូលផលសមបត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ហើយ អង្គុយក្នុងទីដេក គឺ និរោធ គប្បីឃើញដូចវេលាដែលសោយភោជនមាន រសល្អរបស់ព្រះរាជា ហើយស្តេចចុះត្រង់ទីខាងក្នុងខ្លោងទ្វារក្រុងសាកេត ដោយរថទី ៧ ព្រមទាំងការហែហមទៅដោយពពួកញាតិមិត្ត នៅខាងលើ ប្រាសាទ ។

ព្រះធម្មសេនាបតីសារីបុត្ត សួរវិសុទ្ធិ ៧ ដល់ព្រះបុណ្ណៈ ដែលពោល

នូវកថាវត្ថុ ១០ ដោយប្រការដូច្នេះ ។ ព្រះបុណ្ណៈ ក៏វិសជ្ជនាកថាវត្ថុ ១០ ប្រការ ។ ក៏ព្រះធម្មសេនាបតីកាលសួរយ៉ាងនេះ ដឹង ឬមិនដឹង ទើបសួរ ឬក៏ថា លោកជាអ្នកឆ្លាតក្នុងលទ្ធិ ទើបសួរក្នុងវិស័យ ឬមិនឆ្លាតក្នុងលទ្ធិ ទើបសួរក្នុងអវិស័យ ចំណែកព្រះបុណ្ណត្ថេរៈដឹង ឬមិនដឹង ទើបវិសជ្ជនា ឬថាលោកជាអ្នកឆ្លាតក្នុងលទ្ធិ ទើបវិសជ្ជនាក្នុងវិស័យ ឬមិនឆ្លាតក្នុងលទ្ធិ ទើបវិសជ្ជនាក្នុងអវិស័យ ។ ក៏ព្រះធម្មសេនាបតីសារីបុត្តជាអ្នកដឹង និងជាអ្នកឆ្លាតក្នុងលទ្ធិ ទើបសួរក្នុងលទ្ធិ ព្រោះដូច្នោះ ព្រះបុណ្ណៈកាលពោលទើបពោលទឹងព្រះធម្មសេនាបតីប៉ុណ្ណោះ ព្រះបុណ្ណៈជាអ្នកដឹង ជាអ្នកឆ្លាតក្នុងលទ្ធិ ទើបឆ្លើយក្នុងវិស័យ ព្រោះដូច្នោះ ព្រះធម្មសេនាបតីសារី-បុត្ត កាលពោល គប្បីពោលជាមួយព្រះបុណ្ណៈប៉ុណ្ណោះ ។ ក៏សេចក្តីដែលលោកបំព្រួញទុកក្នុងវិសុទ្ធិទាំងឡាយ លោកក៏ធ្វើឲ្យពិស្តារហើយក្នុងកថាវត្ថុទាំងឡាយ សេចក្តីដែលលោកបំព្រួញទុកក្នុងកថាវត្ថុទាំងឡាយ លោកក៏ធ្វើឲ្យពិស្តារក្នុងវិសុទ្ធិទាំងឡាយ សេចក្តីនោះ គប្បីជ្រាបដោយន័យនេះ ។ ពិតហើយ ក្នុងវិសុទ្ធិទាំងឡាយ សីលវិសុទ្ធិតែមួយ ក៏មកជាកថាវត្ថុ ៤ គឺ **អប្បិច្ឆកថា សន្តុដ្ឋិកថា អសំសគ្គកថា សីលកថា** ។ ចិត្តវិសុទ្ធិតែមួយ ក៏មកជាកថាវត្ថុ ៣ គឺ **បវិវេកកថា វិរិយារម្ភកថា**

សមាធិកថា ។ លំដាប់ដំបូង ខ្លឹមសារដែលលោកបំព្រួញទុកក្នុងវិសុទ្ធិទាំងឡាយ លោកក៏ធ្វើឲ្យពិស្តារហើយក្នុងកថាវត្ថុទាំងឡាយ ដោយប្រការដូច្នេះ ។ ចំណែកបណ្តាកថាវត្ថុទាំងឡាយ បញ្ញាកថាតែមួយ មកជាវិសុទ្ធិ ៥ គឺ ៖ **ទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ ញាណទស្សនវិសុទ្ធិ** ។ សេចក្តីដែលលោកបំព្រួញទុកក្នុងកថាវត្ថុ លោកធ្វើឲ្យពិស្តារហើយក្នុងវិសុទ្ធិទាំងឡាយ ដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ ព្រះសារីបុត្តត្ថេរៈ កាលសួរវិសុទ្ធិ ៧ មិនសួរយ៉ាងដទៃ សួរចំពោះកថាវត្ថុ ១០ ប៉ុណ្ណោះ ។ ចំណែកព្រះបុណ្ណត្ថេរៈ កាលនឹងវិសជ្ជនាវិសុទ្ធិ ៧ ក៏មិនវិសជ្ជនាយ៉ាងដទៃ វិសជ្ជនាចំពោះកថាវត្ថុ ១០ ប៉ុណ្ណោះ ។ សូម្បីលោកទាំងពីរនោះ ដឹងហើយថាជាអ្នកឆ្លាតក្នុងលទ្ធិ គប្បីជ្រាបថា ការសួរ និងវិសជ្ជនាបញ្ហាក្នុងវិស័យប៉ុណ្ណោះ ។

(៣៧) បទថា **កោ នាម អាយស្មា** សេចក្តីថា ព្រះថេរៈមិនស្គាល់ឈ្មោះរបស់លោកក៏ទេ តែកាលស្គាល់ ក៏សួរដោយបំណងនឹងបានសេចក្តីត្រេកអរ ។ ក៏ព្រះថេរៈ កាលនឹងត្រេកអរទើបពោលពាក្យនេះថា **កថញ្ចា បន អាយស្មន្តំ** ។ បទថា **មន្តាណិបុត្តោ** បានដល់ ជាបុត្តរបស់នាងព្រាហ្មណី

ឈ្មោះថា មន្តាណី ។ បទថា **តំ** ក្នុងពាក្យថា **យថាតំ** នេះគ្រាន់តែជានិបាត ។ ការសង្ខេបក្នុងសេចក្តីនេះ មានដូច្នេះថា លោកព្យាករហើយដូចព្រះសាវកបានស្តាប់ការព្យាករណ៍ ។ បទថា **អនុមាស្ស អនុមាស្ស**[១] គឺ ពិចារណានូវកថាវត្ថុ ១០ ។ ឆ្នូត គឺ សំពត់ជូត ហៅថា **វេលៈ** ក្នុងពាក្យថា **វេលណ្ឌុកេន**[១] នេះ បើសិនសព្រហ្មចារីទាំងឡាយឲ្យលោកអង្គុយក្នុងទីនោះ បរិហារ[២] ឆ្នូតនៅលើសីសៈ ក៏នឹងគប្បីបានឃើញ សូម្បីការបានឃើញយ៉ាងនេះ ក៏ជាលាភរបស់សព្រហ្មចារីពិត ព្រោះដូច្នោះ លោកទើបសម្តែងឧបាយនៃការឃើញរឿយ ៗ ដោយការកំណត់ដែលមិនមែនជាឋានៈ ។ ក៏ព្រះថេរៈ កាលមិនបរិហារយ៉ាងនេះ ត្រូវការនឹងសួរបញ្ហា ឬត្រូវការនឹងស្តាប់ធម៌ ក៏រំពៃមើលថា តើព្រះថេរៈឈរទីកន្លែងណា អង្គុយកន្លែងណានឹងគប្បីប្រព្រឹត្ត ។ តែកាលបរិហារយ៉ាងនេះ ក៏ឱនសីសៈចុះក្នុងខណៈដែលត្រូវការឲ្យព្រះថេរៈអង្គុយ លើអាសនៈដ៏សមគួរជាធំ ទើបសួរបញ្ហា ឬស្តាប់ធម៌បាន ។ លោកទើបសម្តែងឧបាយ

---

១ អដ្ឋកថាថៃថា អនុមស្ស អនុមស្ស , បិដកខ្មែរ អនុមាស្ស អនុមាស្ស យកតាមបិដកខ្មែរ ។

១ អដ្ឋកថាថៃ វេលញ្ឌុកេន , អ៊ីរុបនិងភូមា ចេណ្ឌុកេន , បិដកខ្មែរ វេលណ្ឌុកេន យកតាមបិដកខ្មែរ ។

២ បរិហារ ប្រែថា ការពោលដោះស្រាយ ឬ ពោលដោះប្រស្នា តាមវចនានុក្រមខ្មែរ ។

នៃការឃើញរឿយៗ ដោយការកំណត់វត្ថុដែលមិនមែនឋានៈ ដោយប្រការដូច្នេះ ។

(៣៨) បទថា **សារីបុត្តោតិ ច បន មំ** សេចក្ដីថា ក៏សព្រហ្មចារីទាំងឡាយ ស្គាល់យើងយ៉ាងនេះថា ជាបុត្តរបស់នាងព្រាហ្មណីឈ្មោះថា សារី ។ បទថា **សត្ថុកប្បេន** បានដល់ ដូចព្រះសាស្ដា ។ ព្រះបុណ្ណៈលើកព្រះសារីបុត្តត្ថេរៈ តាំងទុកដូចចន្ទមណ្ឌលដោយបទតែមួយប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ ពិតហើយ ការដែលព្រះថេរៈជាព្រះធម្មកថិកដោយចំណែកមួយប្រាកដហើយក្នុងទីនេះ ក៏កាលណាហៅអាមាត្យថា ជាអ្នកធំ គប្បីហៅដូចជាព្រះរាជា , ហៅគោថា មានមាឌប៉ុនដំរី , ហៅបឹងថា មានទំហំប៉ុនមហាសមុទ្រ , ហៅពន្លឺដែលភ្លឺថា ភ្លឺដូចពន្លឺព្រះចន្ទ និងព្រះអាទិត្យ ។ តពីនោះ ក៏មិនមានការហៅសព្រហ្មចារីទាំងនោះថា ធំ ។ កាលនឹងហៅសូម្បីព្រះសាវកជាធំ ក៏គប្បីហៅថា ប្រៀបស្មើព្រះពុទ្ធជាម្ចាស់ ។ តពីនោះ ក៏មិនមានព្រះថេរៈនោះជាធំ ។ ព្រះបុណ្ណៈ លើកព្រះថេរៈតាំងទុកដូចជាចន្ទមណ្ឌលដោយបទតែមួយប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា **ឯត្តកំបិ នោ នប្បដិភាសេយ្យ** នេះ មានអធិប្បាយយ៉ាងនេះថា មិនមានការឈ្លាសសម្រាប់ព្រះថេរៈអ្នកមិនប្រមាទ ដែលសម្រេចបដិសម្ភិទា ក៏សេចក្ដីឧបមានេះ យ៉ាងណា លោកនាំមកហើយ

មិនគួរនាំសេចក្តីឧបមានោះមក គួរពោលតែអត្ថន័យប៉ុណ្ណោះ ប៉ុន្តែនឹងនាំសេចក្តីឧបមាមកបាន ក៏ចំពោះអ្នកដែលមិនដឹងដោយឧបមាទាំងឡាយ តែក្នុងអដ្ឋកថា លោកបដិសេធសេចក្តីនេះ ពោលថា ដែលឈ្មោះថាសេចក្តីឧបមានាំមកបាន សូម្បីក្នុងសម្នាក់របស់ព្រះសម្ពុទ្ធទាំងឡាយ ក៏លោកកោតក្រែងព្រះថេរៈ ទើបពោលយ៉ាងនេះ ។ បទថា **អនុមាសេយ្យ** **អនុមាសេយ្យ បុច្ឆិតា** បានដល់ កំណត់ទុកច្បាស់លាស់ ក្នុងការសួរកថាវត្ថុ ១០ ។ សួរថា ក៏ការបុច្ឆា ឬវិសជ្ជនាបញ្ហាជារបស់ធ្ងន់ ។ ឆ្លើយថា ការរៀនសូត្រហើយ បុច្ឆាមិនធ្ងន់ ចំណែកការវិសជ្ជនាទើបធ្ងន់ , ទាំងបុច្ឆាទាំងវិសជ្ជនា មានហេតុ ឬមានការណ៍ ក៏ធ្ងន់ទាំងអស់ ។ បទថា **សម្មោទីសុំ** បានដល់ មានចិត្តរីករាយ ស្មើគ្នា ។ ទេសនាចប់តាមលំដាប់អនុសន្ធិ ដោយប្រការដូច្នេះឯង ។

" ចប់អដ្ឋកថា រថវិនីតសូត្រ ទី ៤ "

# អដ្ឋកថា
## និវាបសូត្រទី៤

(៣៤) **និវាបសូត្រ** មានពាក្យផ្ដើមថា ខ្ញុំម្ចាស់បានស្ដាប់មកហើយយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិវាបសូត្រនោះ ដូចតទៅនេះ ៖

អ្នកណាមែងដាំដំណាំ គឺ ស្មៅទុកក្នុងព្រៃដើម្បីត្រូវការនឹងចាប់សត្វម្រឹគ ដោយតាំងចិត្តថា យើងនឹងចាប់ពួកម្រឹគដែលមកស៊ីស្មៅនេះបានស្រួល អ្នកនោះ ឈ្មោះថា **នេវាបិក** ។ បទថា **និវាបំ** បានដល់ដំណាំដែលគប្បីដាំ ។ បទថា **និវុត្តំ** បានដល់ ការដាំ ។ បទថា **មិគជាតា** បានដល់ ពួកម្រឹគ ។ បទថា **អនុបខជ្ជ** ប្រែថា មិនចូលទៅបៀតបៀន ។ បទថា **មុច្ឆិតា** បានដល់ វង្វេងដោយអំណាចតណ្ហា អធិប្បាយថា ស្ទុះចូលទៅកាន់ហឫទ័យដោយតណ្ហា ហើយឲ្យដល់អាការវង្វេង ។ បទថា **មទំ អាបជ្ជិស្សន្តិ** បានដល់ នឹងដល់ការស្រវឹងដោយអំណាចមានះ ។ បទថា **បមាទំ** បានដល់ ភាវៈ គឺ ភាពជាអ្នកវង្វេងសតិ ។ បទថា **យថាកាមករណីយា ភវិស្សន្តិ** សេចក្ដីថា យើងប្រាថ្នាដោយប្រការណា

នឹងត្រូវធ្វើដោយប្រការនោះ ។ បទថា **ឥមស្មឹ និវាបេ** បានដល់ ក្នុងស្ថានជាទីដាំដំណាំនេះ ។ បានឮថា ឈ្មោះថា ស្មៅ ដែលបានដាំទុកនេះ មានការដុះល្អក្នុងរដូវប្រាំងក៏មាន ។ រដូវប្រាំង រមែងមានដោយប្រការណា ៗ ស្មៅនោះ រមែងជាស្មៅមានគុម្ពក្រាស់ ដូចស្មៅក្រាស់ម្យ៉ាង ( ស្មៅព្រៃ ) និងដូចដុំពពក ដោយប្រការនោះៗ ។ ពួកព្រានក្ដូរក្នុងកន្លែងមួយដែលសម្បូណ៌ដោយទឹក ហើយដាំស្មៅនោះ ធ្វើរបង ប្រកបដោយទ្វារដើម្បីរក្សាទុក ។ លុះកាលដែលរដូវប្រាំងហួតហែង ស្មៅគ្រប់កន្លែង រមែងស្វិតក្រៀម ទឹកមានត្រឹមតែសើមអណ្ដាតក៏រកបានដោយលំបាក ក្នុងវេលានោះ សត្វម្រឹគទាំងឡាយនាំគ្នាស៊ីស្មៅស្ងួត និងស្លឹកឈើចាស់ ៗ ត្រាច់ទៅយ៉ាងស្រៀវស្រោញ ហិតក្លិនស្មៅដែលដាំទុក មិនបានគិតដល់ការស្លាប់ និងការចាប់ជាដើម ធ្លុះរបងចូលទៅ ។ ពិតណាស់ ស្មៅដែលដាំទុក រមែងជាទីស្រឡាញ់ ជាទីពេញចិត្តក្រៃលែងរបស់ពួកសត្វម្រឹគទាំងនោះ ។ ម្ចាស់ស្មៅ ឃើញពួកម្រឹគទាំងនេះ ធ្វើដូចជាមិនដឹងអស់ ២-៣ ថ្ងៃ បើកទ្វារខាងក្នុងទីដំណាំ សូម្បីអណ្ដូងទឹកក៏មាននៅក្នុងទីនោះៗ ពួកសត្វម្រឹគចូលទៅតាមទ្វារដែលបើកទុក ស៊ីផឹកហើយ ក៏ចៀសចេញទៅ ។ ក្នុងថ្ងៃស្អែកឡើង ក៏មិនមានអ្នកណាធ្វើអ្វី ៗ

ព្រោះដូច្នោះ ទើបបក់ស្លឹកត្រចៀកស៊ីផឹក ហើយមិនប្រញាប់ចេញទៅ ។ ថ្ងៃស្អែកឡើងមិនមានអ្នកណាធ្វើអ្វី ស៊ីផឹកតាមសប្បាយ ចូលទៅដេកនៅក្នុងគុម្ពោតព្រៃឈើ , ពួកព្រាន ដឹងថា សត្វម្រឹគប្រហែស ក៏បិទទ្វារឡោមព័ទ្ធ គប់ វាយ តាំងតែពីជាយព្រៃទៅ សត្វម្រឹគទាំងនោះ ត្រូវម្ចាស់ស្មៅធ្វើបានតាមសេចក្ដីត្រូវការក្នុងព្រៃស្មៅនោះ ដោយប្រការដូច្នេះ ។

(៤០) បទថា **តត្រ ភិក្ខវេ** បានដល់ ម្នាលភិក្ខុទាំងឡាយ ក្នុងហ្វូងសត្វម្រឹគទាំងនោះ ។ បទថា **បឋមា មិគជាតា** ដែលឈ្មោះថា ហ្វូងសត្វម្រឹគទី ១ និងទី ២ រមែងមិនមាន ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់កំណត់តាមលំដាប់ ហ្វូងម្រឹគដែលមកដល់ សម្ដែងបញ្ញាក់ឈ្មោះម្រឹគ ទី ១ ទី ២ ទី ៣ ទី ៤ ។ បទថា **ឥទ្ធានុភាវា** បានដល់ ព្រោះនឹងធ្វើបានតាមបំណង ។ ពិតណាស់ ភាពជាអ្នកស្ទាត់ជំនាញនោះឯង លោកសំដៅយកឫទ្ធិ និងអំណាច ក្នុងទីនេះ ។

(៤១) បទថា **ភយភោគា** បានដល់ ការបរិភោគ ដោយសេចក្ដីខ្លាច ។ បទថា **ពលវីរិយំ** បានដល់ វាយោធាតុដែលបក់ ទៅមក អធិប្បាយថា វាយោធាតុនោះបាត់ទៅ ។

(៤២) បទថា **ឧបនិស្សាយ អាសយំ កប្បេយ្យាម** សេចក្ដីថា កាល

កាលពួកម្រឹគដេកស៊ីក្នុងខាងក្នុងក្តី មកពីខាងក្រៅទំពាស៊ីក្តី រមែងមានតែការភ័យខ្លាចប៉ុណ្ណោះ សត្វម្រឹគទាំងនោះគិតថា ក៏ពួកយើងអាស្រ័យកន្លែងដំណាំនោះ ទើបអាស្រ័យនៅកន្លែងមួយ ។ បទថា **ឧបនិស្សាយ អាសយំ កប្បយីសុ** សេចក្តីថា ដែលឈ្មោះថា ពួកព្រាន រមែងមិនមានការធ្វេសប្រហែសគ្រប់ ៗ វេលា ពួកម្រឹគអាស្រ័យកន្លែងដំណាំ ( ចម្ការបន្លែស្មៅ ) ដោយតាំងចិត្តថា ពួកយើងដេកក្នុងគុម្ពោតព្រៃ និងជើងរបង ក្នុងទីនោះៗ កាលណាព្រានទាំង នោះចេញទៅលប់មុខ ឬទៅស៊ីបាយ ទើបចូលទៅដល់ចម្ការដំណាំ លុះស៊ីផឹករួចហើយ ក៏ចូលទៅកាន់ទីនៅរបស់ខ្លួន ហើយអាស្រ័យនៅក្នុងទីស្តុក មានគុម្ពោតឈើ និងជើងរបងជាដើម ។ បទថា **កុញ្ជឹសុ** បានដល់ ដឹងវេលាដែលពួកព្រានធ្វេសប្រហែស ដោយន័យដូចពោលហើយ ប្រញាប់ប្រញាល់ចូលទៅស៊ី ។ បទថា **កេដុភិនោ** បានដល់ កលមាយាដែល សិក្សាមក ។ បទថា **ឥទ្ធិមន្តា** ប្រែថា ដូចសត្វមានឫទ្ធិ ។ បទថា **បរជនា** បានដល់យក្ស យក្សទាំងនេះ មិនមែនសត្វម្រឹគ ។ បទថា **អាគតឹ វា គតឹ វា** បានដល់ ពួកយើងមិនដឹងការគតិរបស់ពួកព្រានទាំងនោះដូច្នេះថា ពួកម្រឹគទាំងនេះ រមែងមកតាមផ្លូវដែលឈ្មោះយ៉ាងនេះ នៅទីកន្លែងឯណោះ ។ បទថា **ទណ្ឌវាគុរាហិ** បានដល់ អន្ទាក់ គឺ កំណាត់ឈើ

និងអន្លប់ឈើ ។ បទថា **សមន្តា សម្បទេសំ អនុបរិវារេសុំ** សេចក្តីថា អ្នកដាំដំណាំមានមាយាច្រើន គិតថា សត្វម្រឹគទាំងនេះ នឹងមិនទៅឆ្ងាយ នឹងដេកនៅក្នុងទីជិតនេះឯង ទើបធ្វើរបងព័ទ្ធជុំវិញចម្ការដំណាំដ៏ធំរបស់ខ្លួន ។

បទថា **អទ្ទសាសុំ** សេចក្តីថា ព័ទ្ធយ៉ាងនេះ ក៏វាយអន្ទាក់បង្កាត់ដោយជុំវិញ ហើយឃ្លាំមើល ។ បទថា **យត្ថ តេ** បានដល់ ពួកព្រានទាំងនោះ បានទៅចាប់ក្នុងទីណា ក៏បានឃើញក្នុងទីនោះ ។

(៤៣-៤៤) បទថា **យន្នូន មយំ យត្ថ អគតិ** សេចក្តីថា បានឮថា ព្រានទាំងនោះគិតយ៉ាងនេះថា ពួកសត្វម្រឹគដែលដេកស៊ីនៅខាងក្នុងក្តី មកពីខាងក្រៅស៊ីក្តី នៅក្នុងទីជិតស៊ីក្តី រមែងមានការភ័យខ្លាចទាំងអស់ ។ ពិតហើយ សូម្បីសត្វទាំង នោះត្រូវព័ទ្ធចាប់ដោយអន្ទាក់ ព្រោះដូច្នោះ សត្វម្រឹគទាំងនោះ ទើបគិតយ៉ាងនេះថា បើយើងទៅយ៉ាងណាៗ យើងនឹងដេកក្នុងទីដែលពួកអ្នកចម្ការ និងពួកអ្នកធ្វើចម្ការទៅមិនដល់ ។ បទថា **អញ្ញេ យដ្ឋេស្សន្តិ** បានដល់ បៀតបៀនដល់សត្វម្រឹគដទៃ ៗ ដែលនៅឆ្ងាយពីទីនោះ ៗ ។ បទថា **តេ យដ្ឋិតា អញ្ញេ** បានដល់ សត្វម្រឹគដែលត្រូវបៀតបៀនទាំងនោះ ក៏នឹងត្រូវប្រជ្រៀតសត្វម្រឹគដទៃៗ ដែលនៅឆ្ងាយជាងនោះ ។ បទថា **ឯវំ ឥមំ និវាបំ និវុត្តំ សព្វសោ មិគជាតា វិញ្ចិស្សន្តិ** បានដល់

ហ្វូងសត្វម្រឹគទាំងអស់នឹងលះបង់ចម្ការបន្លែ ដែលពួកយើងដាំទុក ។ បទថា **អជ្ឈុបេក្ខយ្យាម** បានដល់ គប្បីខ្វល់ខ្វាយដល់ការចាប់សត្វម្រឹគទាំងនោះ ។ ក៏កាលសត្វម្រឹគទាំងឡាយ នាំគ្នាមកដោយអាការយ៉ាងណាក៏ដោយ ពួកយើងក៏នឹងបានកូនសត្វម្រឹគខ្លះ មេម្រឹគខ្លះ សត្វម្រឹគកម្លាំងតិចខ្លះ សត្វព្រាត់ហ្វូងខ្លះ , កាលមិនមក រមែងមិនបានអ្វី ៗ ។ បទថា **អជ្ឈុបេក្ខិសុ ខោ ភិក្ខវេ** បានដល់ គិតយ៉ាងនេះហើយ ទើបខ្វល់ខ្វាយ ។

(៤៥) ក្នុងពាក្យថា **អមុំ និវាបំ និវុត្តំ មារស្ស អមូនិ ច លោកាមិសានិ** នេះ ពាក្យថា និវាបក្តី , ពាក្យថា លោកាមិសានិក្តី ជាឈ្មោះរបស់កាមគុណ ៥ ដែលជាចំណីនៃវដ្តៈ ។ មារ មិនបានសាបព្រោះកាមគុណដូចជំណាំទេ តែផ្សាយអំណាច គ្របដណ្តប់លើអ្នកដែលត្រេកអរក្នុងកាមគុណ ។ ដូច្នោះ កាមគុណ ទើបឈ្មោះថា ជានុយបញ្ឆោតរបស់មារ ។ ព្រោះហេតុនោះ ទើបលោកពោលថា **អមុំ និវាបំ និវុត្តំ មារស្ស** យ៉ាងនេះ ។ បទថា **ន បរិមុច្ចិំសុ មារស្ស ឥទ្ធានុភាវា** បានដល់ ជាអ្នកធ្លាក់ក្នុងអំណាចរបស់មារ ត្រូវមារធ្វើបានតាមត្រូវការ ។ នេះជាការប្រៀបធៀប ដោយការបព្វជ្ជាព្រមដោយបុត្រ និងភរិយា ។

(៤៦) ឈ្មោះថា **ចេតោវិមុត្តិ** ក្នុងពាក្យថា **ចេតោវិមុត្តិ បរិហាយិ** នោះ បានដល់ អធ្យាស្រ័យដែលកើតឡើងថា ពួកយើងនឹងនៅក្នុងព្រៃ អធិប្បាយថា អធ្យាស្រ័យនោះសាបសូន្យ ។ សេចក្តីថា **តថូបមេ អហំ ភិក្ខវេ ឥមេ ទុតិយេ** នេះ ជាការប្រៀបធៀប ដោយការបព្វជ្ជាប្រកបដោយធម៌របស់ព្រាហ្មណ៍ ។ ពិតណាស់ ព្រាហ្មណ៍ទាំងឡាយប្រព្រឹត្តកុមារព្រហ្មចរិយៈ ៤៨ ឆ្នាំ គិតថា នឹងបន្តប្រពៃណី ព្រោះខ្លាចវង្សៈដាច់ ស្វែងរកទ្រព្យ បានភរិយា គ្រប់គ្រងផ្ទះ កាលកើតកូនមួយគិតថា យើងមានបុត្តហើយ វង្សៈមិនដាច់ ហើយបន្តប្រពៃណី ទើបចេញបួសទៀត ឬមានប្រពន្ធតាមដើម ។

(៤៧) បទថា **ឯវំ ហិ តេ ភិក្ខវេ តតិយា សមណព្រាហ្មណា ន បរិមុច្ចឹសុ** សេចក្តីថា សមណព្រាហ្មណ៍សូម្បីទាំងនោះ មិនផុតពីឫទ្ធិ និងអំណាចរបស់មារដូចមុន បានជាអ្នកត្រូវមារធ្វើតាមអំពើចិត្ត ។

សួរថា ៖ ក៏សមណព្រាហ្មណ៍ទាំងនោះ ធ្វើយ៉ាងណា ។

ឆ្លើយថា ៖ សមណព្រាហ្មណ៍ទាំងនោះ ទៅកាន់ស្រុកនិគម និងរាជធានី ឲ្យសាងអាស្រមនៅក្នុងអារាម និងសួននោះៗ ឲ្យក្មេងនៅក្នុងត្រកូលទាំងឡាយសិក្សាសិល្បៈ មានប្រការផ្សេងៗ ដូចជាសិល្បៈជិះសេះ និងរថ ជាដើម ។ ដូច្នោះ សមណព្រាហ្មណ៍ទាំងនោះត្រូវអន្ទាក់ គឺ

ទិដ្ឋិរបស់មារ ជាអ្នកមានបាបរូបរឹត ត្រូវមារធ្វើបានតាមអំពើចិត្ត ដូចហ្វូងសត្វ ទី ៣ ដែលត្រូវព័ទ្ធដោយសំណាញ់ ។

(៤៨) សេចក្តីថា **តថូបមេ អហំ ភិក្ខវេ ឥមេ ចតុត្ថេ** នេះ ជាគ្រឿងនាំមកប្រៀបធៀបជាមួយសាសនានេះ ។

(៤៩) បទថា **អន្ធមកាសិ មារំ** សេចក្តីថា មិនបំផ្លាញកែវភ្នែករបស់មារ តែចិត្តរបស់ភិក្ខុដែលចូលឈាន ដែលជាបាទរបស់វិបស្សនា រមែងអាស្រ័យអារម្មណ៍នេះប្រព្រឹត្តទៅ ដូច្នោះ មារ ទើបមិនអាចនឹងឃើញបាន ។ ដោយហេតុនោះទើបពោលថា **អន្ធមកាសិ មារំ** យ៉ាងនេះ ។ បទថា **អបទំ វធិត្វា មារចក្ខុំ** សេចក្តីថា ដោយបរិយាយនេះឯង លោកទើបសម្លាប់ ដោយប្រការដែលចក្ខុរបស់មារមិនមានផ្លូវ អស់ផ្លូវ មិនមានទីអាស្រ័យ ប្រាសចាកអារម្មណ៍ ។

បទថា **អទស្សនំ គតោ បាបិមតោ** បានដល់ ដោយបរិយាយនោះឯង មារមានចិត្តបាប ទើបមើលមិនឃើញ ។ ពិតហើយ មារនោះ មិនអាចមើលឃើញរូបរាង គឺ ញាណរបស់ភិក្ខុចូលឈាន ដែលជាបាទរបស់វិបស្សនានោះ ដោយមំសចក្ខុរបស់ខ្លួនបាន ។ បទថា **បញ្ញាយ ចស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ** សេចក្តីថា ព្រោះឃើញអរិយសច្ចៈ ៤

ដោយមគ្គបញ្ញា អាសវៈ ៤ ក៏អស់ទៅ ។ បទថា **តិណ្ណោ លោកេ វិសត្តិកំ** បានដល់ ដល់ការរាប់យ៉ាងនេះថា **វិសត្តិកា** ព្រោះជាប់នៅនិងជ្រួតជ្រាបទៅក្នុងលោក ។ បទថា **វិសត្តិកា** សេចក្ដីថា ដែលឈ្មោះថា **វិសត្តិកា** ព្រោះអត្ថថាអ្វី ឈ្មោះថា **វិសត្តិកា** ព្រោះថា ជ្រួតជ្រាបផ្សាយទៅ ពង្រីកទៅយ៉ាងសម្បូរ ធំទូលាយ ប្រាសចាកអំណាច នាំវត្ថុដែលជាពិសមក មានវាទៈជាពិស មានឫសជាពិស មានផលជាពិស មានគ្រឿងបរិភោគជាពិស ឬថា តណ្ហានោះផ្សព្វផ្សាយទៅក្នុងរូប សំឡេង ក្លិន រសនិងផោដ្ឋព្វៈ ព្រោះដូច្នោះ ទើបឈ្មោះថា **វិសត្តិកា** ។ អ្នកឆ្លង ឆ្លងចេញឆ្លងផុតពីតណ្ហា រាប់ថា **វិសត្តិកា** ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះលោកទើបពោលថា **តិណ្ណោ លោកេ វិសត្តិកំ** ដូច្នេះ ៕

" ចប់អដ្ឋកថា និវាបសូត្រ ទី ៥ "

# អដ្ឋកថា

## បាសរាសិសូត្រ ទី៦

❋❋❋

(៥០) បាសរាសិសូត្រ មានពាក្យផ្ដើមថា ខ្ញុំម្ចាស់បានស្ដាប់មក ហើយយ៉ាងនេះ ៖

គប្បីជ្រាបវិនិច្ឆ័យក្នុងបាសរាសិសូត្រនោះ បទថា **សាធុ មយំ អាវុសោ** បានដល់ ពោលអង្វរករ ។ បានឮមកថា ភិក្ខុអ្នកជនបទប្រមាណ ៥០០ អង្គនោះ គិតនឹងគាល់ព្រះទសពល ទើបទៅកាន់ក្រុងសាវត្ថី ។ ក៏ភិក្ខុទាំងនោះបានគាល់ព្រះសាស្ដាហើយ នៅមិនទាន់បានស្ដាប់ធម្មីកថា ។ ដោយសេចក្ដីគោរពក្នុងព្រះសាស្ដា ភិក្ខុទាំងនោះទើបមិនអាចនឹងក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គប្រោសមេត្តាសម្ដែងព្រះធម្មីកថាដល់ពួកខ្ញុំព្រះអង្គ ។ ព្រោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ ជាគ្រុ កម្រនឹងបានចូលជួប ដូចស្ដេចរាជសីហ៍ត្រាច់ទៅតាមទំនើងចិត្ត ដូចដំរីដែលចុះប្រេង ដូចអសិរពិសដែលបើកពពារ ដូចគំនរភ្លើងធំ ។ សមដូចដែល លោកពោលទុកថា ៖

ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ចូលគាល់បានដោយលំបាក

ដូចអសិរពិស ដូចកេសរាជសីហ៍ ដូចស្តេចដំរី ។

ភិក្ខុទាំងនោះមិនអាចអង្វរព្រះសាស្តា ជាអ្នកដែលចូលគាល់បាន ដោយលំបាក យ៉ាងនេះដោយខ្លួនឯង ទើបអង្វរព្រះអានន្ទថា *សាធុ មយំ អាវុសោ* ដូច្នេះ ។

បទថា *អប្បេវ នាម* បានដល់ ធ្វើម្តេចហ្ន៎ ពួកយើងនឹងគប្បីបាន ចូលគាល់ ។ ក៏ព្រោះហេតុអ្វី ទើបព្រះថេរៈពោលនឹងភិក្ខុទាំងនោះថា ពួកលោកគប្បីចូលទៅកាន់អាស្រមរបស់រម្មកព្រាហ្មណ៍ ។ ព្រោះមាន កិរិយាប្រាកដ ព្រោះកិរិយាព្រះទសពល រមែងប្រាកដដល់ព្រះថេរៈ ។ ព្រះថេរៈជ្រាបថា ថ្ងៃនេះព្រះសាស្តាប្រថាប់នៅឯវត្តជេតពន ទ្រង់សម្រាក ពេលថ្ងៃក្នុងបុព្វារាម ថ្ងៃនេះស្តេចចូលបិណ្ឌបាតតែព្រះអង្គឯង ថ្ងៃនេះ ហែហមទៅដោយភិក្ខុសង្ឃ វេលានេះ ស្តេចចារិកទៅក្នុងជនបទ សួរថា ក៏ចេតោបរិយញ្ញាណរមែងមានដើម្បីឲ្យលោកដឹងដូច្នេះ បានយ៉ាងណា ។ ឆ្លើយថា មិនមាន ។ លោកដឹងដោយន័យ តាមកិរិយាដែលធ្វើទុក ដោយ ដឹងតាមការគិតស្មាន ។ ពិតហើយ ថ្ងៃនោះ ព្រះមានព្រះភាគជាម្ចាស់ ប្រថាប់នៅក្នុងវត្តជេតពន មានពុទ្ធបំណងសម្រាកពេលថ្ងៃក្នុងបុព្វារាម ក្នុងវេលាណា ក្នុងវេលានោះ ទ្រង់សម្តែងអាការ គឺ ការទុកដាក់សេនា-

សនៈ និងគ្រឿងបរិក្ខារ ។ ព្រះថេរៈទុកដាក់អំបោះ និងសក្ការៈដែលគេបោះចោលជាដើម ។ សូម្បីក្នុងវេលាដែលព្រះអង្គ ទ្រង់ប្រថាប់ក្នុងបុព្វារាម ហើយស្តេចយាងមកវត្តជេតពនសម្រាកក្នុងវេលាថ្ងៃ ក៏ន័យនេះដូចគ្នា ។ ក៏ក្នុងគ្រាណាមានពុទ្ធបំណង ស្តេចនឹងយាងទៅបិណ្ឌបាតតែមួយព្រះអង្គឯង គ្រានោះ ក៏ទ្រង់បដិបត្តិសរីរកិច្ចពីព្រលឹម ចូលព្រះគន្ធកុដិបិទទ្វារ ចូលផលសមាបត្តិ ។ ព្រះថេរៈជ្រាបដោយសញ្ញានោះថា ថ្ងៃនេះព្រះមានព្រះភាគជាម្ចាស់ ប្រថាប់ប្រមើលមើលពួកសត្វដែលគួរត្រាស់ដឹង ហើយទើបឲ្យសញ្ញាដល់ភិក្ខុទាំងឡាយថា អាវុសោទាំងឡាយ ថ្ងៃនេះ ព្រះមានព្រះភាគជាម្ចាស់ បំណងនឹងចូលទៅតែមួយព្រះអង្គឯង ពួកលោកត្រូវត្រៀមភិក្ខាចារ ។ ក៏គ្រាណាមានព្រះបំណងនឹង មានភិក្ខុជាបរិវារ គ្រានោះ ទ្រង់បង្ហើបទ្វារព្រះគន្ធកុដិ ប្រថាប់គង់ចូលផលសមាបត្តិ ។ ព្រះថេរៈជ្រាបដោយសញ្ញានោះ ទើបឲ្យសញ្ញាដល់ភិក្ខុទាំងឡាយដើម្បីទទួលបាត្រ និងចីវរ ។ តែគ្រាណាមានពុទ្ធបំណងស្តេចចារិកទៅក្នុងជនបទ គ្រានោះនឹងសោយលើសពី ២ ម៉ាត់ ហើយស្តេចចង្ក្រមទៅមកៗ គ្រប់ពេលវេលា ។ ព្រះថេរៈជ្រាបដោយសញ្ញានោះ ទើបឲ្យសញ្ញាដល់ភិក្ខុទាំងឡាយថា លោកដ៏មានអាយុទាំងឡាយ ព្រះមានព្រះ-

ភាគជាម្ចាស់ មានពុទ្ធបំណងស្តេចទីងចារិកទៅក្នុងជនបទ ពួកលោកចូរធ្វើកិច្ចដែលគួរធ្វើរបស់លោកចុះ ។ ព្រះមានព្រះភាគជាម្ចាស់ ក្នុងបឋមពោធិកាល ប្រថាប់មិនជាប្រចាំ ២០ ព្រះវស្សា , ក្រោយមកបានប្រថាប់ជាប្រចាំក្នុងក្រុងសាវត្ថី ២៥ ព្រះវស្សា ១ ថ្ងៃៗ ទ្រង់គង់ពីរកន្លែង ។ ពេលយប់ប្រថាប់នៅក្នុងវត្តជេតពន ព្រឹកឡើងហែហមដោយភិក្ខុសង្ឃស្តេចចូលបិណ្ឌបាតក្នុងក្រុងសាវត្ថីតាមទ្វារទិសខាងត្បូង ស្តេចចេញតាមទ្វារទិសខាងកើត ទ្រង់សម្រាកព្រះកាយពេលថ្ងៃក្នុងបុព្វារាម ។ ពេលយប់ប្រថាប់នៅក្នុងបុព្វារាម ព្រឹកឡើង ស្តេចយាងបិណ្ឌបាតក្នុងក្រុងសាវត្ថីតាមទ្វារទិសខាងកើត ហើយស្តេចចេញតាមទ្វារទិសខាងត្បូង ទ្រង់សម្រាកព្រះកាយពេលថ្ងៃក្នុងវត្តជេតពន ព្រោះហេតុអ្វី ។ ព្រោះទ្រង់អនុគ្រោះដល់ត្រកូលពីរ ។ ពិតហើយ ធម្មតាថា អ្នកណាមួយតាំងនៅក្នុងភាពជាមនុស្សដូចលោកអនាថបិណ្ឌិកសេដ្ឋី និងស្ត្រីដទៃដែលតាំងនៅក្នុងភាពជាមាតុគ្រាម ដូចជានាងវិសាខាមហាឧបាសិកា ដែលបរិច្ចាគទ្រព្យឧទ្ទិសព្រះតថាគត រមែងមិនមាន ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់គង់ ២ កន្លែង ក្នុងមួយថ្ងៃ ដើម្បីអនុគ្រោះដល់ត្រកូលទាំងនោះ ។ ក្នុងថ្ងៃនោះ ទ្រង់ប្រថាប់នៅក្នុងវត្តជេតពន ។ ព្រោះដូច្នោះ ព្រះថេរៈទើប

គិតថា ថ្ងៃនេះ ព្រះមានព្រះភាគជាម្ចាស់ ស្ដេចនិមន្តបិណ្ឌបាតក្នុងក្រុងសាវត្ថី , ក្នុងវេលារសៀល ស្ដេចយាងទៅកាន់ខ្លោងទ្វារទិសខាងកើត ដើម្បីទ្រង់នឹងស្រង់ទឹក កាលបើដូច្នេះ យើងទូលអារាធនាព្រះមានព្រះ-ភាគជាម្ចាស់ ដែលប្រថាប់ឈរស្រង់ទឹកហើយ ទៅកាន់អាស្រមរបស់រម្មកព្រាហ្មណ៍ កាលបើដូច្នេះ ភិក្ខុទាំងនេះ នឹងបានស្ដាប់ធម្មីកថាចំពោះព្រះភ័ក្ត្រព្រះមានព្រះភាគជាម្ចាស់ យ៉ាងនេះហើយ ទើបបានពោលជាមួយភិក្ខុទាំងនោះយ៉ាងនេះ ។ បទថា **មិគារមាតុបាសាទោ** បានដល់ ប្រាសាទនាងវិសាខាឧបាសិកា ។ ពិតហើយ នាងវិសាខានោះ លោកហៅថា មិគារមាតា ព្រោះមិគារសេដ្ឋីស្ថាបនាទុកក្នុងឋានៈជាមាតា ។ បទថា **បដិ-សល្លានា វុដ្ឋិតោ** សេចក្ដីថា ក្នុងប្រាសាទនោះ មានបន្ទប់ដ៏មានសិរីសម្រាប់ព្រះមានព្រះភាគជាម្ចាស់ , ត្រង់កណ្ដាលបន្ទប់ដ៏មានសិរី គឺ សម្រាប់ព្រះមហាសាវ័កទាំងពីរ ។ ព្រះថេរៈបើកទ្វារ បោសខាងក្នុងបន្ទប់នាំយកផ្កាដែលជ្រុះចេញ ចាត់ចែងគ្រែ និងតាំងហើយ បានថ្វាយសញ្ញាដល់ព្រះសាស្ដា ។ ព្រះសាស្ដា ស្ដេចយាងចូលបន្ទប់ដ៏មានសិរី មានសតិសម្ប-ជញ្ញៈ ទ្រង់ផ្ទុំលើសីហសេយ្យាសនៈ ដោយផ្អៀងកាយទៅខាងស្ដាំ ទ្រង់រំងាប់ការក្រវល់ក្រវាយ ក្រោកឡើង ប្រថាប់គង់ចូលសមាបត្តិ ចេញពី

ផលសមាបត្តិក្នុងវេលារសៀល ។ លោកសំដៅយកពាក្យនោះ ទើបពោលថា **បដិសល្លានា វុដ្ឋិតោ** ។ បទថា **បរិសិញ្ចិតុំ** សេចក្តីថា ក៏អ្នកណាដុសខ្លួនដោយធូលីដីជាដើម ឬដុសខ្លួនដោយថ្មដុសជាដើម ទើបងូតទឹក អ្នកនោះហៅថា រមែងងូត ។ អ្នកណាមិនធ្វើយ៉ាងនោះ ងូតតាមប្រក្រតីនោះឯង អ្នកនោះលោកហៅថា រមែងស្រោច ។ ដែលឈ្មោះថាទឹកលាយដោយធូលី នឹងគប្បីនាំទៅដូច្នេះ មិនជាប់នៅក្នុងសរីរៈរបស់ព្រះតថាគត តែដើម្បីកាន់តាមរដូវកាល ព្រះមានព្រះភាគជាម្ចាស់ រមែងចុះស្រង់ទឹកតែម្យ៉ាង ។ ដោយហេតុនោះ ទើបលោកពោលថា **គត្តានិ បរិសិញ្ចិតុំ** ទ្រង់ស្រោចស្រពព្រះកាយ ។

បទថា **បុព្វកោដ្ឋកោ** ប្រែថា ខ្លោងទ្វារនៃទិសខាងកើត ។

បានឮមកថា ក្នុងក្រុងសាវត្ថី គ្រាខ្លះវិហារក៏ធំ គ្រាខ្លះក៏តូច ។ គ្រានោះឯង វិហារនោះ កាលព្រះមានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា **វិបស្សី** មានទំហំ ១ យោជន៍ , សម័យ **ព្រះសិខីព្រះពុទ្ធជាម្ចាស់** មានទំហំ ៣ គាវុត , សម័យ **ព្រះវេស្សភូព្រះពុទ្ធជាម្ចាស់** មានទំហំ ១ គាវុត , សម័យ **ព្រះកោនាគមនៈព្រះពុទ្ធជាម្ចាស់** មានទំហំកន្លះគាវុត , សម័យ **ព្រះកស្សបព្រះពុទ្ធជាម្ចាស់** មានទំហំ ២០ ឧសភៈ , សម័យ **ព្រះមាន-**

ព្រះភាគជាម្ចាស់របស់យើង ទាំងឡាយមានទំហំ ៨ ករីសៈ ។ សូម្បីនគរនោះ ជួនកាលក៏នៅទិសខាងកើតរបស់វិហារនោះ ជួនកាលក៏នៅទិសខាងត្បូង ជួនកាលក៏នៅទិសខាងលិច ជួនកាលក៏នៅទិសខាងជើង ។ ចំពោះព្រះគន្ធកុដិនៃជេតពនវិហារ ស្ថានទីប្រតិស្ឋានជើងគ្រែទាំង ៤ ក៏ស្ថិតនៅកន្លែងតែមួយ ។ ពិតហើយ ដែលឈ្មោះថា **ចេតិយស្ថានដែលមិនប្រែប្រួល** ៤ កន្លែង គឺ ៖

ស្ថានទីមហាពោធិបល្ល័ង្ក ១ , ស្ថានទីប្រកាសព្រះធម្មចក្កក្នុងព្រៃឥសិបតនៈ ១ , ស្ថានទីជាទីប្រតិស្ឋានជណ្ដើរក្នុងគ្រាដែលស្ដេចចុះចាកទេវលោកនៅសង្កស្សនគរ ១ , ស្ថានទីព្រះក្រឡាបន្ទំ ( បរិនិព្វាន ) ១ ។ ក៏ខ្លោងទ្វារខាងមុខនេះ ជាខ្លោងទ្វារទិសខាងកើត មានព្រះវិហារទំហំ ២០ ឧសភៈ របស់ព្រះសម្មាសម្ពុទ្ធកស្សបទសពល ។ សូម្បីឥឡូវនេះ វិហារនោះ ក៏នៅត្រង់កន្លែងខ្លោងទ្វារខាងមុខនោះឯង ។ ក្នុងសម័យព្រះសម្មាសម្ពុទ្ធកស្សបទសពល ស្ទឹងអចិរវតីហូរព័ទ្ធនគរ ដល់ខ្លោងទ្វារខាងមុខត្រូវទឹកច្រោះធ្វើឲ្យកើតស្រះទឹកធំ មានកំពង់ជ្រៅទៅតាមលំដាប់ ។ នៅទីនោះ មានកំពង់ទឹកគួរមនោរម្យ មានខ្សាច់ប្រៀបដូចជាផែនប្រាក់ ដេរដាសពាសពេញ បែកជាចំណែក ៗ យ៉ាងនេះគឺ ៖

-កំពង់ទឹកសម្រាប់ ព្រះរាជា ១

-សម្រាប់អ្នកនគរ ១

-សម្រាប់ភិក្ខុសង្ឃ ១

-សម្រាប់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ១ ដូច្នោះ

ព្រះមានព្រះភាគជាម្ចាស់ ជាមួយព្រះអានន្ទ ទើបស្តេចយាងចូលទៅកាន់ខ្លោងទ្វារខាងមុខនេះ ដែលតាំងនៅដើម្បីស្រង់ទឹក ស្រោចស្រពព្រះវរកាយ ។ គ្រានោះ ព្រះអានន្ទបង្អោនសំពត់ស្រង់ទឹកចូលទៅថ្វាយ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ផ្លាស់សំពត់ក្រហម ២ ជាន់ ទ្រង់ស្លៀកសំពត់ងូតទឹក ។ ព្រះថេរៈទទួលចីវរផ្ទាំងធំ និងសំពត់ ២ ជាន់ទុកក្នុងដៃរបស់ខ្លួន ។ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចុះស្រង់ទឹក ។ ហ្វូងត្រីនិងអណ្តើកក្នុងទឹក ក៏មានពណ៌ដូចមាសទាំងអស់ ព្រមជាមួយពេលដែលព្រះអង្គទ្រង់ចុះស្រង់ទឹក ក្នុងកាលនោះ ប្រៀបដូចជាយកត្រឡោកយន្តស្រោចទឹកមាស និងដូចជាពេលដែលលាតត្រដាងផែនមាស ។ កាលបើព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងធម្មទំនៀមការស្រង់ទឹក ទ្រង់ស្រង់ទឹកហើយ ព្រះថេរៈក៏បង្អោនសំពត់ផ្ទាំងក្រហម ២ ជាន់ថ្វាយ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ស្លៀកជណ្តប់សំពត់នោះ ទ្រង់ក្រវាត់វត្តព័ន្ធចង្កេះ

ប្រៀបដូចជាផ្នែកបន្ទោរ ទ្រង់ចាប់ចីវរជំត្រង់ជាយទាំងពីរ រួមជាយបង្អោន ចូលមកធ្វើឲ្យដូចជាត្របកផ្កាឈូក ប្រថាប់ឈរ ។ ដោយហេតុនោះ ទើបលោកពោលថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ស្រង់ទឹកត្រង់កន្លែង ទ្វារខាងមុខ ស្តេចឡើងប្រថាប់ឈរមានចីវរមួយផ្ទាំង ។ ក៏ព្រះសរីរៈ របស់ព្រះមានព្រះភាគជាម្ចាស់ ដែលប្រថាប់ឈរយ៉ាងនេះរុងរឿង ដូច ស្រះពោរពេញទៅដោយផ្កាឈូក និងឧប្បល ដែលកំពុងរីក ដូចដើម បារិច្ឆត្តកៈ ដែលមានផ្ការីកស្គុះស្គាយ និងដូចផ្ទៃមេឃដែលភ្លឺព្រិច ៗ ទៅ ដោយផ្កាយ និងពន្លឺព្រះអាទិត្យស្រទំ ដូចអំពាវនាវយកសិរីមង្គលដ៏ប្រសើរ លក្ខណៈដ៏ប្រសើរ ៣២ របស់ព្រះអង្គដែលស្រស់ល្អ ឡោមព័ទ្ធដោយ ព្រះរស្មីមួយព្យាម រុងរឿងយ៉ាងក្រៃលែង ដូចដួងព្រះច័ន្ទ ៣២ ដួង ដួងព្រះអាទិត្យ ៣២ ដួង ដែលក្រងទុក ដូចព្រះចៅចក្រពត្តិ ៣២ អង្គ ដូចទេវរាជ ៣២ អង្គ និងដូចមហាព្រហ្ម ៣២ អង្គ ដែលស្ថិតនៅតាម លំដាប់ ។ នេះឈ្មោះថា វណ្ណភូមិ គប្បីជ្រាបកម្លាំងរបស់ព្រះធម្មថិកក្នុង ឋានៈបែបនេះថា ធម្មថិកដែលអង់អាចគួរនឹងនាំសេចក្តីឧបមា និងហេតុ មកពោលសរសើរព្រះសរីរៈ និងព្រះគុណ របស់ព្រះពុទ្ធជាម្ចាស់ទាំង-ឡាយក្នុងឋានៈបែបនេះដោយចុណ្ណិយបទ ឬគាថាទាំងឡាយឲ្យបរិបូណ៌ ។

បទថា **គត្តានិ បុព្វាបយមានោ** សេចក្តីថា រង់ចាំភាពជាប្រក្រតីធ្វើ
ឲ្យព្រះកាយអស់ទឹក អធិប្បាយថា ធ្វើឲ្យស្ងួត ។ ពិតហើយ កាលណា
ព្រះមានព្រះភាគជាម្ចាស់ មានព្រះវរកាយសើមដោយទឹក ដណ្តប់ចីវរ ក៏
កើតជាផ្កា ។ បរិក្ខារក៏ខូច ។ តែទឹកដែលលាយដោយធូលី រមែងមិន
ជាប់ក្នុងព្រះសរីរៈរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទឹកក៏រអិលត្រឡប់
ទៅ ដូចដំណក់ទឹកដែលដក់លើស្លឹកឈូក ។ សូម្បីដូច្នេះ ព្រោះសេចក្តី
គោរពក្នុងសិក្ខា ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់ចាប់ចីវរផ្ទាំងធំទាំង
ពីរជ្រុង ដោយព្រះតម្រិះនេះថា ឈ្មោះថា ធម្មទំនៀមរបស់បព្វជិត ប្រថាប់
ឈរបិទព្រះកាយខាងមុខ ។ ខណៈនោះ ព្រះថេរៈគិតថា ព្រះមានព្រះ-
ភាគជាម្ចាស់ ទ្រង់ដណ្តប់ចីវរធំ និងត្រឡប់ព្រះអង្គ ទ្រង់លំបាកតាំងពី
ការផ្តើមឆ្ពោះទៅមិគារមាតុប្រាសាទ ឈ្មោះថា ប្តូរពុទ្ធបំណង រមែងធ្ងន់
ដូចលាដៃចាប់រាជសីហ៍ ដែលដើរម្នាក់ឯង ដូចចាប់ប្រមោយដំរីចុះប្រេង
ឬដូចចាប់ក-អសិរពិស ដែលកំពុងបើកពពារ ទើបពណ៌នាគុណអាស្រម
របស់រម្មកព្រាហ្មណ៍ ហើយទូលអង្វរព្រះមានព្រះភាគជាម្ចាស់ ដើម្បីបាន
ស្តេចយាងទៅក្នុងទីនោះ ។ ព្រះថេរៈធ្វើយ៉ាងនោះ ។ ព្រោះហេតុនោះ
ទើបលោកពោលថា **អថខោ អាយស្មា អានន្ទោ ។បេ។ អនុកម្បំ ឧបា-**

**ទាយ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **អនុកម្បំ ឧបាទាយ** បានដល់ អាស្រ័យសេចក្ដីអនុគ្រោះភិក្ខុ ៥០០ អង្គ ដែលទៅកាន់អាស្រមនោះ ដោយតាំងចិត្តស្ដាប់ធម្មីកថាចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគជាម្ចាស់ អធិប្បាយថា ធ្វើសេចក្ដីករុណាក្នុងភិក្ខុទាំងឡាយ ។ បទថា **ធម្មិយា កថាយ** សេចក្ដីថា អង្គុយប្រជុំគ្នាសរសើរព្រះបារមី ១០ ប្រការ ណាមួយ និងមហាភិនេស្ក្រមណ៍ ។ បទថា **អាគយមានោ** បានដល់ ងើយមើល អធិប្បាយថា មិនប្រញាប់ប្រញាល់ ស្ដេចចូលទៅដោយការប្រកាន់អង្គថា តថាគត ជាព្រះពុទ្ធប្រថាប់ឈររហូតដល់គេនិយាយគ្នាចប់ ។

(៥១) បទថា **អគ្គឡំ អាកោដេសិ** បានដល់ គោះទ្វារ ។ បទថា **វិវរឹសុ** សេចក្ដីថា ក្នុងពេលនោះឯង ភិក្ខុទាំងឡាយក៏មកបើកទ្វារ ព្រោះអង្គុយរង់ចាំដើម្បី ស្ដាប់ ។ បទថា **បញ្ញត្តេ អាសនេ** សេចក្ដីថា បានឮថា សម័យពុទ្ធកាល ភិក្ខុសូម្បីមួយអង្គនៅក្នុងទីណា ៗ ក៏ចាត់ចែងពុទ្ធាសនៈ ទុកក្នុងទីនោះ ៗ ទាំងអស់ ។

ព្រោះហេតុអ្វី ? ។ គេថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់យកព្រះហឫទ័យទុកដាក់ដល់ភិក្ខុ ដែលរៀនកម្មដ្ឋានក្នុងសំណាក់របស់ព្រះអង្គ ហើយនៅក្នុងទីសប្បាយ ភិក្ខុអង្គនោះ ទទួលកម្មដ្ឋានក្នុងសម្នាក់របស់

តថាគតហើយ អាចធ្វើគុណវិសេសឲ្យកើតឡើង ឬមិនទេហ្ន៎ ។ លំដាប់នោះ ទ្រង់ឃើញភិក្ខុនោះលះបង់កម្មដ្ឋាន កំពុងត្រិះរិះក្នុងអកុសលវិតក្កៈ ពេលនោះ ក៏ទ្រង់ត្រិះរិះគិតថា យ៉ាងណាទៅអកុសលវិតក្កៈទាំងឡាយ ទើបគ្របសង្កត់កុលបុត្តនេះ ដែលរៀនកម្មដ្ឋានក្នុងសម្នាក់នៃព្រះសាស្តាដូចយើង ឲ្យលិចចុះក្នុងវដ្តទុក្ខដែលដឹងមិនបាន ទើបទ្រង់សម្តែងព្រះអង្គក្នុងទីនោះ ៗ ឯង ដើម្បីអនុគ្រោះកុលបុត្តនោះ ទ្រង់ទូន្មានកុលបុត្តនោះហើយ ស្តេចហោះត្រឡប់ទៅកាន់កន្លែងប្រថាប់របស់ព្រះអង្គ ។ លំដាប់នោះ ភិក្ខុទាំងឡាយបានទទួលឱវាទយ៉ាងនេះ ទើបគិតថា ព្រះសាស្តាទ្រង់ជ្រាបចិត្តរបស់ពួកយើង ទើបស្តេចមកសម្តែងព្រះអង្គប្រថាប់ឈរនៅជិតៗពួកយើង ក្នុងខណៈនោះ ឈ្មោះថា ការស្វែងរកអាសនៈ ជាការៈដោយប្រការទូលថា បពិត្រព្រះអង្គដ៏ចម្រើន មេត្តាប្រថាប់គង់ក្នុងទីនោះ ប្រោសប្រថាប់គង់កន្លែងនេះ ទើបចាត់ចែងអាសនៈទុក ។ ភិក្ខុណាមានតាំង ភិក្ខុនោះក៏ចាត់តាំង ភិក្ខុណាមិនមាន ភិក្ខុនោះ ក៏រៀបគ្រែ ឬបន្ទះក្តារឈើ ថ្មឬគំនរខ្សាច់ ។ កាលមិនមាន ក៏យកស្លឹកឈើចាស់ ៗ មកក្រាលធ្វើជាគំនរទុកក្នុងទីនោះ ។ តែរឿងនេះ មានអាសនៈដែលចាត់ទុកតាមធម្មតាទាំងអស់ ។ លោកសំដៅយកអាសនៈនោះ ទើបពោលថា **បញ្ញត្តេ អាសនេ**

**និសីទិ** យ៉ាងនេះ ។ បទថា **កាយនុត្ត** សេចក្តីថា លោកទាំងឡាយ អង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ ។ បាលីថា **កាយនេត្ថ** ដូច្នោះ ក៏បាន ក៏មានខ្លឹមសារថា ពួកលោកអង្គុយប្រជុំគ្នាក្នុងទីនេះដោយរឿងអ្វីហ្ន៎ ។ បាលីថា **កាយនោត្ថ** យ៉ាងនេះក៏មាន បាលីនោះ ក៏មានខ្លឹមសារដូចសេចក្តីដើមដូចគ្នា ។ បទថា **អន្តរា កថា** បានដល់ រឿងដទៃមយ៉ាង ចន្លោះការធ្វើទុកក្នុងចិត្តដល់ការរៀន ការសាកសួរកម្មដ្ឋានជាដើម ។ បទថា **វិប្ប-កតា** បានដល់ នៅមិនទាន់ចប់ គឺ នៅមិនទាន់ដល់ទីបំផុត ព្រោះការមករបស់យើងជាបច្ច័យ ។ បទថា **អថ ភគវា អនុប្បត្តោ** សេចក្តីថា គ្រានោះ គឺ កាលនោះ ព្រះមានព្រះភាគជាម្ចាស់ ស្តេចយាងមក ។ បទថា **ធម្មីកថា វា** បានដល់ ឬធម្មីកថាដែលអាស្រ័យកថាវត្ថុ ១០ ។ ក៏ពាក្យថា **អរិយោ វា តុណ្ហីភាវោ** នេះ ទាំងទុតិយជ្ឈាន ទាំងមូលកម្មដ្ឋាន គប្បីជ្រាបថា អរិយតុណ្ហីភាព ព្រោះដូច្នេះ ភិក្ខុអង្គុយចូលឈាននោះក្តី អង្គុយកំណត់មូលកម្មដ្ឋានជាអារម្មណ៍ក្តី គប្បីជ្រាបថា អង្គុយដោយអរិយតុ-ណ្ហីភាព ។ ពាក្យថា **ទ្វេមា ភិក្ខវេ បរិយេសនា** មានអនុសន្ធិជាមួយគ្នា ។ ភិក្ខុទាំងនោះបានធ្វើឲ្យជាការៈរបស់ព្រះថេរៈ ដោយតាំងចិត្តស្តាប់ធម្មីកថាចំពោះព្រះភក្ត្រ ។ ព្រះថេរៈបានឆ្ពោះទៅកាន់អាស្រមរបស់ភិក្ខុទាំងនោះ ។

ភិក្ខុទាំងនោះអង្គុយក្នុងទីនោះ មិនមែនសន្ទនាដោយរឿងតិរច្ឆានកថា គឺថា អង្គុយសន្ទនាគ្នា ក្នុងរឿងធម្មៈ ។ គ្រានោះព្រះមានព្រះភាគជាម្ចាស់ ទ្រង់ផ្ដើមទេសនានេះ ដើម្បីសម្ដែងថា ការស្វែងរករបស់ពួកអ្នក នេះឈ្មោះថា **អរិយបរិយេសនា** ។

(៥២) បណ្ដាបទទាំងនោះក្នុងបទថា **កតមា ច ភិក្ខវេ អនរិយា បរិយេសនា** នេះ សេចក្ដីថា បុរសដែលច្លាតក្នុងផ្លូវ កាលសម្ដែងផ្លូវដែលគួរវៀរមុន ទើបពោលថា ចូរលះបង់ផ្លូវឆ្វេង កាន់យកផ្លូវស្ដាំ យ៉ាងណាមិញ ព្រះមានព្រះភាគជាម្ចាស់ក៏ដូច្នេះ ព្រោះព្រះអង្គជាបុគ្គលដែលច្លាតក្នុងទេសនា ទើបទ្រង់ប្រាប់ ការស្វែងរកដែលមិនមែនជាអរិយៈ ឲ្យលះបង់មុន ជាខាងក្រោយ ទើបចែកលំដាប់ឧទ្ទេសទុកថា តថាគតនឹងប្រាប់ការស្វែងរកក្រៅពីនេះ ដូច្នេះហើយទើបត្រាស់យ៉ាងនេះ ។

បទថា **ជាតិធម្មោ** ប្រែថា មានការកើតជាសភាវៈ ។

បទថា **ជរាធម្មោ** ប្រែថា មានសភាពចាស់ជាសភាវៈ ។

បទថា **ព្យាធិធម្មោ** ប្រែថា មានសេចក្ដីឈឺជាសភាវៈ ។

បទថា **មរណធម្មោ** ប្រែថា មានសេចក្ដីស្លាប់ជាសភាវៈ ។

បទថា **សោកធម្មោ** ប្រែថា មានសេចក្ដីសោកជាសភាវៈ ។

បទថា **សង្កិលេសធម្មោ** ប្រែថា មានសេចក្តីសៅហ្មងជាសភាវៈ ។

បទថា **បុត្តភរិយំ** បានដល់ បុត្ត និង ភរិយា ។

ក្នុងបទទាំងពួងក៏មានន័យដូច្នេះ ។ ក៏ក្នុងពាក្យថា **ជាតរូបរជតំ**[១] នេះ **ជាតរូបំ** បានដល់ មាស ។ **រជតំ** បានដល់ មាសកលោហៈជាដើមណាមួយ ដែលគេសន្មតគ្នា ។ ដោយបទថា **ជាតិធម្មា ហេតេ ភិក្ខវេ ឧបធយោ** ទ្រង់សម្តែងថា កាមគុណ ៥ នោះ ឈ្មោះ **ឧបធិ** ឧបធិទាំងអស់នោះ មានការកើតជាធម្មៈ ។ មាស និងប្រាក់ លោកមិនបានកាន់យកក្នុងព្យាធិធម្មវារៈជាដើម ព្រោះមាស និងប្រាក់នោះ មិនមានព្យាធិមានរោគឈឺក្បាលជាដើម មិនមានមរណៈ ពោលគឺ ចុតិដូចសត្វទាំងឡាយ មិនកើតសេចក្តីសោក តែរមែងសៅហ្មងដោយសង្កិលេស មានជាជាដើម ព្រោះដូច្នោះ ទើបលោកកាន់យកក្នុងសង្កិលេសិកធម្មវារៈ ទាំងកាន់យកក្នុងជាតិធម្មវារៈដែរ ព្រោះមានរជូវជាសមុដ្ឋាន ទាំងកាន់យកក្នុងជរាធម្មវារៈដែរ ព្រោះស្នឹមចាប់ ទើបគ្រាំគ្រា ។

(៥៣) បទថា **អយំ ភិក្ខវេ អរិយបរិយេសនា** សេចក្តីថា ម្នាលភិក្ខុ

---

[១] ពាក្យថា **ជាតរូបរជតំ** ក្នុងបិដកខ្មែរសរសេរថា **ជាតរូបរជតំ** ។

ទាំងឡាយ ការស្វែងរកនេះ គប្បីជ្រាបថា ការស្វែងរករបស់ព្រះអរិយៈ ព្រោះមិនមានទោសក្នុងខ្លួនឯងខ្លះ ព្រោះព្រះអរិយៈគប្បីស្វែងរកខ្លះ ។

(៩៤) សួរថា ព្រោះហេតុអ្វី ទើបផ្តើមពាក្យថា **អហម្បិ សុទំ ភិក្ខវេ** ។

ឆ្លើយថា ដើម្បីសម្តែង កាលស្តេចចេញមហាភិនេស្ក្រមណ៍តាំងពីដើមដំបូង ។

បានឮថា ព្រះអង្គមានព្រះតម្រិះយ៉ាងនេះថា ភិក្ខុទាំងឡាយអំពីមុន ក៏តថាគតស្វះស្វែងរករបស់ដែលមិនមែនជាការស្វែងរក របស់ព្រះអរិយៈ តថាគតនោះ លះបង់ការស្វែងរកដែលមិនមែនអរិយៈ ហើយស្វែងរករបស់ដែលជាអរិយៈ ទើបសម្រេចសព្វញ្ញុតញ្ញាណ សូម្បីព្រះបញ្ចវគ្គីយ៍ ក៏ស្វែងរបស់ដែលមិនមែនជាអរិយៈ ពួកលោកបានលះបង់របស់ដែលមិនមែនអរិយៈនោះ ស្វែងរករបស់ដែលជាអរិយៈ សម្រេចខីណាសវភូមិ សូម្បីពួកអ្នកក៏ធ្វើដំណើរតាមផ្លូវនេះ តថាគត និងព្រះបញ្ចវគ្គីយ៍ ការស្វែងរកដែលជាអរិយៈ ទើបចាត់ជាការស្វែងរករបស់ពួកអ្នក ព្រោះដូច្នោះ ដើម្បីទ្រង់សម្តែងការចេញមហាភិនេស្ក្រមណ៍របស់ព្រះអង្គតាំងអំពីដើមមក ។

(៩៥) បណ្តាបទទាំងនោះ បទថា **ទហរោវ សមានោ** ប្រែថា កំពុងនៅ

កំលោះ ។ បទថា **សុសុកាឡកេសោ** បានដល់ សក់ខ្មៅរលើប អធិប្បាយថា មានសក់ពណ៌ដូចជាផ្កាអញ្ចន ។ បទថា **ភទ្រេន** ប្រែថា ស្អាត , បទថា **បឋមេន វយសា** បានដល់ តាំងនៅដោយបឋមវ័យ ក្នុងបណ្តាវ័យទាំង ៣ ។ បទថា **អកាមកានំ** បានដល់ កាលមិនប្រាថ្នា ។ បទថា **អកាមកានំ** នេះ ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃអនាទរ ឈ្មោះថា **អស្សុមុខា** ព្រោះមានទឹកព្រះនេត្រហូរជោកព្រះភក្ត្រនៃព្រះមាតា និងបិតា ដែលមានព្រះភក្ត្រជោកដោយទឹកព្រះនេត្រ អធិប្បាយថា អ្នកមានព្រះភក្ត្រជោកដោយទឹកព្រះនេត្រ ។ បទថា **រុទន្តានំ** បានដល់ យំរៀបរាប់ ។ បទថា **កឹកុសលំ គវេសី** បានដល់ ស្វែងរកកុសលអ្វី ។ បទថា **អនុត្តរំ សន្តិវរបទំ** សេចក្តីថា ស្វែងរកបទដ៏ប្រសើរ ពោលគឺ សេចក្តីស្ងប់ដ៏ខ្ពស់បំផុត បានដល់ ព្រះនិព្វាន ។ បទថា **អាឡារោ** ក្នុងពាក្យថា **យេន អាឡារោ** នេះ ជាឈ្មោះរបស់តាបសនោះ ។ បានឮថា តាបសនោះឈ្មោះថា **ទីឃបិង្គល** ។ ដោយហេតុនោះ តាបសនោះ ទើបមាននាមថា **អាឡារ** ។ បទថា **កាលាមោ** ជាគោត្រ ។ បទថា **វិហារតាយស្មា** ប្រែថា សូមលោកដ៏មានអាយុនិមន្តនៅសិន ។ បទថា **យត្ថ វិញ្ញូបុរិសោ** បានដល់ បុរសដែលជាបណ្ឌិតក្នុងធម៌ណា ។ បទថា **សកំ អាចរិយកំ** បាន

ដល់ លទ្ធិអាចារ្យរបស់ខ្លួន ។ បទថា **ឧបសម្បជ្ជ វិហរេយ្យ** បានដល់ គប្បីចូលដល់ដោយហេតុប៉ុណ្ណោះ ជាការដែលគេបានធ្វើឱកាសហើយ ។ បទថា **តំ ធម្មំ** បានដល់ បែបផែនលទ្ធិរបស់គេទាំងនោះ ។ បទថា **បរិយាបុណឹ** បានដល់ លុះបានស្តាប់ហើយរៀនយក ។ បទថា **ឱដ្ឋបហតមត្តេន** សេចក្តីថា ដោយហេតុត្រឹមតែហាមាត់ដើម្បីទទួលពាក្យ ដែលគេពោលអធិប្បាយថា ត្រឹមតែចរចាប្រាស្រ័យ ទៅវិញទៅមក ។ បទថា **លបិតលាបនមត្តេន** បានដល់ ដោយហេតុត្រឹមតែកាន់យកពាក្យសម្តីដែលគេរអ៊ូរទាំ ។ បទថា **ញាណវាទំ** បានដល់ វាទៈថា យើងនឹងដឹងច្បាស់ ។ បទថា **ថេរវាទំ** បានដល់ វាទៈថារឹងមាំ ។ ពាក្យនេះ សំដៅសេចក្តីថា ខ្ញុំម្ចាស់ជាអ្នករឹងមាំក្នុងសេចក្តីនេះ បទថា **អហញ្ចេវ អញ្ញេ ច** សេចក្តីថា មិនមែនមានតែយើងដែលពោលម្នាក់ប៉ុណ្ណោះ សូម្បីអ្នកដទៃជាច្រើនក៏ពោលយ៉ាងនេះ ។ បទថា **កេវលំ សទ្ធា មត្តកេន** សេចក្តីថា ដោយហេតុត្រឹមតែសទ្ធាដ៏បរិសុទ្ធប៉ុណ្ណោះ មិនមែនធ្វើឲ្យដឹងច្បាស់ដោយបញ្ញា ។ បានឮថា ព្រះពោធិសត្វរៀនធម៌ដោយវាចាប៉ុណ្ណោះ បានដឹងថា ព្រះកាលាម បានត្រឹមតែបរិយត្តិដោយវាចាត្រឹមតែធម៌នេះក៏ទេ លោកបានសមាបត្តិ ៧ យ៉ាងពិតប្រាកដ ដោយហេតុនោះ លោកទើបមានការ

គិតយ៉ាងនេះ ។ បទថា **អកិញ្ចញ្ញាយតនំ បវេទេសិ** សេចក្តីថា បានឲ្យយើងដឹងសមាបត្តិ ៧ ដែលមានអកិញ្ចញ្ញាយតនសមាបត្តិជាទីបំផុត ។ បទថា **សទ្ធា** បានដល់ សទ្ធាដើម្បីឲ្យកើតសមាបត្តិទាំង ៧ នេះ ។ សូម្បីក្នុងសេចក្តីព្យាយាមជាដើម ក៏ន័យនេះដូចគ្នា ។ បទថា **បទហេយ្យំ** បានដល់ គប្បីធ្វើសេចក្តីព្យាយាម ។ បទថា **ន ចិរស្សេវ ខិប្បមេវ តំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសឹ** [១] បានដល់ ន័យថា ព្រះពោធិសត្វទ្រង់បំពេញសេចក្តីព្យាយាម ធ្វើសមាបត្តិ ៧ ឲ្យកើតឡើងត្រឹមតែវេលា ២-៣ ថ្ងៃប៉ុណ្ណោះ ដូចទាញវាំងននមាស ៧ ជាន់ចេញ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ ។

បទថា **លាភា នោ អាវុសោ** សេចក្តីថា បានឮថា លោកកាលាមៈ នេះ ជាមនុស្សមិនប្រណែន មិនឫស្យា ព្រោះដូច្នោះ លោកគិតថា អ្នកនេះមកធ្វើអ្វី ធ្វើធម៌នេះឲ្យកើតបានយ៉ាងនេះហើយ ក៏មិនឫស្យា ត្រឡប់ជាជ្រះថ្លា កាលនឹងប្រកាសសេចក្តីជ្រះថ្លា ទើបពោលយ៉ាងនេះ ។ បទថា

១ បទថា ន ចិរស្សេវ ខិប្បមេវ តំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសឹ ពាក្យនេះមាននៅក្នុងព្រះត្រៃបិដកខ្មែរ តែក្នុងអដ្ឋកថាថៃសរសេរថា ន ចិរស្សេវ តំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសឹ សម្រេចយកតាមបិដកខ្មែរ ។

**ឧភោ វសន្តា ឥមំ គណំ បរិហរាម** សេចក្តីថា លោកពោលថា គណៈនេះ ជាគណៈធំ យើងទាំង ២ នាក់ ជួយគ្នារក្សាចុះ ហើយបានឲ្យសញ្ញាដល់គណៈ ។ លោកពោលថា សូម្បីយើងក៏បានសមាបត្តិ ៧ ព្រះមហាបុរសក៏បានសមាបត្តិ ៧ ដូចគ្នា មនុស្សមួយចំនួនប៉ុណ្ណោះ រៀនបរិកម្មក្នុងសម្នាក់របស់យើង ដូច្នេះហើយ បានបែងចែកគណៈឲ្យពាក់កណ្តាល ។ បទថា **ឧឡារាយ** ប្រែថា ខ្ពស់បំផុត ។ បទថា **បូជាយ** បានដល់ គេថាទាំងស្រីទាំងប្រុស ដែលជាឧបដ្ឋាករបស់តាបសកាលាមៈ កាន់យករបស់ក្រអូប និងផ្កាឈើជាដើមមក ។ តាបសកាលាមៈប្រាប់ថា អ្នកទាំងឡាយចូរទៅបូជាព្រះមហាបុរសចុះ ។ មនុស្សទាំងនោះ បូជាព្រះមហាបុរសហើយ បូជាតាបសកាលាមៈដោយរបស់ដ៏សេស ។ មនុស្សទាំងឡាយនាំយកគ្រែ តាំងជាដើម ដែលមានតម្លៃច្រើនឲ្យដល់ព្រះមហាបុរស បើមានសល់ ខ្លួនឯងទើបទទួល ។ ក្នុងទីដែលទៅជាមួយគ្នា តាបសកាលាមៈ បង្គាប់ឲ្យរៀបចំសេនាសនៈយ៉ាងល្អដល់ព្រះពោធិសត្វ ខ្លួនឯងទទួលចំណែកដ៏សេស ។ ក្នុងពាក្យថា **នាយំ ធម្មោនិព្វិទាយ** ជាដើម សេចក្តីថា ធម៌ គឺ សមាបត្តិ ៧ នេះ មិនប្រព្រឹត្តទៅដើម្បីនឿយណាយក្នុងវដ្តៈ មិនប្រព្រឹត្តទៅដើម្បីលះបង់សេចក្តីត្រេកអរ មិនប្រព្រឹត្តទៅដើម្បី

*វិលត់រាគៈជាដើម មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ មិនប្រព្រឹត្តទៅដើម្បីការដឹងក្រៃលែងនូវធម៌ដែលគួរដឹងក្រៃលែង មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹងសច្ចៈ ៤ មិនប្រព្រឹត្តទៅធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ បទថា* ***យាវទេវ អាកិញ្ចញ្ញាយតនូបបត្តិយា*** *សេចក្តីថា ប្រព្រឹត្តទៅត្រឹមតែកើតក្នុងអាកិញ្ចញ្ញាយតនភព ដែលមានអាយុប្រមាណ ៦០.០០០ កប្ប ( ប្រាំមួយម៉ឺនកប្ប ) មិនខ្ពស់ជាងនោះ ធម៌នេះ ជាធម៌វិលមកទៀតទាំងឲ្យដល់ឋានៈឯណា ឋានៈនោះក៏មិនផុតអំពីជាតិ ជរា មរណៈបានឡើយ ត្រូវឡោមព័ទ្ធទុកដោយអន្ទាក់មច្ចុរាជទាំងអស់ ។ ក៏ឯបុរសអត់ឃ្លាន បានភោជនដែលគួរពេញចិត្ត បរិភោគឆ្អែតឆ្អន់សប្បាយរីករាយហើយបោះបង់ដោយអំណាចទឹកប្រមាត់ខ្លះ ស្លេស្មខ្លះ ដោយវង្វេងភ្លេចទៅខ្លះ មិនបានគិតថា យើងនឹងបរិភោគជុំបាយជាមួយគ្នាទៀត យ៉ាងណាមិញតាំងពីនោះមក ព្រះមហាសត្វក៏ដូច្នោះដូចគ្នា សូម្បីធ្វើសមាបត្តិ ៧ ឲ្យកើតដោយឧស្សាហៈយ៉ាងខ្លាំង ឃើញទោសផ្សេង ៗ ដោយការវិលមកជាដើមនេះ ក្នុងសមាបត្តិទាំងនោះ មិនបានកើតចិត្តគិតថា យើងនឹងគិត ឬនឹងចូល នឹងតាំងនៅ នឹងចេញ ឬនឹងពិចារណាធម៌នោះទៀត ។ បទថា* ***អនលង្ករិត្វា*** *បានដល់ មិនគប្បីពេញចិត្តរឿយ ៗ ថា នឹងល្មមអ្វីដោយ*

របស់នេះ នឹងពេញចិត្តអ្វី ដោយរបស់នេះ ។ បទថា **និព្វិជ្ជ** ប្រែថា នឿយណាយ ។ បទថា **អបក្កមី** ប្រែថា ដោះចេញហើយ ។

(៥៦) បទថា **ន ខោ ភមោ ឥមំ ធម្មំ** សេចក្តីថា ព្រះពោធិសត្វរៀនធម៌សូម្បីក្នុងទីនេះ ដឹងទូទៅថា ធម៌ គឺ សមាបត្តិ ៨ នេះ ជាធម៌ ដែលឧទកតាបសរាមបុត្តតាំងទុក រៀនត្រឹមតែដោយវាចាប៉ុណ្ណោះ តែដែលពិតឧទកតាបសរាមបុត្តជាអ្នកបានសមាបត្តិ ៨ ដោយហេតុនោះ ព្រះពោធិសត្វទើបគិតយ៉ាងនេះថា **ន ខោ ភមោ ។បេ។ ជានំ បសុរំ វិហាសិ** ។ ពាក្យដ៏សេសក្នុងសេចក្តីនេះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងវារៈខាងដើមនោះឯង ។

(៥៧) ខេត្តធំ អធិប្បាយថា គំនរខ្សាច់ធំ ឈ្មោះថា **ឧរុវេលា** ក្នុងពាក្យថា **យេន ឧរុវេលា សេនានិគមោ** នេះ ។ ន័យមួយទៀត ខ្សាច់លោកហៅថា **ឧរុ** ព្រំដែន ហៅថា **វេលា** ។ គប្បីជ្រាបពាក្យនេះ យ៉ាងនេះថា ខ្សាច់ដែលគេនាំយកមកកន្ទងព្រំដែន ឈ្មោះថា **ឧរុវេលា** ។

ដូចបានស្តាប់មកក្នុងអតីតកាល គ្រាដែលព្រះសម្ពុទ្ធជាម្ចាស់មិនទាន់ឧប្បត្តិ កុលបុត្តប្រមាណ ១០ ពាន់នាក់ បួសជាតាបសនៅក្នុងប្រទេសនោះ ថ្ងៃមួយប្រជុំគ្នា តាំងកតិកាគ្នាទុកថា ដែលឈ្មោះថា កាយកម្ម និង

វចីកម្ម ប្រាកដដល់ជនទាំងឡាយពួកដទៃ ចំណែកមនោកម្មមិនប្រាកដ ព្រោះដូច្នោះ អ្នកណាត្រិះរិះដល់កាមវិតក្កៈ ព្យាបាទវិតក្កៈ ឬវិហិង្សា-វិតក្កៈ អ្នកដទៃដែលនឹងដាស់តឿននោះមិនមាន អ្នកនោះចូរដាស់តឿនខ្លួនដោយខ្លួនឯង ត្រូវយកកាជនៈដាក់ខ្សាច់ឲ្យពេញ នាំមកគរទុកក្នុងទីនេះ នេះជាការដាក់ទោសអ្នកនោះ ។ តាំងពីនោះមក អ្នកណាត្រិះរិះវិតក្កៈ ដូច្នោះ អ្នកនោះត្រូវយកកាជនៈដាក់ខ្សាច់នាំមកទុកក្នុងទីនេះ គំនរខ្សាច់ធំកើតឡើង ដោយលំដាប់ក្នុងទីនោះ ដោយប្រការដូច្នេះ តពីនោះ អ្នកដែលកើតមកក្នុងជំនាន់ក្រោយ ទើបហ៊ុំព័ទ្ធគំនរខ្សាច់ធំនោះ ទុកធ្វើជាចេតិយដ្ឋាន លោកសំដៅយកគំនរខ្សាច់ធំនោះ ទើបពោលថា **ឧរុវេលាតិ ។បេ។ អត្ថោ ទដ្ឋព្វោ** ។

បទថា **សេនានិគមោ** ប្រែថា និគមរបស់សេនា ។ និទានថា ពួកជនក្នុងសម័យបឋមកប្ប មានការសម្រាកកងទ័ពនៅក្នុងទីនោះ ព្រោះដូច្នោះ ទីនោះទើបហៅថា សេនានិគមក៏មាន ។ បាឋៈថា **សេនានិគាមោ** ក៏បាន ។ អធិប្បាយថា បិតារបស់នាងសុជាតា ឈ្មោះថា **សេនានិ** ស្រុករបស់នាយសេនានិនោះ ។ បទថា **តទវសរឹ** ប្រែថា រួមចុះក្នុងទីនោះ ។ បទថា **រមណីយំ ភូមិភាគំ** បានដល់ ភូមិភាគដែលគួររីករាយ ដែលស្រស់

ល្អដោយផ្កាឈើក្នុងទឹក និងលើ គោក មានប្រការផ្សេងៗ រីកស្គុសស្គាយ ។ បទថា **បាសាទិកំ វនសណ្ឌំ** សេចក្តីថា បានឃើញដងព្រៃដែលឲ្យកើតសេចក្តីជ្រះថ្លា ដូចក្បាច់នៃកន្ទុយសត្វក្ងោក ។ បទថា **នទិញ្ច សន្ទន្តឹ** សេចក្តីថា បានឃើញស្ទឹងនេរញ្ជរាមានទឹកថ្លាពណ៌ខៀវ ត្រជាក់ដូចគំនរកែវមណី កំពុងហូរមិនដាច់ ។ បទថា **សេតកំ** បានដល់ ស្អាត ប្រាសចាកភក់ជ្រាំ ។ បទថា **សុបតិត្ថំ** បានដល់ ប្រកបដោយកំពង់ដ៏ល្អ រាក់ជ្រៅដោយលំដាប់ ។ បទថា **រមណីយំ** បានដល់ ទេសភាពគួរសប្បាយរីករាយ មានខ្សាច់ដែលគៀរទុកដូចផ្ទាំងប្រាក់ មានត្រី និងអណ្តើកច្រើន ។ បទថា **សមន្តា ច គោចរគាមំ** សេចក្តីថា បានឃើញគោចរគ្រាម ដែលរកភិក្ខាបានដោយងាយ សម្រាប់បព្វជិតដែលមកដល់ហើយ សម្បូរណ៍ទៅដោយគមនាគមន៍ក្នុងទីមិនឆ្ងាយ ដោយជុំវិញប្រទេសនោះ ។ បទថា **អលំ វតិទំ** [១] ប្រែថា អាចហ្ន៎ ។ បទថា **តត្ថេវ និសីទិ** លោកពោលយកប្រថាប់គង់លើពោធិបល្ល័ង្ក ។ ពិតណាស់ បទថា **តត្ថេវ** ក្នុងព្រះសូត្រមុនលោកបំណងយកស្ថានទីដែលទ្រង់បំពេញទុក្ករកិរិយា ចំណែកក្នុងព្រះសូត្រនេះ លោកសំដៅយកពោធិបល្ល័ង្ក ដោយហេតុនោះ លោកទើប

---

១ ពាក្យថា អលំ វតិទំ មានក្នុងបិដកខ្មែរ ក្នុងអដ្ឋកថាថៃសរសេរថា អលំ វត យកតាមបិដកខ្មែរ ។

ពោលថា **តត្ថេវ និសីទី** ដូច្នេះ ។ បទថា **អលមិទំ បធានាយ** សេចក្តីថា ប្រថាប់គង់ ទ្រង់ត្រិះរិះយ៉ាងនេះថា ទីនេះអាចធ្វើសេចក្តីព្យាយាមបាន ។

(៩៨) បទថា **អជ្ឈគមំ** បានដល់ សម្រេច គឺ បានចំពោះហើយនូវព្រះនិព្វាន ។ បទថា **ញាណញ្ច បន មេ ទស្សនំ** សេចក្តីថា ក៏ឯព្រះសព្វ-ញ្ញុតញ្ញាណ ដែលអាចឃើញធម៌ទាំងពួង កើតឡើងដល់យើង ។ បទថា **អកុប្បា មេ វិមុត្តិ** សេចក្តីថា វិមុត្តិ ដែលប្រកបដោយអរហត្តផលរបស់យើង ឈ្មោះថា **អកុប្ប** ព្រោះមិនកម្រើក និងព្រោះមានអកុប្បធម៌ជាអារម្មណ៍ វិមុត្តិនោះ មិនកម្រើកដោយរាគៈជាដើម ព្រោះដូច្នោះ ទើបឈ្មោះថា អកុប្បៈ សូម្បីមិនកម្រើកជាអកុប្បធម៌ ដែលមានព្រះនិព្វានជាអារម្មណ៍ ព្រោះដូច្នោះ ទើបឈ្មោះថា អកុប្បៈ សូម្បីមានអកុប្បធម៌ជាអារម្មណ៍ ។ បទថា **អយមន្តិមា ជាតិ** ប្រែថា នេះជាជាតិចុងក្រោយបង្អស់ ។ ដោយបទថា **នត្ថិទានិ បុនព្ភវោ** លោកសម្តែងថា សូម្បីបច្ចវេក្ខណញ្ញាណ ក៏កើតឡើងដល់យើងយ៉ាងនេះថា ឥឡូវនេះ យើងមិនមានបដិសន្ធិទៀតទេ ។

(៩៩) បទថា **អធិគតោ** ប្រែថា ចាក់ធ្លុះហើយ ។ បទថា **ធម្មោ** បានដល់ធម៌ គឺ សច្ចៈ ៤ ។ ពាក្យថា **គម្ភីរោ** នេះ ជាពាក្យបដិសេធសេចក្តីរាក់ ។ បទថា **ទុទ្ទសោ** បានដល់ ឈ្មោះថា ឃើញបានដោយលំបាក មិនអាច

ដឹងបានដោយងាយ ព្រោះជាធម៌ដែលជ្រាលជ្រៅ , ឈ្មោះថា ដឹងតាមបានលំបាក ដឹងបានដោយលំបាក មិនអាចដឹងបានដោយងាយ ព្រោះជាធម៌ដែលឃើញបានដោយលំបាក ។ បទថា **សន្តោ** បានដល់ រលត់ ។ បទថា **បណីតោ** បានដល់ មិនក្តៅអន្ទះអន្ទែង ។ ពាក្យទាំងពីរនេះ លោកពោលសំដៅយកលោកុត្តរធម៌ប៉ុណ្ណោះ ។ បទថា **អតក្កាវចរោ** បានដល់ ជាធម៌ដែលមិនគប្បីជាក់ច្បាស់ ស្ទាបស្ទង់ដោយសេចក្តីត្រិះរិះ គឺ ពិចារណាដោយញាណប៉ុណ្ណោះ ។ បទថា **និបុណោ** ប្រែថា ល្អិត ។ បទថា **បណ្ឌិត-វេទនីយោ** បានដល់ ដែលពួកបណ្ឌិតអ្នកបដិបត្តិសម្មាបដិបត្តិគប្បីដឹង ។

បទថា **អាលយរាមា** សេចក្តីថា សត្វទាំងឡាយ រមែងជាប់នឹងកាមគុណ ៥ ព្រោះដូច្នោះ កាមគុណ ៥ នោះ ឈ្មោះថា អាល័យ ។ សត្វទាំងឡាយរមែងជាប់នឹងតណ្ហាវិបរិត ១០៨ ព្រោះដូច្នោះ ទើបលោកហៅថា អាល័យ , សត្វទាំងឡាយ ឈ្មោះថា **អាលយរាមា** ព្រោះត្រេកអរដោយកាមគុណដែលជាទីអាល័យនោះ ។ ឈ្មោះថា **អាលយរតា** ព្រោះត្រេកអរក្នុងកាមគុណដែលជាទីអាល័យ ។ ឈ្មោះថា **អាលយ-សម្មុទិតា** ព្រោះត្រេកអរដោយល្អក្នុងកាមគុណដែលជាទីអាល័យ ។ មានយ៉ាងនេះថា ព្រះរាជាចូលទៅដល់ព្រះរាជឧទ្យាន ដែលសម្បូរដោយដើម

ឈើ ដែលពេញទៅដោយផ្កា និងផ្លែជាដើម ដែលចាត់ចែងទុកយ៉ាងល្អ ទ្រង់ត្រេកអរដោយសម្បត្តិនោះៗ ។ រមែងទ្រង់កម្សាន្តសប្បាយរីករាយមិនចេះឆ្អែត សូម្បីពេលរសៀល ហើយមិនប្រាថ្នានឹងចេញទៅ យ៉ាងណាសត្វទាំងឡាយរមែងត្រេកអរដោយអាល័យ គឺ កាម និងអាលយៈ គឺ តណ្ហាទាំងនេះ ក៏ដូច្នេះ រមែងរីករាយមិនចេះធុញនៅក្នុងសង្សារវដ្ត ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្តែងអាល័យ ២ យ៉ាង ដល់សត្វទាំងនោះឲ្យដូចឧទ្យានភូមិ ទើបត្រាស់ពាក្យជាអាទិ៍ថា **អាលយរាមា** ដូច្នេះ ។ បទថា **យទិទំ** ជានិបាត ។ សំដៅយកឋានៈនៃអាល័យនោះ គប្បីឃើញខ្លឹមសារយ៉ាងនេះថា **យំ ឥទំ** សំដៅយកបដិច្ច-សមុប្បាទ គប្បីឃើញខ្លឹមសារយ៉ាងនេះថា **យោ អយំ** យ៉ាងនេះ ។ បទថា **ឥទប្បច្ចយតាបដិច្ចសមុប្បាទោ** សេចក្តីថា បច្ច័យនៃធម៌ទាំងនេះ ឈ្មោះថា **ឥទប្បច្ចយា** ។ **ឥទប្បច្ចយា** នោះឯង ឈ្មោះថា **ឥទប្បច្ចយតា** , **ឥទប្បច្ចយតា** នោះផង **បដិច្ចសមុប្បាទ** នោះផង ដូច្នោះទើបឈ្មោះថា **ឥទប្បច្ចយាតាបដិច្ចសមុប្បាទ** ។ ពាក្យថា **ឥទប្បច្ចយតាបដិច្ចសមុប្បាទោ** នេះ ជាឈ្មោះរបស់បច្ច័យ មានសង្ខារជាដើម ។ បទថា **សព្វសង្ខារ-សមថោ** ជាដើម គ្រប់បទជាវេវចនៈរបស់ព្រះនិព្វាននោះ ។ ក៏ព្រោះហេតុ

សេចក្តីខ្វល់ខ្វាយនៃសង្ខារទាំងអស់អាស្រ័យព្រះនិព្វាននោះ រមែងស្ងប់រម្ងាប់ ដូច្នោះ និព្វាននោះ ទើបលោកហៅថា **សព្វសង្ខារសមថោ** ជាទីស្ងប់រម្ងាប់សង្ខារទាំងពួង ។ ម្យ៉ាងទៀត ឧបធិទាំងអស់ អាស្រ័យព្រះនិព្វាននោះ រមែងលះបង់តណ្ហាទាំងពួង រមែងអស់ទៅនៃរាគៈ គឺ កិលេសទាំងពួងរមែងរសាយទៅ ទុក្ខទាំងពួងរមែងរលត់ទៅ និព្វាននោះ ទើបលោកហៅថា **សព្វូបធិប្បដិនិស្សគ្គោ** លះនូវឧបធិទាំងពួង , **តណ្ហក្ខយោ** ជាទីអស់ទៅនៃតណ្ហា , **វិរាគោ** ធម៌ជាទីប្រាសចាកកិលេស ។ **និរោធោ** ការរំលត់ ។ ក៏តណ្ហា លោកហៅថា **វាន** ព្រោះចងក្រងភព និងភព ឬកម្ម និងផល ។ ឈ្មោះថា **និព្វាន** ព្រោះចេញចាកតណ្ហា គឺ **វាន** នោះ ។ បទថា **សោមមស្ស កិលមថោ** សេចក្តីថា ឈ្មោះថា ការសម្តែងធម៌ដល់អ្នកមិនដឹង ជាការលំបាកដល់តថាគត សេចក្តីលំបាកឯណាគប្បីមានដល់តថាគត សេចក្តីលំបាកនោះ គប្បីជាការបៀតបៀនដល់តថាគត ។ លោកអធិប្បាយថា គប្បីជាការលំបាកកាយ និងជាការបៀតបៀនកាយយ៉ាងនេះ ។ ទាំងពីរយ៉ាងនោះ មិនមានក្នុងចិត្តរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ។

បទថា **អបិស្សុ** ជានិបាតចុះក្នុងអត្ថថា **កពូន** ។ ព្រះថេរៈនោះ

រមែងសម្តែងថា មិនមានពាក្យនោះប៉ុណ្ណោះ សូម្បីគាថាទាំងនោះ ក៏ប្រាកដហើយ ។

បទថា **មំ** ប្រែថា ដល់យើង ។ បទថា **អនច្ឆរិយា** ជា **អនុ-អច្ឆរិយា** យ៉ាងអស្ចារ្យបន្តិចបន្តួច ។ បទថា **បដិភំសុ** បានដល់ ជាផ្លូវដើរនៃញាណ ពោលគឺ **បដិភាណ** គឺ ដល់កាលដែលនឹងគប្បីបរិវិតក្កៈ ។

បទថា **កិច្ឆេន** បានដល់ មិនមែនជាទុក្ខាបដិបទា ។ ពិតណាស់ មគ្គ ៤ រមែងជាសុខាបដិបទាសម្រាប់ព្រះពុទ្ធជាម្ចាស់ទាំងឡាយពិត ៗ ។ ពាក្យនេះ លោកពោលសំដៅយកអាគមនីយបដិបទានៃព្រះអង្គ ដែលនៅមានរាគៈ និងមានទោសៈ និងនៅមានមោហៈនោះឯង ក្នុងកាលទ្រង់បំពេញព្រះបារមី ទ្រង់កាត់សិរសាដែលប្រដាប់ហើយ គាស់តែងហើយ នាំឈាមក្នុងបំពង់កចេញ ខ្វេះព្រះនេត្រដែលបន្តក់ថ្នាំភ្នែកល្អហើយ ឲ្យទានវត្ថុដទៃ មានយ៉ាងនេះជាដើម គឺ បុត្តជាប្រទីបនៃវង្សត្រកូល ភរិយាដែលមានចរិយាគួរពេញចិត្តដល់ស្មូមយាចកដែលមកដល់ហើយ និងដល់នូវការកាត់ទម្លាយជាដើម ក្នុងអត្តភាពទាំងឡាយដូចខន្តិវាទីតាបស ។ **ហ** អក្សរក្នុងពាក្យថា **ហលំ** នេះ ត្រឹមតែជានិបាត សេចក្តីថា កុំឡើយ ។ បទថា **បកាសិតុំ** ប្រែថា ដើម្បីសម្តែង គឺ មិនចែក មិនសម្តែង បង្រៀន

ធម៌ដែលយើងសម្រេចហើយដោយលំបាកយ៉ាងនេះឡើយ អធិប្បាយថា ធម៌ដែលយើងសម្ដែងហើយនឹងមានប្រយោជន៍អ្វី ។ បទថា **រាគទោសបរេតេហិ** បានដល់ អ្នកដែលមានរាគៈ និងទោសៈពាល់ត្រូវហើយ ឬដែលមានរាគៈ និងទោសៈគ្របសង្កត់ហើយ ។ បទថា **បដិសោតគាមី** បានដល់ សច្ចៈធម៌ ៤ ដែលទៅហើយ យ៉ាងនេះថា **អនិច្ចំ ទុក្ខំ អនត្តា អសុភំ** ( មិនទៀង ជាទុក្ខ ជាអនត្តា មិនស្អាត ) ដែលបញ្ច្រាសក្រសែនៃធម៌ មានសេចក្ដីទៀងជាដើម ។ បទថា **រាគរត្តា** បានដល់ អ្នកត្រេកអរហើយដោយកាមរាគៈ ភវរាគៈ និងទិដ្ឋិរាគៈ ។ បទថា **ន ទក្ខន្តិ** សេចក្ដីថា រមែងមិនឃើញដោយសភាវៈនេះថា មិនទៀង ជាទុក្ខ ជាអនត្តា មិនស្អាត ដូច្នេះ ។ អ្នកណាហ្ន៎ នឹងអាចដើម្បីធ្វើបុគ្គល ដែលមិនឃើញទាំងនោះ ឲ្យកាន់យកយ៉ាងនេះបាន ។ បទថា **តមោក្ខន្ធេន អាវុតា** សេចក្ដីថា អ្នកដែលត្រូវគំនរអវិជ្ជាគ្របសង្កត់ហើយ ។

(៦០) បទថា **អប្បោស្សុក្កតាយ** បានដល់ ដើម្បីមិនមានសេចក្ដីខ្វល់ខ្វាយ អធិប្បាយថា មិនប្រាថ្នានឹងទេសនា ។

សួរថា ក៏ព្រោះហេតុអ្វី ចិត្តរបស់ព្រះអង្គទើបបង្អោនទៅយ៉ាងនេះថា តថាគតផុតហើយ នឹងធ្វើអ្នកដទៃឲ្យផុត , ឆ្លងហើយ ក៏នឹងធ្វើអ្នកដទៃ

ឲ្យឆ្លង មិនមែនឬ ព្រះអង្គតាំងសេចក្តីប្រាថ្នាទុកថា ៖

យើងអ្នកមានកេទដែលមិនមានអ្នកណាស្គាល់ ធ្វើឲ្យ
ជាក់ច្បាស់ធម៌ក្នុងលោក ហេតុនេះនឹងនៅត្រូវការ
អ្វីយើងសម្រេចសព្វញ្ញុតញ្ញាណហើយនឹងធ្វើលោក
ព្រមទាំងទេវលោកឲ្យឆ្លង ។

ដូច្នេះហើយបំពេញបារមីទាំងឡាយ ក៏សម្រេចសព្វញ្ញុតញ្ញាណ ។

ឆ្លើយថា សេចក្តីនេះជាការពិត ចិត្តរបស់ព្រះអង្គបង្អោនទៅយ៉ាងនេះ ដោយអានុភាពនៃបច្ចវេក្ខណញ្ញាណ ក៏ព្រះអង្គសម្រេចសព្វញ្ញុត-ញ្ញាណ ពិចារណាដល់សភាពដែលសត្វនៅជាប់កិលេស និងការដែលធម៌ជាសភាពជ្រាលជ្រៅ ទើបប្រាកដថា សត្វនៅជាប់កិលេស និងធម៌មានសភាពជ្រាលជ្រៅដោយអាការទាំងពួង ។ កាលដូច្នោះ ក៏ទ្រង់ព្រះតម្រិះថា សត្វទាំងនេះ ពោរពេញទៅដោយកិលេស សៅហ្មងក្រៃលែង ត្រេកអរព្រោះរាគៈ និងព្រោះទោសៈ វង្វេងព្រោះមោហៈ ដូចជាស្បោងដែលពេញទៅដោយទឹកបាយ ដូចពាងពេញទៅដោយប្រេង ដូចសំពត់ចាស់សើមទៅដោយខ្លាញ់ខាប់ និងដូចដៃដែលប្រឡាក់ថ្នាំបន្តក់ភ្នែក សត្វទាំងឡាយនោះ នឹងត្រាស់ដឹងបានយ៉ាងណាទៅ ទើបទ្រង់បង្អោនចិត្តទៅ

យ៉ាងនោះ សូម្បីដោយអានុភាពនៃការពិចារណាដល់ការប្រកាន់កិលេស ក៏ធម៌នេះគប្បីជ្រាបថា ជ្រៅដូចទឹកដែលទ្រផែនដី ឃើញដោយលំបាក ដូចគ្រាប់ស្ពៃដែលយកក្នុំមកបិទបាំង ដឹងតាមបានសែនលំបាក ដូចចុងនៃរោមសត្វទ្រាយដែលបែងចែកចេញជា ៧ ចំណែក ឈ្មោះថា ទានដែលតថាគតព្យាយាមដើម្បីចាក់ធ្លុះ ធម៌នេះមិនឲ្យហើយមិនមាន ឈ្មោះថា សីលដែលតថាគតមិនបានរក្សាហើយក៏មិនមាន ។ ឈ្មោះថា បារមីណា ៗ ដែលតថាគតមិនបានបំពេញក៏មិនមាន កាលនោះ តថាគតកម្ចាត់កម្លាំងរបស់មារដែលគ្មានឧស្សាហ៍ ផែនដីក៏ញាប់ញ័រ កាលណារលឹកដល់បុព្វេនិវាសញ្ញាណក្នុងបឋមយាមក៏មិនបានញាប់ញ័រ កាលជម្រះទិព្វចក្ខុក្នុងមជ្ឈិមយាមក៏មិនញាប់ញ័រ តែកាលចាក់ធ្លុះបដិច្ចសមុប្បាទក្នុងបច្ឆិម-យាម មួយម៉ឺនលោកធាតុកម្រើកញាប់ញ័រ ដូច្នោះ អ្នកដែលមានញាណចាស់ក្លា , សូម្បីដូចតថាគត គង់ចាក់ធ្លុះធម៌នេះបានដោយលំបាកទៅហើយ លោកិយមហាជននឹងចាក់ធ្លុះធម៌នោះបានយ៉ាងណា គប្បីជ្រាបថាទ្រង់បង្អោនចិត្តទៅយ៉ាងនេះ សូម្បីដោយអានុភាពនៃការពិចារណាសេចក្តីជ្រាលជ្រៅនៃព្រះធម៌ដោយប្រការយ៉ាងនេះ ។ មយ៉ាងទៀត កាលសហម្បតីព្រហ្មទូលអារាធនាព្រះអង្គ ក៏ទ្រង់បង្អោនចិត្តទៅយ៉ាងនេះ ព្រោះមាន

ពុទ្ធបំណងនឹងទ្រង់ សម្តែងធម៌ ។ ពិតណាស់ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ជ្រាបថា កាលតថាគតបង្អោនចិត្តទៅ ដើម្បីភាពជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច មហាព្រហ្មក៏នឹងអារាធនាតថាគតសម្តែងធម៌ ។ ដោយសារសត្វទាំងនេះគោរពព្រហ្ម សត្វទាំងនោះសម្គាល់ថា ព្រះសាស្តាមិនមានបំណងនឹងទ្រង់សម្តែងធម៌ តែមហាព្រហ្មអារាធនាតថាគតសម្តែងធម៌ , លោកអ្នកដ៏ចម្រើនទាំងឡាយ ធម៌នេះស្ងប់ប្រណីតហ្ន៎ គប្បីតាំងចិត្តស្តាប់ដោយល្អ អាស្រ័យហេតុនេះ គប្បីជ្រាបថា ព្រះអង្គបង្អោនចិត្តទៅដើម្បីភាពជាអ្នកខ្វល់ខ្វាយតិច មិនបានបង្អោនទៅដើម្បីសម្តែងធម៌ ។

បទថា **សហម្បតិស្ស** សេចក្តីថា បានឮថា សហម្បតីព្រហ្មនោះ សម័យសាសនាព្រះមានព្រះភាគជាម្ចាស់ព្រះនាមថាកស្សបៈ ជាព្រះថេរៈឈ្មោះ សហកៈ ធ្វើបឋមជ្ឈានឲ្យកើត ហើយទៅកើតជាព្រហ្ម មានអាយុមួយកប្បក្នុងភូមិនៃបឋមជ្ឈាន ។ ជនទាំងឡាយ រមែងសំដៅដល់មហាព្រហ្មនោះថា សហម្បតីព្រហ្មនោះ ក្នុងពាក្យនោះ ។ លោកសំដៅយកសហម្បតីព្រហ្មនោះ ទើបពោលថា **ព្រហ្មុនោ សហម្បតិស្ស** ។ បទថា **នស្សតិ វត ភោ** សេចក្តីថា បានឮថា សហម្បតីព្រហ្មនោះ បន្លឺសំឡេងនេះចេញមក ព្រហ្មមួយម៉ឺនលោកធាតុបានឮហើយ ប្រជុំគ្នាទាំងអស់ ។

បទថា **យត្រ ហិ នាម** ប្រែថា ក្នុងលោក ។ បទថា **បុរេតោ បាតុរហោសិ** បានដល់ ប្រាកដជាមួយព្រហ្មមួយពាន់នោះ ។ បទថា **អប្បរជក្ខជាតិកា** បានដល់ ធូលី គឺ រាគៈ ទោសៈ និងមោហៈ ក្នុងកែវភ្នែកដែលសម្រេចដោយបញ្ញា មានប្រមាណតិចតួចរបស់សត្វទាំងនេះ មានសភាវៈយ៉ាងនេះ ព្រោះដូច្នោះ សត្វទាំងនេះទើបឈ្មោះថា **អប្បរជ-ក្ខជាតិកា** មានធូលី គឺ កិលេសក្នុងភ្នែកតិច ។ បទថា **អស្សវនតា** ប្រែថា ព្រោះមិនបានស្តាប់ ។ ដោយបទថា **ភវិស្សន្តិ** លោកសម្តែងថា សត្វទាំងឡាយដែលធ្វើបុណ្យដោយបុញ្ញកិរិយាវត្ថុ ១០ ក្នុងព្រះពុទ្ធជាម្ចាស់អង្គមុនៗ សង្ឃឹមការសម្តែងធម៌ ដូចជាផ្កាឈូកដែលចាស់ត្រូវកំដៅព្រះអាទិត្យ គួរនឹងឈានចុះក្នុងអរិយភូមិ កាលចប់គាថា ៤ បាទ មិនមែនមនុស្សម្នាក់ មិនមែនមនុស្សពីរនាក់ តែច្រើនសែនអ្នក ដែលនឹងត្រាស់ដឹងធម៌ ។ បទថា **បាតុរហោសិ** ប្រែថា ប្រាកដ ។ បទថា **សមលេហិ ចិន្តិតោ** បានដល់ ដែលពួកសាស្តាទាំង ៦ អ្នកមានមន្ទិលគិត ។ ពិតណាស់ សាស្តាទាំងនោះកើតឡើងមុន នាំគ្នាសម្តែងធម៌ គឺ មិច្ឆាទិដ្ឋិដែលមានមន្ទិល ដូចក្រាលបន្ទាទុក និងដូចរាយថ្នាំពិសទុកទូទៅ ក្នុងជម្ពូទីប ។ បទថា **អបាបុរេតំ** បានដល់ បើកទ្វារអមតៈនោះ ។ បទថា

**អមតស្ស ទ្វារំ** បានដល់ អរិយមគ្គ ដែលជាទ្វារអមតនិព្វាន ។ បទថា **សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ** សេចក្តីថា ទូលអង្វរថា បពិត្រព្រះមាន-ព្រះភាគជាម្ចាស់ មុនដំបូងសូមឲ្យសត្វទាំងនោះបានស្តាប់ធម៌ គឺ អរិយ-សច្ចៈ ៤ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់អ្នកមិនមានមន្ទិល ព្រោះមិនមានមន្ទិល គឺ រាគៈជាដើម ត្រាស់ដឹងហើយ ។ បទថា **សេលេ យថា បព្វតមុទ្ធ និដ្ឋិតោ** សេចក្តីថា ឧបមាដូចបុគ្គលអ្នកឈរនៅលើភ្នំថ្មតាន់ មិនចាំបាច់នឹងត្រូវអើតកដើម្បីនឹងមើលមនុស្ស ដែលឈរនៅលើកំពូលភ្នំ ដែលក្រាស់ដោយសិលា ។ បទថា **តថូបមំ** ប្រៀបដូចយ៉ាងនោះ ឬ ឧបមាដូចភ្នំថ្ម ។

ក៏សេចក្តីសង្ខេបក្នុងប្រការនេះ មានយ៉ាងនេះ បុរសអ្នកមានចក្ខុ ឈរនៅលើកំពូលភ្នំថ្ម គប្បីឃើញហ្វូងជនបានដោយជុំវិញ យ៉ាងណា ម្នាលសុមេធអ្នកមានបញ្ញាល្អ ព្រះមានព្រះភាគជាម្ចាស់អ្នកមានសមន្តចក្ខុ ដោយសព្វញ្ញុតញ្ញាណ សូមប្រព្រះអង្គស្តេចយាងឡើងប្រាសាទធម៌ គឺ បញ្ញា មិនសោកសៅដោយព្រះអង្គឯង ទ្រង់ត្រិះរិះពិចារណា ត្រួតត្រា ក្រុមជនអ្នកក្តៅក្រហាយដោយសេចក្តីសោក ត្រូវជាតិ ជរាគ្របសង្កត់ ក៏ ដូច្នោះ ។ ក្នុងសេចក្តីនេះ មានអធិប្បាយថា ជនទាំងឡាយ ធ្វើស្រែជុំវិញ

ជើងភ្នំ ធ្វើខ្ទមត្រង់ភ្លឺស្រែក្នុងទីនោះ ពេលយប់ដុតភ្លើងទុក ក៏សេចក្ដីងងឹតស្អុបដែលប្រកបដោយអង្គ ៤ គប្បីមាន , កាលបើដូច្នោះ បុរសអ្នកមានចក្ខុ ឈរលើកំពូលភ្នំនោះសម្លឹងមើលមកជីស្រែចំការ ក៏មិនប្រាកដភ្លឺស្រែក៏មិនប្រាកដ ខ្ទមក៏មិនប្រាកដ មនុស្សដែលដេកនៅក្នុងទីនោះក៏មិនប្រាកដ , ប្រាកដត្រឹមតែពន្លឺភ្លើងក្នុងខ្ទមប៉ុណ្ណោះ យ៉ាងណា កាលព្រះតថាគតយាងឡើងកាន់ប្រាសាទធម៌ ត្រួតមើលពួកសត្វ ពួកសត្វអ្នកមិនបានធ្វើកម្មល្អ សូម្បីនឹងអង្គុយនៅជិតព្រះជានុខាងស្ដាំក្នុងវិហារជាមួយគ្នាក៏មិនប្រាកដដល់ព្រះពុទ្ធចក្ខុ ដូចបាញ់ធ្នូក្នុងពេលយប់ ចំណែកវេនេយ្យបុគ្គលអ្នកធ្វើកម្មល្អ សូម្បីនឹងនៅក្នុងទីឆ្ងាយ ក៏មកប្រាកដដល់ព្រះអង្គប្រៀបប្រដូចភ្លើង និងដូចភ្នំហិមវន្ត ដូច្នោះ ។ សមដូចគាថាប្រព័ន្ធដែលលោកពោលទុកថា ៖

ទូរេ សន្តោ បកាសេន្តិ ហិមវន្តោវ បព្វតោ
អសន្តេត្ថ ន ទិស្សន្តិ រត្តឹ ខិត្តា យថា សរា

សប្បុរសរមែងប្រាកដក្នុងទីឆ្ងាយដូចភ្នំហិមវន្ត អសប្បុរសនៅក្នុងទីនោះឯង ក៏មិនប្រាកដ ដូចព្រួញដែលបាញ់ទៅក្នុងវេលាយប់ដូច្នោះ ។

បទថា **ឧដ្ឋេហិ** ព្រហ្មទូលអារាធនាព្រះមានព្រះភាគជាម្ចាស់ឲ្យស្តេចចារិកសម្តែងធម៌ ។ ក្នុងពាក្យថា **វីរ** ជាដើម ព្រះមានព្រះភាគជាម្ចាស់ ព្រះនាមថា **វីរ** ព្រោះមានសេចក្តីព្យាយាម ។ ព្រះនាមថា អ្នកឈ្នះសង្គ្រាម ព្រោះទ្រង់ឈ្នះទេវបុត្រមារ មច្ចុមារ និងកិលេសមារ ដូចនាយសារថី ព្រោះជាអ្នកអង់អាចក្នុងការនាំពួកវេនេយ្យសត្វឲ្យឆ្លងកន្តារជាដើម គប្បីជ្រាបថា អ្នកមិនមានបំណុល ព្រោះមិនមានបំណុល គឺ កាមច្ឆន្ទៈ ។

(៦១) បទថា **អជ្ឈេសនំ** ប្រែថា ទូលអង្វរ ។ បទថា **ពុទ្ធចក្ខុនា** បានដល់ ដឹងឥន្ទ្រីយ៍របស់សត្វទន់ខ្ចី ចាស់ក្លា និងដឹងអធ្យាស្រ័យ និងកិលេស ក៏ពាក្យថា **ពុទ្ធចក្ខុ** ជាឈ្មោះរបស់ញាណ ២ ទាំងនេះ សមន្តចក្ខុ ជាឈ្មោះរបស់សព្វញ្ញុតញ្ញាណ , ធម្មចក្ខុ ជាឈ្មោះរបស់មគ្គញ្ញាណ ៣ ។ ក្នុងពាក្យថា **អប្បរជក្ខេ** ជាដើម កិលេសធូលី មានរាគៈជាដើម ក្នុងបញ្ញាចក្ខុរបស់សត្វពួកណាមានតិច ដោយន័យដែលពោលហើយនោះឯង សត្វទាំងនោះ ឈ្មោះថា **អប្បរជក្ខ** សត្វពួកណាមានកិលេសធូលីនោះច្រើន សត្វទាំងនោះ ឈ្មោះថា **មហារជក្ខ** សត្វពួកណាមានឥន្ទ្រីយ៍ គឺ សទ្ធាជាដើមចាស់ក្លា សត្វទាំងនោះឈ្មោះថា **តិក្ខិន្ទ្រិយ** ។ សត្វពួកណាមានឥន្ទ្រីយ៍ទន់ខ្ចី សត្វទាំងនោះ ឈ្មោះថា **មុទិន្ទ្រិយ** សត្វពួកណា

មានអាការ គឺ សទ្ធាជាដើម ទាំងនោះល្អ សត្វទាំងនោះឈ្មោះថា **សវាការ** សត្វពួកណាកំណត់ដឹងហេតុ ដែលទ្រង់ត្រាស់សម្តែង អាចដឹងបានងាយ សត្វទាំងនោះ ឈ្មោះថា **សុវិញ្ញាបយ** សត្វពួកណាឃើញបរលោក និង ទោសថា ជាភ័យ សត្វទាំងនោះ ឈ្មោះថា ឃើញបរលោក និងទោស ថា ជាភ័យ ។

ក៏ក្នុងទីនោះ មានបាលីដូចតទៅនេះ បុគ្គលអ្នកមានសទ្ធាឈ្មោះថា មានកិលេស គឺ ធូលីក្នុងបញ្ញាចក្ខុតិច បុគ្គលអ្នកមិនមានសទ្ធា ឈ្មោះថា អ្នកមានកិលេស គឺ ធូលីក្នុងបញ្ញាចក្ខុច្រើន អ្នកប្រារព្ធសេចក្តីព្យាយាម ឈ្មោះថា **អប្បរជក្ខ** , អ្នកខ្ជិលច្រអូស ឈ្មោះថា **មហារជក្ខ** , អ្នកមាន សតិរឹងមាំ ឈ្មោះថា **អប្បរជក្ខ** , អ្នកមានសតិវង្វេងភ្លេច ឈ្មោះថា **មហារជក្ខ** , អ្នកមានចិត្តតាំងមាំ ឈ្មោះថា **អប្បរជក្ខ** , អ្នកមានចិត្តមិន តាំងមាំឈ្មោះថា **មហារជក្ខ** , អ្នកមានបញ្ញាឈ្មោះថា **អប្បរជក្ខ** , អ្នក មានបញ្ញាថោកទាបឈ្មោះថា **មហារជក្ខ** , បុគ្គលអ្នកមានសទ្ធាយ៉ាងនោះ ឈ្មោះថា មានឥន្ទ្រិយចាស់ក្លា ។ល។ បុគ្គលអ្នកមានបញ្ញា ឈ្មោះថា អ្នក ឃើញបរលោក និងទោស ថាជាភ័យ បុគ្គលដែលមានបញ្ញាថោកទាប ឈ្មោះថា មិនឃើញបរលោក និងទោស ថាជាភ័យ ។ បទថា **លោកោ**

បានដល់ លោក គឺ ខន្ធៈ , លោក គឺ ធាតុ , លោក គឺ អាយតនៈ , លោក គឺ សម្បត្តិភព , លោក គឺ សម្បត្តិសមភព , លោក គឺ វិបត្តិភព , លោក គឺ វិបត្តិសមភព ។ លោក ១ គឺ សត្វទាំងពួងស្ថិតនៅបានដោយអាហារ , លោក ២ គឺ នាម និងរូប , លោក ៣ គឺ វេទនា ៣ , លោក ៤ គឺ អាហារ ៤ , លោក ៥ គឺ ឧបាទាន ៥ , លោក ៦ គឺ អាយតនៈខាងក្នុង , លោក ៧ គឺ វិញ្ញាណឋិតិ ៧ , លោក ៨ គឺ លោកធម៌ ៨ , លោក ៩ គឺ សត្តាវាស ៩ , លោក ១០ គឺ អាយតនៈ ១០ , លោក ១២ គឺ អាយតនៈ ១២ , លោក ១៨ គឺ ធាតុ ១៨ ។ បទថា **វជ្ជំ** សេចក្តីថា កិលេសទាំងពួងចាត់ជាទោស ទុច្ចរិតទាំងពួងចាត់ជាទោស អភិសង្ខារទាំងពួងចាត់ជាទោស កម្មដែលជាហេតុនាំសត្វទៅកាន់ភពទាំងពួងចាត់ជាទោស ក៏ត្រូវសម្គាល់ក្នុងលោកនេះ និងក្នុងទោសនេះថា ជាភ័យយ៉ាងខ្លាំងក្លាប្រាកដហើយ ដូចពេជ្ឈឃាតងារដាវ ព្រះតថាគតរមែងដឹង ឃើញ ដឹងទូទៅនូវឥន្រ្ទិយ៍ទាំង ៥ នេះ ដោយអាការ ៥០ ឈ្មោះថា ឥន្រ្ទិយបរោបរិយត្តិញ្ញាណរបស់ព្រះតថាគត ។

បទថា **ឧប្បលិនិយំ** ប្រែថា ក្នុងព្រៃឈូក ។ សូម្បីពាក្យក្រៅពីនេះ ក៏ន័យនេះដូចគ្នា ។ បទថា **អន្តោនិមុគ្គបោសីនិ** បានដល់ ផ្កាឈូក

ដែលនៅក្នុងទឹក ដែលធម្មជាតិចិញ្ចឹមទុក ។ បទថា **ឧទកំ អច្ចុគ្គម្ម តិដ្ឋន្តិ** បានដល់ ងើបពីទឹកហើយតាំងនៅ ។ ក្នុងផ្កាឈូកទាំងនេះ ពួកណាឡើងផុតពីទឹកតាំងនៅ រង់ចាំទទួលសម្ផស្សពន្លឺព្រះអាទិត្យនឹងរីកក្នុងថ្ងៃនេះ ពួកណាតាំងនៅស្មើទឹកក៏នឹងរីកក្នុងថ្ងៃស្អែក ពួកណានៅក្នុងទឹក លិចនៅក្នុងទឹក ដែលជាធម្មជាតិចិញ្ចឹមទុក ពួកនោះក៏នឹងរីកក្នុងថ្ងៃទី ៣ ។ ចំណែកផ្កាឈូកដែលនៅក្នុងស្រះជាដើមសូម្បីពួកដទៃ នៅក្នុងទឹកក៏មាន ពួកណានឹងមិនរីក ពួកនោះក៏នឹងជាអាហាររបស់ត្រី និងអណ្តើកតែម្យ៉ាង ផ្កាឈូកទាំងនោះ លោកមិនបានសម្តែងឡើងកាន់បាលី ក៏គួរសម្តែង ។ ដូចយ៉ាងនេះថា ផ្កាឈូក ៤ យ៉ាងនោះ យ៉ាងណាមិញ បុគ្គល ៤ ជំពូក គឺ ឧគ្ឃដិតញ្ញូ , វិបច្ចិតញ្ញូ , នេយ្យៈ , បទបរមៈ ក៏ដូច្នោះដូចគ្នា ។ ក្នុងបុគ្គលទាំង ៤ ពួកនោះ បុគ្គលណាត្រាស់ដឹងធម៌ព្រមជាមួយការលើកមាតិកាធម៌ បុគ្គលនេះលោកហៅថា **ឧគ្ឃដិតញ្ញូ** ។ បុគ្គលណាត្រាស់ដឹងធម៌ កាលលោកចែកអត្ថនៃភាសិតសង្ខេបដោយពិស្តារបាន បុគ្គលនេះលោកហៅថា **វិបច្ចិតញ្ញូ** ។ បុគ្គលណា យកចិត្តទុកដាក់ដោយប្រពៃ ទាំងដោយឧទ្ទេស ទាំងដោយបរិបុច្ឆា សេពគប់ ចូលទៅជិតកល្យាណមិត្ត ទើបត្រាស់ដឹងធម៌ បុគ្គលនេះហៅថា **នេយ្យៈ** ។ បុគ្គលណា ស្តាប់ច្រើនក្តី

ពោលច្រើនក្តី ទ្រទ្រង់ចាំច្រើនក្តី បង្រៀនច្រើនក្តី ក៏នៅមិនបានត្រាស់ដឹង ក្នុងជាតិនោះ បុគ្គលនេះ លោកហៅថា **បទបរមៈ** ។ បណ្តាបុគ្គលទាំងនោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រួតមើលមួយម៉ឺនលោកធាតុ ដែលប្រដូចជាព្រៃឈូកជាដើម ទ្រង់ក៏បានឃើញថា ឧគ្ឃដិតញ្ញូ ប្រៀបដូចផ្កាឈូករីកក្នុងថ្ងៃនេះ , វិបច្ចិតញ្ញូ ប្រៀបដូចផ្កាឈូករីកក្នុងថ្ងៃស្អែក , នេយ្យ ប្រៀបដូចផ្ការីកក្នុងថ្ងៃទី ៣ , បទបរមៈ ប្រៀបដូចផ្កាឈូកជាអាហាររបស់ត្រី និងអណ្តើក ។ ក៏ព្រះមានព្រះជាម្ចាស់ កាលទ្រង់ឃើញ ក៏ទ្រង់ឃើញដោយអាការគ្រប់យ៉ាង យ៉ាងនេះថា សត្វមានប្រមាណប៉ុណ្ណេះ មានកិលេស គឺ ធូលីក្នុងបញ្ញាចក្ខុតិច ទាំងនេះមានកិលេស គឺ ធូលីក្នុងបញ្ញាចក្ខុច្រើន បណ្តាសត្វទាំងនោះ ពួកនេះជាឧគ្ឃដិតញ្ញូយ៉ាងនេះ ជាដើម ។ ព្រះធម្មទេសនារបស់ព្រះមានព្រះភាគជាម្ចាស់ រមែងឲ្យសម្រេចប្រយោជន៍ក្នុងអត្តភាពនេះប៉ុណ្ណោះដល់បុគ្គល ៣ ប្រភេទ ក្នុងចំនួនបុគ្គលទាំងនោះ បទបរមៈ មានវាសនាដើម្បីប្រយោជន៍ក្នុងអនាគតកាល ។ គ្រានោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ជ្រាប់ថា ព្រះធម្មទេសនា នឹងនាំប្រយោជន៍មកឲ្យដល់បុគ្គល ៤ ប្រភេទ ទើបទ្រង់ធ្វើឲ្យកើតព្រះពុទ្ធបំណង ដែលទ្រង់នឹងសម្តែងធម៌ ទើបទ្រង់ចែកពួកសត្វ ក្នុងភព ៣ ទាំងអស់ជា ២ គឺ ភព្វបុគ្គល និង

អភព្វបុគ្គល ។ លោកសំដៅយកសត្វពួកណា ទើបពោលពាក្យនេះទុកថា ពួកសត្វដែលប្រកបដោយការហាមកម្ម ហាមវិបាក ហាមកិលេស មិនមានសទ្ធា កាត់មិនដាច់ មិនមានបញ្ញា មិនគួរឈានចុះកាន់សេចក្តីពេញចិត្តក្នុងកុសលធម៌ពិតប្រាកដ សត្វទាំងនោះចាត់ជា **អភព្វៈ** ។ ពួកសត្វណាដែលមានភព្វទាំងនោះដូចម្តេច គឺ ពួកសត្វដែលមិនប្រកបដោយការហាមកម្ម ហាមវិបាក ហាមកិលេស ។ល។ សត្វទាំងនេះចាត់ជា **ភព្វៈ** ។ ក្នុងសត្វ ២ ប្រភេទនោះ ព្រះមានព្រះជាម្ចាស់ ទ្រង់លះអភព្វទាំងអស់ ទ្រង់កំណត់កាន់យកដោយព្រះញាណ ចំពោះភព្វបុគ្គលប៉ុណ្ណោះ ទ្រង់ចែកជា ៦ ចំណែក គឺ ពួកនេះ មានរាគចរិត សទ្ធាចរិត និងពុទ្ធិចរិត ។ លុះចែកយ៉ាងនេះហើយ ក៏ទ្រង់ព្រះតម្រិះ និងសម្តែងធម៌ប្រោស ។ បទថា **បច្ចភាសិ** ប្រែថា ត្រាស់ចំពោះ ។ បទថា **អបារុតា** ប្រែថា បើក ។ បទថា **អមតស្ស ទ្វារា** បានដល់ អរិយមគ្គ ។ ពិតហើយ អរិយមគ្គនោះ ជាទ្វារនៃព្រះនិព្វាន ពោលគឺ អមតៈ ព្រះមានព្រះជាម្ចាស់ ទ្រង់សម្តែងថា អរិយមគ្គនោះ តថាគតបើកទុកហើយ ។ បទថា **បមុញ្ចន្តុ សទ្ធំ** បានដល់ សូមសព្វសត្វចូរបញ្ចេញ ចូរបង្ហូរសទ្ធារបស់ខ្លួន ។ ក្នុងពីរបទក្រោយ មានសេចក្តីយ៉ាងនេះថា សូម្បីតថាគត ក៏យល់ថា នឹងលំបាកផ្លូវកាយ និង

វាថា ទើបមិនពោលធម៌ខ្ពស់បំផុត ដ៏ប្រណីតនេះ ដែលស្អាតជំនាញហើយ សូម្បីប្រព្រឹត្តទៅដោយល្អ តែមកដល់ឥឡូវនេះ សូមជនទាំងពួង ចូរបង្អោន នូវកាជនៈ គឺ សទ្ធាចូលមក តថាគតនឹងធ្វើសេចក្ដីត្រិះរិះរបស់សត្វទាំង នោះឲ្យពេញ ។

(៦២) បទថា **តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ** សេចក្ដីថា យើងមាន ការត្រិះរិះយ៉ាងនេះថា តថាគតនឹងគប្បីសម្ដែងធម៌ដល់អ្នកណាមុនហ្ន៎ សេចក្ដី ត្រិះរិះដែលទាក់ទងដល់ការសម្ដែងធម៌នេះ កើតឡើងហើយ ។ សួរថា ក៏ការត្រិះរិះនេះកើតឡើងពីពេលណា ។ ឆ្លើយថា កាលបានត្រាស់ជាព្រះ ពុទ្ធជាម្ចាស់ក្នុងសប្ដាហ៍ទី ៨ ។ ក្នុងសេចក្ដីនោះ នឹងពោលដូចតទៅនេះ ៖

បានឮមកថា ក្នុងថ្ងៃមហាភិនេស្រ្កមណ៍ ព្រះពោធិសត្វទ្រង់ឃើញ បន្ទប់ស្រីស្នំអាក្រាត ក៏ស្លុតព្រះទ័យ ទើបត្រាស់ហៅនាយឆន្នៈមកប្រាប់ថា ចូរនាំសេះកណ្ឋកៈមក មាននាយឆន្នៈជាសម្លាញ់ ស្ដេចទ្រង់យាងឡើងលើ ខ្នងសេះចេញចាកព្រះនគរ ទ្រង់សម្ដែងចេតិយស្ថាន បានឲ្យសេះកណ្ឋកៈ ត្រឡប់វិញ ទ្រង់លះរាជសម្បត្តិ ( ធ្វើដំណើរឆ្លងនគរ ៣ ) ទ្រង់បួសជិត ឆ្នេរស្ទឹងអនោមានទី ស្ដេចចារិកទៅតាមលំដាប់ ដើម្បីស្វែងរកអាហារក្នុង ក្រុងរាជគ្រឹះ ប្រថាប់គង់នៅក្បែរភ្នំបណ្ឌវៈ ត្រូវព្រះបាទពិម្ពិសារត្រាស់សួរ

ដល់នាម និងគោត្រ ត្រាស់សូមឲ្យទ្រង់ទទួលរាជសម្បត្តិ តែទូលថា កុំឡើយមហាបពិត្រ អាត្មាភាពមិនត្រូវការរាជសម្បត្តិទេ អាត្មាភាពលះរាជសម្បត្តិ ហើយមកប្រកបសេចក្ដីព្យាយាម ដើម្បីត្រូវការជួយសង្គ្រោះដល់សត្វ ព្រះអង្គចេញបួសដោយបំណងនឹងបានទៅជាព្រះពុទ្ធជាម្ចាស់ ដើម្បីកម្ចាត់បង់សេចក្ដីវិលវល់ក្នុងលោក ទ្រង់ទទួលពាក្យប្ដេជ្ញារបស់ព្រះបាទពិម្ពិសារថា បើយ៉ាងនោះ ព្រះអង្គបានជាព្រះពុទ្ធជាម្ចាស់ហើយ សូមមេត្តាប្រោស ស្ដេចយាងមកនគរទូលព្រះបង្គំមុនគេ យ៉ាងនេះ ។ ហើយស្ដេចចូលទៅរកអាឡារតាបសកាឡាមគោត្រ និងឧទ្ទកតាបសរាមបុត្រ កាលមិនជួបខ្លឹមសារនៃធម៌ទេសនា របស់តាបសទាំងពីរនោះ ទើបគេចចេញទៅបំពេញទុក្ករកិរិយារហូតអស់ ៦ ឆ្នាំ នៅឧរុវេលា កាលមិនអាចចាក់ធ្លុះអមតធម៌ បានធ្វើព្រះកាយឲ្យឆ្អែតដោយ ការសោយអាហារដែលគ្រោតគ្រាត ៗ គ្រានោះ ធីតាកុដុម្ពីក៏ម្នាក់ឈ្មោះ សុជាតា នៅក្នុងឧរុវេលគ្រាមតាំងសេចក្ដីប្រាថ្នានៅនឹងដើមនិគ្រោធ ១ ដើមថា បើនាងខ្ញុំបានរៀបការជាមួយនឹងអ្នកដែលមានជាតិស្មើគ្នា សូមកូនដំបូងជាកូនប្រុស រួចធ្វើការបួងសួង ៗ នាងសម្រេចប្រាថ្នានោះហើយ ៗ ថ្ងៃវិសាខបុណ្ណមី នាងរៀបចំមធុបាយាសយ៉ាងល្អ នៅវេលាជិតភ្លឺ ដោយមានបំណងថា នឹងធ្វើការ

បួនសួនពីព្រលឹម ។ កាលដែលកំពុងដាំមធុបាយាសនោះ ពពុះបាយាស ប៉ោងធំៗ ផុសឡើង វិលទៅខាងស្តាំ ។ សូម្បីចំណែកដែលត្រូវសម្ផស្ស ក៏មិនខ្ទាតចេញទៅខាងក្រៅ ។ មហាព្រហ្មបាំងឆត្រ ។ ស្តេចលោកបាល ទាំង ៤ កាន់ព្រះខ័នរក្សា ។ សក្កទេវរាជ មកប្រមូលឈើស្ងួត (ឧស) ហើយបង្កាត់ភ្លើង ។ ទេវតាក្នុងទ្វីបទាំង ៤ ក៏ប្រមូលឱជារសមកដាក់ក្នុង មធុបាយាសនោះ ។ ព្រះពោធិសត្វរង់ចាំវេលាកិច្ចាចារ ស្តេចយាងទៅពី ព្រលឹម ប្រថាប់គង់នៅក្រោមនិគ្រោធ ស្ត្រីបំរើមកបោសសម្អាតគល់ឈើ ប្រាប់ដល់នាងសុជាតាថា ទេវតាមកអង្គុយនៅក្រោមដើមឈើហើយ ។ នាង សុជាតា តុបតែងគ្រឿងប្រដាប់ទាំងពួងហើយ ដាក់មធុបាយាសដាក់ក្នុង ថាសមាសមានតម្លៃ ១០០.០០០ , គ្របដោយថាសមាសមួយទៀត ហើយ លើកទូលយកទៅ ឃើញព្រះមហាបុរស ទើបដាក់ថាសមាសនោះចុះ ថ្វាយ បង្គំហើយពោលថា មនោរថរបស់នាងខ្ញុំសម្រេចហើយ យ៉ាងណា សូម មនោរថរបស់លោក ក៏ចូរសម្រេចដូច្នោះចុះ ហើយក៏ត្រឡប់ទៅវិញ ។ ព្រះពោធិសត្វ ស្តេចទៅដល់មាត់ច្រាំងស្ទឹងនេរញ្ជរាហើយ ដាក់ថាសមាស ទុកក្បែរឆ្នេរស្ទឹង ចុះស្រង់ទឹក ស្តេចឡើងហើយ ទ្រង់ពូតបាយមធុបាយាស ចំនួន ៤៩ ដុំ សោយបាយមធុបាយាសនោះ ហើយទ្រង់បន្ទឺថា បើយើងនឹង

បានជាព្រះពុទ្ធថ្ងៃនេះ សូមឲ្យថាសមាសអណ្តែតប្រាសខ្សែទឹក យ៉ាងនេះ ហើយទ្រង់បណ្តែតថាសទៅ ។ ថាសក៏អណ្តែតប្រាសខ្សែទឹក ហើយឈប់បន្តិច ក៏ធ្លាក់ចុះទៅកាន់ភពរបស់កាឡនាគរាជ ត្រូតសង្កត់ថាសរបស់ព្រះពុទ្ធជាម្ចាស់ ៣ ព្រះអង្គ ។ ព្រះមហាសត្វប្រថាប់សម្រាកពេលថ្ងៃ នៅជិតដងព្រៃ ដល់ពេលល្ងាច ទ្រង់ទទួលស្បូវ ៨ ក្តាប់ដែលសោត្ថិយព្រាហ្មណ៍ថ្វាយ ហើយស្តេចឡើងកាន់ពោធិមណ្ឌលស្ថាន ប្រថាប់ឈរ នៅចំណែកទិសខាងត្បូង ។ ប្រទេសនោះ បានញាប់ញ័រដូចតំណក់ទឹកក្នុងស្លឹកឈូក ។ ព្រះមហាក្សត្រទ្រង់ត្រិះរិះថា ត្រង់នេះ មិនអាចទ្រទ្រង់គុណរបស់យើងបាន ក៏ស្តេចទៅកាន់ចំណែកទិសខាងលិច ។ សូម្បីទីនោះ ក៏ញាប់ញ័រដូចគ្នា ។ ស្តេចយាងទៅចំណែកទិសខាងជើង ។ សូម្បីទីនោះ ក៏ញ័រដូចគ្នា ទើបស្តេចទៅទិសខាងកើត នៅទីនោះ ស្ថានដែលធ្វើជាបល្ល័ង្កមិនញាប់ញ័រឡើយ ដូចសសរបង្គោលដែលកប់ទុកល្អហើយ ។ ព្រះមហាសត្វ ទ្រង់រិះគិតថា ទីនេះ ជាកន្លែងដែលរុះរើបង្អួចកិលេស របស់ព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ទ្រង់ចាប់ចុងស្បូវទាំងនោះ ហើយរលាស់ចុងស្បូវ ដូចជាជាងវិចិត្រកម្មគូរដោយចុងជក់ ព្រះពោធិសត្វទ្រង់ចូលទៅជិតគល់ពោធិ៍ ទ្រង់អធិដ្ឋានសេចក្តីព្យាយាមមានអង្គ ៤ ថា ទ្រង់នឹងមិនទំលាយភ្នែន ហើយទ្រង់គង់

ពិចារណានូវធម៌ ។ ក្នុងកាលនោះឯង មារនិម្មិតដៃ ១០០០ ឡើងកាន់ដំរីឈ្មោះគិរិមេខលៈ កំពស់ ១៥០ យោជន៍ នាំពលមារ ៩ យោជន៍ ក្រឡេកមើលមួយចំហៀងភ្នែក ចូលជិតប្រៀបដូចភ្នំ ។ ព្រះមហាសត្វទ្រង់លាព្រះហស្តត្រាស់ថា យើងបានបំពេញបារមី ១០ មិនមានសមណព្រាហ្មណ៍ទេវតា មារ ឬព្រហ្មជាសាក្សី តែក្នុងអត្តភាពដែលជាព្រះវេស្សន្តរ មហាប្រឹថពី បានជាសាក្សីរបស់យើងក្នុង ៧ ឋានៈ សូម្បីឥឡូវនេះមហាប្រឹថពីដែលមិនមានចិត្ត និងឧបមាដូចកំណាត់ឈើ ក៏ជាសាក្សី ។ ក្នុងនោះឯងមហាប្រឹថពី ក៏បញ្ចេញសំឡេងស្រែកមួយរយដង មួយពាន់ដង ដូចកណ្តឹងដែលត្រូវដោយញញួរដែក ហើយមួរយកពលមារទៅគរទុកនៅឯកណ្តាប់មាត់ចក្រវាឡ ។ ក្នុងកាលព្រះអាទិត្យនៅមិនទាន់លិចទៅនោះឯង ព្រះមហាសត្វ ក៏ទ្រង់កម្ចាត់ពលមារបាន ។ ទ្រង់ជម្រះបុព្វេនិវាសញ្ញាណ ក្នុងបឋមយាម ទិព្វចក្ខុញ្ញាណក្នុងមជ្ឈិមយាម ទ្រង់ញាំងញាណចុះក្នុងបដិច្ច-សមុប្បាទក្នុងបច្ឆិមយាម ទ្រង់ពិចារណាវដ្តៈ និងវិវដ្តៈ វេលាជិតភ្លឺ ក៏បានត្រាស់ជាព្រះពុទ្ធជាម្ចាស់ ទ្រង់បរិវិតក្កថា តថាគតធ្វើសេចក្តីព្យាយាមដើម្បីបល្ល័ង្កនេះរហូតមកអស់សែនកោដិកប្បយ៉ាងនេះ ហើយប្រថាប់អង្គុយពែនភ្នែនក្នុងឥរិយាបថមួយ រហូតមួយសប្តាហ៍ ។ តមក ទេវតាពួកខ្លះកើត

សេចក្តីសង្ស័យថា នៅមានធម៌ដែលធ្វើឲ្យជាព្រះពុទ្ធផ្សេងទៀតឬ ។ គ្រា នោះព្រះមានព្រះភាគជាម្ចាស់ ទ្រង់ចេញពីសមាបត្តិក្នុងថ្ងៃទី ៨ ទ្រង់ជ្រាប សេចក្តីសង្ស័យរបស់ពួកទេវតា ទើបស្តេចហោះ សម្តែងយមកប្បាដិហារ្យ ដើម្បីកម្ចាត់បង់សេចក្តីសង្ស័យ កាលទ្រង់កម្ចាត់បង់សេចក្តីសង្ស័យរបស់ ទេវតាទាំងនោះហើយ ទ្រង់ប្រថាប់ឈរនៅទិសខាងជើង ចៀងខាងកើត អំពីបល្ល័ង្កបន្តិច ទ្រង់ពិនិត្យមើលទីកន្លែងសម្រេចផលនៃព្រះបារមី ដែល ទ្រង់បំពេញមកអស់ ៤ អសង្ខេយ្យកម្រៃមួយសែនកប្ប ចំពោះព្រះបល្ល័ង្ក និងពោធិព្រឹក្ស ដោយដួងព្រះនេត្រមិនពព្រិច កន្លងទៅមួយសប្តាហ៍ ។ ស្ថានទីនោះឈ្មោះថា **អនិមិ្មសចេតិយ** ។ តមក ស្តេចយាងចង្រ្កមនៅ នឹងរតនចង្រ្កម នៅអំពីទិសខាងកើតចៀងទិសខាងលិចក្នុងរវាងព្រះបល្ល័ង្ក និងកន្លែងទ្រង់ប្រថាប់ឈរ កន្លងទៅមួយសប្តាហ៍ ។ ស្ថានទីនោះឈ្មោះថា **រតនចង្ក្រមចេតិយ** ។ តពីនោះ ពួកទេវតាក្នុងទិសខាងលិច និម្មិតផ្ទះកំពូល ធ្វើដោយកែវទុក ។ ប្រថាប់គង់នៅក្នុងផ្ទះនោះ ទ្រង់ពិចារណាអភិធម្ម- បិដក ដោយចំពោះសមន្តបដ្ឋានអនន្តន័យ ក្នុងអភិធម្មនោះ កន្លងទៅមួយ សប្តាហ៍ ។ ស្ថានទីនោះឈ្មោះថា **រតនឃរចេតិយ** ។ នៅក្នុងទីជិតពោធិ- មណ្ឌលស្ថាននោះឯង កន្លងទៅ ៤ សប្តាហ៍ ដោយអាការយ៉ាងនេះ ក្នុង

សប្តាហ៍ទី ៤ ស្តេចចេញពីគល់ពោធិព្រឹក្ស ស្តេចចូលទៅកាន់ អជបាលនិគ្រោធ ។ ទ្រង់ពិចារណានូវធម៌ក្នុងទីនោះ ប្រថាប់គង់សោយវិមុត្តិសុខ ។ កាលទ្រង់ពិចារណាជ្រើសរើសធម៌ ក៏ទ្រង់ពិចារណាត្រឹមតែន័យនៃអភិធម្មក្នុងធម៌នោះ គឺ គម្ពីរដំបូង ឈ្មោះធម្មសង្គណិប្បករណៈ តពីនោះ ក៏វិភង្គប្បករណៈ ធាតុកថាប្បករណៈ បុគ្គលប្បញ្ញត្តិប្បករណៈ កថាវត្ថុប្បករណៈ យមកប្បករណៈ តពីនោះ មហាបករណៈ ឈ្មោះបដ្ឋាន ។

កាលចិត្តរបស់ព្រះអង្គយាងចុះក្នុងបដ្ឋាន ដ៏ល្អិតសុខុមក្នុងព្រះអភិធម្មនោះ បីតិក៏កើតឡើង ។ កាលបីតិកើតឡើង ព្រះលោហិតក៏ថ្លា កាលព្រះលោហិតថ្លា ព្រះឆវីក៏ស្រស់ថ្លា កាលព្រះឆវីស្រស់ថ្លា ព្រះរស្មីប្រមាណប៉ុនផ្ទះកំពូលជាដើម ក៏ផុសឡើងពីព្រះកាយចំណែកខាងមុខ ផ្សាយទៅរហូតអនន្តចក្រវាឡ ទៅទិសខាងកើត ដូចហ្វូងស្តេចឆទ្ទន្តស្ទុះទៅក្នុងអាកាស ។ ព្រះរស្មីក៏ផុសឡើងចេញពីព្រះកាយចំណែកខាងខ្នង ផ្សាយទៅទិសខាងលិច ។ ផុសឡើងពីចុងព្រះអង្សាខាងស្តាំ ក៏ផ្សាយទៅទិសខាងត្បូង ។ ផុសឡើងពីចុងព្រះអង្សាខាងឆ្វេង ផ្សាយទៅរហូតអនន្តចក្រវាឡក្នុងទិសខាងជើង ។ ព្រះរស្មី មានពណ៌ដូចបណ្តូលកែវប្រវាឡក៏ចេញអំពីផ្ទៃព្រះបាទទម្ទុះប្រឹថពី ញែកទឹកជាពីរចំណែក ទម្លាយកងខ្យល់

ផ្សាយទៅរហូតដល់អជដាកាស រស្មីពណ៌ខៀវ ដូចកម្រងកែវមណីនិលជាធុន ផុសឡើងអំពីព្រះសិរសាទម្ល៉ុះទៅលោក ៦ ជាន់ កន្លងផុតព្រហ្មលោក ៩ ជាន់ ផ្សាយទៅរហូតអជដាកាស ថ្ងៃនោះ ពួកសត្វដ៏ច្រើនមិនមានប្រមាណក្នុងចក្រវាឡ ក៏មានពណ៌ដូចមាសទាំងអស់ ។ ក៏ឯក្នុងថ្ងៃនោះ ព្រះរស្មីទាំងនោះ ដែលផ្សាយចេញពីព្រះសរីរៈរបស់ព្រះមានព្រះភាគជាម្ចាស់ ក៏ប្រព្រឹត្តិទៅរហូតដល់អនន្តលោកធាតុ នៅរហូតសព្វថ្ងៃនេះ ។

ព្រះមានព្រះភាគជាម្ចាស់ កាលបើប្រថាប់គង់នៅក្នុងអជបាលនិគ្រោធ កន្លងទៅមួយសប្តាហ៍ដោយអាការយ៉ាងនេះហើយ តពីនោះ ក៏ប្រថាប់គង់នៅនឹងមុចលិន្ទមួយសប្តាហ៍ទៀត ។ លុះព្រះមានព្រះភាគជាម្ចាស់នោះប្រថាប់គង់ប៉ុណ្ណោះ មហាភ្លៀងដែលមិនមានរដូវកាលក៏ធ្លាក់ ធ្វើឲ្យលំហសកលចក្រវាឡពេញប្រៀប ។ ដំណាលមកថា ភ្លៀងដូច្នោះ ធ្លាក់ក្នុងកាលតែពីរប៉ុណ្ណោះ គឺ ក្នុងកាលស្តេចចក្រពត្តិ ឬព្រះពុទ្ធជាម្ចាស់ឧប្បត្តិ មហាភ្លៀងនោះ ក៏កើតក្នុងពុទ្ធកាលនេះ ។ ក៏កាលមហាភ្លៀងនោះកើតឡើងហើយ ស្តេចនាគឈ្មោះមុចលិន្ទក៏ត្រិះរិះថា ភ្លៀងនេះ កើតឡើងកាលព្រះសាស្តាស្តេចចូលមកកាន់ពិភពរបស់យើង ព្រះអង្គគួរនឹងបានជម្រកបាំងភ្លៀង ។ ស្តេចនាគនោះនៅរិះគិតថា សូម្បីនឹងអាចនិម្មិតប្រាសាទជារតនៈ

៧ ប្រការបាន បើដូច្នោះ ក៏នឹងមិនមានផលធំ ចាំបាច់យើងនឹងធ្វើសេចក្តីខ្វល់ខ្វាយដោយការថ្វាយដល់ព្រះទសពល ហើយទើបពង្រីកអត្តភាពឲ្យធំ យករង្វេលឡោមជុំវិញព្រះសាស្តាជា ៧ ជាន់ បើកពពារបាំងពីខាងលើ ៗ ឱកាសខាងក្នុងរង្វេល ផ្នែកខាងក្រោម មានទំហំប៉ុនលោហប្រាសាទ ។ ស្តេចនាគមានអធ្យាស្រ័យបង្អោនទៅថា ព្រះសាស្តានឹងប្រថាប់នៅដោយឥរិយាបថដែលទ្រង់ត្រូវការ ។ ព្រោះដូច្នោះ ទើបឡោមព័ទ្ធឱកាសធ្វើឲ្យធំទុកយ៉ាងនេះ ។ តុបតែងរតនបល្ល័ង្ក ទុកត្រង់កណ្តាល មានពិដានសំពត់មានកម្រងផ្កាក្រអូប កម្រងផ្កាគ្រប់សព្វ វិចិត្រដោយផ្កាមាស នៅអំពីខាងលើ ។ ប្រទីបប្រេងក្រអូបភ្លឺទាំង ៤ ជ្រុង តាំងប្រអប់ខ្លឹមច័ន្ទ បើកចំហទុកទាំង ៤ ទិស ។ ព្រះមានព្រះភាគជាម្ចាស់ ប្រថាប់នៅនឹងមុចលិន្ទនោះកន្លងទៅមួយសប្តាហ៍ ដោយអាការយ៉ាងនោះ តអំពីនោះ ប្រថាប់គង់នៅនឹងរាជាយតនព្រឹក្សមួយសប្តាហ៍ទៀត ។ សប្តាហ៍ទី ៨ តអំពីរាជាយតនព្រឹក្ស ទ្រង់ទំពាឈើស្ទន់ និងថ្នាំសម៉ ដែលសក្កទេវរាជនាំមកថ្វាយ ទ្រង់ខ្ពុរព្រះឱស្ឋហើយ កាលស្តេចចតុលោកបាលបង្អោនបាត្រសិលា មានតម្លៃពិសេសថ្វាយ ក៏សោយបិណ្ឌបាតរបស់តបុស្សៈ និងភល្លិកៈ ជាពាណិជ្ជ ២ នាក់ ហើយស្តេចត្រឡប់មកប្រថាប់គង់ នៅនឹងអជបាលនិគ្រោធទៀត

ទ្រង់កើតបរិវិតក្កៈនេះ ដែលព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ទ្រង់បរិវិតក្កៈមកហើយ ។

បណ្តាបទទាំងនោះ បទថា **បណ្ឌិតោ** បានដល់ អ្នកប្រកបដោយភាពជាបណ្ឌិត ។ បទថា **ព្យាត្តោ** បានដល់ អ្នកប្រកបដោយសេចក្តីឆ្លាត ។ បទថា **មេធាវី** បានដល់ អ្នកប្រកបដោយបញ្ញាថ្នាក់មូលដ្ឋាន ។ បទថា **អប្បរជក្ខជាតិកា** គឺ សត្វបរិសុទ្ធអស់កិលេស ព្រោះគ្របសង្កត់ទុកបានដោយសមាបត្តិ ។ បទថា **អាជានិស្សតិ** គឺ កំណត់ដឹង ចាក់ធ្លុះ ។ បទថា **ញាណញ្ច បន មេ** បានដល់ ព្រះសព្វញ្ញុតញ្ញាណកើតឡើងដល់តថាគត ។ មានន័យថា ព្រះមានព្រះភាគជាម្ចាស់ មិនសម្រេចព្រះទ័យតាមពាក្យដែលទេវតាទូលប៉ុណ្ណោះ ទ្រង់ពិចារណាដោយព្រះអង្គឯង ដោយព្រះសព្វញ្ញុតញ្ញាណ ក៏ទ្រង់ជ្រាបថា អាឡារតាបសកាលាមបុត្រ ធ្វើកាលកិរិយាបាន ៧ ថ្ងៃ រាប់អំពីថ្ងៃនេះ កើតក្នុងអាកិញ្ចញ្ញាយតនភពហើយ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សំដៅដល់សេចក្តីនោះ ទើបត្រាស់ថា **ញាណញ្ច បន មេ ទស្សនំ ឧទបាទិ** ដូច្នេះ ។ បទថា **មហាជានិយោ** គឺ ឈ្មោះថា **មហាជានិយ** ព្រោះមានសេចក្តីវិនាសធំ ព្រោះជាអ្នកវិនាសសាបសូន្យចាកមគ្គផល ដែលគប្បីសម្រេចក្នុងរវាង ៧ ថ្ងៃ ។ អាឡារតាបសកាលា-

មគោត្រនោះ ក៏មិនមានសោតបសាទដែលនឹងស្តាប់ធម៌ ទោះបីព្រះអង្គស្តេចទៅសម្តែងប្រោស ព្រោះលោកកើតក្នុងអខណៈ ( អសម័យដែលមិនគួរនឹងត្រាស់ដឹង ) សូម្បីបទដែលនឹងនាំមកជាឋានៈនៃព្រះធម្មទេសនានេះ ក៏មិនមាន ដោយហេតុនេះ ទើបទ្រង់សម្តែងថា **មហាជានិយោ ជាតោ** កើតអន្តរាយធំយ៉ាងនេះ ។ បទថា **អភិទោសកាលកតោ** គឺ ធ្វើកាលកិរិយាទៅហើយកាលពីយប់មិញ ។ បទថា **ញាណញ្ច បន មេ** បានដល់ ព្រះសព្វញ្ញុតញ្ញាណបានកើតឡើងហើយ សូម្បីដល់តថាគត ។ មានន័យថា ព្រះមានព្រះភាគជាម្ចាស់ ទ្រង់មិនសម្រេចព្រះទ័យតាមពាក្យរបស់ទេវតា ទ្រង់ប្រមើលមើលដោយព្រះសព្វញ្ញុតញ្ញាណ ទ្រង់ក៏ឃើញថា ឧទ្ទកតាបសរាមបុត្រធ្វើកាលកិរិយាទៅហើយ វេលាយប់ម្សិលមិញនេះ កើតក្នុងនេវសញ្ញានាសញ្ញាយតនភព ។ ព្រោះហេតុនោះ ទើបត្រាស់យ៉ាងនេះ ។ ពាក្យដ៏សេស ក៏ដូចន័យនោះឯង ។ បទថា **ពហុការា** ប្រែថា មានឧបការច្រើន ។ បទថា **បធានបហិតត្តំ ឧបដ្ឋហឹសុ** សេចក្តីថា ពួកភិក្ខុបញ្ចវគ្គីយ៍ទំនុកបម្រុងតថាគត ជាអ្នកតាំងសេចក្តីប៉ុនប្រាថ្នាដើម្បី ធ្វើសេចក្តីព្យាយាមដោយការបោសសំអាតបរិវេណទីលំនៅ ដោយការកាន់បាត្រ ចីវរ ដាប់តាមទៅ ដោយការឲ្យទឹកខ្ពុរមាត់ ឈើស្ទន់ដុសធ្មេញជាដើម ។

ក៏អ្នកណា ដែលឈ្មោះបញ្ចវគ្គិយ៍នោះ ។ គឺ ព្រាហ្មណ៍ ៨ នាក់ បានទាយព្រះសុបិន្ត និងទាយព្រះលក្ខណៈ ក្នុងវេលាដែលព្រះពោធិសត្វប្រសូត្រ តាមគាថាប្រព័ន្ធថា ៖

រាមោ ធជោ លក្ខណោ ជោតិ មន្តីយញ្ញោ
សុភោជោ សុយាមោ សុទត្តោ ឯតេតទា
អដ្ឋ អហេសុ ព្រាហ្មណា ឆឡង្គវា មន្ត
វិយាការីសុ ។

គ្រានោះ បានមានព្រាហ្មណ៍ ៨ នាក់ទាំងនេះ គឺ រាមៈ ធជៈ លក្ខណៈ ជោតិ មន្តិ យញ្ញៈ សុភោជៈ សុយាមៈ សុទត្តៈ ប្រើឆឡង្គវមន្តព្យាករណ៍ ( ព្រះលក្ខណៈ ) ។

បណ្តាព្រាហ្មណ៍ ៨ នាក់នោះ ៣ នាក់ព្យាករណ៍ជាគតិ ២ ថា អ្នកប្រកបដោយលក្ខណៈយ៉ាងនេះ នៅគ្រប់គ្រងផ្ទះក៏នឹងបានជាស្តេចចក្រពត្តិ ចេញបួសក៏នឹងបានត្រាស់ជាព្រះពុទ្ធជាម្ចាស់ ។ ព្រាហ្មណ៍ ៥ នាក់ ព្យាករណ៍គតិតែមួយថា អ្នកប្រកបដោយលក្ខណៈទាំងនេះ នឹងមិនគ្រប់គ្រងផ្ទះ នឹងជាព្រះពុទ្ធជាម្ចាស់តែម្យ៉ាង ។ បណ្តាព្រាហ្មណ៍ទាំងនោះ ៣ នាក់មុន

កាន់តាមបទមន្ត ។ ចំណែក ៥ នាក់នេះ ឈានកន្លងបទមន្ត ។ ពួកគេទើបលះបង់រន្ទាន់ពេញភាជនៈ ដែលខ្លួនបានមកពីពួកញាតិ អស់សេចក្តីសង្ស័យថា ព្រះមហាបុរសនេះ នឹងមិននៅគ្រប់គ្រងផ្ទះ នឹងជាព្រះពុទ្ធជាម្ចាស់តែម្យ៉ាង ទើបបួសជាសមណៈ ឧទ្ទិសព្រះពោធិសត្វ ។ អាចារ្យពួកខ្លះពោលថា ពួកដែលបួសជាបុត្ររបស់ព្រាហ្មណ៍ទាំងនេះ យ៉ាងនេះក៏មាន ។ ពាក្យនេះអដ្ឋកថាជំទាស់ ។ តំណាលមកថា ព្រាហ្មណ៍ ៥ នាក់នោះ កាលនៅកំលោះចេះមន្តច្រើន ដូច្នោះ ព្រាហ្មណ៍ទាំងនោះ ទើបនៅក្នុងឋានៈអាចារ្យ ។ ក្រោយមក ព្រាហ្មណ៍ទាំងនោះគិតគ្នាថា ពួកយើងមិនអាចលះបង់បុត្រ-ភរិយាបួសបាន ទើបបួសនៅក្នុងកាលជាកំលោះតែម្តង ប្រើប្រាស់សេនាសនៈដែលគួរមនោរម្យ ត្រាច់ទៅ ។ តែត ៗ មក បានសួរគ្នាថា អ្នកដ៏ចម្រើន ព្រះមហាបុរសចេញបួសហើយឬ ។ ពួកមនុស្សទាំងឡាយពោលថា ពួកអ្នកនឹងជួបព្រះមហាបុរសបានពីទីណា លោកសោយសម្បត្តិដូចជាទេវតា កណ្តាលចំណោមនាងរបាំ ៣ ប្រភេទ លើប្រាសាទ ៣ រដូវ ។ ព្រាហ្មណ៍ទាំង ៥ នាក់គិតថា ញាណរបស់មហាបុរសនៅមិនទាន់ចាស់ក្លា ហើយនាំគ្នាខ្វល់ខ្វាយតិច ។

សួរថា ក៏ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគជាម្ចាស់ ត្រាស់ថា

បញ្ចវគ្គិយ៍ មានឧបការៈដល់តថាគតច្រើន ព្រះអង្គនឹងទ្រង់សម្តែងធម៌ដល់ពួកអ្នកដែលមានឧបការៈប៉ុណ្ណោះ ទ្រង់មិនសម្តែងធម៌ដល់ពួកអ្នកដែលមិនមានឧបការៈឬ ។ ឆ្លើយថា មិនមែនទ្រង់មិនសម្តែងធម៌ទេ ការពិតព្រះអង្គទ្រង់ប្រមើលមើលអាឡារតាបសកលាមគោត្រ និងឧទ្ទកតាបស-រាមបុត្រ ដោយការសន្សំបារមី ។ តែវៀរព្រះអញ្ញាកោណ្ឌញ្ញៈចេញ ក៏មិនអាចមានអ្នកធ្វើឲ្យជាក់ច្បាស់ធម៌បានមុនគេ ក្នុងពុទ្ធមណ្ឌលនេះ ។ ព្រោះហេតុអ្វី ។ ព្រោះអញ្ញាកោណ្ឌញ្ញៈ មានឧបនិស្ស័យ ៣ យ៉ាង ។

តំណាលមកថា ក្នុងជាតិមុនមានបងប្អូន ២ នាក់ ។ ក្នុងវេលាធ្វើបុណ្យ បុរសជាបងគិតនឹងថ្វាយទានបាយយ៉ាងវិសេស ៩ ដង ក្នុងរដូវស្រូវមួយរដូវ ។ គាត់ថ្វាយទានបាយយ៉ាងវិសេសក្នុងពេលសាបព្រោះ ។ វេលាស្រូវផើមក៏ប្រឹក្សាជាមួយប្អូនថា ប្អូនអើយ វេលាស្រូវផើម នឹងប្រូតស្រូវផើមថ្វាយទាន ។ ប្អូនប្រាប់ថា បងត្រូវការនឹងធ្វើស្រូវខ្ចី ឲ្យខូចឬ បងដឹងថាប្អូនមិនព្រម ក៏បែងចែកស្រែគ្នា ប្រូតស្រូវផើមពីស្រែចំណែករបស់ខ្លួន ចម្រាញ់យកប្រេងផ្សំជាមួយទឹកដោះថ្លា និងទឹកអំពៅថ្វាយទាន ។ គាត់ក៏ឲ្យធ្វើអង្ករ ដែលប្រូតកាត់យ៉ាងពិសេសថ្វាយទាន វេលាចងកណ្តាប់ក៏ឲ្យរៀបចំ ពេលដែស្រូវអាចធ្វើអំបុកបាន ក៏ធ្វើអំបុកយ៉ាងពិសេសថ្វាយ

ទាន វេលាប្រូតថ្វាយទានយ៉ាងពិសេស ។ វេលាពូកកណ្ដាប់ជាដើម ក៏ឲ្យថ្វាយទានយ៉ាងពិសេស , វេលាជញ្ជូនកណ្ដាប់ចូលលាន ក៏ថ្វាយទានយ៉ាងពិសេស , វេលាបញ្ជាន់ស្រូវ ក៏ថ្វាយទានយ៉ាងពិសេស , វេលាជញ្ជូនស្រូវចូលជង្រុក ក៏ចាត់ចែងថ្វាយទានយ៉ាងពិសេស ៩ លើក ក្នុងរដូវស្រូវមួយរដូវ ដូចពោលមកនេះ ។ ចំណែកប្អូនរបស់គេ អស់រដូវស្រូវហើយ ទើបថ្វាយទាន ។ ទាំងពីរនាក់នោះ បង ក៏គឺ ព្រះអញ្ញាកោណ្ឌញ្ញៈ ប្អូន ក៏គឺ សុភទ្ទបរិព្វាជក ។ វៀរព្រះថេរៈចេញ ក៏មិនមានអ្នកដទៃៗ ដែលនឹងអាចធ្វើឲ្យជាក់ច្បាស់នូវធម៌បានមុន ព្រោះលោកថ្វាយទានដ៏ពិសេស ៩ លើក ក្នុងរដូវស្រូវមួយរដូវ ។ ក៏ពាក្យថា **ពហុការា ខោ មេ បញ្ចវគ្គិយា** នេះ ត្រឹមតែត្រាស់ ដោយទ្រង់រលឹកដល់ឧបការៈប៉ុណ្ណោះ ។

បទថា **ឥសិបតនេ មិគទាយេ** សេចក្ដីថា នៅក្នុងប្រទេសនោះ កាលព្រះពុទ្ធជាម្ចាស់ មិនទាន់ឧបត្តិឡើង ព្រះបច្ចេកពុទ្ធទាំងឡាយ ឈប់សម្រាកដោយនិរោធសមាបត្តិរហូតមួយសប្ដាហ៍ នឹងនៅភ្នំគន្ធមាទន៍ ចេញអំពីនិរោធសមាបត្តិ ហើយទំពាឈើស្ទន់ឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋស្រះអានោតត្តៈ កាន់បាត្រចីវរ ហោះទៅហើយចុះឃ្លុំចីវរក្នុងទីនោះ ហើយត្រាច់ទៅបិណ្ឌបាត្រក្នុងព្រះនគរ ឆាន់ជាស្រេច ដល់វេលា ក៏ហោះពីទីនោះ

ទៅ ៗ ព្រៃនោះ ឥសីទាំងឡាយចុះ និងចូលទៅក្នុងទីនោះ ហេតុនោះ ទីនោះទើបមានឈ្មោះថា **ឥសិបតន** ចំណែកដែលហៅថា **មិគទាយ** នោះ ព្រោះឲ្យអភ័យដល់សត្វម្រឹគទាំងឡាយ ដោយហេតុនោះ លោកទើបហៅថា **ឥសិបតនេ មិគទាយេ** ។

(៦៣) បទថា **អន្តរា ច គយំ អន្តរា ច ពោធឹ** បានដល់ ក្នុងស្ថានទីចម្ងាយ ៣ គាវុត ក្នុងចន្លោះនៃតំបន់គយា និងពោធិព្រឹក្ស ។ តាំងពីពោធិមណ្ឌលស្ថាន ដល់តំបន់គយា ៣ គាវុត ។

ក្រុងពារាណសី ២៨ យោជន៍ ។ ឧបកាជីវក បានឃើញព្រះមានព្រះភាគជាម្ចាស់ ក្នុងចន្លោះពោធិស្ថាន និងតំបន់គយា ។ តែព្រោះប្រកបដោយ **អន្តរា** ស័ព្ទ ទើបលោកធ្វើជាទុតិយាវិភត្តិ ។ តែក្នុងទី នេះ អ្នកអក្សរសាស្ត្រប្រកបដោយ **អន្តរា** ស័ព្ទ តែម្យ៉ាងប៉ុណ្ណោះថា **អន្តរា គាមញ្ច នទិញ្ច យាតិ** នៅចន្លោះស្រុក និងស្ទឹង **អន្តរា** ស័ព្ទ នោះក៏ប្រកបសូម្បីដោយបទទី ២ , កាលមិនប្រកប ក៏មិនដល់ទុតិយាវិភត្តិ តែក្នុងទីនេះ លោកប្រកបហើយ ទើបបានពោលយ៉ាងនេះ ។ បទថា **អទ្ធានមគ្គប្បដិបន្នំ** សេចក្តីថា ដើរផ្លូវដែលរាប់ថាឆ្ងាយ អធិប្បាយថា ដើរផ្លូវវែង ។ ពិតហើយ សម័យដែលដើរផ្លូវឆ្ងាយកន្លះយោជន៍ ក៏ឈ្មោះថា ផ្លូវ

ឆ្ងាយ ព្រោះព្រះបាលីក្នុងវិភង្គ មានជាដើមថា គប្បីធាន់ ដោយគិតនឹងដើរផ្លូវកន្លះយោជន៍ ។ តាំងពីពោធិមណ្ឌលស្ថាន ដល់តំបន់គយា ផ្លូវ ៣ គាវុត ។ បទថា **សព្វាភិភូ** បានដល់ គ្របសង្កត់ផ្លូវដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ហើយតាំងនៅ ។ បទថា **សព្វវិទូ** សេចក្តីថា បានដឹង បានដល់ ត្រាស់ដឹងនូវទៅដល់ធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ ។ បទថា **សព្វេសុ ធម្មេសុ អនូបលិត្តោ** បានដល់ មិនជាប់នៅ ព្រោះអស់កិលេសក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងនោះ ។ បទថា **សព្វញ្ជហោ** បានដល់ លះធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៣ តាំងនៅ ។ បទថា **តណ្ហក្ខយេ វិមុត្តោ** បានដល់ ផុតចាកអារម្មណ៍ ក្នុងព្រះនិព្វានជាទីអស់ទៅនៃតណ្ហា ។ បទថា **សយំ អភិញ្ញាយ** បានដល់ ដឹងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ ដោយខ្លួនឯង ។ បទថា **កមុទ្ទិសេយ្យំ** សេចក្តីថា យើងនឹងគប្បីលើកអ្នកដទៃថា អ្នកនោះជាអាចារ្យរបស់តថាគត ។ បទថា **ន មេ អាចរិយោ អត្ថិ** សេចក្តីថា តថាគតមិនមានអាចារ្យក្នុងលោកុត្តធម៌ ។ បទថា **នត្ថិ មេ បដិបុគ្គលោ** សេចក្តីថា មិនមានបុគ្គលដែលនឹងដូចជាតថាគត ។ បទថា **សម្មាសម្ពុទ្ធោ** បានដល់ ត្រាស់ដឹងឯងនូវសច្ចៈ ៤ ដោយប្រពៃ ដោយហេតុ ដោយន័យ ។ បទថា **សីតិភូតោស្មិ** ឈ្មោះថា

ជាអ្នកត្រជាក់ ព្រោះរលត់ភ្លើង គឺ អស់កិលេសមិនសល់ ឈ្មោះថា រលត់ ព្រោះកិលេសទាំងឡាយរលត់ទៅ ។ បទថា **កាសិនំ បុរំ** បានដល់ នគរក្នុងដែនកាសី ។ បទថា **អហញ្ញិ អមត ទុន្ទុភឹ** សេចក្តីថា ដើរផ្លូវ បំណងនឹងវាយអមតភេរី ដើម្បីឲ្យសត្វមានកែវភ្នែកបានឃើញធម៌ ។ បទ ថា **អរហសិ អនន្តជិនោ** បានដល់ លោកគួរជាអនន្តជិនឬ ។ បទថា **ហុវេយ្យាវុសោ** សេចក្តីថា ឧបកាជីវកពោលថា អ្នកមានអាយុ នឹងគប្បី មានឈ្មោះយ៉ាងនោះឬ ។ បទថា **បក្កាមិ** បានដល់ បានទៅកាន់ជនបទ ឈ្មោះថា **វង្គហារ** ។

## រឿង ឧបកាជីវក

ក្នុងជនបទនោះ ឧបកាជីវកអាស្រ័យនៅភូមិព្រានបរបាញ់សត្វ ។ ប្រធានព្រានម្រឹគជាអ្នកទំនុកបម្រុងគាត់ ។ ក្នុងជនបទនោះ មានអ្នក នេសាទកាចសាហាវ ឲ្យគាត់រស់នៅ ដោយភាជនៈតែមួយ ។ ព្រានបរបាញ់ ម្រឹគ ទៅបរបាញ់ក្នុងទីឆ្ងាយ ទើបប្រាប់ធីតា ឈ្មោះនាវាថា កុំប្រហែស ក្នុងព្រះអរហន្តរបស់ពួកយើង និងពួកកូនជាបង ៗ ។ ក៏ធីតារបស់ព្រាន នោះ មានរូបឆោមគួរសរសើរ សម្បូរដោយទ្រង់ទ្រាយសណ្ឋាន , ថ្ងៃស្អែក

ឡើង ឧបកៈមកផ្ទះ ប្រទះស្រីវ័យក្មេងនោះចូលមកទំនុកបំរុង ធ្វើការប្រតិបត្តិគ្រប់យ៉ាង កើតសេចក្ដីស្រឡាញ់យ៉ាងខ្លាំងក្លា មិនអាចស្ងួម្បីតែនឹងស៊ី ក៏កាន់យកភាជនៈអាហារទៅទីលំនៅ របស់ខ្លួនបានដាក់អាហារទុកម្ខាងគិតថា បើយើងបាននាងនាវា ទើបនឹងមានជីវិត បើមិនបាន ក៏នឹងស្លាប់ ហើយដេកអត់អាហារ ។ ថ្ងៃទី ៧ នាយព្រានត្រឡប់មក សួរធីតាអំពីរឿងរបស់ឧបកៈ ។ ធីតាប្រាប់ថា គាត់មកតែមួយថ្ងៃប៉ុណ្ណោះ ហើយមិនបានមកទៀតទេពុក ។ ទាំងគ្រឿងប្រដាប់មកពីព្រៃនោះឯង នាយព្រានប្រាប់ធីតាថា ពុកនឹងចូលទៅសួរគាត់ខ្លួនឯង ហើយទៅភ្លាម ចាប់ជើងសួរថា លោកម្ចាស់ដ៏ចម្រើន លោកមិនសប្បាយព្រោះរឿងអ្វីទៅ ។ ឧបកៈដកដង្ហើម ននៀលទៅមក ។ នាយព្រានពោលថា លោកម្ចាស់ដ៏ចម្រើនប្រាប់មកចុះ ខ្ញុំអាចធ្វើបាន ក៏នឹងធ្វើគ្រប់យ៉ាង ។ ឧបកៈ ទើបប្រាប់ថា បើយើងបាននាងនាវា ក៏នឹងមានជីវិតរស់នៅ បើមិនបាន នឹងស្លាប់ក្នុងទីនេះឯងប្រសើរជាង ។ នាយព្រានសួរថា លោកម្ចាស់ដ៏ចម្រើន លោកចេះសិល្បៈអ្វីខ្លះទេ ។ ឧបកៈឆ្លើយថា យើងមិនចេះទេ ។ នាយព្រានពោលថា កាលមិនចេះសិល្បៈអ្វី ៗ នឹងទៅគ្រប់គ្រងផ្ទះបានឬទេ ។ ឧបកៈនោះ ទើបពោលថា យើងមិនចេះសិល្បៈពិតឲ្យ ៗ តែយើងជាអ្នក

វែកសាច់របស់លោកទៅលក់បាន ។ នាយព្រាន គិតថា គាត់ពេញចិត្ត នឹងកិច្ចការរបស់យើង ទើបឲ្យសំពត់ស្លៀកមួយផ្ទាំងនោះ ទៅផ្ទះ ប្រគល់ ជីតាឲ្យ ។ អាស្រ័យការផ្សំផ្គុំរបស់អ្នកទាំងពីរនោះ ក៏កើតបុត្រមួយ ។ ទាំងពីរនាក់ស្វាមីភរិយា ទើបតាំងឈ្មោះបុត្រថា សុភទ្ទះ ។ ពេលបុត្រយំ នាងនិយាយថា អាកូនអ្នកវែកសាច់ អាកូនព្រានអ្នកបរបាញ់សត្វ កុំយំ ដូច្នេះជាដើម ចំអកឡកឡឺយដោយចម្រៀងបំពេរកូន ។ ឧបកៈ ពោលថា ស្រីល្អ នាងឯងយល់ថា ខ្ញុំមិនមានទីពឹងឬ ខ្ញុំមានសំឡាញ់ម្នាក់ឈ្មោះ អនន្តជិន ខ្ញុំនឹងទៅកាន់សម្នាក់របស់គេ ។ នាងនាវាជីងថា ស្វាមីលំបាកចិត្ត ដោយអាការយ៉ាងនេះ ទើបពោលរឿយ ៗ ។ ថ្ងៃមួយ ឧបកៈនោះ មិនលា អ្នកណា ក៏សំដៅទៅដល់មជ្ឈិមប្រទេស ។ ក៏សម័យនោះ ព្រះមានព្រះភាគ ជាម្ចាស់ ប្រថាប់នៅនឹងវត្តជេតពនមហាវិហារ នាក្រុងសាវត្ថី ទ្រង់ផ្តាំភិក្ខុ ទាំងឡាយទុកមុនថា ភិក្ខុទាំងឡាយ អ្នកណាមកសួររកអនន្តជិន ពួកអ្នក ចូរចង្អុលប្រាប់ដល់គេ ។ សូម្បីជីវកក៏សួររឿយៗ ទៅថា អនន្តជិន នៅ ឯណា ពេលមកដល់ក្រុងសាវត្ថីតាមលំដាប់ ឈរនៅកណ្តាលព្រះវិហារ សួរថា អានន្តជិន នៅឯណា ។ ភិក្ខុទាំងឡាយ ក៏នាំគាត់ទៅដល់សម្នាក់ ព្រះមានព្រះភាគជាម្ចាស់ ។ ឧបកៈនោះ ឃើញព្រះមានព្រះភាគជាម្ចាស់

ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចាំខ្ញុំម្ចាស់បានទេ ទ្រង់ត្រាស់ថា អើ ឧបកៈ ចាំបាន ក៏អ្នកនៅឯណា ទូលថា វង្កហារជនបទព្រះអង្គ ។ ទ្រង់ត្រាស់ថា ឧបកៈ អ្នកចាស់ហើយណា បួសបានឬ ។ ទូលថា ល្មមនឹងបួសបាន ព្រះអង្គ ។ ព្រះមានព្រះភាគជាម្ចាស់ ឲ្យបួសប្រទានកម្មដ្ឋានដល់គេ ។ ឧបកៈនោះ ធ្វើកិច្ចក្នុងកម្មដ្ឋាន តាំងនៅក្នុងអនាគាមិផល ធ្វើកាលកិរិយាហើយ បដិសន្ធិក្នុងជាន់អវិហា ហើយសម្រេចព្រះអរហត្តក្នុងខណៈកើតនោះឯង ។ ពិតណាស់ ជន ៧ នាក់ លុះកើតក្នុងសុទ្ធាវាសជាន់អវិហា ក៏សម្រេចជាព្រះអរហត្ត ។ ក្នុងចំនួន ៧ នាក់ នោះ ឧបកៈជាមនុស្សម្នាក់ ។ សមពិតដូចពាក្យដែលលោកពោលយ៉ាង នេះថា

ភិក្ខុ ៧ អង្គផុតហើយ អស់ភគៈ ទោសៈហើយ ឆ្លង
កិលេស ដែលផ្សាយទៅក្នុងលោក ចូលដល់សុទ្ធា
វាសព្រហ្ម ជាន់អវិហា គឺ មនុស្ស ៣ នាក់បានដល់
ឧបកៈ , បលគណ្ឌ , បុក្កុសាតិ , ៤ នាក់ទៀត គឺ
ភទ្ទិយ , ខណ្ឌទេវ , ពាហុទត្តិ និងបិង្គិយៈ ទាំង ៧
នាក់នោះ លះកាយមនុស្សហើយ ចូលដល់កាយជា
ទិព្វ ។

(៦៤) បទថា **សណ្ណបេសុំ** បានដល់ ធ្វើកតិកា ។ បទថា **ពាហុ-លិកោ** បានដល់ បដិបត្តិដើម្បីប្រយោជន៍ ដល់សេចក្តីប្រាថ្នាច្រើនក្នុងចីវរជាដើម ។ បទថា **បធានវិព្ភន្តោ** បានដល់ សាបសូន្យចាកសេចក្តីព្យាយាម ។ បទថា **អាវត្តោ ពាហុល្លាយ** បានដល់ វិលមកដើម្បីត្រូវការចីវរជាដើមច្រើនៗ ។ បទថា **អបិច ខោ អាសនំ ឋបេតព្វំ** សេចក្តីថា បញ្ញត្តិយ៍ពោលថា គប្បីក្រាលត្រឹមអាសនៈទុក សម្រាប់លោកអ្នក ដែលកើតក្នុងត្រកូលខ្ពស់ ។ បទថា **នាសក្ខឹសុ** សេចក្តីថា បញ្ញត្តិយ៍ត្រូវអានុភាពព្រះពុទ្ធជាម្ចាស់គ្របសង្កត់ទុក ទើបតាំងនៅក្នុងកតិការបស់ខ្លួនមិនបាន ។ បទថា **នាមេន ច អាវុសោ វាទេន ច សមុទ ចរន្តិ** សេចក្តីថា ហៅគោតមៈ ហៅអាវុសោ អធិប្បាយថា ពោលពាក្យបែបនេះថា អាវុសោគោតម វេលាដែលលោកបំពេញព្យាយាមនៅទីឧរុវេលា ពួកយើងកាន់បាត្រ ចីវរ ត្រាច់ទៅ ថ្វាយទឹកខ្ពុរព្រះឱស្ឋ និងឈើជម្រះធ្មេញ ( ឈើស្ទន់ ) បោសបរិវេណទីលំនៅ ខាងក្រោយមក នរណានឹងធ្វើវត្តបដិបត្តិដល់លោក កាលពួកយើងរត់ចោលទៅហើយ លោកមិនគិតខ្វះទេឬ ។ បទថា **ឥរិយាយ** បានដល់ ដោយការដើរទៅដែលធ្វើបានដោយលំបាក ។ បទថា **បដិបទាយ** បានដល់ ការបដិបត្តិ ដែលធ្វើបានដោយលំបាក ។

បទថា **ទុក្ករការិកាយ** បានដល់ ការធ្វើបានដោយលំបាក មានការធ្វើអាហារដោយសណ្ដែកខៀវ សណ្ដែកក្អែប មួយទូកដៃ ឬកន្លះទូកដៃជាដើម ។ បទថា **អភិជានាថ មេ នោ** បានដល់ ពួកអ្នកធ្លាប់ដឹងដល់ពាក្យដែលតថាគតពោលនេះឬ ។ បទថា **ឯវរូបំ ភាសិតមេតំ** សេចក្ដីថា ការត្រាស់ពាក្យបែបនេះ ។ អធិប្បាយថា អ្នកមានអាយុ តថាគតមកពេលយប់ ឬពេលថ្ងៃ ដើម្បីសង្គ្រោះអនុគ្រោះពួកអ្នក កុំគិតឡើយក្នុងការបំពេញព្យាយាមនៅឯឧរុវេលា ឱកាស ឬនិមិត្តប្រាកដដល់តថាគត ព្រោះដូច្នោះទើបបានពោលពាក្យបែបនេះខ្លះ ។ ពួកណាមានសតិ ដោយព្រះតម្រាស់មួយបទប៉ុណ្ណោះ កើតសេចក្ដីគោរពជឿថា ណ្ហើយចុះ អ្នកនេះ ជាព្រះពុទ្ធជាម្ចាស់ពិតប្រាកដហើយ ហើយពោលថា **នោ ហេតំ ភន្តេ** ពាក្យនោះមិនធ្លាប់បានស្ដាប់ទេព្រះអង្គ ។ បទថា **អសក្ខឹ ខោ អហំ ភិក្ខវេ បញ្ច-វគ្គិយេ ភិក្ខូ សញ្ញាបេតុំ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ តថាគតអាចធ្វើឲ្យភិក្ខុបញ្ចវគ្គីយ៍ដឹងថា តថាគត ជាព្រះពុទ្ធ ជាព្រះអរហន្ត ។ ក៏គ្រានោះ ព្រះមានព្រះភាគជាម្ចាស់ ស្ដេចមកក្នុងថ្ងៃឧបោសថ ទ្រង់ធ្វើឲ្យភិក្ខុបញ្ចវគ្គីយ៍ បានដឹងសេចក្ដីដែលព្រះអង្គជាព្រះពុទ្ធ ត្រាស់ធម្មចក្កប្បវត្តន-សូត្រ ធ្វើព្រះកោណ្ឌញ្ញៈឲ្យជាកាយសក្ខី ។ វេលាចប់ព្រះសូត្រ ព្រះថេរៈ

តាំងនៅក្នុងសោតាបត្តិផល ព្រមដោយព្រហ្ម ១៨ កោដិ ។ ព្រះអាទិត្យអស្តង្គត ទេសនាក៏ចប់ហើយដែរ ។ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំព្រះវស្សា ក្នុងព្រៃឥសិបតនមិគទាយវ័ននោះឯង ។ ពាក្យថា **ទ្វេបិ សុទំ ភិក្ខវេ ភិក្ខូ ឱវទាមិ** ជាដើម ត្រាស់ដើម្បីសម្តែងកាលស្តេចមិនទាន់ចូលស្រុក សូម្បីដើម្បីបិណ្ឌបាត តាំងពីថ្ងៃមួយរោច ។ ដើម្បីនឹងទ្រង់ជម្រះមន្ទិលដែលកើតឡើងក្នុងព្រះកម្មដ្ឋានរបស់ភិក្ខុទាំងឡាយនោះ ។ ព្រះមានព្រះភាគជាម្ចាស់ ទើបបានប្រថាប់នៅក្នុងព្រះវិហារប៉ុណ្ណោះ ។ ភិក្ខុទាំងនោះ បានទៅកាន់សំណាក់ព្រះមានព្រះភាគជាម្ចាស់ ហើយទូលសួរដល់មន្ទិលរបស់កម្មដ្ឋាន ដែលកើតឡើង ។ ចំណែកព្រះមានព្រះភាគជាម្ចាស់ ស្តេចទៅកាន់ទី ដែលភិក្ខុទាំងនោះអង្គុយ ទ្រង់បន្ទោរបង់មន្ទិល ។ លំដាប់នោះ បណ្តាភិក្ខុបញ្ចវគ្គីយ៍ទាំងនោះ ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់នាំភត្តចេញទៅយ៉ាងនេះ ទូន្មានហើយ ព្រះវប្បត្ថេរ បានជាព្រះសោ-តាបន្នៈ ក្នុងថ្ងៃបាដិបទ ( ១រោច ) , ថ្ងៃ ២ រោច ព្រះភទ្ទិយៈ , ថ្ងៃ ៣ រោច ព្រះមហានាម , ថ្ងៃ ៤ រោច ព្រះអស្សជិ ។ ក្នុងថ្ងៃ ៥ រោចនៃកាឡបក្ខ ព្រះមានព្រះភាគជាម្ចាស់ ឲ្យព្រះបញ្ចវគ្គីយ៍ទាំងអស់ប្រជុំរួមគ្នា ត្រាស់អនត្តលក្ខណសូត្រ ។ វេលាចប់ព្រះសូត្រ ភិក្ខុទាំងអស់ តាំងនៅក្នុងព្រះ

អរហត្តផល ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា **អថខោ ភិក្ខវេ បញ្ចវគ្គិយា ភិក្ខូ ។បេ។ អនុត្តរំ យោគក្ខេមំ និព្វានំ អជ្ឈគមឹសុ** យ៉ាងនេះ ។ បទថា **នត្ថិទានិ បុនព្ភវោ** សេចក្ដីថា ព្រះមានព្រះជាម្ចាស់ បានត្រាស់កថាមគ្គណាទុកមុន កាលណាទ្រង់សម្ដែងអនុសន្ធិជាមួយគ្នាយ៉ាងនេះថា សូម្បីពួកអ្នក ក៏ឡើងកាន់ផ្លូវរបស់តថាគត និងរបស់បញ្ចវគ្គិយ៍ ការស្វែងរករបស់ពួកអ្នក ឈ្មោះថា **អរិយបរិយេសនា** ដូច្នេះ ទើបទ្រង់នាំកថាមគ្គត្រឹមប៉ុណ្ណោះ ។

(២៥) ឥឡូវនេះ ក៏ព្រោះហេតុស្វែងរកកាមគុណ ៥ ជាអនរិយបរិយេសនា សូម្បីរបស់ពួកបព្វជិតអ្នកមិនពិចារណា បរិភោគបច្ច័យ ៤ ដោយអំណាចកាមគុណ ៥ ដូច្នោះ ដើម្បីនឹងទ្រង់សម្ដែងសេចក្ដីនោះ ទើបត្រាស់ថា **បញ្ចិមេ ភិក្ខវេ កាមគុណា** ជាដើម ។ ក្នុងកាមគុណ ៥ នោះ កាមគុណ ៤ មានរូប ដែលគប្បីដឹងបានដោយចក្ខុជាដើម រមែងមានក្នុងបច្ច័យ ៤ មានបាត្រ និងចីវរជាដើម ដែលបានមកថ្មី ។ ចំណែករសក្នុងកាមគុណនោះ គឺ រសក្នុងការបរិភោគកាមគុណ សូម្បីទាំង ៥ រមែងមានក្នុងបិណ្ឌបាត និងភេសជ្ជៈ ដែលពេញចិត្ត ។ កាមគុណ ៤ រមែងមានក្នុងសេនាសនៈ បរិក្ខារសូម្បីនោះ ក៏គឺ រសក្នុងការបរិភោគនោះ

ឯង ។ ព្រោះហេតុអ្វី ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់ផ្ដើមថា **យេ ហិ កេចិ ភិក្ខវេ** យ៉ាងនេះ ។ ព្រោះថា ព្រះមានព្រះភាគជាម្ចាស់ កាលបើទ្រង់សម្ដែងកាមគុណ ៥ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីត្រូវការ នឹងបដិសេធពួកដែលពោលយ៉ាងនេះថា ឈ្មោះថា អនរិយបរិយេសនា តាំងពីបួស និងជាអរិយបរិយេសនា របស់បព្វជិត បានពីទីណា ទើបទ្រង់ ផ្ដើមទេសនានេះ ដើម្បីសម្ដែងថា ការបរិភោគ ដោយការមិនពិចារណា បច្ច័យ ៤ ជាអនរិយបរិយេសនា សូម្បីរបស់បព្វជិត ។ បណ្ដាបទទាំងនោះ បទថា **គធិតា** បានដល់ ត្រេកអរដោយសេចក្ដីត្រេកអរ ព្រោះតណ្ហា ។

បទថា **មុច្ឆិតា** បានដល់ ឱនក្រាបដោយសេចក្ដីគោរព ដោយ អំណាចតណ្ហា ។ បទថា **អជ្ឈាបន្នា** បានដល់ ត្រូវតណ្ហាគ្របសង្កត់ ហើយ ។ បទថា **អនាទីនវ ទស្សាវិនោ** បានដល់ មិនឃើញទោស ។ បច្ចវេក្ខណញ្ញាណ លោកហៅថា និស្សរណៈ ក្នុងពាក្យថា **អនិស្សរ-ណបញ្ញា** វៀរបច្ចវេក្ខណញ្ញាណនោះ ។

(៦៦) ឥឡូវនេះ កាលទ្រង់សម្ដែងឧបមាដែលនឹងសាធកខ្លឹមសារ នោះ ទើបត្រាស់ថា **សេយ្យថាបិ ភិក្ខវេ** ជាអាទិ៍ ។ គប្បីជ្រាបសេចក្ដីប្រៀប ធៀបក្នុងពាក្យនោះ យ៉ាងនេះ ។ សេចក្ដីថា សមណព្រាហ្មណ៍ ដូចសត្វ

ម្រឹគក្នុងព្រៃ , បច្ច័យ ៤ ដូចជាអន្ទាក់ ដែលព្រានដាក់ទុកក្នុងព្រៃ វេលាដែលសមណព្រាហ្មណ៍ទាំងនោះ មិនពិចារណា បរិភោគបច្ច័យ ៤ ដូចវេលាដែលព្រាននោះ ដាក់អន្ទាក់ហើយដេក វេលាដែលសមណព្រាហ្មណ៍ទាំងឡាយ ត្រូវមារធ្វើតាមអំពើចិត្ត ធ្លាក់ទៅក្នុងអំណាចមារ ដូចដែលព្រានមក សត្វម្រឹគទៅណាមិនបានតាមអំពើចិត្ត ។ ម្យ៉ាងទៀត ការពិចារណាបច្ច័យ ៤ ហើយ បរិភោគរបស់សមណព្រាហ្មណ៍ គប្បីឃើញដូចវេលាដែលសត្វម្រឹគនៅមិនទាន់ជាប់អន្ទាក់ ដេកសង្កត់អន្ទាក់ ការមិនធ្លាក់ទៅកាន់អំណាចព្រានដែលមក សត្វម្រឹគក៏ទៅបានតាមចិត្ត ។ បទថា **វិសង្ហា** បានដល់ ផុតពីសេចក្តីខ្លាច ផុតពីសេចក្តីសង្ស័យ ។ បទដ៏សេសក្នុងទីគ្រប់កន្លែងមាន សេចក្តីងាយទាំងអស់ ។

( ចប់ អដ្ឋកថា ចាសរាសិសូត្រទី ៦ )

# អដ្ឋកថា

## ចុល្លហត្ថិបទោបមសូត្រ ទី ៧

(៦៧) *ចុល្លហត្ថិបទោបមសូត្រ ផ្ដើមឡើងថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ៖*

*គប្បីជ្រាបវិនិច្ឆ័យ ក្នុងចុល្លហត្ថិបទោបមសូត្រនោះ ដូចតទៅនេះ បទថា* ***សព្វសេតេន វឡវាភិរថេន*** *សេចក្ដីថា រថដែលទឹមដោយលា ៤ ជំពូក សសុទ្ធ ដែលលោកពោលទុកយ៉ាងនេះថា បានឮថា សេះស មានគ្រឿងប្រដាប់សដែលទឹមហើយ រថសមានគ្រឿងប្រដាប់ស មានបរិវារស រស្មីស រំពាត់ស ឆត្រស សំពត់ជួតក្បាលក៏ស សំពត់ស ស្បែកជើងស ដោយផ្លិតវាលវិជ្ជនីស ។ ក៏ជម្មតាថា រថនេះមាន ២ យ៉ាង គឺ រថចំបាំង និងរថសម្រាប់តុបតែង ។ បណ្ដារថទាំង ២ នោះ រថចំបាំងមានទ្រង់ទ្រាយ ៤ ជ្រុង មិនធំធូនអាចដាក់បាន ២-៣ នាក់ រថសម្រាប់តុបតែង ធំទាំងបណ្ដោយទាំងទទឹង ។ ក្នុងរថតុបតែងមនុស្ស ៨ នាក់ ឬ ១០ នាក់ គឺ មនុស្សបាំងឆត្រ មនុស្សកាន់ផ្លិតវាវិជ្ជនី មនុស្សកាន់ផ្លិតស្លឹកត្នោត អាចនឹងឈរ អង្គុយ ឬដេក បានតាមស្រួល សូម្បីរថនេះ*

ឈ្មោះថា រថតុបតែងតែម្យ៉ាង ។ រថទាំងអស់នោះ ព្រមដោយកង់ បង្អួច និងទូករថ ស្រោបដោយប្រាក់ ។ ធម្មតា លាក៏ពណ៌ស សូម្បីគ្រឿងតុបតែងសេះទាំងនោះ ក៏ធ្វើដោយប្រាក់ សូម្បីខ្សែក៏ជ្រលក់ទឹកប្រាក់ សូម្បីសំពត់ក៏ស្រោបដោយប្រាក់ សូម្បីព្រាហ្មណ៍ក៏ស្លៀកសំពត់ស ដណ្តប់សំពត់ស លាបដោយគ្រឿងស តុបតែងកម្រងផ្កាស ពាក់ចិញ្ចៀនទាំង ១០ ម្រាម ពាក់ទំហូទាំងសងខាង រួមសេចក្តីដូចពោលមកនេះជាដើម សូម្បីគ្រឿងតុបតែងរបស់ថេនោះ ក៏ជាប្រាក់ទាំងអស់ ។ សូម្បីព្រាហ្មណ៍ជាបរិវាររបស់ព្រាហ្មណ៍នោះ ក៏តុបតែងដោយសំពត់ គ្រឿងលាបជារបស់ក្រអូប និងកម្រងផ្កាសនោះដូចគ្នា ។ ដោយហេតុនោះ លោកទើបពោលថា **សព្វសេតេន វឡវាភិរថេន** ។

បទថា **សាវត្ថិយា និយ្យាតិ** សេចក្តីថា បានឮថា រាល់ ៦ ខែ ព្រាហ្មណ៍នោះ នឹងធ្វើប្រទក្សិណព្រះនគរម្តង ។ នឹងមានការឃោសនាជាមុនថា ព្រាហ្មណ៍ នឹងធ្វើប្រទក្សិណថ្ងៃប៉ុណ្ណោះ ចាប់ពីថ្ងៃនេះទៅ ។ មនុស្សទាំងឡាយឮរឿងនោះហើយ ពួកដែលមិនចេញពីព្រះនគរ ក៏មិនចេញទៅ សូម្បីពួកដែលទៅហើយក៏ត្រឡប់មកវិញ ដោយបំណងនឹងមើលសិរីសម្បត្តិរបស់អ្នកមានបុណ្យ ។ ថ្ងៃណាព្រាហ្មណ៍ធ្វើប្រទក្សិណព្រះនគរ

ថ្ងៃនោះ ពីព្រឹកព្រហាម មនុស្សនឹងបោសថ្នល់ក្នុងព្រះនគរ កៀរខ្សាច់ឲ្យស្មើ រោយផ្កាព្រមនិងលាជ តាំងឆ្នាំងទឹកដែលមានទឹកពេញ លើកដើមចេក និងទង់ ធ្វើនគរទាំងមូលឲ្យក្រអូបទៅដោយក្លិនធូប ។ ពីព្រឹកព្រលឹម ព្រាហ្មណ៍ក៏ងូតទឹក គឺ ដាំក្បាលទៅក្នុងទឹក ស៊ីអាហារស្រាលមុនអាហារធ្ងន់ តែងខ្លួនដោយសំពត់សជាដើម ដូចន័យដែលពោលហើយចុះពីប្រាសាទ ឡើងរថ ។ កាលនោះ ព្រាហ្មណ៍ទាំងនុ៎ះ តុបតែងដោយសំពត់ គ្រឿងលាប និងមាលាសទាំងអស់ កាន់ឆ័ត្រសឡោមព័ទ្ធ ជាណុស្សោណិព្រាហ្មណ៍នោះ តពីនោះ ក៏ចែកផ្លែឈើដល់ពួកក្មេងជំទង់ ៗ មុនដើម្បីឲ្យមហាជនជុំគ្នា តពីនោះ ក៏បាចមាសក: និងកហាបណ: មហាជនក៏ជំនុំគ្នាខ្លះ ក៏ស្រែកសំឡេងហ៊ោគឹកកង និងលើកសំពត់បក់រលាស់ទូទៅ ។ លំដាប់នោះ កាលមង្គលិកព្រាហ្មណ៍ និងសោវត្ថិកព្រាហ្មណ៍ជាដើម ធ្វើសិរីសួស្តីមង្គល ធ្វើប្រទក្សិណព្រះនគរដោយសម្បត្តិដ៏ធំ ។ មនុស្សអ្នកមានបុណ្យទាំងឡាយ ក៏ឡើងទៅលើប្រាសាទមួយជាន់ជាដើម បើកបង្អួច និងទ្វារ ដូចកាជន៍ស សម្លឹងមើល ។ ចំណែកព្រាហ្មណ៍ឆ្ពោះមុខទៅផ្លូវទ្វារទិសខាងត្បូង ដូចជាគ្របព្រះនគរទុកដោយសម្បត្តិ គឺយស និងសិរីរបស់ខ្លួន ។ ដោយហេតុនោះ លោកទើបពោលថា **សាវ-**

**ត្តិយា និយ្យាតិ** ។ បទថា **ទិវាទិវស្ស** ប្រែថា ថ្ងៃរបស់ថ្ងៃ អធិប្បាយថា វេលាកណ្តាលថ្ងៃ ។ បទថា **បិលោតិកំ បរិព្វាជកំ** បានដល់ បរិព្វាជកជាអ្នកបានឈ្មោះ ដោយហៅថា គេទស្រីយ៉ាងនេះថា **បិលោតិកា** ។ បានឮថា បរិព្វាជកនោះ ជាកំលោះ នៅក្នុងបឋមវ័យ មានវណ្ណៈដូចមាសសុទ្ធ ធ្វើជាពុទ្ធុបដ្ឋាកព្រះតថាគត និងព្រះមហាថេរៈ ពីព្រឹកព្រលឹមកាន់យកឈើ ៣ ជុំ និងគ្រឿងបរិក្ខារ មានបំពង់ទឹកជាដើម ចេញពីជេតវ័ន្តដើរឆ្ពោះទៅផ្លូវព្រះនគរ ។ ជាណុស្សោណិព្រាហ្មណ៍នោះ ឃើញបិលោ-តិកបរិព្វាជកនោះ ដើរមកពីចម្ងាយ ។ បទថា **ឯតទវោច** សេចក្តីថា ជាណុស្សោណិព្រាហ្មណ៍ ចាំបានថា បិលោតិកបរិព្វាជក ធ្លាប់មកសម្នាក់ដោយលំដាប់ ទើបពោលពាក្យបញ្ឆោក់គោត្រត្រកូល អើលោក វច្ឆាយនៈទៅណាមកណា ។ ក្នុងបទថា **បណ្ឌិតោ មញ្ញតិ** នេះ មានសេចក្តីយ៉ាងនេះថា លោកវច្ឆាយនៈ សម្គាល់ព្រះសមណគោតមថា ជាបណ្ឌិតឬទេ ។ បទថា **កោ ចាហំ កោ** សេចក្តីថា ខ្ញុំម្ចាស់នឹងដឹងបញ្ញា និងសេចក្តីធ្លាតរបស់ព្រះសមណគោតមបានពីណាមក ដោយពាក្យថា **កោ ច សម-ណស្ស គោតមស្ស បញ្ញាវេយ្យត្តិយំ ជានិស្សាមិ** នេះ បិលោតិកបរិព្វាជកសម្តែងថា ខ្លួនមិនដឹងសូម្បីគ្រប់ប្រការ យ៉ាងនេះថា ខ្ញុំម្ចាស់នឹងដឹងការ

មានបញ្ញា និងការឆ្លាតរបស់ព្រះសមណគោតមបានពីទីណា នឹងដឹងដោយហេតុអ្វី ។ បទថា **សោបិ នូនស្ស តាទិសោ ច** នេះ បិលោតិកបរិព្វាជកសម្តែងថា អ្នកណានឹងគប្បីដឹងការមានបញ្ញា និងការឆ្លាតរបស់ព្រះសមណគោតម សូម្បីអ្នកនោះ ក៏ត្រូវបំពេញបារមី ១០ សម្រេចព្រះសព្វញ្ញុតញ្ញាណជាព្រះពុទ្ធជាម្ចាស់ ដូច្នោះ អ្នកត្រូវការវាស់ភ្នំសិនេរុ ភ្នំហិមវន្តផែនដី ឬអាកាស គួរនឹងបានឈើ ឬខ្សែ ប្រមាណប៉ុណ្ណោះ សូម្បីអ្នកនឹងដឹងព្រះបញ្ញារបស់ព្រះសមណគោតម ក៏គួរនឹងបានព្រះសព្វញ្ញុតញ្ញាណដូចព្រះញាណរបស់ព្រះអង្គដែរ ។ លោកធ្វើការពោលបញ្ជាក់អះអាងក្នុងទីនេះ ដោយសេចក្តីជួយសង្គ្រោះ ។ បទថា **ឧឡារាយ** ប្រែថា ខ្ពស់បំផុតប្រសើរបំផុត ។ បទថា **កោ ចាហំ កោ** សេចក្តីថា យើងនឹងគប្បីសរសើរព្រះសមណគោតមបានពីណា ។ បទថា **កោ ច សមណំ គោតមំ បសំសិស្សាមិ** សេចក្តីថា ខ្ញុំម្ចាស់នឹងសរសើរដោយហេតុអ្វី ។ បទថា **បសត្ថបសត្ថោ** សេចក្តីថា ជាអ្នកប្រសើរដោយគុណរបស់ខ្លួន លើមនុស្សដទៃ ដោយគុណទាំងពួង មនុស្សលោកគេសរសើរហើយ ។

ព្រះអង្គមិនមានកិច្ច គឺ ពោលសរសើរដោយគុណយ៉ាងដទៃ ប្រៀបដូចផ្កាចំប៉ា ផ្កាបទុម ឬច័ន្ទក្រហម រមែងស្រស់ថ្លា និងមានក្លិនក្រអូប

ដោយសិរីនៃពណ៌ និងក្លិនរបស់វា វាមិនមានកិច្ចនឹងលើកសរសើរ ដោយពណ៌ និងក្លិនដែរ និងប្រៀបដូចជាកែវមណី ឬដួងច័ន្ទ រមែងឱកាសដោយពន្លឺភ្លឺរបស់ខ្លួនប៉ុណ្ណោះ ។ មិនមានកិច្ចដោយពន្លឺភ្លឺយ៉ាងដទៃ យ៉ាងណាមិញ ព្រះសមណគោតមក៏ដូច្នោះ ជាអ្នកដែលបណ្ឌិតសរសើរ លើកសរសើរដោយគុណរបស់ខ្លួន ដែលលោកទាំងពួង គេសរសើរហើយ គឺឲ្យដល់ភាពប្រសើរបំផុតនៃលោកទាំងពួង ព្រះអង្គមិនមានកិច្ច គឺ ការសរសើរ ដោយការសរសើរយ៉ាងដទៃទេ ន័យមួយទៀត ជាអ្នកប្រសើរជាងអ្នកប្រសើរទាំងឡាយ សូម្បីព្រោះហេតុនោះ ទើបឈ្មោះថា **បស-ដ្ឋប្បសដ្ឋ** អ្នកប្រសើរបំផុត ជាងអ្នកប្រសើរបំផុតទាំងឡាយ ។ ក៏អ្នកដទៃ ៗ ពួកណាទៅ ឈ្មោះថា ជាអ្នកប្រសើរបំផុត ។ ព្រះបាទបសេន-ទិកោសល ជាអ្នកប្រសើរជាងអ្នកដែនកាសី និងកោសលទាំងឡាយ ព្រះបាទពិម្ពិសា ជាអ្នកប្រសើរជាងអ្នកដែនអង្គៈ និងមគធៈ ស្តេចលិច្ឆវីក្រុងវេសាលី ប្រសើរជាងអ្នកដែនវជ្ជី ស្តេចមល្លក្រុងបាវា ស្តេចមល្លក្រុងកុសិនារា សូម្បីព្រះរាជនោះ ៗ អង្គ ដទៃប្រសើរជាងអ្នកជនបទនោះ ៗ ព្រាហ្មណ៍ មានចង្កីព្រាហ្មណ៍ជាដើម ប្រសើរជាងពួកព្រាហ្មណ៍ទាំងឡាយ , ឧបាសក មានលោកអនាថបណ្ឌិកសេដ្ឋីជាដើម ប្រសើរជាងពួកឧបាសក

នាងឧបាសិកាវិសាខាជាដើម ប្រសើរជាងឧបាសិកាច្រើនរយ បរិព្វាជក មានសកុលទាយីជាដើម ប្រសើរជាងបរិព្វាជកច្រើនរយ ។ មហាសាវិកា មានឧប្បលវណ្ណាថេរីជាដើម ប្រសើរជាងភិក្ខុនីច្រើនរយ ព្រះមហាសាវក មានព្រះសារីបុត្តថេរៈជាដើម ប្រសើរជាងភិក្ខុច្រើនរយ ទេពទាំងឡាយ មាន ស្តេចសក្កៈជាដើម ប្រសើរជាងទេពទាំងឡាយ ព្រហ្មទាំងឡាយ មាន មហាព្រហ្មជាដើម ប្រសើរជាងព្រហ្មច្រើនពាន់ លោកទាំងនោះ រមែង លើកសរសើរ លើកតម្កើង សរសើរព្រះទសពលទាំងអស់គ្រប់គ្នា ព្រោះ ហេតុដូច្នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ លោកទើបហៅថា **បសង្គប្បសង្គ** ប្រសើរជាងអ្នកប្រសើរ ។ បទថា **អត្ថវសំ** ប្រែថា អានិសង្សប្រយោជន៍ ។ គ្រានោះ បរិព្វាជក កាលប្រាប់ហេតុនៃសេចក្តីជ្រះថ្លារបស់ខ្លួនដល់ជាណុ-ស្សោណិព្រាហ្មណ៍នោះ ទើបពោលថា **សេយ្យថាបិ ភោ កុសលោ នាគវនិកោ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **នាគវនិកោ** បានដល់ បុរសអ្នករៀនសិល្បៈស្រុកនាគវន ។ ក៏បុរសអ្នករៀនសិល្បៈពីអ្នកដទៃ ហៅថា **នាគវនិក** ។ បទថា **ចត្តារិ បទានិ** បានដល់ បទ គឺ ញាណ , ស្នាម គឺ ញាណ ៤ អធិប្បាយថា ឋានទីដែលញាណជាន់ ។

(៦៨) បទថា **បណ្ឌិតេ** ក្នុងពាក្យថា **ខត្តិយបណ្ឌិតេ** ជាដើម

បានដល់ អ្នកប្រកបដោយភាពជាបណ្ឌិត ។ បទថា **និបុណោ** ប្រែថា អ្នកល្អិត គឺ អ្នកដឹងអត្ថដ៏ល្អិត បានដល់ អ្នកអាចចាក់ធ្លុះអត្ថដ៏ល្អិតដទៃ ៗ ។ បទថា **កតបរប្បវាទេ** បានដល់ ដឹងបរប្បវាទ និងធ្វើការញាំញីបរប្បវាទ ។ បទថា **វាលវេធិរូបេ** ប្រែថា ប្រដូចនាយខ្មាន់ធ្នូអ្នកបាញ់រោមទ្រាយ ។ បទថា **បញ្ហំ អភិសង្ខរោន្តិ** បានដល់ តាំងបញ្ហា ២ បទខ្លះ ៣ បទខ្លះ ៤ បទខ្លះ ។ បទថា **វាទំ អារោបេស្សាម** បានដល់ លើក ទោសឡើង ។ បទថា **នចេវ សមណំ គោតមំ បញ្ហំ បុច្ឆន្តិ** សេចក្តីថា ព្រោះហេតុអ្វី ទើបមិនសួរ ។

បានឮថា ព្រះដ៏មានព្រះភាគជាម្ចាស់ កាលណាទ្រង់សម្តែងធម៌ ក្នុងកណ្តាលបរិស័ទ ទើបទ្រង់ត្រួតមើលអធ្យាស្រ័យរបស់បរិស័ទ កាលនោះ ទើបទ្រង់ឃើញខត្តិយបណ្ឌិតទាំងឡាយនោះ មកតែងបញ្ហាដ៏អាថ៌កំបាំង ឈ្មោះថា **ឱវដ្ដិកសារបញ្ហាវគ្គនេ** ព្រះអង្គមិនត្រូវខត្តិយបណ្ឌិត សួរឡើយ កាលណាត្រាស់សួរបញ្ហាទាំងនេះថា ក្នុងការសួរបញ្ហា មានទោសត្រឹមប៉ុណ្ណេះ ក្នុងការឆ្លើយបញ្ហា មានទោសត្រឹមប៉ុណ្ណេះ ក្នុងអត្ថ បទ អក្ខរៈ មានទោសត្រឹមប៉ុណ្ណេះ គប្បីត្រាស់សួរយ៉ាងនេះ ព្រោះដូច្នោះ ទើបទ្រង់ដាក់ទុកក្នុងវាងធម្មកថា ហើយកម្ចាត់បញ្ហាដែលខត្តិយបណ្ឌិតចាំ មកតែងជា **ឱវដ្ដិកបញ្ហា** ដោយប្រការដូច្នេះ ។ ពួកខត្តិយបណ្ឌិត រមែងនឹងសប្បាយ

ចិត្តថា ជាការល្អសម្រាប់យើងហ្ន៎ ដែលពួកយើង មិនត្រូវសួរបញ្ហានេះ ក៏បើគប្បីសួរ ព្រោះព្រះសមណគោតម គប្បីបោះបង់ពួកយើងឲ្យអស់ទីពឹង ។ ម្យ៉ាងទៀត ធម្មតាថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ កាលណាសម្ដែងធម៌ រមែងផ្សាយមេត្តាទៅដល់បរិស័ទ មហាជន រមែងមានចិត្តជ្រះថ្លាក្នុងព្រះទសពល ដោយការផ្សាយមេត្តា ។ ក៏ព្រះពុទ្ធជាម្ចាស់ទាំងឡាយ មានព្រះរូបឆោមល្អឆើតគួរសរសើរ មានព្រះសូរសេងពីរោះ មានព្រះជីវ្ហាទន់ មានព្រះទន្តរាបស្និទ្ធ ត្រាស់សម្ដែងធម៌ ដូចស្រោចស្រពហឫទ័យដោយទឹកអម្រឹត ។ នៅទីនោះ មនុស្សពួកនោះ ដែលមានចិត្តជ្រះថ្លា ព្រោះទ្រង់ផ្សាយមេត្តា ក៏មានការគិតយ៉ាងនេះថា ពួកយើងមិនអាចធ្វើខ្លួនជាសត្រូវជាមួយព្រះដ៏មានព្រះភាគជាម្ចាស់ អ្នកត្រាស់ព្រះវាចាគ្មានពីរ ព្រះវាចាមិនជាមោឃៈ ព្រះវាចាដែលនាំសត្វចេញចាកទុក្ខបែបនោះ ទើបមិនទូលសួរ ព្រោះខ្លួនជ្រះថ្លាហើយ ។ បទថា **អញ្ញទត្ថុ** ប្រែថា ដោយចំណែកមួយ ។ បទថា **សាវកា សម្បជ្ជន្តិ** បានដល់ សាវកដោយការដល់នូវសរណៈ ។ បទថា **តទនុត្តរំ** កាត់បទថា **តំ អនុត្តរំ** ។ បទថា **ព្រហ្មចរិយបរិយោសានំ** បានដល់ ព្រះអរហត្តផល ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយ ។ ពិតហើយ សមណព្រាហ្មណ៍ទាំងនោះ រមែងបួសដើម្បី

អរហត្តផលនោះ ។ បទថា **បនំ វត ភោ អនស្សាម** សេចក្តីថា អ្នកដ៏ចម្រើន ប្រសិនបើយើងមិនចូលគាល់ទេ យើងនឹងដល់នូវសេចក្តីវិនាស ព្រោះមិនបានចូលជិត តែពួកយើងមិនបានវិនាសឡើយ ព្រោះហេតុ បានចូលគាល់ ។ បទទាំងពីរ ក៏ជាវេវចនៈរបស់បទដើមនោះឯង ក្នុងពាក្យថា **អស្សមណាវ សមានា** ជាដើម សេចក្តីថា ឈ្មោះថា មិនជាសមណៈ ព្រោះមិនស្ងប់ ឈ្មោះថា មិនមែនជាព្រាហ្មណ៍ ព្រោះមិនបណ្តែតបាប នឹងមិនបានជាអរហន្ត ព្រោះមិនកម្ចាត់សត្រូវ គឺ កិលេស ។

(៦៩) បទថា **ឧទានំ ឧទានេសិ** បានដល់ នាំឡើងនូវរបស់ដែលគួរនាំឡើង ។ ដូចសេចក្តីថា ប្រេងណាមិនអាចនៅក្នុងវង្វាស់វង្វាល់បាន ក៏ហូរហួសទៅ ប្រេងនោះលោកហៅថា **អវសេក** ហូរហួសទៅ ទឹកណាមិនអាចជាប់នៅក្នុងស្រះបាន ហៀរទៅឯង ទឹកនោះហៅថា ឱឃៈ ទឹកជន់ យ៉ាងណា ពាក្យសម្តីដែលកើតពីបីតិណា រមែងមិនអាចចាប់ហឫទ័យទុក បាន ក៏ហៀរចេញទៅខាងក្រៅ មិននៅខាងក្នុង ពាក្យនេះក៏ហៅថា ឧទាន ដូច្នោះ ។ អធិប្បាយថា បញ្ចេញពាក្យដែលកើតពីបីតិ មានសភាពដូច្នេះ ។ បទថា **ហត្ថិបទោបមោ** មានវិគ្រោះថា ស្នាមជើងដំរី ដោយឧបមានៃ ធម៌នោះ ហេតុនោះ ធម៌នោះឈ្មោះថា មានស្នាមជើងដំរីជាឧបមា ។ លោកសម្តែង

ថា ធម៌នោះ រមែងមិនបរិបូណ៌ ធំ ទូលាយយ៉ាងនេះ ។

(៧០) បទថា **នាគវនិកោ** បានដល់ ហ្មដំរីជាអ្នកសិក្សា សិល្បៈដំរី ហើយ ។ សួរថា កាលណាជាយ៉ាងនេះ ព្រោះហេតុអ្វីក្នុងទីនេះ ទើប មិនពោលថា អ្នកឆ្លាត ។ ឆ្លើយថា ព្រោះនឹងសម្តែងបែងចែកឲ្យដឹងថា មនុស្សណាឆ្លាត ទុកខាងមុខ ។ មែនហើយ អ្នកដែលនឹងចូលទៅ បើជា អ្នកឆ្លាត គេនឹងនៅមិនសម្រេចចិត្តមុន ព្រោះដូច្នោះ ក្នុងទីនេះ លោកទើប មិនពោលថា អ្នកឆ្លាត តែពោលទុកខាងមុខ ។ បទថា **វាមនិកា** បានដល់ ដំរីមេពោះធំ ខ្វី មិនវែង ពោលថា វែង បទថា **ឧច្ចា ច និសេវិតំ** ដំរីនោះ តែងត្រដុសនឹងទីកន្លែងត្រដុស ត្រង់ដើមជ្រៃជាដើម ដែលខ្ពស់ ៧-៨ ហត្ថ ។ បទថា **ឧច្ចាកឡារិកា** នេះ ជាឈ្មោះនៃមេដំរី ដែលមានជើង ខ្ពស់ ដូចជាឈើប្រត់ និងដែល ឈ្មោះថា **កឡារិកា** ព្រោះមានភ្លុក ក្រហម ។ គេថា ដំរីញីទាំងនោះ មានភ្លុកមួយឡើង មួយចុះ ហើយ ភ្លុកទាំងពីរ ឃ្លាតឆ្ងាយពីគ្នា ។ បទថា **ឧច្ចា ច ទន្តេហិ អារញ្ជិតានិ** សេចក្តីថា ទីដែលចាក់ដោយភ្លុក ដាច់ដូចយកពូថៅកាប់ត្រង់ដើមជ្រៃ ជាដើម ដែលខ្ពស់ ៧-៨ ហត្ថ ។ បទថា **ឧច្ចា កណេរុកា នាម** បានដល់ មានជើងវែងដូចឈើប្រត់ និងដែលឈ្មោះថា **កណេរុកា** ព្រោះមានភ្លុកង ។

បានឮថា ដំរីញីទាំងនោះ មានក្លុក-ង ព្រោះដូច្នោះ លោកទើបហៅថា **ករេនុកា** ។ បទថា **សោ ទិដ្ឋំ គច្ឆតិ** សេចក្តីថា ព្រានដំរីនោះ ទៅមិនទាន់សម្រេចចិត្តថា យើងមកតាមស្នាមជើងដំរីណា ដំរីនោះ គឺ ដំរីនេះឯង មិនមែនដំរីដទៃ ។ យើងឃើញស្នាមជើងដំបូងណា នៅមិនទាន់សម្រេចចិត្តថា ជាស្នាមជើងរបស់ដំរីញីគម យើងទៅឃើញស្នាមជើងណា ក្នុងកន្លែងដែលទាប ក៏នៅមិនទាន់សម្រេចចិត្តថា នុ៎ះជាស្នាមជើងដំរីញី **កឡា-រិកា** ឬរបស់ដំរីញី **ករេនុកា** កាលបើឃើញដំរីធំប៉ុណ្ណោះ ក៏សម្រេចចិត្តថា ស្នាមជើងទាំងអស់នោះ ជាស្នាមជើងរបស់ដំរីធំនេះឯង ។ ក្នុងពាក្យថា **ឯវមេវ ខោ** នេះ ប្រៀបសេចក្តីឧបមាយ៉ាងនេះ ។ គប្បីជ្រាបព្រះធម៌ទេសនាតាំងអំពីខាងដើម រហូតដល់លះនីវរណថា ដូចដំរីព្រៃ ។ យោគាវចរ ដូចព្រានដំរីអ្នកឆ្លាត ព្រះសម្មាសម្ពុទ្ធជាម្ចាស់ដូចស្តេចដំរី ។ ឈាន និងអភិញ្ញា ដូចស្នាមជើងដំរីធំ សេចក្តីដែលព្រះយោគាវចរ មិនសម្រេចចិត្តថា ធម្មតាថា ឈាន និងអភិញ្ញាទាំងនេះ រមែងមាន សូម្បីដល់បរិព្វាជកក្រៅព្រះសាសនា ដូចសេចក្តីដែលព្រានដំរី សូម្បីឃើញស្នាមជើងក្នុងទីនោះ ៗ ក៏សម្រេចចិត្តថា នេះជាស្នាមជើងរបស់ដំរីញី **វាមនិកា** របស់ដំរីញី **កឡារិកា** ឬរបស់ដំរីញី **ករេនុកា** សេចក្តីដែល

ព្រះអរិយសាវកសម្រេចព្រះអរហត្តហើយ សម្រេចចិត្ត ក៏ដូចព្រានដំរីឃើញដំរីធំហើយ ក៏សម្រេចចិត្តថា ស្នាមជើងដែលយើងឃើញ ក្នុងទីនោះ ៗ គឺ ជាស្នាមជើងដំរីធំនេះប៉ុណ្ណោះ មិនមែនដំរីដទៃ ក៏នឹងធ្វើការប្រៀបធៀបតាមសេចក្តីឧបមានេះដល់ចប់ ក៏គួរ ។ សូម្បីក្នុងទីនេះក៏គួរដូចគ្នា ។ តែត្រូវចាប់បទបាលី ដែលមកតាមលំដាប់ ធ្វើក្នុងទីនេះតែម្យ៉ាង។ សព្ទថា **ឥធ** ក្នុងពាក្យនេះជានិបាតប្រើក្នុងអត្ថ ទេស: លំនៅ ។ **ឥធ** សព្ទនេះ កន្លែងខ្លះលោកពោលអាងដល់លោក ដូចដែលទ្រង់ត្រាស់ទុកថា ព្រះតថាគតរមែងឧប្បត្តិក្នុងលោកនេះ ។ កន្លែងខ្លះ លោកពោលអាងដល់សាសនា ដូចដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះប៉ុណ្ណោះ មានសមណទី ១ សមណទី ២ ។ កន្លែងខ្លះលោកពោលអាង **ឱកាស** ដូចទ្រង់ត្រាស់ទុកថា ៖

**កាលយើងជាទេពនៅក្នុងឱកាសនេះ នោះហើយ**
**យើងក៏បានអាយុមកទៀត អ្នកនិរទុក្ខលោកត្រូវ**
**ដឹងយ៉ាងនេះ ។**

កន្លែងខ្លះ លោកពោលអាងត្រឹមតែធ្វើបទឲ្យពេញប៉ុណ្ណោះ ដូចដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតឆាន់ហើយ គប្បីហាម

កត្តុបុះ ។ តែក្នុងទីនេះគប្បីជ្រាបថា លោកពោលសម្តៅយក **លោក** ។ លោកអធិប្បាយទុកថា ម្នាលព្រាហ្មណ៍ **តថាគតឧបត្តិក្នុងលោកនេះ** ជាព្រះអរហន្ត ។ល។ ជាអ្នកភ្ញាក់ហើយ ជាអ្នកចែកធម៌ ។ ក្នុងស័ព្ទទាំងនោះ ស័ព្ទថា **តថាគត** លោកពោលទុកពិស្តារហើយ ក្នុងមូលបរិយាយសូត្រ ស័ព្ទថា អរហន្តជាដើម លោកពោលទុកពិស្តារហើយ ក្នុងវិសុទ្ធិ-មគ្គ ។ ក៏ក្នុងពាក្យថា **លោកេ ឧប្បជ្ជតិ** នេះ បទថា **លោក** មាន ៣ គឺ ឱកាសលោក សត្វលោក សង្ខារលោក ។ តែក្នុងទីនេះ លោកបំណងយកសត្វលោក ។

ព្រះតថាគត សូម្បីកាលកើតក្នុងសត្វលោក រមែងមិនកើតក្នុងទេវលោក មិនកើតក្នុងព្រហ្មលោក រមែងកើតតែក្នុងមនុស្សលោកប៉ុណ្ណោះ សូម្បីក្នុងមនុស្សលោក ក៏មិនកើតក្នុងចក្រវាឡដទៃ កើតក្នុងចក្រវាឡនេះប៉ុណ្ណោះ ។ សូម្បីក្នុងចក្រវាឡនោះ ក៏មិនកើតក្នុងទីគ្រប់កន្លែង រមែងកើតក្នុងមជ្ឈិមប្រទេស ដែលមានបណ្តោយ ៣០០ យោជន៍ ទទឹង ២៥០ យោជន៍ ដោយជុំវិញ ៩០០ យោជន៍ លោកកំណត់ទុកយ៉ាងនេះ គឺ ទិសបូព៌ មាននិគមឈ្មោះថា **កជង្គលៈ** តពីនោះជាមហាសាល តពីនោះជាបច្ចន្តជនបទ រួមក្នុងជាមជ្ឈិមជនបទ , ទិសអាគ្នេយ៍ មានស្ទឹង ឈ្មោះថា

***សល្លវតី*** គពីនោះជាបច្ចន្តជនបទ រួមក្នុងមជ្ឈិមជនបទ , ក្នុងទិសទក្សិណ មាននិគម ឈ្មោះថា ***សេតកណ្ណិកៈ*** គពីនោះ ជាបច្ចន្តជនបទ រួមក្នុងមជ្ឈិម ជនបទ , ក្នុងទិសបច្ចិម មានស្រុកព្រាហ្មណ៍ ឈ្មោះថា ***ថូន*** គពីនោះ ជាបច្ចន្តជនបទ រួមក្នុងមជ្ឈិមជនបទ , ក្នុងទិសឧត្តរ មានភ្នំឈ្មោះថា ***ឧសិរធជៈ*** គពីនោះ ជាបច្ចន្តជនបទ រួមក្នុងមជ្ឈិមជនបទ ។ មិនមែន ព្រះតថាគតតែមួយអង្គឯងប៉ុណ្ណោះ ព្រះបច្ចេកពុទ្ធជាម្ចាស់ ព្រះអគ្គសាវក ព្រះអសីតិមហាថេរៈ ព្រះពុទ្ធមាតា ព្រះពុទ្ធបិតា ព្រះចៅចក្រពត្តិ និង ព្រាហ្មណ៍មហាសាល គហបតីមហាសាល ពួកជនទៃរមែងកើតក្នុងមជ្ឈិម ប្រទេសនេះទាំងអស់ ។ ក្នុងមជ្ឈិមប្រទេសនោះ ព្រះតថាគត ឈ្មោះថា ***ឧប្បត្តិ*** រាប់តាំង ពីសោយមធុបាយាស ដែលនាងសុជាតាថ្វាយ រហូត ដល់ព្រះអរហត្តមគ្គ ឈ្មោះថា អ្នកឧប្បត្តិក្នុងអរហត្តផល ឈ្មោះថា រមែង ឧប្បត្តិតាំងពីចេញមហាអភិនេស្រ្កមណ៍រហូត ដល់ព្រះអរហត្តតាំងពីតុសិ- តភព រហូតដល់អរហត្តមគ្គ ឬតាំងពីបាទមូលនៃព្រះពុទ្ធជាម្ចាស់ ទ្រង់ ព្រះនាមថា ***ទីបង្ករ*** រហូតដល់អរហត្តមគ្គ ឈ្មោះថា អ្នកឧប្បត្តិក្នុងអរ- ហត្តផល ក្នុងទីនេះ លោកសំដៅយកការៈ ដែលព្រះតថាគតឧប្បត្តិមុនគេ ទាំងអស់ ទើបពោលថា ***ឧប្បជ្ជតិ*** ។ ពិតហើយ ក្នុងទីនេះបានសេចក្តីថា

**តថាគតោ លោកេ ឧប្បន្នោ ហោតិ** ព្រះតថាគតរមែងឧបត្តិក្នុងលោក ។

បទថា **សោ ឥមំ លោកំ** សេចក្តីថា ព្រះដ៏មានព្រះភាគជាម្ចាស់នោះ ទ្រង់សម្តែងលោកនេះថា គួរពោលក្នុងឥឡូវនេះ ។ បទថា **សទេវកំ** ប្រែថា ព្រមដោយទេព ឈ្មោះថា **សទេវក** ។ ព្រមដោយមារ ឈ្មោះថា **សមារក** ព្រមដោយព្រហ្ម ឈ្មោះថា **សព្រហ្មក** ព្រមដោយសមណនិងព្រាហ្មណ៍ ឈ្មោះថា **សស្សមណព្រាហ្មណី** ឈ្មោះថា **បជា** ព្រោះកើតទូទៅព្រមដោយទេព និងមនុស្ស ឈ្មោះថា **សទេវមនុស្ស** ។ ក្នុងពាក្យទាំងនោះគប្បីជ្រាបស័ព្ទថា កាមាវចរទេព ទី ៥ ដោយពាក្យថា **សទេវកៈ** ។ ស័ព្ទថា កាមាវចរទេពទី ៦ ដោយពាក្យថា **សមារកៈ** ។ ស័ព្ទថា **ព្រហ្មកាយិកៈ** ជាដើម ដោយពាក្យថា **សព្រហ្មកៈ** ស័ព្ទថា សមណ និងព្រាហ្មណ៍ ដែលជាសត្រូវរបស់ព្រះសាសនា និងអ្នកស្ងប់បាប អ្នកបណ្តេតបាប ដោយពាក្យថា **សស្សមណព្រាហ្មណី** ស័ព្ទថា **សត្តលោកេ** ដោយពាក្យថា **បជា** ស័ព្ទថា **ទេព** ដោយសម្មតិទេព និងមនុស្សដ៏សេសដោយពាក្យថា **សទេវមនុស្ស** ។ សត្វលោក និងឱកាសលោក គប្បីជ្រាបថា លោកកាន់យកដោយ ៣ បទ សត្វលោកតែម្យ៉ាង គប្បីជ្រាបថាលោកកាន់យកដោយអំណាច **បជា** ដោយបទទាំងពីរក្នុងពាក្យនេះ ដោយ

ប្រការដូច្នេះ ។

ម្យ៉ាងទៀត អរូបាវចរលោក លោកកាន់យកដោយសព្ទថា **សទេវកៈ** ឆកាមាវចរទេវលោក ដោយសព្ទថា **សមារកៈ** , រូបព្រហ្មលោក លោកកាន់យកដោយសព្ទថា **សព្រហ្មកៈ** មនុស្សលោក ឬសត្វលោកដ៏សេសជាមួយទេវតាដោយសម្មតិ លោកកាន់យកដោយអំណាចបរិស័ទ ៤ ដោយសព្ទថា **សស្សមណព្រាហ្មណី** ជាដើម ។

ម្យ៉ាងទៀត ក្នុងទីនេះ លោកពោលដល់សេចក្តីដែលព្រះដ៏មាន-ព្រះភាគជាម្ចាស់ ទ្រង់ធ្វើឲ្យច្បាស់លោកទាំងមូល ដោយកំណត់យ៉ាងខ្ពស់ដោយពាក្យថា **សទេវកៈ** ។ លំដាប់នោះ កាលណាទ្រង់នឹងកម្ចាត់សេចក្តីសង្ស័យរបស់ពពួកជន អ្នកមានការគិតយ៉ាងនេះថា **វសវត្តីមារ** អ្នកមានអនុភាពច្រើន ជាអ្នកធំ ក្នុងឆកាមាវចរទេព សូម្បីនោះ ព្រះអង្គទ្រង់ធ្វើឲ្យច្បាស់ហើយឬ ដូច្នេះទើបត្រាស់ថា **សមារកំ** ។

ម្យ៉ាងទៀត កាលណាទ្រង់កម្ចាត់សេចក្តីសង្ស័យរបស់ពួកជន អ្នកមានការគិតថា ព្រហ្មអ្នកមានអានុភាពច្រើន ប្រើអង្គុលីមួយ បញ្ចេញរស្មីទៅក្នុង ១.០០០ ចក្រវាឡ បញ្ចេញរស្មីទៅក្នុង ១០.០០០ ចក្រវាឡ ដោយ ២ អង្គុលី ។ល។ ១០ អង្គុលី និងសោយសុខ ដែលកើតពីឈានសមាបត្តិ

ដ៏កំពូល ព្រហ្មសូម្បីនោះ ព្រះអង្គទ្រង់ធ្វើឲ្យច្បាស់ឬ ដូច្នេះទើបត្រាស់ថា **សព្រហ្មកំ** តពីនោះ កាលណាទ្រង់នឹកម្ចាត់ សេចក្ដីសង្ស័យរបស់ពពួកជនអ្នកមានសេចក្ដីគិតថា សមណព្រាហ្មណ៍ជាច្រើន ជាសត្រូវចំពោះសាសនាសូម្បីទាំងនោះ ព្រះអង្គទ្រង់ធ្វើឲ្យច្បាស់ហើយឬ ដូច្នេះ ទើបត្រាស់ថា **សស្សមណព្រាហ្មណី បជំ** ក៏ឯកាលព្រះអង្គប្រកាសសេចក្ដីដែលព្រះអង្គទ្រង់ធ្វើឲ្យជាក់ច្បាស់ចំពោះមារ និងសមណព្រាហ្មណ៍ទាំងនោះយ៉ាងខ្ពស់បំផុត យ៉ាងនេះហើយ លំដាប់នោះ កាលណាទ្រង់នឹងប្រកាសសេចក្ដីដែលព្រះអង្គទ្រង់ធ្វើឲ្យច្បាស់ដល់សត្វលោកដ៏សេស ដោយកំណត់យ៉ាងខ្ពស់ សំដៅដល់សម្មតិទេព និងមនុស្សដ៏សេស ទើបត្រាស់ថា **សទេវមនុស្សំ** ។ ក្នុងពាក្យនេះ មានលំដាប់សេចក្ដីជាក់ច្បាស់យ៉ាងនេះ ។

ក៏ព្រះបុរាណាចារ្យ ពោលថា **សទេវកំ** បានដល់ ដ៏សេស និងពួកទេវតានិងមារ ។ បទថា **សមារកំ** បានដល់ លោកដ៏សេស និងមារ ។ បទថា **សព្រហ្មកំ** បានដល់ លោកដ៏សេស និងពួកព្រហ្មណ៍ ។ លោកដាក់ពួកសត្វដែលចូលដល់ត្រៃកពសូម្បីទាំងអស់ ចុះក្នុងបទទាំងបី ដោយអាការបីដោយប្រការដូច្នេះ កាលនឹងកំណត់កាន់យកដោយបទដើមទាំងពីរទៀត ទើបពោលថា **សស្សមណព្រាហ្មណី បជំ សទេវមនុស្សំ** យ៉ាងនេះ ។ គឺថា

លោកកំណត់យកត្រៃជាតុប៉ុណ្ណោះ ដោយអាការនោះៗ ដោយបទទាំង ៥ ដោយប្រការដូច្នេះ ។

ក្នុងពាក្យថា **សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ** បទថា **សយំ** ប្រែថា ឯង ។ បទថា **អភិញ្ញា** ប្រែថា ដឹង អធិប្បាយថា ដឹងដោយញាណដ៏ក្រៃលែង ។ បទថា **សច្ឆិកត្វា** បានដល់ ធ្វើឲ្យប្រចក្ស គឺថា លោកបដិសេធការប៉ាន់ស្មានជាដើម ដោយសេចក្តីនេះ ។ បទថា **បវេទេតិ** បានដល់ ធ្វើឲ្យរាក់ ឲ្យដឹងច្បាស់ ប្រាប់ប្រកាស ។ បទថា **សោ ធម្មំ ទេសេតិ អាទិមជ្ឈបរិយោសានកល្យាណំ** សេចក្តីថា ព្រះដ៏មានព្រះភាគជាម្ចាស់នោះ ទ្រង់អាស្រ័យករុណាក្នុងសត្វទាំងឡាយ ទ្រង់សម្តែងធម៌ មានសុខដែលកើតពីវិវេកដ៏កំពូល កាលណាទ្រង់សម្តែង ធម៌នោះមិនថា តិច ឬច្រើន ក៏ទ្រង់សម្តែងដោយប្រការ **មានលំអរបទដើម** ជាដើម ។ អធិប្បាយថា ទ្រង់សម្តែងមានលំអរបទដើម , លំអរបទកណ្តាល , បទចុង សាសនាក៏មានដូចគ្នា ។ គាថាសូម្បី ៤ បាទ បាទដំបូង ឈ្មោះថា បទដើមនៃសាសនា តពីនោះ ២ បាទ ឈ្មោះថា បទកណ្តាល បទចុងក្រោយឈ្មោះថា បទចុង ។ ព្រះសូត្រដែលមានអនុសន្ធិ ១ ពាក្យនិទានជាខាងដើម ពាក្យថា **ឥទមវោច** ជាបទចុង ចន្លោះពាក្យទាំងពីរ ឈ្មោះថា

បទកណ្ដាល ។ ព្រះសូត្រដែលមានអនុសន្ធិច្រើន អនុសន្ធិដំបូង ជាបទខាងដើម អនុសន្ធិខាងក្រោយ ជាបទខាងចុង ត្រង់កណ្ដាលអនុសន្ធិមួយ អនុសន្ធិពីរ ឬច្រើនអនុសន្ធិ ជាបទកណ្ដាល ។ ចំណែកសាសនា **សីល សមាធិ វិបស្សនា** ឈ្មោះថា បទខាងដើម ។ សមពិត ដូចពាក្យដែលលោកពោលទុកថា អ្វីជាបទខាងដើមនៃកុសលធម៌ សីលដែលបរិសុទ្ធល្អ និងទិដ្ឋិដែលត្រង់ ។ អរិយមគ្គ ដែលលោកពោលទុកយ៉ាងនេះថា ភិក្ខុទាំងឡាយ មានមជ្ឈិមាបដិបទាដែលតថាគតត្រាស់ដឹងដោយខ្លួនឯង ក្រែ-លែងហើយ ឈ្មោះថា បទកណ្ដាល , ផល និងនិព្វាន ឈ្មោះថា បទខាងចុង ។ ពិតហើយ ផល លោកហៅថា ខាងចុង ក្នុងពាក្យនេះថា ម្នាលព្រាហ្មណ៍ព្រហ្មចរិយៈនេះ មានប្រយោជន៍យ៉ាងនេះ មានសារៈយ៉ាងនេះ មានខាងចុងយ៉ាងនេះ ។ និព្វានលោកហៅថាខាងចុង ក្នុងពាក្យនេះថា វិសាខៈ ប្រព្រឹត្តព្រហ្មចរិយៈ ដែលចុះកាន់ព្រះនិព្វាន មាននិព្វានជាខាងមុខ មាននិព្វានជាខាងចុង ។ ក្នុងទីនេះ លោកប្រាថ្នាយកបទខាងដើម បទកណ្ដាល បទចុងនៃទេសនា ។ ពិតហើយ ព្រះដ៏មានព្រះភាគជាម្ចាស់កាលទ្រង់សម្ដែងធម៌ ទ្រង់សម្ដែងសីលជាខាងដើម សម្ដែងមគ្គជាកណ្ដាល សម្ដែងនិព្វានជាបរិយោសាន ។ ដោយហេតុនោះ លោកទើបពោលថា

*សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ* ដូច្នេះ ព្រោះដូច្នោះ ព្រះធម្មកថិកសូម្បីដទៃ កាលពោលធម៌ គប្បីសម្តែងសីលជាខាងដើម សម្តែងមគ្គ ជាកណ្តាល សម្តែងនិព្វានជាបរិយោសាន នេះជាគោលការណ៍របស់ព្រះធម្មកថិក ។

បទថា *សាត្ថំ សព្យញ្ជនំ* សេចក្តីថា ទេសនារបស់ព្រះធម្មកថិកណាអាស្រ័យពណ៌នារឿងបបរ បាយ មនុស្សស្រី មនុស្សប្រុសជាដើម ព្រះធម្មកថិកនោះ មិនសម្តែងធម៌ជាសាត្ថៈ មានប្រយោជន៍ ចំណែកព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់លះធម្មទេសនាដូច្នោះ ទ្រង់សម្តែងទេសនាអាស្រ័យសតិប្បដ្ឋាន ៤ ជាដើម ព្រោះដូច្នោះ លោកទើបពោលថា ទ្រង់សម្តែងធម៌ជាសាត្ថៈ មានប្រយោជន៍ ។ មួយទៀត ទេសនារបស់ភិក្ខុណាប្រកបដោយព្យញ្ជនៈមួយជាដើម ឬមានព្យញ្ជនៈខ្វាក់ទាំងអស់ ឬមានព្យញ្ជនៈបើកទាំងអស់ សង្កត់ទាំងអស់ ទេសនារបស់ភិក្ខុនោះ ឈ្មោះថា អព្យញ្ជនៈ ព្រោះមិនមានសេចក្តីបរិបូណ៌ដោយព្យញ្ជនៈ ដូចភាសារបស់មនុស្សមិលក្ខៈ ដូចទមិឡ ដូចមនុស្សព្រៃ និងមនុស្សផ្តេសផ្តាសជាដើម ។ ចំណែកព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់លះទេសនាដូច្នោះ ទ្រង់មិនប៉ះពាល់ព្យញ្ជនៈ ១០ យ៉ាង ដែលលោកពោលទុកយ៉ាងនេះ ៖

*១-សិថិល ២-ធនិត ៣-ទីឃៈ ៤-រស្សៈ ៥-លហុ*

*៦-គរុ ៧-និគ្គហិត ៨-សម្ពន្ធ ៩-វវត្ថិត ១០-វិមុត្ត*

*ដែលជាគោលការណ៍ពង្រីកតួព្យញ្ជនៈ ១០ ប្រភេទ ទ្រង់សម្តែងធម៌ មានព្យញ្ជនៈបរិបូណ៌ ព្រោះដូច្នោះ លោកទើបពោលថា ទ្រង់សម្តែងធម៌ ជាសព្យញ្ជនៈ ព្រមដោយព្យញ្ជនៈ ។ ពាក្យថា **កេវលំ** ក្នុងពាក្យថា **កេវលបរិបុណ្ណំ** នេះ ប្រែថា អស់ជើង ។ បទថា **បរិបុណ្ណំ** ប្រែថា មិនខ្វះមិនលើស ។ លោកអធិប្បាយទុកយ៉ាងនេះថា ទ្រង់សម្តែងធម៌បរិបូណ៌ ដោយអស់ជើង សូម្បីទេសនាត្រឹមតែមួយ ដែលមិនបរិបូណ៌មិនមាន ។ បទថា **បរិសុទ្ធំ** ប្រែថា ប្រាសចាក សេចក្តីសៅហ្មង ។ ពិតហើយ ព្រះធម្មកថិកណា អាស្រ័យធម្មទេសនានេះ សម្តែងធម៌ដោយប្រាថ្នាលាភ ឬសក្ការៈ ទេសនារបស់ធម្មកថិកនោះ មិនបរិសុទ្ធ ។ ចំណែកព្រះដ៏មាន-ព្រះភាគជាម្ចាស់ ទ្រង់មិនស្វែងរកលោកាមិសៈ សម្តែងធម៌ មានព្រះហឫទ័យទន់ភ្លន់ដោយមេត្តាភាវនា ដើម្បីប្រយោជន៍ ទ្រង់សម្តែងដោយព្រះទ័យដែលតាំងនៅក្នុងសភាពដែលនឹងលើកឲ្យខ្ពស់ឡើង ព្រោះដូច្នោះ លោកទើបហៅថា ទ្រង់សម្តែងធម៌បរិសុទ្ធ ។ សាសនាទាំងមូល ដែលសង្គ្រោះសិក្ខា ៣ លោកហៅថា **ព្រហ្មចរិយៈ** ក្នុងពាក្យនេះថា **ព្រហ្មចរិយំ បកាសេតិ***

យ៉ាងនេះ ព្រោះដូច្នោះ លោកទើបហៅថា ទ្រង់ប្រកាសព្រហ្មចរិយៈ ។ ក្នុងពាក្យថា **សោ ធម្មំ ទេសេតិ អាទិកល្យាណំ ។បេ។ បរិសុទ្ធំ** នេះ គប្បីឃើញខ្លឹមសារយ៉ាងនេះថា ព្រះដ៏មានព្រះភាគជាម្ចាស់ កាលណាទ្រង់សម្តែងយ៉ាងនេះ ឈ្មោះថា ទ្រង់ប្រកាសព្រហ្មចរិយៈ គឺ សាសនាទាំងមូល ដែលសង្គ្រោះដោយសិក្ខា ៣ ។

លោកអធិបា្បាយថា ការប្រព្រឹត្តយ៉ាងប្រសើរ ឬការប្រព្រឹត្តរបស់ព្រះអរិយជាម្ចាស់ទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម ដ៏ប្រសើរ ព្រោះអត្ថថា ប្រសើរបំផុត ឈ្មោះថា **ព្រហ្មចរិយ** ។ បទថា **តំ ធម្មំ** បានដល់ ធម៌ដល់ព្រមដោយប្រការដូចពោលហើយនោះ ។

សួរថា ព្រោះហេតុអ្វី ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ចង្អុលយកគហបតីមុនថា **សុណាតិ គហបតិ** ។ ឆ្លើយថា ព្រោះគហបតីកម្ចាត់មានះអស់បាន និងមានចំនួនច្រើន ។ ពិតហើយ ដោយច្រើនមនុស្សដែលបួសចេញពីខត្តិយត្រកូល រមែងអាស្រ័យជាតិ ធ្វើនូវមានះ អ្នកបួសពីត្រកូលព្រាហ្មណ៍អាស្រ័យមន្ត ធ្វើមានះ អ្នកបួសពីត្រកូល មានជាតិថោកទាបក៏តាំងនៅមិនបាន ព្រោះខ្លួនមានជាតិផ្សេង ។ ចំណែកក្មេងសម្រាប់ក្នុងត្រកូលគហបតី មានញើសហូរជោកខ្លួន ឡើងផ្កាអំបិល ភ្ជួរដី កម្ចាត់មានះ និង

សេចក្តីរីងត្អឹងបាន ក្មេងទាំងនោះ បួសហើយក៏មិនមានមានះ មិនរឹងត្អឹង រៀនព្រះពុទ្ធវចនៈតាមកម្លាំង ធ្វើកិច្ចក្នុងវិបស្សនា រមែងអាចស្ថិតនៅក្នុងព្រះអរហត្តបាន ក៏មនុស្សដែលឈ្មោះថា ចេញបួសពីត្រកូលក្រៅពីនេះ មិនមានច្រើន ពួកគហបតីទាំងនោះ មានច្រើនដូច្នេះ ព្រះមានព្រះភាគជាម្ចាស់ ទើបបង្អុលគហបតីមុន ព្រោះកម្ចាត់មានះបានហើយ មានច្រើន ។ បទថា **អញ្ញតរស្មឹ វា** បានដល់ ឬក្នុងត្រកូលក្រៅពីនេះ ត្រកូលណាមួយ ។ បទថា **បច្ឆា ជា តោ** ប្រែថា កើតខាងក្រោយ ។ បទថា **តថាគតេ សទ្ធំ បដិលភតិ** សេចក្តីថា ស្តាប់ធម៌ដែលបរិសុទ្ធហើយ ត្រឡប់បានសទ្ធាក្នុងព្រះតថាគត ដែលជាម្ចាស់នៃធម៌ថា ព្រះដ៏មានព្រះភាគជាម្ចាស់ ជាសម្មាសម្ពុទ្ធហ្ន៎ ។ បទថា **ឥតិសញ្ចិក្ខតិ** បានដល់ ការពិចារណាឃើញយ៉ាងនេះ ។ បទថា **សម្ពាធោ ឃរាវាសវាសោ** សេចក្តីសូម្បីថា ពីរនាក់ប្តីប្រពន្ធ នៅផ្ទះឆ្ងាយពីគ្នា ៦០ ហត្ថ ឬចន្លោះ ១០០ យោជន៍ សូម្បីដូច្នេះ ឃរាវាសក៏ឈ្មោះថា ចង្អៀតចង្អល់ ព្រោះអត្ថថា ពីរនាក់ប្តីប្រពន្ធនោះ មានសេចក្តីកង្វល់ មានសេចក្តីព្រួយបារម្ភណ៍ ។ ពាក្យថា **រជាបថោ** លោកពោលទុកក្នុងមហាអដ្ឋកថា បានដល់ ឋានៈដែលតាំងឡើងនៃធូលី គឺ រាគៈជាដើម ។ សូម្បីនឹងពោលថា ផ្លូវមកក៏គួរ ។ បព្វជ្ជា ប្រៀបដូចកណ្តាលវាល ព្រោះ

អត្ថថា មិនជាប់ ដូច្នោះ លោកទើបពោលថា **អព្ភោកាស** ។ ពិតហើយ អ្នកបួសហើយ សូម្បីនៅក្នុងផ្ទះកំពូល ប្រាសាទកែវ និងទេពវិមានជាដើម ដែលមានទ្វារបង្អួចបិទ ដែលគេបិទបាំងទុក ក៏មិនទើរមិនទាក់ ដោយហេតុនោះ ទើបត្រាស់ថា បព្វជ្ជា ទំនេរយ៉ាងក្រៃលែង ។ ម្យ៉ាងទៀត ឃរាវាស ឈ្មោះថា ចង្អៀតចង្អល់ ព្រោះមិនមានឱកាសធ្វើបុណ្យ , ឈ្មោះថា **រជាបថ** ព្រោះជាទីរួមនៃធូលី គឺ កិលេស ដូចគំនរសម្រាម ដែលគេមិនប្រយ័ត្ន បព្វជ្ជា ឈ្មោះថា **អព្ភោកាស** ព្រោះមានឱកាសធ្វើបុណ្យបានតាមសប្បាយ ។

ក្នុងពាក្យថា **នយិទំ សុករំ ។ល។ បព្វជេយ្យំ** នេះ នឹងពោលយ៉ាងសង្ខេបយ៉ាងនេះ **ព្រហ្មចរិយ** គឺ សិក្ខា ៣ នេះ ឈ្មោះថា បរិបូណ៌ ដោយចំណែកមួយ ព្រោះធ្វើមិនដាច់សូម្បីមួយថ្ងៃគប្បីឲ្យដល់ **ចរិមកចិត្ត** និងឈ្មោះថា បរិសុទ្ធដោយចំណែកមួយ ព្រោះមិនអាប់ឱនដោយមន្ទិល គឺ កិលេស សូម្បីតែមួយថ្ងៃឲ្យដល់ **ចរិមកចិត្ត** ។ បទថា **សង្ខលិខិតំ** បានដល់ គប្បីប្រព្រឹត្តដូចគ្នានឹងស័ង្ខខាត់ គឺ ធៀប ដោយស័ង្ខដែលគេខាត់ហើយ ។ អ្នកគ្រប់គ្រងផ្ទះ គឺ អ្នកនៅកណ្តាលចំណោមផ្ទះ ប្រព្រឹត្តព្រហ្មចរិយដ៏បរិសុទ្ធបរិបូណ៌ដោយចំណែកមួយ ដូចស័ង្ខនេះ ធ្វើមិនបានងាយ ។ បើដូច្នេះ យើងគប្បីកោរសក់ និងពុកមាត់ គ្រង គឺ ស្លៀកដណ្តប់សំពត់ ដែលឈ្មោះ

ថា **កាសាយ** ព្រោះជ្រលក់ដោយទឹកអម្ចត់ ដែលសមគួរសម្រាប់អ្នកប្រព្រឹត្ត ព្រហ្មចរិយៈ ចេញពីផ្ទះបួសមិនមានផ្ទះ ។ ក៏ព្រោះហេតុដែលការងារ មាន ប្រាសាទ ក្សួរស្រែ និងលក់ដូរជាដើម ឧបត្ថម្ភដល់ការគ្រប់គ្រងផ្ទះ ហៅថា **អគារិយ** ហើយអគារិយកិច្ចនោះ មិនមានក្នុងបព្វជ្ជា ដូច្នោះ បព្វជ្ជាគប្បី ជ្រាបថា **អនគារិយ** ក្នុងពាក្យនេះ ។ មិនមានកិច្ចរបស់អ្នកគ្រប់គ្រងផ្ទះនោះ ។ បទថា **បព្វជយ្យំ** ប្រែថា គប្បីបដិបត្តិ ។ បទថា **អប្បំ វា** សេចក្តីថា ភោគៈទាបជាងមួយពាន់ចុះមក ឈ្មោះថា តិច ខ្ពស់ជាងមួយពាន់ឡើងទៅ ឈ្មោះថា ច្រើន ។ វដ្ដិ គឺ ញាតិ ឈ្មោះថា ញាតិសន្តាន ព្រោះអត្ថថា ទាក់ទិនញាតិសន្តាន នោះទាបជាង ២០ ចុះមក ឈ្មោះថា តិច ខ្ពស់ជាង ២០ ឡើងទៅ ឈ្មោះថា ច្រើន ។

(៧១) បទថា **ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ** សេចក្តីថា ភិក្ខុអ្នកឈ្មោះថា **សមាបន្ន** ព្រោះសិក្សាក្នុងសិក្ខា ពោលគឺ អធិសីល និងសាជីវៈ ពោលគឺ សិក្ខាបទ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បញ្ញត្តិហើយ ចំពោះភិក្ខុ ទាំងឡាយអ្នកនៅរួមគ្នា មានជីវិតជាមួយគ្នា មានការប្រព្រឹត្តស្មើគ្នា ដូច្នោះ ភិក្ខុនោះ ទើបឈ្មោះថា សិក្ខាសាជីវសមាបន្នៈ សម្រាប់ភិក្ខុទាំងឡាយ ។ សេចក្តីថា ធ្វើសិក្ខាឲ្យបរិបូណ៌ និងមិនកន្លងល្មើសសាជីវៈ ចូលដល់សិក្ខា

និងសាជីវៈទាំងពីរនោះ ។ កថាពោលដោយ បាណាតិបាតជាដើម ក្នុងពាក្យថា **បាណាតិបាតំ បហាយ** ជាដើម លោកពោលទុកពិស្តារហើយក្នុងកាលមុន ។ បទថា **បហាយ** បានដល់ លះសភាពទ្រុស្តសីល ពោលគឺចេតនាសម្លាប់សត្វនេះ ។ បទថា **បដិវិរតោ ហោតិ** សេចក្តីថា វៀរចាកពីសភាពទ្រុស្តសីលនោះ តាំងពីពេលលះបានហើយ ។ បទថា **និហិត-ទណ្ឌោ និហិតសត្ថោ** សេចក្តីថា ឈ្មោះថា ចោលដំបង ចោលសស្ត្រា ព្រោះមិនកាន់ទៅដើម្បីសម្លាប់គេ ។ ក៏ក្នុងទីនេះ ឧបករណ៍ដ៏សេសទាំងអស់ វៀរដំបងចេញ គប្បីជ្រាបថា កាំបិត ព្រោះជាឧបករណ៍បៀតបៀនសត្វទាំងឡាយ ។ ភិក្ខុទាំងឡាយ កាន់ឈើច្រត់ ឬកាំបិតសម្រួចឈើជំរះធ្មេញ ឬកាំបិតបត់ មិនមែនដើម្បីនឹងសម្លាប់គេ ដូច្នោះ ទើបរាប់ថាចោលដំបង ចោលកាំបិត ។ បទថា **លជ្ជី** បានដល់ អ្នកប្រកបដោយសេចក្តីខ្មាស់ មានសេចក្តីខ្ពើមបាប ជាលក្ខណៈ ។ បទថា **ទយាបន្នោ** បានដល់ ការអាណិតអាសូរ គឺ ភាពជាអ្នកមានចិត្តប្រកបដោយមេត្តា ។ បទថា **សព្វបាណភូតហិតានុកម្បី** បានដល់ ជាអ្នកអនុគ្រោះសព្វសត្វដោយប្រយោជន៍ឧបការៈ អធិប្បាយថា ឈ្មោះថា ជាអ្នកមានចិត្តឧបការៈដល់សព្វសត្វ ព្រោះជាអ្នកមានសេចក្តីអាណិតអាសូរនោះ ។ បទថា **វិហរតិ**

បានដល់ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ គឺ ចិញ្ចឹមអត្តភាព ។ បុគ្គលដែលឈ្មោះថា **ទិន្នាទាយី** ព្រោះការកាន់យករបស់របរ ដែលគេឲ្យហើយប៉ុណ្ណោះ ។ ឈ្មោះថា **ទិន្នបាដិកង្ខី** ព្រោះប្រាថ្នាចំពោះតែរបស់ដែលគេឲ្យដោយចិត្តប៉ុណ្ណោះ ។ បុគ្គលណា រមែងលួច បុគ្គលនោះ ឈ្មោះថាចោរ ដោយការលួច ឈ្មោះថា **អថេនេន** មិនមែនដោយការលួច ឈ្មោះថា ជាអ្នកស្អាត ព្រោះជាអ្នកមិនលួចនោះឯង ។ បទថា **អត្តនា** ប្រែថាដោយអត្តភាព លោកអធិប្បាយទុកថា បើដូច្នោះ គេរមែងធ្វើអត្តភាពឲ្យស្អាតបាន ។ បទថា **អព្រហ្មចរិយំ** ប្រែថា ប្រព្រឹត្តមិនប្រសើរ ។ ឈ្មោះថា ព្រហ្មចារី ព្រោះប្រព្រឹត្តអាចារៈដ៏ប្រសើរ គឺ ប្រសើរបំផុត ។ បទថា **អារាចារី** បានដល់ អ្នកប្រព្រឹត្តឃ្លាតឆ្ងាយពីអព្រហ្មចរិយៈ ។ បទថា **មេថុនា** បានដល់ **អសទ្ធម្ម** ដែលរាប់ថា មេថុន ព្រោះសេពដោយបានវោហារថា **មេថុនកៈ** ព្រោះដូចជាត្រូវរាគៈរួបរឹត ។ បទថា **គាមធម្មា** ប្រែថា ធម៌របស់អ្នកស្រុក ។ ឈ្មោះថា **សច្ចវាទី** ព្រោះនិយាយពាក្យពិត ។ ឈ្មោះថា **សច្ចសន្ធោ** ព្រោះយកសច្ចៈជាមួយសច្ចៈភ្ជាប់តគ្នា អធិប្បាយថា មិននិយាយលាយកុហក ។ ការពិត បុរសណាពេលខ្លះនិយាយកុហក ពេលខ្លះនិយាយពាក្យពិត មិនយកសច្ចៈនិងសច្ចៈ

ភ្ជាប់តគ្នា ព្រោះសច្ចៈជាមួយមុសាវាទ មិននៅក្នុងខាងក្នុង ព្រោះហេតុនោះ បុរសនោះ មិនឈ្មោះថា យកសច្ចៈនិងសច្ចៈភ្ជាប់តគ្នា តែអ្នកនោះមិនមែនដូច្នោះទេ ។ អ្នកមិនពោលមុសាវាទ សូម្បីព្រោះហេតុនៃជីវិត តែយកសច្ចៈនិងសច្ចៈភ្ជាប់តគ្នា និយាយពាក្យពិតរហូតមួយរឿង ព្រោះហេតុនោះ អ្នកនោះឈ្មោះថា **សច្ចសន្ធៈ** ។ បទថា **ថេតោ** ប្រែថា ម៉ឺងម៉ាត់ អធិប្បាយថា អ្នកនិយាយម៉ឺងម៉ាត់ ។ ពិតហើយ បុគ្គលម្នាក់ ជាអ្នកមានពាក្យសម្ដីមិនម៉ឺងម៉ាត់ ដូចជ្រលក់សំពត់ដោយល្មៀត ដូចបោះបង្គោលទុកត្រង់គំនរអង្កាម និងដូចត្រឡាច ដែលគេដាក់ទុកលើខ្នងសេះ ដូច្នោះ ។ មួយទៀត មានពាក្យសម្ដីម៉ឺងម៉ាត់ ដូចស្នាមចារឹកក្នុងថ្ម និងដូចសសរខឿន សូម្បីកាលគេយកដាវកាប់សិរសា ក៏មិនពោលពាក្យសម្ដីឲ្យជាពីរ អ្នកនេះ ឈ្មោះថា **ឋេត** អ្នកមានពាក្យសម្ដីម៉ឺងម៉ាត់ ។ បទថា **សច្ចយិកោ** ប្រែថា បុគ្គលអ្នកដែលគួរជឿបាន អធិប្បាយថា អ្នកគួរជឿ ។ សេចក្ដីពិត បុគ្គលខ្លះ ជាអ្នកមិនគួរជឿ កាលណាគេសួរ ពាក្យនេះនរណាពោល បុគ្គលឯណោះពោលឬ រមែងត្រូវគេតបថា កុំជឿពាក្យរបស់អ្នកនោះ ។ បុគ្គលមួយ ជាបុគ្គលដែលគេគួរជឿបាន ពេលគេសួរថា ពាក្យនេះនរណាពោល អ្នកឯណោះពោលឬ រមែងត្រូវតវ៉ាថា គេនិយាយពាក្យនេះប៉ុណ្ណោះ

ជាប្រមាណ ឥឡូវនេះ មិនមានពាក្យដែលត្រូវសាកសួរ ពាក្យនេះត្រូវជា យ៉ាងនោះឯង អ្នកនេះលោកហៅថា អ្នកដែលគួរជឿបាន ។

បទថា **អវិសំវាទកោ លោកស្ស** សេចក្តីថា រមែងមិនពោលពាក្យជាពិស និងមនុស្សលោក ព្រោះមានប្រក្រតីពោលតែពាក្យសច្ចៈនោះ ។ បទថា **ឥមេសំ ភេទាយ** សេចក្តីថា ដើម្បីបំផ្លាញពួកជនដែលបានព្ញក្នុងសម្នាក់របស់អ្នកដែលនិយាយថា បានស្តាប់មកពីខាងនេះ ។ បទថា **ភិន្នានំ វា សន្ធាតា** សេចក្តីថា កាលណាមនុស្ស ២ ផ្នែក ជាមិត្រនឹងគ្នា ឬជាអ្នកដែលទាក់ទងគ្នា មានការរួមឧបជ្ឈាយ៍ជាមួយគ្នាជាដើម បែកគ្នាដោយកិច្ចយ៉ាងណាខ្លះហើយ អ្នកដែលគួរជឿបាន ចូលទៅរកម្តងមួយផ្នែកហើយ និយាយធ្វើសេចក្តីស្មានជាដើមថា ការណ៍យ៉ាងនេះ មិនសមគួរដល់ពួកលោកអ្នកកើតក្នុងត្រកូល ដូច្នេះ អ្នកជាពហូសូតយ៉ាងនេះទេ ដូច្នេះ ។ បទថា **អនុប្បទាតា** បានដល់ អ្នកជួយ ទំនុកបំរុងបុគ្គលដែលសម្រុះសម្រួលហើយ អធិប្បាយថា អ្នកដែលគួរជឿបាន ឃើញអ្នកទាំងពីរសាមគ្គីគ្នាហើយ និយាយធ្វើឲ្យចាំបានថា ការណ៍យ៉ាងនេះ ជាការណ៍សមគួរដល់ពួកលោកអ្នក ដែលកើតក្នុងត្រកូលបែបនោះ អ្នកដែលប្រកបដោយគុណបែបនេះ យ៉ាងនេះជាដើម ។ ឈ្មោះថា **សមគ្គារាមោ** ព្រោះមាន

អ្នកមានសាមគ្គីជាទីមកត្រេកអរ អធិប្បាយថា អ្នកសាមគ្គីគ្នា មិនមានក្នុងទីណា រមែងមិនប្រាថ្នានឹងនៅក្នុងទីនោះ ។ បាលីថា **សមគ្គារាមោ** យ៉ាងនេះក៏មាន ។ សេចក្តីក៏យ៉ាងនេះដូចគ្នា ។ បទថា **សមគ្គរតោ** បានដល់ អ្នកត្រេកអរក្នុងពួកមនុស្ស អ្នកព្រមព្រៀងគ្នា អធិប្បាយថា រមែងមិនប្រាថ្នានឹងលះបុគ្គលដែលជាអ្នកសាមគ្គីគ្នាទាំងនោះ ទៅក្នុងដទៃ ។ ឈ្មោះថា ជាអ្នករីករាយក្នុងអ្នកសាមគ្គីគ្នា ព្រោះជាបុគ្គលដែលគួរឲ្យជឿបាន ។ ឃើញក្តី ឮក្តី នៅពួកមនុស្សអ្នកមានសាមគ្គីគ្នា រមែងត្រេកអរ ។ បទថា **សមគ្គករណឹ វាចំ ភាសិតា** សេចក្តីថា បុគ្គលអ្នកដែលគួរជឿបាននោះ រមែងពោលវាចា ដែលធ្វើមនុស្សឲ្យសាមគ្គីគ្នា ដែលជាវាចាសម្តែងគុណរបស់សាមគ្គីតែម្យ៉ាង មិនពោលវាចាផ្ទុយគ្នាពីនេះ ។ ទោស លោកហៅ ឯល ក្នុងបទថា **នេលា** នោះដូច **នេល** ស័ព្ទ ដែលព្រះដ៏មាន-ព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ទុកក្នុងគាថានេះថា **នេលង្គោ សេតបច្ឆាទោ** យ៉ាងនេះជាដើម ។ បទថា **កិណ្ណសុខា** បានដល់ វាចាដែលពីរោះត្រចៀក គឺ មិនកើតសេចក្តីស៊កសៀត ដូចត្រូវម្ជុលចាក់ ព្រោះជាវាចាពីរោះដោយព្យញ្ជនៈ ឈ្មោះថា វាចាជាទីតាំងនៃសេចក្តីស្រឡាញ់ ព្រោះវាចានោះមិនធ្វើឲ្យកើតសេចក្តីក្រោធ ធ្វើសេចក្តីស្រឡាញ់ ឲ្យកើតទូទៅក្នុងសរីរៈ

ព្រោះជាវាចាពីរោះដោយអត្ថ ។ ឈ្មោះថា ជាវាចាចាប់ចិត្ត ព្រោះវាចានោះ រមែងដល់ចិត្ត គឺ មិនប៉ះទង្គិច ចូលទៅដល់ចិត្តដោយស្រួល ។ ឈ្មោះថា ជាវាចាអ្នកក្រុង ព្រោះវាចានោះ មាននៅក្នុងក្រុង ហេតុជាវាចាដែល បរិបូណ៌ដោយគុណ ។ ឈ្មោះថា **បោរី** ព្រោះវាចានោះ ជាវាចាទន់ភ្លន់ ប្រៀបដូចជាស្ត្រីអ្នកចម្រើនក្នុងបុរី យ៉ាងនេះក៏មាន ។ ឈ្មោះថា **បោរី** ព្រោះវាចានោះ ជាវាចាអ្នកស្រុកយ៉ាងនេះ មានអធិប្បាយថា ជាពាក្យ សម្តីរបស់អ្នកក្រុង ។ ដោយសេចក្តីថា អ្នកក្រុង រមែងជាអ្នកមានពាក្យ សម្តីសមគួរ ។ គឺ ហៅមនុស្សល្មមឪពុកថា ឪពុក មនុស្សល្មមម៉ែថា ម៉ែ ល្មមបងថា បង ។ ឈ្មោះថា អ្នកមានវាចា ដែលមនុស្សជាច្រើនស្រឡាញ់ ចូលចិត្ត ព្រោះពាក្យសម្តីបែបនោះ រមែងជាវាចា ដែលមនុស្សជាច្រើន ពេញចិត្ត ។ ឈ្មោះថា ជាវាចាជាទីពេញចិត្តនៃជនច្រើន ព្រោះវាចានោះ ជាទីពេញចិត្ត គឺ ធ្វើសេចក្តីចម្រើនចិត្តដល់ជនជាច្រើន ព្រោះជាវាចា ដែលមានមនុស្សទាំងឡាយស្រឡាញ់ ប្រាថ្នានោះឯង ។ បុគ្គលអ្នកឈ្មោះ ថា **កាលវាទី** ព្រោះពោលតាមកាល អធិប្បាយថា បុគ្គលនោះ រមែង កំណត់កាលដ៏គួរ ពោលហើយពោលទៀត ។ ឈ្មោះថា **អ្នកមានប្រក្រតី ពោលពាក្យពិត** ព្រោះរមែងពោលពាក្យដែលពិត គឺ ពាក្យពិត បានដល់

ពាក្យពិតតែម្យ៉ាង ។ ឈ្មោះថា **អ្នកមានប្រក្រតីពោលអាស្រ័យប្រយោជន៍** ព្រោះបុគ្គលនោះ ពោលធ្វើឲ្យជាពាក្យអាស្រ័យអត្ថ ដែលជាប្រយោជន៍ ក្នុងភពនេះ និងភពខាងមុខតែម្យ៉ាង ។ ឈ្មោះថា **អ្នកមានប្រក្រតីពោលអាស្រ័យធម៌** ព្រោះបុគ្គលនោះ រមែងពោលធ្វើឲ្យជាពាក្យអាស្រ័យលោកុត្តរធម៌ ៩ ។ ឈ្មោះថា **អ្នកមានប្រក្រតីពោលអាស្រ័យវិន័យ** ព្រោះពោលធ្វើឲ្យជាពាក្យអាស្រ័យសំវរវិន័យ និងបហានវិន័យ ។ ឱកាសទីតាំង លោកហៅថា លក្ខណ លក្ខណនៃវាចានោះមាន ហេតុនោះវាចានោះឈ្មោះថា **មានលក្ខណ** អធិប្បាយថា បុគ្គលដែលគួរជឿបាននោះ រមែងជាអ្នកពោលវាចាដ៏សមគួរ ដែលនឹងគប្បីទទួលទុកក្នុងហឫទ័យ ។ បទថា **កាលេន** សេចក្ដីថា ក៏បុគ្គលអ្នកគួរជឿបាននោះ សូម្បីកាលពោលពាក្យបែបនោះ រមែងមិនពោលក្នុងកាលដែលមិនសមគួរ ដោយប្រកាន់ថា និងពាក្យពោលមានលក្ខណយ៉ាងនេះ តែពិចារណាកាលដ៏សមគួរហើយ ទើបពោល ។ បទថា **សាបទេសំ** សេចក្ដីថា មានឧបមា មានហេតុ ។ បទថា **បរិយន្តវតី** មានសេចក្ដីថា ទីបំផុតនៃវាចានោះ នឹងប្រាកដដោយប្រការណា បុគ្គលអ្នកជឿបាននោះ ពោលសម្ដែងទីបំផុត ដោយប្រការនោះ ។ បទថា **អត្ថសញ្ហិតំ** សេចក្ដីថា ឈ្មោះថា ដល់ព្រមដោយប្រយោជន៍ ព្រោះវាចា

នោះ ដែលបុគ្គលអ្នកចែកដោយន័យសូម្បីជាច្រើន មិនអាចនឹងឲ្យកាន់យកទីបំផុតបាន ម្យ៉ាងទៀត មានសេចក្តីថា បុគ្គលអ្នកគួរជឿនោះ រមែងពោលវាចា ដែលឈ្មោះថា ប្រកបដោយប្រយោជន៍ ព្រោះវាចានោះ ជាវាចាប្រកបដោយប្រយោជន៍ ដែលគេពោល លោកពោលអធិប្បាយទុកថា បុគ្គលអ្នកគួរជឿនោះ មិនលើកពាក្យម្យ៉ាង ហើយត្រឡប់ទៅពោលពាក្យម្យ៉ាងទៀតទេ ។

បទថា **វីជគាមភូតគាមសារម្ភា** សេចក្តីថា វៀរចាកការផ្តាច់ពីជ-គាម ៥ យ៉ាង គឺ ពូជកើតពីឫស ពូជកើតពីដើម ពូជកើតពីថ្នាំង ពូជកើតពីត្រួយ ពូជកើតពីគ្រាប់ និងភូតគាមរបស់ស្មៅពណ៌ខៀវ និងដើមឈើជាដើម ប្រភេទណាមួយ គឺ បំផ្លាញដោយកាត់ និងដុតជាដើម ។ បទថា **ឯកភត្តិកោ** សេចក្តីថា ភត្ត ២ យ៉ាង គឺ ភត្តដែលគប្បីបរិភោគក្នុងវេលាព្រឹក ភត្តដែលគប្បីបរិភោគក្នុងវេលាល្ងាច ក្នុង ២ យ៉ាងនោះ ភត្តដែលគប្បីបរិភោគក្នុងវេលាព្រឹក កំណត់ខាងក្នុងថ្ងៃត្រង់ ភត្តដែលគប្បីបរិភោគក្នុងវេលាល្ងាច កំណត់តាំងពីថ្ងៃត្រង់រហូតដល់ពេលអរុណរះ ព្រោះដូច្នោះ សូម្បីនឹងបរិភោគខាងក្នុងថ្ងៃត្រង់ តាំងពី ១០ ដង ក៏ឈ្មោះថាជាអ្នកមានភត្តតែមួយដង លោកសំដៅយកភាព ជាអ្នកមានភត្តមួយដងនោះ

ពោលថា **ឯកភត្តិកោ** យ៉ាងនេះ ។ ឈ្មោះថា **រត្តូបរតោ** ព្រោះវៀរចាក ការបរិភោគក្នុងវេលាយប់នោះ ។ ការបរិភោគក្នុងវេលាហួសថ្ងៃត្រង់ទៅ រហូតដល់ព្រះអាទិត្យលិច ឈ្មោះថា បរិភោគវេលាវិកាល ។ ព្រោះវៀរ ចាកវិកាលភោជន៍នោះ ទើបឈ្មោះថា វៀរចាកការបរិភោគអាហារក្នុង វេលាវិកាល ។ ឈ្មោះថា **វិសូកទស្សនំ** ព្រោះការមើលដែលជាសត្រូវ ព្រោះមិនអនុលោមតាមព្រះសាសនា ។ ឈ្មោះថា **នច្ចគីតវាទិតវិសូក-ទស្សនា** ព្រោះការរាំ ការច្រៀង ការប្រគុំ ដោយអំណាចរាំខ្លួនឯង និង ឲ្យអ្នកដទៃរាំជាដើម និងការមើលដែលជាសត្រូវចំពោះការរាំជាដើម ដែល ប្រព្រឹត្តទៅសូម្បីយ៉ាងទាប មានសត្វក្ងោក សត្វរាំពេជាដើម ។ ការប្រកប ខ្លួនឯងក្តី ការឲ្យអ្នកដទៃប្រកបក្តី នូវការរាំជាដើម ឬមើលការរាំជាដើម ដែលអ្នកដទៃប្រកប រមែងមិនគួរដល់ភិក្ខុ និងភិក្ខុនីទាំងអស់ ។ បទថា **មាលា** ក្នុងពាក្យថា **មាលា** ជាដើម បានដល់ ផ្កាឈើប្រភេទណាមួយ ។ បទថា **គន្ធំ** បានដល់ វត្ថុក្រអូបប្រភេទណាមួយ ។ បទថា **វិលេបនំ** បានដល់ គ្រឿងលាបធ្វើឲ្យស្បែកភ្លឺ ។ អ្នកតុបតែងក្នុងគ្រឿងប្រដាប់ ទាំងនោះ ឈ្មោះថា ស្អិតស្អាងរាងកាយ ។ អ្នកធ្វើប្រដាប់ឲ្យពេញ ឈ្មោះថា ប្រដាប់ ។ អ្នកត្រេកអរដោយវត្ថុក្រអូប និងគ្រឿងធ្វើឲ្យសម្បុរ

ក្តីស្អាត ឈ្មោះថា តុបតែង ។ ហេតុ លោកហៅថា **ឋាន:** អធិប្បាយថា ព្រោះដូច្នោះ មហាជនធ្វើការទ្រទ្រង់រាងកាយ ដោយផ្កាជាដើមទាំងនោះ ដោយចេតនាគ្រឿងទ្រុស្តសីល ជាអ្នកឈប់ វៀរចាកចេតនាគ្រឿងទ្រុស្ត-សីលនោះ ។ ទីដេកដែលហួសប្រមាណ លោក ហៅថា **ឧច្ចាសយន** ។ គ្រឿងក្រាលដែលមិនសមគួរ ឈ្មោះថា **មហាសយន** ។ អធិប្បាយថា វៀរចាកទីដេកខ្ពស់ និងទីដេកធំហួសប្រមាណនោះ ។ បទថា **ជាតរូបំ** បានដល់ មាស ។ បទថា **រជតំ** សេចក្តីថា វត្ថុពួកណាដល់ការបញ្ញត្តិថា កហាបណៈ មាសកលោហៈ មាសកជ័រ មាសកឈើ វៀរចាកការទទួលវត្ថុទាំងពីរនោះ អធិប្បាយថា មិនទទួលខ្លួនឯង មិនឲ្យអ្នកដទៃទទួលវត្ថុទាំងពីរនោះ មិនត្រេកអរក្នុងវត្ថុទាំងពីរ ដែលអ្នកដទៃទុកដាក់ឲ្យ ។

បទថា **អមកធញ្ញប្បដិគ្គហណា** បានដល់ វៀរចាកការទទួលធញ្ញជាតិឆៅ ៧ យ៉ាង គឺ ស្រូវសាលី ស្រូវខ្សាយ ស្រូវដំណើប ស្រូវស្រងែ ស្កួយ ថ្ពៅ ស្មៅគែលលលក មិនមែនហាមការទទួលធញ្ញជាតិនោះ តែម្យ៉ាងប៉ុណ្ណោះ សូម្បីការប៉ះពាល់ដល់ភិក្ខុទាំងឡាយ ។ ក្នុងបទថា **អាមកមំសប្បដិគ្គហណា** នេះ សេចក្តីថា ការទទួលសាច់ និងត្រីឆៅរមែងមិនគួរដល់ភិក្ខុទាំងឡាយ ការប៉ះពាល់ក៏មិនគួរ ក្រៅអំពីដែលទ្រង់

អនុញ្ញាតទុកដោយចំពោះ ។ ពាក្យថា **ឥត្ថី** ក្នុងពាក្យថា **ឥត្ថីកុមារិក-ប្បដិគ្គហណា** នេះ បានដល់ ស្ត្រីដែលកំពុងនៅនឹងបុរស ក្រៅពីនោះ ចាត់ជាស្ត្រីក្រមុំ ។ ការទទួលក្តី ការចាប់ពាល់ក្តី នូវស្ត្រីទាំងនោះ ។ ក្នុងបទថា **ទាសីទាសប្បដិគ្គហណា** នេះ សេចក្តីថា មិនគួរទទួលជនទាំងនោះទុក ដោយទាសាទាសីឡើយ តែកាលគេនិយាយថា ខ្ញុំថ្វាយជាកប្បិយ-ការកៈ ខ្ញុំថ្វាយជាអ្នកបំរើកត្ត ក៏គួរទទួលបាន ។ ក្នុងពពែ និងចៀមជាដើម មានស្រែ និងចំការជាទីបំផុត គប្បីពិចារណា ន័យដែលសមគួរ និងមិនសមគួរតាមវិន័យ ។ ក្នុងបណ្តាស្រែ និងចំការនោះ ឈ្មោះថា ស្រែ គឺ កន្លែងដាំបព្វណ្ណជាតិ , ឈ្មោះថា ចំការ គឺ កន្លែងដាំអបរណ្ណជាតិ ។ ម្យ៉ាងទៀត កន្លែងដែលបព្វណ្ណជាតិ និងអបរណ្ណជាតិ ទាំងពីរដុះឡើងនោះ ឈ្មោះថា ភូមិភាគ ដែលមិនបានធ្វើទុកដើម្បីប្រយោជន៍នោះ ឈ្មោះថា ចំការ ។ ក៏ក្នុងទីនេះ លោករួមសូម្បីបឹង ត្រពាំងជាដើម ដោយមានស្រែ និងចំការជាសំខាន់ ។ ការទូត គឺ ការកាន់សំបុត្រ ឬពិតមានរបស់គ្រហស្ថទៅក្នុងទីនោះៗ ហៅថា **ទូតេយ្យ** (ការជូនព័តមាន) ។ ការទៅដោយកិច្ចបន្តិចបន្តួចៗ របស់អ្នកផ្ញើរពីផ្ទះនេះ ទៅកាន់ផ្ទះនោះ លោកហៅថាការបម្រើ ។ ការធ្វើទាំងពីរយ៉ាងនោះ ឈ្មោះថា **អនុយោគ** ព្រោះដូច្នោះ

គប្បីឃើញសេចក្ដីក្នុងប្រការនេះថា ការប្រកបរឿយៗ នូវការជួនដំណឹង និងការបម្រើ ។ បទថា **កយវិកយា** បានដល់ ការទិញ និងការលក់ ។ បទថា **កូដំ** ក្នុងពាក្យថា **តុលាកូដំ** ជាដើម បានដល់ ភាពវៀចវេរ ។ មុនដំបូងបង្អស់ ក្នុងការវៀចវេរទាំងនោះ ការវៀចវេរដោយថ្លឹងជញ្ជីង មាន ៤ យ៉ាងគឺ វៀចវេរដោយរូប វៀចវេរដោយអវយវៈ វៀចវេរដោយការទទួល វៀចវេរដោយការបិទបាំង ។ ក្នុងការវៀចវេរ ៤ យ៉ាងនោះ ឈ្មោះថា **ការវៀចវេរដោយរូប** គឺ ការធ្វើថ្លឹងជញ្ជីង ២ ឲ្យមានរូបដូចគ្នា កាលណាទទួល ក៏ទទួលដោយថ្លឹងជញ្ជីងមួយធំ កាលណាឲ្យក៏ឲ្យដោយថ្លឹងជញ្ជីងមួយតូច ។ ឈ្មោះថា **វៀចវេរដោយអវយវៈ** គឺ កាលណាទទួល ក៏ទទួលដោយយកដៃសង្កត់ថ្លឹងខាងក្រោយ កាលណាឲ្យក៏យកដៃសង្កត់ថ្លឹងជញ្ជីញខាងមុខ ។ ឈ្មោះថា **ការវៀចវេរដោយទទួល** គឺ កាលណាទទួល ក៏ចាប់ខ្សែខាងដើម កាលណាឲ្យក៏ចាប់ខ្សែខាងចុង ។ ឈ្មោះថា **វៀចវេរដោយការបិទបាំង** គឺ ធ្វើថ្លឹងជញ្ជីងឲ្យប្រហោងក្នុង ហើយដាក់កំទេចដែកខាងក្នុង ។ កាលណាទទួល ក៏ធ្វើថ្លឹងជញ្ជីងនោះទុកខាងក្រោយ កាលណាឲ្យ ក៏ធ្វើថ្លឹងជញ្ជីងទុកខាងចុង ។

ថាសមាស ហៅសំរិត ។ ការវៀចវេរដោយថាសមាសនោះ ឈ្មោះ

ថា រៀចរេរដោយសំរិត ។ យ៉ាងណា ? គឺ ធ្វើថាសមាសមួយ ហើយធ្វើថាសលោហៈដទៃ ២-៣ ឲ្យមានពណ៌ដូចមាស តពីនោះទៅកាន់ជនបទចូលទៅរកត្រកូលអ្នកមានណាមួយ ពោលថា អ្នកចូរទិញភាជន៍មាសកាលណាគេសួរតម្លៃ ជាអ្នកប្រាថ្នានឹងឲ្យរបស់ដែលមានតម្លៃច្រើនជាង ។ តពីនោះ កាលណាអ្នកទាំងនោះនិយាយថា ប្រាប់មកមើលខ្ញុំនឹងដឹងថា ថាសទាំងនេះ ជាមាសបានយ៉ាងណា ទើបប្រាប់ថា លោកចូរសាកមើលចុះ ហើយយកថាសមាសជុសនឹងថ្ម ហើយប្រគល់ថាសទាំងអស់ឲ្យ ។ ឈ្មោះថា **ការរៀចរេរដោយគ្រឿងវាល់** មាន ៣ យ៉ាងគឺ **ហទយភេទ** ១ **សិខាភេទ** ១ **រជ្ជុភេទ** ១ ។ ក្នុង ៣ យ៉ាងនោះ **ហទយភេទ** ប្រើក្នុងវេលាវាល់ខ្ទាញ់ទឹកដោះថ្លា និងប្រេងជាដើម គឺ កាលនឹងទិញទឹកដោះថ្លា និងប្រេងជាដើមទាំងនោះ ក៏ប្រាប់ថា សូមឲ្យចាក់បន្តិចៗ ហើយទឹកដោះថ្លា និងប្រេងជាច្រើន ហូរទៅក្នុងខាងកាជន៍ដោយគ្រឿងវាល់ ដែលមានប្រហោងខាងក្នុងកាលណានឹងលក់ ក៏បិទប្រហោងធ្វើឲ្យពេញឆាប់ៗ ហើយឲ្យទៅ ។

**សិខាភេទ** ប្រើក្នុងវេលាវាល់ល្ង និងអង្ករជាដើម ។ គឺ កាលនឹងវាល់ទិញល្ង និងអង្ករជាដើមទាំងនោះ ក៏ធ្វើឲ្យកំពុងឡើងបន្តិចម្តងៗ កាលណាវាល់លក់ ក៏ប្រញាប់វាល់ឲ្យពេញហើយគៀរលក់ទៅ ។

**វដ្ឌភេទ** ប្រើក្នុងវេលាវាស់ស្រែ , បឹង , ចំការ ។ គឺ កាលណា មិនបានឲ្យថ្លៃឈ្នួល ក៏វាស់ស្រែដែលមិនធំ ក៏ឲ្យធំបាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **អក្កោដន** ជាដើម ។ បទថា **អក្កោដនំ** សំដៅយកការកោង ដើម្បីធ្វើមនុស្សជាអ្នកម្ចាស់របស់ មិនឲ្យជាម្ចាស់របស់ ។ បទថា **វញ្ចនំ** បានដល់ ការកុហកអ្នកដទៃដោយឧបាយនោះ ។ ក្នុងសេចក្តីនោះ មានរឿងមួយជាឧទាហរណ៍ដូចតទៅនេះ មានដំណាលមកថា នាយព្រានម្នាក់ ចាប់មេម្រឹគ និងកូនម្រឹគមក ។ អ្នកលេងម្នាក់និយាយនឹងគេថា អ្នកដ៏ចម្រើន មេម្រឹគថ្លៃប៉ុន្មាន កូនម្រឹគថ្លៃប៉ុន្មាន ។ គេឆ្លើយថា មេម្រឹគថ្លៃ ២ កហាបណៈ កូនម្រឹគថ្លៃ ១ កហាបណៈ អ្នកលេងទើបឲ្យមួយកហាបណៈ ហើយនាំយកកូនម្រឹគទៅ បានមួយក្លែត ក៏ត្រឡប់មក និយាយថា ខ្ញុំមិនត្រូវការកូនម្រឹគនោះទេ លោកចូរឲ្យមេម្រឹគដល់ខ្ញុំ ។ បើដូច្នោះ លោកចូរឲ្យ ២ កហាបណៈ ។ អ្នកលេងនោះនិយាយថា អ្នកដ៏ចម្រើន យើងឲ្យមួយកហាបណៈដល់លោក កាលមុនហើយមិនមែនឬ ។ ព្រានម្រឹគទទួលថា អើ ! ឲ្យហើយ ។ ទើបពោលថា លោកចូរយកកូនម្រឹគនេះទៅ កាលបើដូច្នោះ កហាបណៈនោះ និងកូនម្រឹគ ដែលមានតម្លៃ ១ កហាបណៈនេះ ទើបរួមជា ២ កហាបណៈ ។ នាយព្រានគិត

ថា គេពោលមានហេតុផល ទើបទទួលយកកូនម្រឹគទុក ហើយឲ្យមេម្រឹគទៅ ។ បទថា **និកតិ** បានដល់ ការបោកបញ្ឆោតដោយវិធីបន្ទំ ដោយធ្វើរបស់ដែលមិនមែនសង្វារ ថាជាសង្វារ ដែលមិនមែនកែវមណី ថាជាកែវមណី ដែលមិនមែនមាស ថាជាមាស ដោយការត្រឡប់ត្រឡិន ឬដោយការបញ្ឆោត ។ បទថា **សាវិយោគោ** ប្រែថា ការត្រឡប់ត្រឡិន ដោយការវៀចវេរ ។ ពាក្យថា **សាវិយោគោ** នេះ ជាឈ្មោះនៃការវៀចវេរជាដើមទាំងនេះ នោះឯង ។ ព្រោះដូច្នោះ គប្បីឃើញសេចក្តីក្នុងពាក្យថា **សាវិយោគោ** នេះថា ត្រឡប់ត្រឡិនដោយការវៀចវេរ ត្រឡប់ត្រឡិនដោយការឆបោក ។ អាចារ្យពួកខ្លះពោលថា ការបង្ហាញរបស់មួយហើយផ្លាស់ទៅជារបស់មួយទៀត ឈ្មោះថា **សាវិយោគោ** ឆ្លើយត្រឡប់ត្រឡិន ។ តែពាក្យនេះ លោកក៏រួមចូលដោយការឆបោកដូចគ្នា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្តីថា **ឆេទន** ជាដើម ពាក្យថា **ឆេទនំ** បានដល់ ការកាត់ដៃជាដើម បទថា **វធោ** បានដល់ ការធ្វើឲ្យស្លាប់ ។ បទថា **ពន្ធោ** បានដល់ កាចោប់ចងដោយគ្រឿងចង គឺ ខ្សែជាដើម ។ បទថា **វិបរាមោសោ** បានដល់ ការបិទបាំង មាន ២ យ៉ាង គឺ បាំងដោយហិមៈ (ទឹកសន្សើម) និងបាំងដោយគុម្ពឈើ ។ ក្នុង ២ យ៉ាងនោះ បាំងដោយហិមៈ ក្នុងវេលា

ទឹកសន្សើមធ្លាក់ ហើយនឹងនិយាយកុហក និងជនអ្នកដើរទៅ នេះហៅថា **ហិមវិបរាមោស** បាំងដោយហិមៈ ។ បាំងដោយគុម្ពឈើជាដើម ហើយនិយាយកុហក នេះហៅថា **គុម្ពវិបរាមោស** បាំងដោយគុម្ពឈើ ។ ការប្លន់អ្នកស្រុក និងអ្នកនិគមជាដើម ហៅថា **អាលោបោ** ការប្លន់ ។ បទថា **សហសាការោ** បានដល់ ការធ្វើយ៉ាងឆាប់រហ័ស គឺ ចូលទៅកាន់ទូកក្នុងកនឹងអាវុធទាំងឡាយ ហើយធក់របស់របរតាមប្រាថ្នាទៅ ជាអ្នកវៀរចាកពីអាការកាប់សម្លាប់ ចាប់ចង បាំង ប្លន់ ក្នុងអាវុធនោះ ដោយប្រការដូច្នេះ ។

បទថា **សោ សន្តុដ្ឋោ ហោតិ** សេចក្តីថា ភិក្ខុនេះប្រកបដោយបច្ច័យសន្តោស ១២ យ៉ាង ក្នុងបច្ច័យ ៤ ដូចពោលហើយក្នុងកាលមុន ។ មួយទៀត **បរិក្ខារ ៨** គឺ ត្រៃចីវរ បាត្រ កាំបិតតូចសម្រាប់ ធ្វើឈើដុសធ្មេញ ម្ជុល ខ្សែក្រវាត់ចង្កេះ សំពត់ត្រងទឹក រមែងគួរ ដល់ភិក្ខុអ្នកប្រកបដោយសេចក្តីសន្តោសក្នុងបច្ច័យ តាមមានតាមបាន ១២ យ៉ាងនេះ ។ សមពិតដូចព្រះបុរាណាចារ្យ ពោលទុកថា ៖

បរិក្ខារទាំងនេះ គឺ ត្រៃចីវរ បាត្រ កាំបិតតូច
ម្ជុល និងវត្ថុពន្ធចង្កេះ ជា ៨ ទាំងសំពត់ត្រងទឹក

រមែងគួរដល់ភិក្ខុអ្នកប្រកបសេចក្តីព្យាយាមផង ។

បរិក្ខារទាំងនោះ សូម្បីទាំងអស់ ជាគ្រឿងបរិហារកាយក៏បាន បរិហារផ្ទៃក៏បានយ៉ាងណា ដទៃពីនោះ ត្រៃចីវររមែងបរិហារ គឺ ការពារបិទបាំងកាយ ក្នុងគ្រាដែលស្លៀកដណ្តប់ ព្រោះដូច្នោះ ទើបឈ្មោះថា ជាគ្រឿងបរិហារកាយ រមែងបរិហារ គឺ ចិញ្ចឹមក្រពះ ក្នុងគ្រាដែលត្រងទឹកផឹក និងក្នុងគ្រាដែលវេចខ្ចប់ផ្លែឈើតូចធំ ដែលគួរទំពាស៊ីបានដោយជាយចីវរនោះ ព្រោះដូច្នោះ ទើបឈ្មោះថា ជាគ្រឿងបរិហារផ្ទៃ ។ សូម្បីបាត្រ ក៏ជាគ្រឿងបរិហារកាយក្នុងពេលដែលដងទឹក ដោយបាត្រនោះងូត និងក្នុងគ្រាដែលដងទឹកដោយបាត្រនោះព្រោះព្រំកុដិ ។ ជាគ្រឿងបរិហារក្រពះ ក្នុងគ្រាទទួលអាហារដោយបាត្រនោះឆាន់ ។ សូម្បីកាំបិតតូច រមែងជាគ្រឿងបរិហារកាយក្នុងគ្រាដែលពុះឈើដុសធ្មេញ និងក្នុងគ្រាដែលធ្វើជើងគ្រែ ជើងតាំង ដងឆ័ត្រ ជាគ្រឿងបរិហារផ្ទៃ ក្នុងគ្រាដែលកាប់អំពៅ បកដូងជាដើម ។ សូម្បីម្ជុល រមែងជាគ្រឿងបរិហារកាយ ក្នុងគ្រាដែលដេរចីវរ ក៏ជាគ្រឿងបរិហារផ្ទៃ ក្នុងគ្រាចុចនំ ឬផ្លែឈើឆាន់ ។ សូម្បីវត្តពន្ធចង្កេះ រមែងជាគ្រឿងបរិហារកាយ ក្នុងគ្រាក្រវាត់ដើរទៅ ក៏ជាគ្រឿងបរិហារផ្ទៃ ក្នុងគ្រាចងអំពៅជាដើម កាន់យកទៅ ។ សូម្បីសំពត់ត្រងទឹក រមែងជាគ្រឿងបរិហារ

កាយ ក្នុងគ្រាដែលត្រូវទឹកផឹកដោយសំពត់នោះ ហើយធ្វើការប្រោះព្រំសេនាសនៈ ជាគ្រឿងបរិហារផ្ទៃ ក្នុងគ្រាដែលត្រូវទឹកផឹក និងក្នុងគ្រាដែលខ្ចប់ល្ង បាយ និងអំបុកជាដើម ដោយសំពត់នោះហើយឆាន់ ។ នេះជាប្រមាណបរិក្ខាររបស់ភិក្ខុអ្នកមានបរិក្ខារ ៨ ប៉ុណ្ណោះ ។

ចំណែកភិក្ខុអ្នកមានបរិក្ខារ ៩ ចូលទៅដល់ទីដេក និងមានគ្រឿងក្រាលសម្រាប់សេនាសនៈនោះ ឬកូនសោក៏គួរ ។ ភិក្ខុអ្នកមានបរិក្ខារ ១០ នឹងមានសំពត់និសីទនៈ ឬផ្ទាំងស្បែកក៏គួរ ។ ភិក្ខុអ្នកមានបរិក្ខារ ១១ នឹងមានឈើច្រត់មនុស្សចាស់ ឬនាឡិ ប្រេងក៏គួរ ។ ភិក្ខុអ្នកមានបរិក្ខារ ១២ នឹងមានឆត្រ ឬស្បែកជើងក៏គួរ ។ ក៏ក្នុងភិក្ខុទាំងនោះ ភិក្ខុអ្នកមានបរិក្ខារ ៨ ប៉ុណ្ណោះ ឈ្មោះថា អ្នកមានសេចក្ដីសន្ដោស ក្រៅពីនោះ អ្នកណាៗ ក៏មិនគួរពោលថា មិនសន្ដោស ជាអ្នកប្រាថ្នាច្រើន ជាអ្នកប្រាថ្នាធំ ភិក្ខុទាំងអស់នោះ ជាអ្នកប្រាថ្នាតិច សន្ដោស ចិញ្ចឹមងាយ និងមានការប្រព្រឹត្តស្រាលដោយពិត ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់មិនបានសម្ដែងព្រះសូត្រនេះ ដោយអំណាចនៃភិក្ខុទាំងនោះ ទ្រង់សម្ដែងដោយអំណាចនៃភិក្ខុអ្នកមានបរិក្ខារ ៨ ។ ពិតណាស់ ភិក្ខុមានបរិក្ខារ ៨ នោះ ខ្ចប់កាំបិត និងម្ជុលទុកក្នុងសំពត់តម្រងទឹក រក្សាទុកដាក់ក្នុងបាត្រ ហើយព្យួរបាត្រទុក

ដែលនឹងរង់ចាំស្លៀកដណ្ដប់ត្រៃចីវរ ក្រវាត់វត្ថពន្ធចង្កេះ ហើយចៀសចេញទៅសប្បាយតាមប្រាថ្នា ។ លោកមិនត្រូវការត្រឡប់មកយកអ្វីទៀតទេ ។ យ៉ាងនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងការប្រព្រឹត្តស្រាលព្រមរបស់ភិក្ខុនេះ ទើបទ្រង់ត្រាស់ថា **សន្តុដ្ឋោ ហោតិ កាយបរិហារិយេន ចីវរេន** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **កាយបរិហារិយេន** គឺត្រឹមតែជាគ្រឿងបរិហារកាយ ។ បទថា **កុច្ឆិបរិហារិយេន** បានដល់ ត្រឹមតែជាគ្រឿងបរិហារផ្ទៃ ។ បទថា **សមាទាយេវ បកបាមតិ** សេចក្ដីថា លោកកាន់យកត្រឹមតែគ្រឿងបរិក្ខារ ៨ ទាំងអស់នោះជាប់ខ្លួនទៅ រមែងមិនទាក់ទើ ឬជាប់ថា វិហារ បរិវេណ ឧបដ្ឋាករបស់យើង ភិក្ខុអ្នកមានបរិក្ខារ ៨ នោះ ប្រើប្រាស់សេនាសនៈ ដែលខ្លួនប្រាថ្នាហើយ ក្នុងព្រៃសណ្ឌ: គល់ឈើ ជាយព្រៃ នៅតែម្នាក់ឯង អង្គុយម្នាក់ឯង មិនមានមិត្រក្នុងឥរិយាបទទាំងពួង ដូចព្រួញដែលស្ទុះទៅផុតអំពីធ្នូ និងដូចដំរីចុះប្រេងគេចចេញចាកហ្វូង ដូច្នោះ មែងដល់ភាពជាអ្នកដូចកុយរមាស ដែលលោកពណ៌នាទុកយ៉ាងនេះថា ៖

ចាតុទ្ទិសោ អប្បដិឃោ ច ហោតិ សន្តុស្សមានោ
អតរីតរេន បរិស្សយានំ សហិតា អច្ឆម្ភី ឯកោ ចរេ

ខគ្គវិសាណកប្បោ ។

ភិក្ខុអ្នកសន្តោស រមែងជាអ្នកនៅជាសុខក្នុងទិសទាំង ៤ និង

ជាអ្នកមិនសោប់សេល់ សន្តោសដោយបច្ច័យតាមមានតាម

បានគ្របសង្កត់អន្តរាយទាំងឡាយ មិនញាប់ញ័រ ត្រាច់ទៅ

ម្នាក់ឯង ដូចកុយរមាស ។

ឥឡូវនេះ កាលទ្រង់សាធកៈសេចក្តីនោះ ដោយឧបមា ទើបទ្រង់ត្រាស់ថា **សេយ្យថាបិ** ជាដើម ។ បណ្តាបទទាំងនោះ បទថា **បក្ខី សកុណោ** បានដល់ បក្សី ។ បទថា **ឌេតិ** ប្រែថា ហើរ ។ ក៏សេចក្តីសន្និដ្ឋានក្នុងប្រការនេះ មានដូច្នេះ ។ ធម្មតា បក្សីទាំងឡាយដឹងថា ដើមឈើក្នុងទីឯណោះ មានផ្លែទុំ ទើបនាំគ្នាមកអំពីទិសផ្សេងៗ ហោះ ចឹកស៊ីផ្លែរបស់ដើមឈើនោះ ដោយក្រចក ស្លាប និងចំពុះជាដើម ។ បក្សីពួកនោះ មិនមានការគិតថា នេះសម្រាប់ថ្ងៃ នេះសម្រាប់ស្អែក តែកាលណាផ្លែឈើអស់ វាក៏មិនត្រូវការរក្សាដើមឈើទុក មិនត្រូវយកស្លាប ក្រចក ឬចំពុះ ទុកដាក់នៅនឹងដើមឈើនោះ ដោយការពិត មិនមានសេចក្តីអាល័យក្នុងដើមឈើនោះ សត្វណាប្រាថ្នាទិសខាងណា សត្វនោះមានភារៈ គឺ ស្លាបរបស់ខ្លួនប៉ុណ្ណោះ ហើរទៅខាងទិសនោះ យ៉ាងណា ភិក្ខុនោះក៏ដូច្នោះដូច

គ្នា មិនមានសេចក្ដីគិត ប្រាសចាក សេចក្ដីអាល័យចេញទៅ តាំងចិត្តនឹងចេញទៅតែម្យ៉ាង ។ បទថា **អរិយេន** ប្រែថា មិនមានទោស ។ បទថា **អជ្ឈត្តំ** ប្រែថា ក្នុងអត្តភាពរបស់ខ្លួន ។ បទថា **អនវជ្ជសុខំ** ប្រែថា សុខដែលមិនមានទោស ។ បទថា **សោ ចក្ខុនា រូបំ ទិស្វា** សេចក្ដីថា ភិក្ខុនោះ គឺ ជាអ្នកប្រកបដោយសីលក្ខន្ធដែលជាអរិយនេះ ឃើញរូបដោយចក្ខុវិញ្ញាណ ។ ពាក្យដែលនឹងគប្បីពោលក្នុងបទដ៏សេសទាំងអស់ ពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

បទថា **អព្យាសេកសុខំ** បានដល់ សុខដែលមិនច្របូកច្របល់ដោយកិលេស ។ លោកពោលថា សុខដែលមិនទាក់ទិនដោយកិលេស ក៏មាន ។ ពិតហើយ សុខក្នុងឥន្ទ្រិយសំវរៈ ឈ្មោះថា មិនទាក់ទិន ព្រោះប្រព្រឹត្តទៅដោយអំណាចត្រឹមតែរូបដែលឃើញហើយ ក្នុងអារម្មណ៍ មានរូបដែលឃើញហើយជាដើម ។ បទថា **សោ អភិក្កន្តេ បដិក្កន្តេ** សេចក្ដីថា ភិក្ខុនោះ គឺ អ្នកប្រកបដោយការសង្រួមឥន្ទ្រិយ មានចិត្តជាទី ៦ ជាអ្នកមានប្រក្រតីធ្វើនូវការដឹងខ្លួនដោយសតិ និងសម្បជញ្ញៈ ក្នុងឋានៈទាំង ៧ នេះ មានការឈានទៅមុខ និងការត្រឡប់ថយជាដើម ។ ពាក្យដែលនឹងគប្បីពោលក្នុងសេចក្ដីនោះ បានពោលទុកហើយ ក្នុងសតិប្បដ្ឋានសូត្រនោះឯង ។

(៧២) ដោយពាក្យថា **សោ តមិនា ច** ជាដើម លោកសម្ដែង ទុកយ៉ាងណា ។ លោកសម្ដែងដល់បច្ច័យសម្បត្តិ នៃការនៅព្រៃ ។ ពិត ណាស់ ការនៅព្រៃរបស់អ្នកដែលមិនមានបច្ច័យ ទាំងនេះរមែងមិនសម្រេច និងត្រូវតិះដៀលថាដូចជាសត្វតិរច្ឆាន ឬព្រានព្រៃ ។ ពួកទេវតា ដែលនៅ ក្នុងព្រៃ នាំគ្នាប្រកាសកងរំពង ដោយសំឡេងដែលគួរខ្ពើមថា ភិក្ខុអាក្រក់ បែបនេះ នៅព្រៃធ្វើអ្វី យកដៃវាយក្បាល ធ្វើអាការឲ្យចៀសចេញទៅ ។ ការមិនមានកត្តិយស ក៏ផ្សាយទៅថា ភិក្ខុឯណោះចូលទៅព្រៃ ធ្វើកម្មអាក្រក់ ដូច្នេះ ។ តែការនៅព្រៃរបស់ភិក្ខុដែលមានបច្ច័យ ៤ ទាំងនោះ រមែងសម្រេច ។ ការពិត កាលណាលោកពិចារណាដល់សីលរបស់ខ្លួន មិនឃើញមានការ ពពាល ពព្រុះអ្វីៗ ក៏ធ្វើឲ្យកើតបីតិ ពិចារណាឃើញរបស់នោះ ដោយ ការអស់ទៅ រមែងឈានចុះកាន់អរិយភូមិ ។ ពួកទេវតាដែលអាស្រ័យនៅ ក្នុងព្រៃ សប្បាយចិត្ត ត្រេកអរ ក៏សរសើរ ។ កិត្តិយសរបស់ភិក្ខុនោះ រមែងផ្សាយចេញទៅ ដូចតំណក់ប្រេងល្ង ដែលដាក់ក្នុងទឹក ដោយប្រការ ដូច្នោះ ។ បណ្ដាបទទាំងនោះ បទថា **វិវិត្តំ** ប្រែថា សាបសូន្យ អធិប្បាយ ថា មិនមានសំឡេង គឺ គ្មានសំឡេង ។ ក៏លោកសំដៅយកពាក្យនេះឯង ទើបពោលទុកក្នុងវិភង្គថា បទថា **វិវិត្តំ** សេចក្ដីថា សូម្បីថា **សេនាសនៈមាន**

ក្នុងទីជិតសោត ហើយសេនាសនៈនោះ មិនពោរពេញទៅដោយគ្រហស្ថ និងបព្វជិត ព្រោះដូច្នោះ សេនាសនៈនោះ ឈ្មោះថា **វិវិត្ត** ។ ឈ្មោះថា សេនាសនៈ ព្រោះជាទីដេក ជាទីអង្គុយ ពាក្យនោះ ជាឈ្មោះរបស់គ្រែ និងតាំងជាដើម ។ ដោយហេតុនោះ លោកទើបពោលថា បទថា **សេនាសន** បានដល់ សេនាសនៈ គឺ ទីដេក ទីអង្គុយ ជើងម៉ា ពូក ខ្នើយ វិហារ រានហាល ប្រាសាទ ផ្ទះល្វែង ប៉ម សាលា កន្លែងពួន គុម្ពឫស្សី គល់ឈើ មណ្ឌប ជាទីដែលភិក្ខុត្រូវអាស្រ័យ ទាំងអស់នោះ ចាត់ជា សេនាសនៈ ។ ម្យ៉ាងទៀត វិហារ រានហាល ប្រាសាទ ផ្ទះល្វែង គុហារ ឈ្មោះថា វិហារសេនាសនៈ សេនាសនៈ គឺ កន្លែងនៅ ។ គ្រែ ជើងម៉ា ពូក ខ្នើយ នេះឈ្មោះថា **មញ្ចបីឋសេនាសន** កំផែង ស្បឹកចាក កំណាត់ស្បែក គ្រឿងក្រាលធ្វើដោយស្មៅ គ្រឿងក្រាលធ្វើដោយស្លឹកឈើ នេះឈ្មោះថា **សន្ថតសេនាសន** សេនាសនៈ គឺ សន្ថត ជាទីកន្លែងភិក្ខុអាស្រ័យ នេះ ឈ្មោះថា **ឱកាសសេនាសនៈ** សេនាសនៈ គឺ ទីទំនេរ រួមទាំង ៤ ដូច ពោលមកនេះ ចាត់ជាសេនាសនៈ ។ សេនាសនៈទាំងអស់នោះ លោករួម សេចក្ដីទុកដោយសព្ទថា សេនាសនៈដូចគ្នា ។ ព្រះដ៏មានព្រះភាគជាម្ចាស់ កាលណាទ្រង់សម្ដែងសេនាសនៈ ដែលសមគួរដល់ភិក្ខុ អ្នកចារិកទៅក្នុង

ទិសទាំង ៤ ដូចសត្វស្វាបនេះ ទើបទ្រង់ត្រាស់ពាក្យថា **អរញ្ញំ រុក្ខមូលំ** យ៉ាងនេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **អរញ្ញំ** បានដល់ កន្លែងទាំងអស់ ក្រៅពីសសរខឿនចេញ ឈ្មោះថា ព្រៃ ។ មានដំណាលមកដោយរឿងភិក្ខុទីពីរពួក ។ សេនាសនៈមិនល្អ ៥០០ កូនធ្នូជាទីបំផុត ឈ្មោះថា សេនាសនៈព្រៃ ក៏សេនាសនៈនេះ សមគួរដល់ភិក្ខុនេះ ។ លក្ខណៈរបស់សេនាសនៈនោះ បានពោលទុកហើយក្នុងធុតង្គនិទ្ទេសក្នុងវិសុទ្ធិមគ្គ ។ បទថា **រុក្ខមូលំ** បានដល់ គល់ឈើដែលស្ងាត់ មានម្លប់ត្រជាក់កន្លែងណាមួយ ។ បទថា **បព្វតំ** ប្រែថា ភ្នំថ្ម ។ ពិតណាស់ កាលភិក្ខុប្រើទឹកឯល្អាង ត្រង់ភ្នំសិលានោះ អង្គុយនៅក្រោមម្លប់នៃដើមឈើដែលត្រជាក់ ត្រូវខ្យល់បក់មកពីទិសផ្សេងៗ ដែលប្រាកដ ចិត្តក៏មានអារម្មណ៍តែមួយ ។ ទឹក លោកហៅថា **កំ** ក្នុងពាក្យថា **កន្ទរំ** កន្លែងដែលទឹកដក់ កន្លែងដែលទឹកច្រោះ បានដល់ ប្រទេសមានភ្នំ អាចារ្យពួកខ្លះហៅថា **នទីតុម្ព** ខ្លះ **នទីកុញ្ជ** ខ្លះ ។ ការពិត ក្នុងប្រទេសដែលមានភ្នំនោះ មានខ្សាច់ដូចបន្ទះប្រាក់ ទឹកដូចបណ្ដូលកែវមណី រមែងហូរឆ្លងកាត់ព្រៃក្រាស់ ដូចពិដានកែវមណីនៅអំពីខាងលើ ភិក្ខុចុះក្នុងជ្រោះរហាលបែបនេះ ផឹកទឹកស្រឡាបខ្លួនឲ្យត្រជាក់ លើកខ្សាច់ឡើង ក្រាលសំពត់ចីវរបង្សុកូល ធ្វើ

សមណធម៌ ចិត្តក៏មានអារម្មណ៍តែមួយ ។ បទថា **គិរិគុហំ** បានដល់ ប្រហោង ធំ ដូចទីឯខ្មុក្ក រវាងកូន ភ្នំ ២ ឬភ្នំតែមួយជាមួយគ្នា ។ លក្ខណៈព្រៃស្មសាន ពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **វនបត្ថំ** បានដល់ ឈ្មោះរបស់សេនាសនៈដែលដាច់ស្រយាល ។ បទថា **អព្ភោកាសំ** បានដល់ ទីមិនមានការប្រក់បាំង ។ តែភិក្ខុប្រាថ្នា ក៏បាំងឆ័ត្រនៅក្នុងទីនោះបាន ។ បទថា **បលាលបុញ្ជំ** បានដល់ គំនរចំបើង ពិតហើយ ពួកភិក្ខុទាញចំបើងអំពីគំនរចំបើងធំ ធ្វើទីលំនៅដូចញកភ្នំ និងទីពួន រាយចំបើងទុកខាងគុម្ពឈើជាដើម ហើយអង្គុយធ្វើសមណធម៌ខាងក្រោម លោកសំដៅយកគំនរចំបើងនោះ ទើបពោលពាក្យនុ៎ះ ។ បទថា **បច្ឆាភត្តំ** គឺ ខាងក្រោយភត្ត ។ បទថា **បិណ្ឌបាតបដិក្កន្តោ** ប្រែថា ត្រឡប់ពីបិណ្ឌបាត ។ បទថា **បល្លង្កំ** បានដល់ អង្គុយពែនភ្នែន បទថា **អាភុជិត្វា** ប្រែថា ជាប់គ្នា ។ បទថា **ឧជុំ កាយំ បណិធាយ** បានដល់ តាំងកាយខាងលើឲ្យត្រង់ យកចុងនិងចុងឆ្អឹងខ្នងជើង ១៨ កំណាត់ ឲ្យទល់គ្នា ។ ពិតហើយ ភិក្ខុអង្គុយយ៉ាងនេះ ស្បែក សាច់ សរសៃ មិនជំទាស់គ្នា កាលបើយ៉ាងនោះ វេទនាទាំងឡាយ ដែលគប្បីកើតគ្រប់ខណៈ ព្រោះការជំទាស់នៃស្បែក សាច់ សរសៃទាំងនោះជាបច្ច័យ ក៏មិនកើតដល់ភិក្ខុនោះ កាលណាវេទនាទាំង

នោះមិនកើតឡើង ចិត្តក៏មានអារម្មណ៍តែមួយ ។ កម្មដ្ឋាន ក៏មិនវិនាស ក៏ចូលដល់សេចក្តីចម្រើនលូតលាស់ល្អ ។ បទថា **បរិមុខំ សតិ ឧបដ្ឋបេត្វា** សេចក្តីថា តាំងសតិត្រង់ចំពោះព្រះកម្មដ្ឋាន ឬធ្វើទុកខាងក្នុង ។ ដោយហេតុនោះហើយ លោកទើបពោលទុកក្នុងវិភង្គថា សតិរមែងតាំងមាំដោយល្អ ត្រង់ចុងច្រមុះ ឬស្រមោលមុខ ដោយហេតុនោះ លោកទើបពោលទុកថា តាំងសតិទុកជុំវិញមុខ ។ ម្យ៉ាងទៀត សព្ទថា **បរិ** មានអត្ថថា កាន់យកដោយជុំវិញ សព្ទថា **មុខំ** មានអត្ថថា នាំចេញ សព្ទថា **សតិ** មានអត្ថថា ប្រាកដ ដោយហេតុនោះ លោកទើបពោលថា **បរិមុខំ សតី** គប្បីឃើញសេចក្តីក្នុងពាក្យនេះ ដោយន័យដែលពោលមកហើយក្នុងបដិ-សម្ភិទាមគ្គ ដោយប្រការដូច្នេះ ។ ក្នុងពាក្យនេះ មានសេចក្តីសង្ខេបយ៉ាងនេះថា **បរិគ្គហិតនិយ្យានំ សតី កត្វា** ធ្វើសតិជាគ្រឿងនាំចេញពីទុក្ខ ដែលកំណត់ទុកជាអារម្មណ៍ ។

ឧបាទានក្ខន្ធ ៥ ឈ្មោះថា **លោក** ក្នុងពាក្យថា **អភិជ្ឈំ លោកេ** នេះ ព្រោះអត្ថថា គ្រាំគ្រា ទ្រុឌទ្រោម ព្រោះដូច្នោះ ក្នុងពាក្យនេះ មានខ្លឹមសារយ៉ាងនេះថា លះរាគៈក្នុងឧបាទានក្ខន្ធ ៥ សង្កត់កាមច្ឆន្ទៈ ។ បទថា **វិគតាភិជ្ឈេន** សេចក្តីថា ឈ្មោះថា ប្រាសចាកអភិជ្ឈា ព្រោះលះបង់

ដោយវិក្ខម្ភនប្បហាន មិនមែនដូចចក្ខុវិញ្ញាណ ។ បទថា **អភិជ្ឈាយ ចិត្តំ បរិសោធេតិ** សេចក្តីថា រមែងដោះចិត្តចាកអភិជ្ឈា គឺ ធ្វើដោយប្រការដែលអភិជ្ឈានោះព្រលែង និងកាលព្រលែងហើយ ក៏មិនជាប់ចិត្តនោះទៀត ។ សូម្បីក្នុងពាក្យថា **ព្យាបាទបទោសម្បហាយ** យ៉ាងនេះជាដើម ក៏ន័យនេះដូចគ្នា ។ ឈ្មោះថា **ព្យាបាទ** ព្រោះជាគ្រឿងបៀតបៀន គឺ ចិត្តលះប្រក្រតីដើម ដូចនំកុម្មាសផ្អូមជាដើម ។ ឈ្មោះថា **បទោស** ព្រោះប្រទូសរ៉ាយដោយការឲ្យដល់ភាពពិការនៃចិត្ត ឬក៏ប្រទូសរ៉ាយអ្នកដទៃឲ្យវិនាស ។ ពាក្យទាំងពីរនេះ ជាឈ្មោះនៃសេចក្តីក្រោធដូចគ្នា ។ **ថីន** ជាជំងឺផ្លូវចិត្ត **មិទ្ធ** ជាជម្ងឺរបស់ចេតសិក ។ ទាំងថីនៈ ទាំងមិទ្ធៈ ឈ្មោះថា ថីនមិទ្ធៈ ។ បទថា **អាលោកសញ្ញី** បានដល់ អ្នកប្រកបដោយបញ្ញាដ៏បរិសុទ្ធ ប្រាសចាកនីវរណៈ ព្រោះអាចចាំពន្លឺដែលខ្លួនឃើញ ទាំងយប់ទាំងថ្ងៃបាន ។ បទថា **សតោ សម្បជានោ** បានដល់ ប្រកបដោយសតិ និងញាណ (បញ្ញា) ។ ទាំងពីរនេះ លោកពោលទុក ព្រោះជាធម៌ឧបការៈដល់អាលោកសញ្ញា ។ ទាំងឧទ្ធច្ចៈ និងកុក្កុច្ចៈ ឈ្មោះថា ឧទ្ធច្ចកុក្កុច្ចៈ ។ បទថា **តិណ្ណវិចិកិច្ឆោ** ប្រែថា ឆ្លងផុតសេចក្តីសង្ស័យបានហើយ ។ ឈ្មោះថា **អកថំកថី** អ្នកមិនមានសេចក្តីសង្ស័យជាហេតុ ពោលយ៉ាងណា ព្រោះមិនប្រព្រឹត្តទៅយ៉ាង

នេះថា នេះជាយ៉ាងណា ។ បទថា **កុសលេសុ ធម្មេសុ** បានដល់ ធម៌មិនមានទោស ។ អធិប្បាយថា មិនសង្ស័យ មិនងឿងឆ្ងល់យ៉ាងនេះថា ធម៌ទាំងនេះជាកុសល ឬធម៌ទាំងនេះ ចាត់ជាកុសល បានយ៉ាងណា ។ ក្នុងសេចក្តីនេះ មានសេចក្តីសង្ខេបយ៉ាងនេះ ។ តែកាលបើពោលដោយចែកតាមអត្ថ និងលក្ខណៈ នៃពាក្យជាដើមក្នុងនីវរណៈទាំងនេះ ពាក្យដែលគួរពោលទាំងអស់ ក៏ពោលទុកហើយ ។

(៧៣-៧៥) បទថា **បញ្ញាយ ទុព្វលីករណេ** សេចក្តីថា នីវរណៈទាំង ៥ នេះ កាលកើត រមែងធ្វើបញ្ញាមិនឲ្យកើត ទាំងដែលជាលោកិយ៍ និងលោកុត្តរៈដែលនៅមិនទាន់កើត សូម្បីដែលកើតហើយ ក៏ញ៉ាំងសមាបត្តិ ៨ អភិញ្ញា ៥ ឲ្យដាច់ធ្លាក់ចុះ ព្រោះដូច្នោះ លោកទើបពោលថា **បញ្ញាយ ទុព្វលីករណេ** ធ្វើបញ្ញាឲ្យខ្សោយកម្លាំង ។ បទថា **តថាគតបទំ ឥតិបិ** សេចក្តីថា ផ្លូវ គឺញាណ ស្នាមជើង គឺ ញាណ របស់ព្រះតថាគតសូម្បីនេះ លោកពោលថា ឋានៈ ដែលញាណជាន់ហើយ ។ បទថា **តថាគតនិសេវិតំ** បានដល់ ឋានៈ ដែលភ្លុកដំរី គឺ ញាណរបស់ ព្រះតថាគតកោសហើយ ។ បទថា **តថាគតារញ្ជិតំ** បានដល់ ឋានៈ ដែលព្រះចង្កូមកែវ គឺ ញាណរបស់ព្រះតថាគតប៉ះពាល់ហើយ ។

**(៧៦-៧៧)** *បទថា* ***យថាភូតំ បជានាតិ*** *បានដល់ រមែងដឹងតាមសភាវៈពិត ។ បទថា* ***នត្វេវ តាវ អរិយសាវកោ និដ្ឋំគតោ ហោតិ*** *សេចក្តីថា ញាណ និងអភិញ្ញាទាំងនេះរមែងមានទូទៅ សូម្បីមនុស្សខាងក្រៅព្រះសាសនា ព្រោះដូច្នោះ ព្រះអរិយសាវក ទើបមិនសម្រេចមុន ដែលឈ្មោះថា នៅមិនសម្រេចមុន ក៏ព្រោះនៅមិនទាន់សម្រេច សូម្បីក្នុងខណៈនៃមគ្គចិត្ត ។ បទថា* ***អបិ ច ខោ និដ្ឋំ គច្ឆតិ*** *សេចក្តីថា ម្យ៉ាងទៀត ក្នុងខណៈនៃមគ្គចិត្ត រមែងដល់សេចក្តីសម្រេចក្នុងរតនៈ ៣ ដោយអាការនេះថា ព្រះដ៏មានព្រះភាគជាម្ចាស់ ជាព្រះសម្មាសម្ពុទ្ធហ្ន៎ ដូចអ្នកទាក់ដំរី ឃើញដំរីធំដូច្នោះ ។ បទថា* ***និដ្ឋំ គតោ ហោតិ*** *សេចក្តីថា កាលដល់ការសម្រេចក្នុងខណៈនៃមគ្គចិត្តយ៉ាងនេះ រមែងបានសេចក្តីសម្រេចក្នុងរតនៈ ៣ ដោយអាការទាំងពួង ព្រោះមានកិច្ចទាំងអស់ស្រេចហើយ ក្នុងខណៈអរហត្តផលចិត្ត ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង មានសេចក្តីងាយទាំងអស់ ។*

(ចប់ អដ្ឋកថា ចុល្លហត្ថិបទោបមសូត្រ ទី ៧)

# អដ្ឋកថា

## មហាហត្ថិបទោបមសូត្រ ទី ៨

(៧៨) *មហាហត្ថិបទោបមសូត្រ ផ្តើមឡើងថា ខ្ញុំម្ចាស់បានស្តាប់មក ហើយយ៉ាងនេះ*

*គប្បីជ្រាបវិច្ឆ័យ ក្នុងមហាហត្ថិបទោបមសូត្រនោះ បទថា* ***ជង្គលានំ*** *ប្រែថា អ្នកសញ្ចរទៅលើដែលដី ។ បទថា* ***បាណានំ*** *បានដល់ សត្វមានជើង និងសត្វមិនមានជើង ។ បទថា* ***បទជាតានិ*** *ប្រែថា ស្នាមជើងទាំងឡាយ ។ បទថា* ***សមោធានំ គច្ឆន្តិ*** *បានដល់ ការប្រជុំចុះ គឺដាក់ចុះ ។ បទថា* ***អគ្គមក្ខាយតិ*** *ប្រែថា លោកពោលថាប្រសើរ ។ បទថា* ***យទិទំ មហន្តត្តេន*** *សេចក្តីថា លោកពោលថា វិសេស ព្រោះមានស្នាមជើងធំ អធិប្បាយថា មិនមែនធំដោយគុណ ។ បទថា* ***យេ កេចិ កុសលាធម្មា*** *បានដល់ កុសលធម៌ មិនមែនលោកិយៈ ឬលោកុត្តរៈពួកណាមួយ ។* ***សង្គហៈ*** *ក្នុងពាក្យថា* ***សង្គហំ គច្ឆន្តិ*** *នេះ មាន ៤ យ៉ាង គឺ សជាតិសង្គហៈ ១ សញ្ជាតិសង្គហៈ ១ កិរិយាសង្គហៈ ១ គណនសង្គហៈ ១ ។ បណ្តាសង្គហៈ ៤ យ៉ាងនោះ ការរួបរួមតាមជាតិរបស់ខ្លួនយ៉ាងនេះថា*

សូមក្សត្រទាំងពួងចូរមក សូមព្រាហ្មណ៍ ទាំងពួងចូរមក ដូច្នោះឈ្មោះថា **សញ្ជាតិសង្គហ** ។ ការរួបរួមតាម ប្រទេសនៃមនុស្សជាតិជាមួយគ្នា យ៉ាងនេះថា មនុស្សក្នុងដែនកោសលទាំងអស់ អ្នកដែនមគធៈទាំងអស់ ឈ្មោះថា **សញ្ជាតិសង្គហ** ។ ការរួបរួមដោយកិរិយា ដូចដែលថា ពលរថ្កទាំងអស់ ពលកាន់ធ្នូទាំងអស់ ឈ្មោះថា **កិរិយាសង្គហ** ។ ការរួបរួមយ៉ាងនេះថា ចក្ខាយតនៈ រួមចូលក្នុងខន្ធណា ចក្ខាយតនៈរួមចូលក្នុងរូបក្ខន្ធណា កាលត្រូវពោលដោយសេចក្តីនោះ ចក្ខាយតនៈ លោកក៏រួមចូលជាមួយរូបក្ខន្ធ ឈ្មោះថា **គណនសង្គហ** ។ សូម្បីក្នុងទីនេះ លោកសំដៅ **គណនសង្គហ** នេះឯង ។

សួរថា ក៏ក្នុងការឆ្លើយបញ្ហាថា បណ្តាអរិយសច្ចៈ ៤ ណាជាកុសល ណាជាអកុសល ណាជាអព្យាក្រិត ដូច្នេះ ព្រះមហាថេរៈ ចែកកុសលចិត្តសូម្បីដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ថា ជាសច្ចៈពាក់កណ្តាលប៉ុណ្ណោះ ព្រោះមានមកក្នុងព្រះបាលីថា **សមុទយសច្ចៈ** ចាត់ជាអកុសល **មគ្គសច្ច** ចាត់ជាកុសល **និរោធសច្ច** ចាត់ជាអព្យាក្រិត **ទុក្ខសច្ច** គ្រាខ្លះជាកុសល គ្រាខ្លះជាអកុសល គ្រាខ្លះជាអព្យាក្រិត មិនមែនឬ កាលបើដូច្នេះ ព្រោះហេតុអ្វីព្រះមហាថេរៈ ទើបពោលថា កុសលធម៌ទាំងនេះ ប្រជុំចុះក្នុងអរិយសច្ចៈ

៤ ។ ឆ្លើយថា ព្រោះកុសលធម៌ទាំងនោះ រួមនៅក្នុងសច្ចៈទាំងឡាយ ។ ពិតណាស់ សិក្ខាបទ ១៥០ សិក្ខាបទ ដែលឲ្យសម្រេចប្រយោជន៍ រមែងជាអធិសីលសិក្ខា ម្យ៉ាងទៀត ភិក្ខុសូម្បីសិក្សាអធិសីលសិក្ខានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងថា ឈ្មោះថា សិក្សា ៣ ដូចនៅក្នុងព្រះបាលីនេះថា

ម្នាលភិក្ខុទាំងឡាយ សិក្ខាបទ ១៥០ សិក្ខាបទ ដែលបាន
សម្រេចប្រយោជន៍នេះ រមែងសូត្រ រាល់កន្លះខែដែលពួក
កុលបុត្រអ្នកប្រាថ្នាប្រយោជន៍ គប្បីសិក្សា ។

ម្នាលភិក្ខុទាំងឡាយ សិក្ខា ៣ ទាំងនេះ គឺ អធិសីលសិក្ខា អធិ-ចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ព្រោះសិក្ខាបទ ១៥០ សិក្ខាបទនោះ រួមក្នុងសិក្ខាទាំងឡាយ ប្រៀបដូចស្នាមជើងរបស់សត្វទាំងឡាយ មានក្អែចចកទន្សាយ និងសត្វម្រឹគជាដើម រមែងប្រជុំចុះក្នុងចំណែក ១ ក្ដី រមែងប្រជុំចុះក្នុងចំណែក ២-៣-៤ ក្ដី ឈ្មោះថា ក្នុង ៤ ចំណែក នៃស្នាមជើងដំរីមួយ រមែងរួមប្រជុំចុះក្នុងស្នាមជើងដំរីទាំងនោះ មិនផុតពីស្នាមជើងដំរី ព្រោះរួមចុះក្នុងស្នាមជើងដំរីនោះប៉ុណ្ណោះ យ៉ាងណា ធម៌ទាំងឡាយ ដែលរាប់ចុះក្នុងសច្ចៈ ១ ក្ដី ២ ក្ដី ៣ ក្ដី ៤ ក្ដី ក៏ដូច្នោះ ដូចគ្នា រមែងរាប់បញ្ចូលក្នុង

សច្ចៈ ៤ ទាំងអស់ ព្រោះធម៌ទាំងឡាយ រួមនៅក្នុងសច្ចៈទាំងឡាយ ព្រោះហេតុនោះ លោកទើបពោលដល់កុសលធម៌ សូម្បីដែលរួមចូលក្នុងសច្ចៈពាក់កណ្ដាលថា ធម៌ទាំងអស់នោះ រមែងប្រជុំចុះក្នុងអរិយសច្ចៈ ៤ ។ ពាក្យដែលគួរពោលក្នុងបទឧទ្ទេសថា **ទុក្ខំ អរិយសច្ចំ** ជាដើម និងក្នុងបទនិទ្ទេសថា **ជាតិបិ ទុក្ខា** ជាដើម ទាំងអស់បានពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។ តែក្នុងទីនេះ គប្បីជ្រាបចំពោះលំដាប់ទេសនាតែម្យ៉ាង ។

(៧៩) ដូចសេចក្ដីថា ជាងត្បាញផែង អ្នកឆ្លាតបានឫស្សីដ៏ល្អមួយដើម កាត់ជា ៤ កំណាត់ , ៤ កំណាត់នោះ វៀរ ៣ កំណាត់ យកតែមួយកំណាត់ ហើយពុះជា ៥ បន្ទះ , យក ៥ បន្ទះនោះ វៀរទុក ៤ បន្ទះ យកតែមួយបន្ទះ ហើយពុះជា ៥ ចំរៀក , យក ៥ ចំរៀកនោះ វៀរទុក ៤ ចំរៀក យកតែមួយចំរៀក ពុះជា ២ គឺ ចំណែកពោះ ចំណែកខ្នង , វៀរចំណែកខ្នងទុក កាន់យកតែចំណែកពោះ ។ តមកក៏ធ្វើឲ្យជាគ្រឿងត្បាញច្រើនប្រភេទ មានហិប ផ្ដិតវិជ្ជនី និងផ្ដិតស្លឹកត្នោតជាដើម ជាងត្បាញនោះ មិនមានអ្នកណាពោលថា មិនប្រើការ ចំណែកខ្នង ៤ បន្ទះទៀត ៤ ចំណែកទៀត និង ៣ ចំណែកទៀត តែគេមិនអាចប្រើការក្នុងគ្រាជាមួយគ្នាបាន តែនឹងប្រើការតាមលំដាប់ យ៉ាងណា ចំណែកព្រះមហាថេរៈ នេះ

ក៏ដូច្នោះដូចគ្នា ផ្តើមសុត្តន្តៈធំហើយ តាំងមាតិកាដោយអរិយសច្ចៈ ៤ ដូចជាងត្បាញផែង បានឫស្សីដែលល្អហើយ បែងជា ៤ ចំណែកដូច្នោះ ។ ព្រះថេរៈ វៀរតែអរិយសច្ចៈ ៣ ហើយ កាន់យកទុក្ខអរិយសច្ចៈតែម្យ៉ាង ចែកជាខន្ធ ៥ ដូចជាងត្បាញឫស្សី វៀរ ៣ ចំណែក យកចំណែកមួយ ហើយធ្វើចំណែកមួយនោះ ឲ្យជា ៥ ចំណែក ។ បន្ទាប់មក ព្រះថេរៈ វៀរអរូបក្ខន្ធ ៤ ហើយចែករូបក្ខន្ធ និងធ្វើមហាភូតរូប ៤ ឲ្យជា ៥ ចំណែក គឺ មហាភូតរូប ៤ និងឧបាទាយរូប ១ ប្រៀបដូចជាងតម្បាញនោះ វៀរ ៤ ចំណែកកាន់យក ១ ចំណែក ហើយច្រៀកជា ៥ ចំរៀក ដូច្នោះ ។

(៨០) បន្ទាប់ពីនោះមក ព្រះថេរៈវៀរឧបាទាយរូប និងធាតុ ៣ ហើយចែកបឋវីធាតុតែម្យ៉ាង សម្តែងជា ២ ចំណែក គឺ អជ្ឈត្តិករូប រូបខាងក្នុង , ពាហិររូប រូបខាងក្រៅ ប្រៀបដូចជាងតម្បាញនោះ វៀរ ៤ ចំណែកកាន់យកមួយចំណែក ហើយច្រៀកជា ២ ចំណែក គឺ ចំណែកពោះ ១ ចំណែកខ្នង ១ ។ ដើម្បីនឹងវៀរបឋវីធាតុខាងក្រៅ ហើយសម្តែងចែកបឋវីធាតុខាងក្នុង ដោយអាការ ២០ ព្រះថេរៈ ទើបពោលពាក្យជាដើមថា **កតមា ចាវុសោ អជ្ឈត្តិកា បឋវីធាតុ** ប្រៀបដូចជាងតម្បាញ វៀរចំណែកខ្នង កាន់យកចំណែកពោះ ទើបធ្វើជាគ្រឿងត្បាញប្រភេទផ្សេងៗ

ដូច្នោះ ។ មយ៉ាងទៀត ប្រៀបដូចជាងតម្បាញ ប្រើការឫស្សីចំណែកខ្នង ៤ ចំរៀកទៀត ៤ ចំណែកទៀត និង ៣ ចំណែកទៀត ដោយលំដាប់ តែមិនអាចប្រើការក្នុងគ្រាជាមួយគ្នាបាន ដោយប្រការដូច្នេះ យ៉ាងណា សូម្បីព្រះថេរៈក៏ដូច្នោះ ចែកបឋវីធាតុខាងក្រៅ និងធាតុ ៤ ទៀត ឧបាទាយរូប អរូបក្ខន្ធ ៤ អរិយសច្ចៈ ៣ ហើយសម្តែងតាមលំដាប់ តែមិនអាចសម្តែងដោយគ្រាជាមួយគ្នាបាន ។

មយ៉ាងទៀត គប្បីបរិយាយលំដាប់សូម្បីនេះ ដោយសេចក្តីឧបមាដោយរាជបុត្រ ឲ្យជាក់ស្តែងដូចតទៅនេះ ។ បានឮមកថា ព្រះរាជាមួយអង្គ មានព្រះរាជឱរស ច្រើនជាង ១.០០០ អង្គ ។ ព្រះអង្គទ្រង់ទុកគ្រឿងតុបតែងរបស់ព្រះឱរសទាំងនោះទុកក្នុងហិបធំ ៤ ទ្រង់ប្រគល់ឲ្យដល់ជេដ្ឋឱរស ដោយត្រាស់បង្គាប់ថា កូនអើយ គ្រឿងប្រដាប់តុបតែងនេះជារបស់ពួកប្អូនរបស់ឯង កាលណាមានមហោស្រព ឯងត្រូវឲ្យគ្រឿងប្រដាប់តុបតែងនេះ ព្រោះដូច្នោះ កាលណាប្អូន ៗ សូម ទើបចាំឲ្យ ។ ជេដ្ឋរាជឱរសនោះទទួលថា ព្រះករុណាម្ចាស់ ទើបទុកក្នុងបន្ទប់ទុក ព្រះរាជសម្បត្តិ ។ ក្នុងថ្ងៃមហោស្រព ពួកព្រះរាជឱរសនោះ នាំគ្នាទៅគាល់ព្រះរាជា ក្រាបទូលថា បពិត្រព្រះបិតា សូមមេត្តាប្រោសព្រះរាជទានគ្រឿងប្រដាប់តុប

តែងដល់ពួកខ្ញុំព្រះអង្គ ពួកខ្ញុំព្រះអង្គនឹងទៅលេងនក្ខត្តឫក្ស ។ ព្រះរាជាត្រាស់ថា កូនអើយ ឪពុកបានប្រគល់គ្រឿងប្រដាប់តុបតែងនៅដៃបងប្រុសរបស់ពួកកូនហើយ ពួកឯងចូរយកគ្រឿងប្រដាប់តុបតែងនោះ ទៅប្រដាប់ចុះ ។ ព្រះរាជឱរសទាំងនោះ ទទួលព្រះតម្រាស់ហើយ នាំគ្នាទៅរកព្រះជេដ្ឋឱរសនោះ ហើយចូលទៅសូមគ្រឿងប្រដាប់តុបតែងពីជេដ្ឋឱរស ។ ជេដ្ឋឱរសបានចូលទៅក្នុងបន្ទប់រក្សា ហើយយកហិបធំ ៤ ចេញ វៀរហិប ៣ ទុក បើកហិប ១ នាំ ហិបតូច ៥ ចេញពីហិបធំនោះ វៀរទុកហិប ៤ បើកតែហិប ១ កាលនាំប្រអប់ ៥ ចេញអំពីហិបតូច វៀរប្រអប់ ៤ ទុក បើកតែប្រអប់ ១ ដាក់ទុកម្ខាង ពេលនោះ ទើបនាំគ្រឿងប្រដាប់ដៃជើងផ្សេងៗ ប្រគល់ឲ្យ ។ ជេដ្ឋឱរស មិនបានបែងចែកពីប្រអប់ ៤ ហិបតូច ៤ ហិបធំ ៤ មុន បើដូច្នេះ ក៏ឲ្យតាមលំដាប់ ព្រោះដូច្នោះ ទើបមិនអាចប្រគល់ឲ្យក្នុងគ្រាជាមួយគ្នាបាន ។

ក្នុងសេចក្តីឧបមានោះ គប្បីឃើញព្រះដ៏មានព្រះភាគជាម្ចាស់ ដូចជាមហារាជ ។ សមពិតដូចពាក្យដែលលោកពោលទុកថា ព្រះដ៏មាន-ព្រះភាគជាម្ចាស់ ជាធម្មរាជាដ៏កំពូល ត្រាស់ថា ម្នាលសេលព្រាហ្មណ៍តថាគតក៏ជាព្រះរាជា ។ គប្បីឃើញព្រះសារីបុត្ត ដូចជេដ្ឋឱរស ។ ដូច

តម្រាស់ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលនឹងហៅដោយប្រពៃ គប្បីហៅភិក្ខុអង្គនោះ (សារីបុត្ត) ថា បុត្តឱរសកើតពីព្រះឱស្ឋ កើតពីធម៌ ដែលជាធម្មនិមិត្ត ជាធម្មទាយាទ តែមិនមែនជាអាមិសទាយាទ របស់ព្រះដ៏មានព្រះភាគជាម្ចាស់ បុគ្គលកាលណាហៅដោយប្រពៃ គប្បីហៅភិក្ខុនោះឯងថា ជាបុត្ត ។ល។ មិនមែនជាអាមិសទាយាទ របស់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ គប្បីឃើញភិក្ខុសង្ឃដូចរាជឱរសច្រើនជាង ១.០០០ អង្គ ។ ដូចតម្រាស់ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ទុកហើយថា

ភិក្ខុច្រើនជាង ១.០០០អង្គ ចូលទៅគាល់ព្រះសុគតអ្នក
សម្ដែងធម៌ប្រាសចាកធូលី ជាអ្នកមិនមានតណ្ហាឈ្មោះ
ថា ហានៈ ជាអ្នកមិនភ័យមកពីទីណាៗ ។

វេលាដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ប្រកាសសច្ចៈ ៤ ទុកក្នុងដៃរបស់ព្រះធម្មសេនាបតី ប្រៀបដូចវេលាដែលព្រះរាជាទ្រង់ទុកគ្រឿងប្រដាប់តុបតែងរបស់ព្រះរាជឱរសទាំងនោះ ទុកក្នុងហិបធំ ៤ ហើយទុកដាក់ក្នុងដៃរបស់ជេដ្ឋឱរស ដូច្នោះ ។ ដោយហេតុនោះឯង ព្រះដ៏មាន-ព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់ថា ភិក្ខុទាំងឡាយ សារីបុត្តសមគួរប្រាប់

បញ្ញត្តិ តែងតាំង បើកបង្ហាញ ចែក ធ្វើឲ្យរាក់ នូវអរិយសច្ចៈ ៤ ដោយពិស្ដារ ។ វេលាដែលភិក្ខុសង្ឃមក ក្នុងសម័យជិតចូលវស្សា ទើបអារាធនាឲ្យសម្ដែងធម៌ ប្រៀបដូចវេលាដែលព្រះឱរសទាំងឡាយ ចូលទៅគាល់ព្រះរាជា ទូលសូមគ្រឿងប្រដាប់តុបតែងក្នុងថ្ងៃមហោស្រព ដូច្នោះ ។ បានឮថា ក្នុងថ្ងៃជិតចូលវស្សា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងព្រះសូត្រ ។ វេលាដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បញ្ជូនភិក្ខុទាំងឡាយទៅកាន់សំណាក់របស់ព្រះធម្មសេនាបតី ដោយតម្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរសេព ចូរគប់សារីបុត្ត និងមោគ្គល្លានចុះ ម្នាលភិក្ខុទាំងឡាយ សារីបុត្ត និងមោគ្គល្លានជាបណ្ឌិត អនុគ្រោះមិត្រសព្រហ្មចារី ប្រៀបដូចពេលដែលព្រះរាជាត្រាស់ថា កូនអើយ ឱពុកបានប្រគល់គ្រឿងប្រដាប់តុបតែងទុកក្នុងដៃបងប្រុសរបស់ពួកឯងហើយ ចូរនាំយកមកប្រដាប់ចុះ ។ វេលាដែលភិក្ខុទាំងឡាយ ស្ដាប់ពាក្យតម្រាស់របស់ព្រះសាស្ដាហើយ ចូលទៅរកព្រះធម្មសេនាបតី ហើយអារាធនាឲ្យសម្ដែងធម៌ ប្រៀបដូចវេលា ដែលពួកព្រះរាជឱរស ស្ដាប់ព្រះតម្រាស់របស់ព្រះរាជាហើយ ចូលទៅកាន់សំណាក់របស់ជេដ្ឋឱរស ហើយសុំគ្រឿងតុបតែង ដូច្នោះ ។ វេលាដែលព្រះធម្មសេនាបតី ផ្ដើមព្រះសុត្តន្តនេះ ហើយសម្ដែងមាតិកា ដោយ

អរិយសច្ចៈ ៤ ប្រៀបដូច វេលាដែលព្រះជេដ្ឋឱរស បើកបន្ទប់យកហិប ៤ ដាក់ទុក ដូច្នោះ ។ ការវៀរអរិយសច្ចៈ ៣ ហើយចែកទុក្ខអរិយសច្ចៈ សម្តែងបញ្ចក្ខន្ធ ប្រៀបដូចការវៀរហិប ៣ បើកហិប ១ យកហិបតូច ៥ ចេញពីហិប ១ នោះ ដូច្នោះ ។ ការដែលព្រះថេរៈវៀរអរូបក្ខន្ធ ៤ ហើយសម្តែងចែករូបក្ខន្ធ ១ , សម្តែង ៥ ចំណែក ដោយមហាភូតរូប ៤ និងឧបាទាយរូប ១ ប្រៀបដូចវៀរហិបតូច ៤ បើកហិប ១ ហើយនាំប្រអប់ ៥ ពីហិបតូច ១ នោះ ដូច្នោះ ។ កាលដែលព្រះថេរៈ វៀរមហាភូតរូប ៣ និងឧបាទាយរូប ហើយចែកបឋវីធាតុតែម្យ៉ាង វៀរបឋវីធាតុខាងក្រៅចេញ ដូចបិទទុក ដើម្បីនឹងសម្តែងបឋវីធាតុខាងក្នុង ដែលមានអាការ ២០ ដោយសភាវៈផ្សេងៗ ទើបពោលពាក្យមានជាអាទិ៍ថា **កតមា ចាវុសោ អជ្ឈត្តិកា បឋវីធាតុ** ។ ប្រៀបដូចវៀរហិប ៤ បើកហិប ១ វៀរហិបដែលបិទទុកម្ខាង ហើយឲ្យគ្រឿងប្រដាប់តុបតែងដៃ និងគ្រឿងប្រដាប់ជើងជាដើម ។ គប្បីជ្រាបថា សូម្បីព្រះថេរៈចែកមហាភូតរូប ៣ ឧបាទាយរូប អរូបក្ខន្ធ ៤ អរិយសច្ចៈ ៣ ហើយសម្តែងតាមលំដាប់ក្នុងខាងក្រោយ ដូចរាជឱរសនោះនាំយកប្រអប់ ៤ ហិបតូច ៤ និងហិប ៣ ទាំងនោះ ហើយប្រទានគ្រឿងប្រដាប់តុបតែងតាមលំដាប់ក្នុងខាងក្រោយ ។

ក៏ពាក្យនោះ លោកពោលទុកថា **កតមា ចាវុសោ អជ្ឈត្តិកា បឋវីធាតុ** ជាដើម គប្បីជ្រាបក្នុងពាក្យនោះ សូម្បីបទទាំងពីរថា **អជ្ឈត្តំ បច្ចត្តំ** នេះ ជាឈ្មោះរបស់ធម្មជាតិ ដែលមាននៅក្នុងខ្លួន ។ បទថា **កក្ខលំ** ប្រែថា រឹង ។ បទថា **ខរិគតំ** ប្រែថា គ្រោតគ្រាត ។ បទថា **ឧបាទិន្នំ** បានដល់ មិនមែនមានតែកម្ម ជាសមុដ្ឋានប៉ុណ្ណោះទេ ។ តែកាលពោលដោយមិនប្លែកគ្នា ពាក្យថា **ឧបាទិន្នំ** នេះ ជាឈ្មោះរបស់រូបដែលតាំងនៅក្នុងសរីរៈ ។ ពិតហើយ រូបដែលតាំងនៅក្នុងសរីរៈ មិនថាជាឧបា-ទិន្នរូប ឬអនុបាទិន្នរូប ឈ្មោះថា ជាឧបាទិន្នរូបទាំងអស់ ដោយការចាប់កាន់ ពាល់ត្រូវ ស្ទាបអង្អែលបាន គឺ សក់ រោម ។ល។ អាហារថ្មី អាហារចាស់ ។ ពាក្យនេះ លោកកំណត់ចែកទុក ដោយជាបឋវីធាតុ ដែលជាខាងក្នុងសម្រាប់កុលបុត្រអ្នកបំពេញធាតុកម្មដ្ឋាន ។ តែក្នុងទីនេះ ពាក្យដែលអ្នកប្រាថ្នានឹងផ្តើមមនសិការ ចម្រើនវិបស្សនា តោងយកព្រះអរហត្តគួរធ្វើទាំងអស់ បានពោលទុកពិស្តារហើយក្នុងវិសុទ្ធិមគ្គនោះឯង ។ តែពាក្យថា ខួរក្បាល មិនបានឡើងកាន់ព្រះបាលីក្នុងទីនេះ ។ តែខួរក្បាលសូម្បីនោះ នាំមកកំណត់ដោយវណ្ណៈ និងសណ្ឋានជាដើម ដោយន័យដែលពោលហើយក្នុងវិសុទ្ធិមគ្គ ទើបមនសិការថា សូម្បីធាតុនេះ ក៏មិន

មានចេតនា អព្យាក្រិត សូន្យទទេ ជារបស់រឹង ចាត់ជាបឋវីធាតុ ។ ដូចគ្នា ។ បទថា **យំ វា បនញ្ញម្បិ** នេះ លោកពោលដើម្បីកំណត់យកបឋវីធាតុដែលនៅក្នុងចំណែក ៣ ក្រៅអំពីនេះ ។ បទថា **យា ចេវ ខោ បន អជ្ឈត្តិកា បឋវីធាតុ** សេចក្តីថា បឋវីធាតុ មានប្រការតាមដែលពោលហើយនេះ ចាត់ជាបឋវីធាតុខាងក្នុង បទថា **យា ច ពាហិរា** សេចក្តីថា បឋវីធាតុ ដែលមកហើយក្នុងវិភង្គដោយន័យថា ដែក លោហៈ សំណជាដើម ចាត់ជាបឋវីធាតុខាងក្រៅ ។

ដោយលំដាប់ពាក្យត្រឹមប៉ុណ្ណេះ ព្រះថេរៈសម្តែងបឋវីធាតុ ដែលជាខាងក្នុង ដោយអាការ ២០ ដោយសភាវៈផ្សេងៗ យ៉ាងពិស្តារ សម្តែងធាតុខាងក្រៅទុកដោយសង្ខេប ។ ព្រោះហេតុអ្វី ។ ព្រោះក្នុងទីណាសត្វមានសេចក្តីអាល័យ ប្រាថ្នា វិកវរ ចោមរោម ប្រកាន់ខ្ជាប់ ប្រកាន់មាំខ្លាំងក្លាក្នុងទីនោះ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ឬពួកព្រះសាវក និងពោលរឿងយ៉ាងពិស្តារ ដើម្បីដកអាល័យជាដើម របស់សត្វទាំងនោះ ។ មួយទៀត ក្នុងទីណាសេចក្តីអាល័យជាដើម របស់ពួកសត្វមិនមានកម្លាំង ក្នុងទីនោះ លោកនឹងពោលដោយសង្ខេប ព្រោះមិនមានកិច្ចដែលនឹងត្រូវធ្វើ ។ ដូចសេចក្តីថា អ្នកស្រែ កាលណាភ្ជួរស្រែ ក៏បញ្ឈប់គោទុកក្នុងទីដែលភ្ជួរ

ជាប់ ព្រោះឫសឈើ និងគល់ឈើក្រាស់ណែនណាន់តាន់តាប់ កកាយដី ឡើង កាត់ឫសឈើ និងគល់ឈើ លើកឡើង ត្រូវធ្វើសេចក្តីព្យាយាម ខ្លាំង ក្នុងទីណាមិនមានឫសឈើ និងដង្គត់ ក៏មិនត្រូវព្យាយាមក្នុងទីនោះ វាយគោភ្ជួរទៅយ៉ាងណា ពាក្យឧបមេយ្យនេះ ក៏គប្បីជ្រាបដូច្នោះ ។

បទថា **បឋវីធាតុរេវេសា** សេចក្តីថា ក៏ធាតុទាំង ២ យ៉ាងនេះ មានលក្ខណៈដូចគ្នា ដោយអត្ថថា រឹង និងគ្រោតគ្រាត សូម្បីនេះ ក៏ចាត់ ជាបឋវីធាតុ លោកសម្តែងប្រកបទុកខាងក្នុង និងខាងក្រៅ ។ ក៏ព្រោះ ហេតុដែលបឋវីធាតុខាងក្រៅប្រាកដថា មិនមានចេតនា បឋវីធាតុខាងក្នុង មិនប្រាកដដូច្នោះទេ ព្រោះដូច្នោះ ព្រះយោគាវចរកំណត់ថា បឋវីធាតុខាង ក្នុងនោះ ដូចគ្នានឹងបឋចីធាតុខាងក្រៅ ព្រោះមិនមានចតេនាដូចគ្នា ទើប កំណត់បានស្រួល ។ ប្រៀបដូចអ្វី ។ ប្រៀបដូចគោ ដែលមិនបានហ្វឹក ហាត់ហើយទឹម និងគោដែលហ្វឹកហាត់ហើយ រមែងប្រវេប្រវារើបម្រះ ២-៣ ថ្ងៃប៉ុណ្ណោះ កាលបើដូច្នោះ មិនយូរប៉ុន្មាន ក៏ហ្វឹកហាត់បាន យ៉ាង ណា ព្រះយោគាវចរកំណត់ថា សូម្បីបឋវីធាតុខាងក្នុង ក៏ដូចគ្នានឹងបឋវី- ធាតុខាងក្រៅ បឋវីធាតុ ក៏នឹងប្រាកដមិនមានចេតនាបាន ក្នុង ២-៣ ថ្ងៃ ប៉ុណ្ណោះ កាលបើដូច្នោះមិនយូរ ទើបបឋវីធាតុខាងក្នុងនោះ ក៏ប្រាជកថា

មិនមានចេតនា ដូច្នោះ ។ បទថា **តំ នេតំ មម** សេចក្តីថា ធាតុទាំងពីរ បណ្ឌិតគប្បីឃើញដោយបញ្ញាដ៏ប្រពៃតាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់យើង នុ៎ះមិនមានជាយើង នុ៎ះមិនមែនតួខ្លួនយើង ។ បទថា **យថាភូតំ** ប្រែថា តាមសភាពពិត ។ អធិប្បាយថា ប្រាកដច្បាស់ធាតុទាំង ២ នោះ មានសភាវៈមិនទៀងជាដើម ព្រោះដូច្នោះ គប្បីឃើញយ៉ាងនេះថា **អនិច្ចំ ទុក្ខំ អនត្តា** ។ បទថា **ហោតិ ខោ សោ អាវុសោ** សេចក្តីថា ព្រោះហេតុអ្វី លោកទើបប្រារព្ធទុក ។ ព្រោះដើម្បីនឹងសម្តែងសេចក្តីវិនាសនៃបឋវីធាតុខាងក្រៅ ដោយអំណាចអាបោធាតុខាងក្រៅ ហើយសម្តែងសេចក្តីវិនាសនៃបឋវីធាតុ ដែលតាំងនៅក្នុងរាងកាយ ដែលជាឧបាទិន្នរូបពិសេសជាងនោះ ។ បទថា **បកុប្បតិ** សេចក្តីថា កម្រើកបានដោយសេចក្តីវិនាស ព្រោះទឹក ។ បទថា **អន្តរហិតា តស្មឹ សមយេ ពាហិរា បឋវីធាតុ ហោតិ** សេចក្តីថា សម័យនោះ បឋវីធាតុរលាយដោយទឹកក្នុងសែនកោដិចក្រវាឡ ហូរតាមទឹកទៅ តាំងតែពីភ្នំជាដើម ទាំងអស់ក៏អន្តរធានទៅ រលាយទៅជាទឹកតែម្យ៉ាង។ បទថា **តាវ មហល្លិកាយ** ប្រែថា ធំត្រឹមនោះ ។ ដែលឈ្មោះថា ធំ ព្រោះមានកម្រាស់យ៉ាងនេះ គឺ ៖

**ទ្វេ សតសហស្សានិ ចត្តារិ នហុតានិ**

*ច ឯត្តកំ លក្ខេន សង្ខាតាយំ វសុន្ធរា ។*

*ផែនដីធំនេះ ពោលដោយចំណែកក្រាស់ប្រមាណ*

*ពីរសែនបួនម៉ឺនយោជន៍ ។*

*តែកាលបើពោលដោយចំណែកទទឹង មានប្រមាណមួយសែនកោ-ដិចក្រវាឡ ដោយប្រការដូច្នេះ ។ បទថា **អនិច្ចតា** ប្រែថា មានហើយក៏ត្រឡប់ជាមិនមានវិញ ។ បទថា **ខយធម្មតា** ប្រែថា មានការអស់ទៅជាសភាវៈ ។ បទថា **វយធម្មតា** ប្រែថា មានការសូន្យទៅ ជាសភាវៈ ។ បទថា **វិបរិណាមធម្មតា** ប្រែថា មានការលះប្រក្រតីជាសភាវៈ ។ លោកពោលដល់អនិច្ចលក្ខណៈតែម្យ៉ាង ទុកគ្រប់បទ ដោយប្រការដូច្នេះ ។ ក៏លក្ខណៈទាំង ៣ រមែងមានក្នុងព្រះបាលីថា របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខ របស់នោះជាអនត្តា ។ បទថា **មត្តដ្ឋកស្ស** ប្រែថា តាំងនៅមួយរយៈកាលបន្តិចបន្តួច ។ ក្នុងបទនោះ គប្បីជ្រាបថា កាយនេះ ស្ថិតនៅមួយរយៈកាលតិចតួច ដោយអាការ ២ គឺ តាំងនៅបន្តិចបន្តួច និងមានកិច្ចបន្តិចបន្តួច ។ ព្រោះកាយនេះ លោកពោលថា ក្នុងខណៈចិត្តជាអតីត បានរស់នៅហើយ មិនមែនកំពុងរស់នៅ មិនមែននឹងរស់នៅ , ក្នុងខណៈចិត្តដែលជាអនាគត នឹងរស់នៅ មិនមែនកំពុងរស់*

នៅ មិនមែនរស់នៅហើយ , ក្នុងខណៈចិត្តដែលជាបច្ចុប្បន្ន កំពុងរស់នៅ មិនមែន រស់នៅហើយ មិនមែននឹងរស់នៅ ដើម្បីសម្តែងថា កាយនេះឯង តាំងនៅបន្តិចបន្តួច លោកទើបពោលពាក្យនេះថា ៖

ជីវិតំ អត្តភាវោ ច សុខទុក្ខា ច កេវលា
ឯកចិត្តសមាយុត្តា លហុសោ វត្តតេ ខណោ ។
ជីវិត អត្តភាព និងសុខទុក្ខទាំងមូល សុទ្ធតែប្រកប
ដោយចិត្តមួយខណៈ រមែងប្រព្រឹត្តទៅឆាប់រហ័ស ។

គប្បីជ្រាបថា កាយនេះ តាំងនៅមួយរយៈកាលតិចតួច ព្រោះតាំងនៅមួយរយៈកាលយ៉ាងនេះ ។ មួយទៀត គប្បីជ្រាបថា កាយនោះ មានកិច្ចបន្តិចបន្តួច ព្រោះជាប់ដោយខ្យល់អស្សាសបស្សាសៈ ជាដើម ។ ពិតហើយ សត្វទាំងឡាយ មានជីវិត ជាប់ទាក់ទងដោយខ្យល់អស្សាសៈ ជាប់ទាក់ទងដោយខ្យល់បស្សាសៈ ខ្យល់អស្សាសៈ ជាប់ទាក់ទងទាំងខ្យល់អស្សាសៈ ទាំងបស្សាសៈ ជាប់ដោយមហាភូតរូប ជាប់ដោយកវឡិង្ការាហារ ជាប់ដោយវិញ្ញាណ ទាំងនេះពោលទុកពិស្តារហើយក្នុងវិសុទ្ធមគ្គ ។

បទថា ឯតំ តណ្ហុបាទិន្នស្ស ប្រែថា ត្រូវតណ្ហាចាប់យក ស្ទាប អង្អែល ។ បទថា អហន្តិ វា មមន្តិ វា អស្មីតិ វា អថខ្វស្ស នោតេវេត្ថ

**ហោតិ** សេចក្ដីថា គ្រានោះឯងភិក្ខុនោះ លើកឡើងកាន់ត្រៃលក្ខណ៍ពិចារណាយ៉ាងនេះ រមែងមិនមានគាហៈ គឺ តណ្ហា មានៈ និងទិដ្ឋិ ៣ យ៉ាង ក្នុងបឋវីធាតុខាងក្នុងនេះថា នេះជាយើងជាដើម អធិប្បាយថា មិនមានឡើយ ។ បឋវីធាតុខាងក្រៅ រមែងអន្តរធានទៅដោយអំណាចតេ-ជោធាតុ វាយោធាតុ ។ ដូចអន្តរធានទៅដោយអំណាចអាបោធាតុ ដូច្នោះ ។ តែក្នុងទីនេះ មកតែម្យ៉ាងប៉ុណ្ណោះ ។ សូម្បីក្រៅពីនេះក៏គប្បីជ្រាបដោយន័យដូចគ្នា ។ ក្នុងពាក្យថា **តញ្ចេ អាវុសោ** នេះ ព្រះថេរៈ កាលផ្ដើមធ្វើការកំណត់អារម្មណ៍ក្នុងសោតទ្វារ របស់ភិក្ខុដែលបំពេញធាតុកម្មដ្ឋាននោះ ទើបសម្ដែងកម្លាំង ។ បទថា **អក្កោសន្តិ** បានដល់ ជេរដោយអក្កោសវត្ថុ ១០ ។ បទថា **បរិភាសន្តិ** បានដល់ គំរាមដោយវាចាថាលោកធ្វើដូច្នេះៗ យើងនឹងដាក់ទោសលោកយ៉ាងនេះៗ ។ បទថា **រោសេន្តិ** ប្រែថា រមែងពោលតិះដៀល ។ បទថា **វិហេសេន្តិ** ប្រែថា រមែងធ្វើឲ្យលំបាក ។ លោកពោលចំពោះការតិះដៀលដោយវាចា ទុកទាំងអស់ ។ បទថា **សោ ឯវំ** សេចក្ដីថា ភិក្ខុបំពេញធាតុកម្មដ្ឋាននោះ រមែងដឹងយ៉ាងនេះ ។ បទថា **ឧប្បន្នា ខោ មេ អយំ** សេចក្ដីថា កើតឡើងព្រោះធាតុ ៤ ដែលកើតប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងកើតឡើង ព្រោះសេចក្ដី

កម្រើកបន្តគ្នា ។ បទថា **សោតសម្ផស្សជា** សេចក្តីថា វេទនាដែលស្ទុះទៅតាមផ្លូវសោតទ្វារ កើតពីសោតសម្ផស្ស ដោយអំណាចឧបនិស្ស័យ ។ ដោយបទថា **ផស្សោ អនិច្ចោ** លោកសម្តែងថា សោតសម្ផស្ស ឈ្មោះថាមិនទៀង ព្រោះអត្ថថា មានហើយត្រឡប់ជាមិនមានវិញ ។ សូម្បីវេទនាជាដើម គប្បីយល់ថា សម្បយុត្តដោយសោតសម្ផស្សតែម្យ៉ាង ។ បទថា **ធាតារម្មណមេវ** បានដល់ អារម្មណ៍ ពោលគឺ ធាតុនោះឯង ។ បទថា **បក្ខន្ទតិ** បានដល់ ធ្លាក់ចុះ ។ ម្យ៉ាងទៀត ពាក្យនោះជាសត្តមីវិភត្តតែម្យ៉ាង ។ កាលបើពោលដោយអំណាចព្យញ្ជនសន្ធិ លោកពោលថា **ធា-តារម្មណមេវ** ក្នុងពាក្យនេះ មានខ្លឹមសារយ៉ាងនេះថា **ធាតារម្មណេយេវ** ក្នុងអារម្មណ៍ គឺ ធាតុ ។ កាលបើពោលដោយអំណាចធាតុ ក្នុងពាក្យថា **វិមុច្ចតិ** នេះ រមែងបានដល់ អធិមោក្ខ មិនត្រេកអរ មិនទោមនស្ស ។ តាមពិតភិក្ខុអ្នកបំពេញធាតុកម្មដ្ឋាននេះ កាលអារម្មណ៍ មកប្រាកដដល់សោតទ្វារ រមែងកំណត់ថា ជាហេតុ ជាអារម្មណ៍ ដែលគួរកំណត់ដឹងជាអារម្មណ៍ដែលចរមក ជាអារម្មណ៍ដែលកើតឡើងមួយជួរខណៈ ។ រឿងពិស្តាររបស់អារម្មណ៍នោះ ពោលទុកហើយក្នុងសតិសម្បជញ្ញបព្វៈ ក្នុងសតិប្បដ្ឋានសូត្រ ។ តែវេទនានោះ ពោលទុកហើយក្នុងសតិប្បដ្ឋាននោះ

ដោយអំណាចចក្ខុទ្វារ ។ ក្នុងទីនេះ គប្បីជ្រាបដោយអំណាចសោតទ្វារ ។

ពិតហើយ ភិក្ខុបំពេញធាតុកម្មដ្ឋាន អ្នកធ្វើការកំណត់យ៉ាងនេះហើយ ចម្រើនវិបស្សនាយ៉ាងខ្លាំងក្លា សូម្បីកាលបើអារម្មណ៍មកប្រាកដក្នុងចក្ខុទ្វារជាដើម រមែងកើតអាវជ្ជនចិត្ត វោដ្ឋព្វនចិត្តដោយឧបាយមិនល្អ ដល់វោដ្ឋព្វនចិត្តហើយ បានអាសេវនចិត្តមួយខណៈ ឬពីរខណៈ ចិត្តក៏ធ្លាក់ចុះកាន់ភវង្គដូចដើម ក៏មិនកើតដោយអំណាចរាគៈជាដើម ភិក្ខុនេះ ឈ្មោះថា ដល់ទីបំផុតវិបស្សនាចាស់ក្លា , ភិក្ខុមួយអង្គ កើតជវនចិត្តមួយម្តង ដោយអំណាចរាគៈជាដើម តែក្នុងទីបំផុតជវនចិត្ត លោកនឹកដោយអំណាចរាគៈជាដើមថា ជវនចិត្តកើតដល់យើង ឈ្មោះថា កំណត់អារម្មណ៍បានហើយ មិនកើតដូច្នោះម្តងទៀត ។ ភិក្ខុមួយអង្គទៀត នឹកដល់មួយលើក ក៏កើតជវនចិត្តដោយអំណាចរាគៈជាដើម ជាលើក ទី ២ ទៀត និងកាលចប់លើកទី ២ កាលនឹកថា ជវនចិត្តកើតដល់យើងហើយ យ៉ាងនេះ ជាការដែលកំណត់អារម្មណ៍ដូចគ្នា ។ ក្នុងគ្រា ទី ៣ ក៏មិនកើតយ៉ាងនោះ ។

ក្នុងបណ្តាភិក្ខុទាំង ៣ អង្គនោះ អង្គទី ១ ចាស់ក្លា អង្គទី ៣ ទន់ខ្សោយ ។ តែពោលដោយអំណាចអង្គទី ២ គប្បីជ្រាបខ្លឹមសារនេះ ក្នុងព្រះសូត្រនេះ មានសត្វប្រចៀចជាគ្រឿងប្រៀបធៀប ដោយសភាពជាឥន្ទ្រីយ៍នោះឯង ។

ព្រះថេរៈកាលបើសម្ដែងកម្លាំងរបស់ភិក្ខុ អ្នកបំពេញធាតុកម្មដ្ឋាន ដោយអំណាចកំណត់ក្នុងសោតទ្វារយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្ដែងក្នុងកាយទ្វារ ទើបពោលពាក្យថា **តញ្ចេ អាវុសោ** ជាដើម ។ ព្រោះភិក្ខុអ្នកដល់អនិដ្ឋារម្មណ៍ រមែងលំបាកក្នុងទ្វារទាំង ២ គឺ សោតទ្វារ និងកាយទ្វារ ព្រោះដូច្នោះ ព្រះមហាថេរៈគិតថា ក្នុងអនាគតកាល កុលបុត្រអ្នកត្រូវការសិក្សា បំពេញសេចក្ដីព្យាយាម ដល់សេចក្ដីសង្រួមក្នុងទ្វារទាំង ២ នោះ នឹងធ្វើទីបំផុតនៃជាតិ ជរា មរណៈបានឆាប់រហ័ស ប្រៀបដូចបុរសម្ចាស់ស្រែ កាន់ចបដើរទៅត្រួតត្រាស្រែ មិនបន្ថែមដីក្នុងទីណាមួយ យកចបកាប់ដីចំពោះក្នុងទីខ្វះខាត ថែមដីក្នុងកន្លែងដែលមានស្មៅ ដូច្នោះ កាលនឹងសម្ដែងការសង្រួមក្នុងទ្វារទាំងពីរនេះហើយ ឲ្យរឹងមាំ ទើបផ្ដើមទេសនានេះ ។

បណ្ដាបទទាំងនោះ បទថា **សមុទាចរន្តិ** បានដល់ ព្យាយាម ។ បទថា **បាណិសម្ផស្សេន** បានដល់ ប្រហារដោយបាតដៃ ។ សូម្បីក្នុងពាក្យក្រៅពីនេះ ក៏មានន័យដូចគ្នា ។ បទថា **តថាភូតោ** ប្រែថា មានសភាវៈយ៉ាងនោះ ។ បទថា **យថាភូតស្មឹ** ប្រែថា តាមសភាវៈ ។ បទថា **កមន្តិ** ប្រែថា ប្រព្រឹត្តទៅ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ឯវំ ពុទ្ធំ**

***អនុស្សរតោ*** ជាដើម ។ ភិក្ខុអ្នកបំពេញចតុធាតុកម្មដ្ឋាន កាលនឹកដល់ ដោយន័យជាដើមថា ***ឥតិបិសោ ភគវា*** ឈ្មោះថា រលឹកដល់ព្រះពុទ្ធជាម្ចាស់ គឺ កាលរលឹកថា ពាក្យនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ហើយដូចគ្នា ក៏ឈ្មោះថា រលឹកដូចគ្នា ។ សូម្បីកាលរលឹក ដោយន័យមានជាអាទិ៍ថា ***ស្វាក្ខាតោ ភគវតា ធម្មោ*** ឈ្មោះថា រលឹកដល់ព្រះធម៌ សូម្បីរលឹកដល់ ***កកចូបមោវាទសូត្រ*** ក៏ឈ្មោះថា រលឹកដល់ដូចគ្នា ។ សូម្បីរលឹកដល់ ដោយន័យជាដើមថា ***សុប្បដិបន្នោ*** ឈ្មោះថា រលឹកដល់ព្រះសង្ឃ សូម្បីរលឹកដល់គុណរបស់ភិក្ខុអ្នកអត់ទ្រាំការកាត់ដោយរណា ក៏ឈ្មោះថា រលឹកដូចគ្នា ។ ក្នុងពាក្យថា ***ឧបេក្ខា កុសលនិស្សិតា សណ្ឋាតិ*** នេះ លោកប្រាថ្នាយក ***វិបស្សនុបេក្ខា*** ។ ក្នុងពាក្យថា ***ឧបេក្ខាកុសលនិស្សិតា សណ្ឋាតិ*** នេះ លោកប្រាថ្នា ***ឆឡង្គុបេក្ខា*** ឧបេក្ខាមានអង្គ ៦ ។ ក៏ឆឡង្គុបេក្ខានេះ ប្រព្រឹត្តទៅដោយអំណាចសេចក្ដីមិនត្រេកអរជាដើម ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍របស់ព្រះខីណាស្រពក៏ពិត សូម្បីយ៉ាងនោះ ភិក្ខុនេះ តាំងវិបស្សនារបស់ខ្លួនដោយសេចក្ដីសម្រេចនៃភាវនា តាមកម្លាំងសេចក្ដីព្យាយាម ក្នុងស្ថានរបស់ឆឡង្គុបេក្ខារបស់ព្រះខីណាស្រព ព្រោះដូច្នោះ វិបស្សនានោះឯង ទើបឈ្មោះថា ឆឡង្គុបេក្ខា ។

(៨១) គប្បីជ្រាបវិនិច្ឆ័យ ក្នុងអាបោធាតុនិទ្ទេស ដូចតទៅនេះ បទថា **អាបោគតំ** បានដល់ របស់ដែលឧបាទិន្នរូប ជ្រួតជ្រាបចូលទៅក្នុងអាបោធាតុទាំងអស់ មានលក្ខណៈជាទឹកសើមជ្រាប ។ ក៏ពាក្យដែលគប្បី ពោលក្នុងពាក្យថា **បិត្តំ សេម្ហំ** ជាដើមទាំងអស់ ព្រមទាំងន័យនៃការនា បានពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **បកុប្បតិ** បានដល់ ហូរទៅដោយឱឃៈ ឬហៀរពីសមុទ្រពចទៅ ។ វាមានសេចក្តីកម្រើកជាប្រក្រតីយ៉ាងនេះ ។ ក៏កាលវេលាដែលលោកវិនាសទៅដោយអាបោធាតុ មួយសែនកោដិចក្រវាឡពេញទៅដោយទឹកតែមួង ។ បទថា **ឱគច្ឆន្តិ** សេចក្តីថា ហូរទៅខាងក្រោម រហូតដល់អស់ វិនាសទៅដូចទឹកដែលដាក់លើចង្ក្រានភ្លើង ដូច្នោះ ។ ក៏ពាក្យដ៏សេសគប្បីជ្រាបដោយន័យមុននោះឯង ។

(៨២) គប្បីជ្រាបវិនិច្ឆ័យ ក្នុងតេជោធាតុនិទ្ទេសដូចតទៅនេះ បទថា **តេជោគតំ** បានដល់ របស់ដែលជាឧបាទិន្នរូបទាំងអស់ ដែលនៅក្នុងតេជោធាតុទាំងអស់ មានលក្ខណៈក្តៅ ។ មយ៉ាងទៀត ឈ្មោះថា **តេជោគតំ** ព្រោះនៅក្នុងភាវៈដែលក្តៅ គឺ តេជោធាតុ ។ ក្នុងអាបោធាតុខាងដើមក្តី ក្នុងវាយោធាតុខាងក្រោយក្តី ក៏ន័យនេះដូចគ្នា ។ បទថា **យេន ច** បានដល់ ដោយតេជោធាតុណា កាលវាកម្រើក កាយនេះក៏ក្តៅ កើតកំដៅដោយភាវៈ

ដែលគ្រាំគ្រាទៅ រយៈមួយថ្ងៃជាដើម ។

បទថា **យេន ច ជីរិយតិ** បានដល់ កាយនេះ រមែងទ្រុឌទ្រោម ដោយតេជោធាតុណា បុគ្គលក៏មានឥន្ទ្រិយ៍ខ្វះខាត អស់កម្លាំង ស្បែកស្វិត សក់ស្កូវជាដើម ដោយតេជោធាតុនោះ ។ បទថា **យេន ច បរិឌយ្ហតិ** សេចក្តីថា កាយនេះ រមែងក្តៅដោយតេជោធាតុណា ដែលកម្រើកហើយ បុគ្គលនោះស្រែកត្អូញថា ក្តៅ ក្តៅ រមែងប្រាថ្នា ការលាបដោយទឹកដោះថ្លា ច័ន្ទទេស ច័ន្ទក្រហមផ្សំនិងទឹកដោះថ្លា ១០០ ដង និងខ្យល់កើតពីការបក់ផ្លិតស្លឹកត្នោត ។ បទថា **យេន ច អសិតំ ខាយិតំ សាយិតំ សម្មា-បរិណាមំ គច្ឆតិ** សេចក្តីថា បាយជាដើម ដែលបរិភោគក្តី ទឹកផឹកជាដើម ដែលផឹកហើយក្តី មៀ្ស និងរបស់ទំពាជាដើម ដែលទំពាហើយក្តី ស្វាយទុំ ទឹកឃ្មុំ និងទឹកអំពៅជាដើម ដែលលិទ្ធហើយក្តី រមែងឆ្អិនដោយប្រពៃ គឺរមែងផ្លាស់ទៅជារស ជាដើមនោះឯង ។ ក្នុងសេចក្តីនេះ មានន័យសង្ខេបយ៉ាងនេះ ។ តែពាក្យដែលនឹងគប្បីពោលដោយពិស្តារទាំងអស់ ព្រមដោយការវិនិច្ឆ័យ បានពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **ហរិតន្តំ** បានដល់ របស់ខៀវស្រស់នោះឯង អធិប្បាយថា តេជោធាតុ អាស្រ័យស្មៅស្រស់ជាដើម ក៏រលត់ ។ បទថា **បន្ថន្តំ** បានដល់ ផ្លូវធំនោះឯង ។ បទថា

**សេលន្តិ** បានដល់ ភ្នំ ។ បទថា **ឧទកន្តិ** បានដល់ ទឹក ។ បទថា **រមណីយំ វា ភូមិភាគំ** បានដល់ ភូមិភាគប្រាសចាកស្មៅ និងគុម្ពឈើ ជាដើមដែលទំនេរ បានដល់ ភូមិភាគដែលល្អល្អ ។ បទថា **អនាហារា** បានដល់ មិនមានអាហារ គឺ មិនមានពូជ ។ លោកពោលសេចក្ដីវិការនៃតេជោ-ធាតុ តាមប្រក្រតីទុកដូច្នេះ ។ ក៏ពេលដែលលោក វិនាសដោយតេជោធាតុ តេជោធាតុក៏ឆេះមួយសែនកោដិចក្រវាឡ សូម្បីត្រឹមតែផេះ ក៏មិនសល់ឡើយ ។ បទថា **នហារុទទ្ទូលេន** បានដល់ ដោយសំណល់របស់ស្បែក ។ បទថា **អគ្គឹ គវេសន្តិ** សេចក្ដីថា មនុស្សទាំងឡាយកាន់យកពូជល្អិតបែបនេះ ស្វែងរកភ្លើង បានត្រឹមតែបន្តិច ក៏ភ្លឺចិញ្ចាចឡើង ។ ពាក្យដ៏សេសសូម្បីក្នុងទីនេះ គប្បីជ្រាបដូចន័យមុននោះឯង ។

(៨៣) គប្បីជ្រាបវិនិច្ឆ័យ ក្នុងវាយោធាតុនិទ្ទេស ដូចតទៅនេះ បទថា **ឧទ្ធង្គមា វាតា** បានដល់ ខ្យល់ដែលបក់ឡើងខាងលើ ដែលប្រព្រឹត្តទៅដោយអាការ មានការកើ និងឡើកជាដើម ។ បទថា **អធោគមា វាតា** បានដល់ ខ្យល់បក់ចុះក្រោម មានការបញ្ចេញឧច្ចារៈ បស្សាវៈ ជាដើម ។ បទថា **កុច្ឆិសយា វាតា** បានដល់ ខ្យល់ដែលបក់ខាងក្រៅពោះវៀនធំជាដើម ។ បទថា **កោដ្ឋាសយា វាតា** បានដល់ ខ្យល់ខាងក្នុងពោះវៀនធំ ។

បទថា **អង្គមង្គានុសារិនោ** បានដល់ ខ្យល់ដែលកើតពីការបត់ចូល លាតចេញជាដើម ដែលជ្រួតជ្រាបទៅតាមអវយវៈតូចធំ ក្នុងរាងកាយទាំងអស់តាមសរសៃ ។ បទថា **អស្សាសោ** បានដល់ ខ្យល់ដកដង្ហើមចូល ។ បទថា **បស្សាសោ** បានដល់ ខ្យល់ដកដង្ហើមចេញ ។ ក្នុងសេចក្ដីនេះមានសេចក្ដីសង្ខេបប៉ុណ្ណេះ ។ តែកាលពោលដោយពិស្ដារ ពាក្យដែលនឹងគប្បីពោលនោះទាំងអស់ ព្រមទាំងការវិនាន័យ បានពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **គាមម្បិ វហតិ** បានដល់ ផាត់នាំផ្ទះទាំងអស់ឲ្យខ្ទេចខ្ទីល្អិតទៅ ។ សូម្បីក្នុងនិគមជាដើម ក៏មានន័យនោះដូចគ្នា ។ វេលាលោកវិនាសដោយខ្យល់នេះ លោកសម្ដែងការផ្លាស់ប្ដូរនៃវាយោធាតុ ដោយអំណាចការកម្ចាត់មួយសែនកោដិចក្រវាឡ ។ បទថា **វិធូបនេន** បានដល់ ផាត់នាំភ្លើងទៅ ។ បទថា **ឱស្សវនេ** បានដល់ សំយាបផ្ទះ ក៏ទឹកហូរចុះមកតាមសំយាបផ្ទះនោះ ព្រោះដូច្នោះ លោកហៅ សំយាបផ្ទះនេះថា **ឱស្សវនេ** ។ ពាក្យដ៏សេសសូម្បីក្នុងទីនេះ គប្បីជ្រាបដោយន័យមុននោះឯង ។

(៨៤) ក្នុងពាក្យថា **សេយ្យថាបិ អាវុសោ** នេះ លោកសម្ដែងដល់អ្វី ។ លោកសម្ដែងដល់មហាភូតរូប ដែលពោលទុកហើយក្នុងកាលមុនថា មិនមែនសត្វ ។ បទថា **កដ្ឋំ** បានដល់ ទព្វសំភារៈ ។ បទថា **វល្លី** បាន

ដល់ វល្លិ៍សម្រាប់ចង ។ បទថា **តិណំ** បានដល់ ដីសម្រាប់បូក ។ បទថា **មត្តិកំ** បានដល់ ដីសម្រាប់លាប ។ បទថា **អាកាសោ បរិវារិតោ** សេចក្ដីថា អាកាសចន្លោះដែលនៅឡោមព័ទ្ធឈើជាដើម ទាំងនោះខាងក្នុង ទាំងខាងក្រៅ ។ បទថា **អគារំ** ក្នុងពាក្យថា **អគារំ ត្វេវ សង្ខ្យំ គច្ឆតិ** គ្រាន់តែជាបញ្ញត្តិ ។ តែកាលឈើជាដើម បែកចេញជាគំនរៗ គំនរឈើ លោកហៅថា **កដ្ឋរាសិ វល្លិរាសិ** ទាំងនោះ ។ បទថា **ឯវមេវខោ** សេចក្ដីថា អាកាសដែលនៅឡោមឆ្អឹងជាដើម ទាំងខាងក្នុង និងខាងក្រៅ អស្រ័យឆ្អឹងជាដើមទាំងនោះ ទើបរាប់ថា រូប ទាំងអស់ដូច្នោះដូចគ្នា ។

ផ្ទះដែលអាស្រ័យឈើជាដើម ឈ្មោះថា **គេហៈ** លោកហៅថា ខត្តិយគេហៈ ព្រាហ្មណគេហៈ យ៉ាងណា សូម្បីរូប ក៏ដូច្នោះដូចគ្នា លោកហៅថា ខត្តិយសរីរៈ ព្រាហ្មណសរីរៈ ។ ការពិតក្នុងទីនេះ សភាវៈអ្វីៗ ដែលឈ្មោះថា សត្វ ឬជីវៈ មិនមាន ។

សួរថា ពាក្យថា **អជ្ឈត្តិកញ្ចេ អាវុសោ ចក្ខុ** នេះ លោកផ្ដើមទុកព្រោះហេតុអ្វី ។ ឆ្លើយថា ឧបាទាយរូប អរូបក្ខន្ធ ៤ និងអរិយសច្ចៈ ៣ លោកមិនបានពោលទុកខាងដើម ឥឡូវនេះ ដើម្បីនឹងពោលឧបាទាយរូបជាដើមទាំងនោះ លោកទើបផ្ដើមទេសនានេះទុក ។ បណ្ដាបទទាំងនោះ

បទថា **ចក្ខុំ អបរិភិន្នំ** បានដល់ កាលចក្ខុបសាទលេតទៅក្តី ត្រូវអារម្មណ៍ខាងក្រៅមកជំទាស់ក្តី ត្រូវប្រមាត់ ស្លេស្ម៍ និងឈាម ពាក់ព័ន្ធក្តី ចក្ខុ-បសាទមិនអាចជាបច្ច័យដល់ចក្ខុវិញ្ញាណបាន មានត្រឹមឈ្មោះថា បែកទៅប៉ុណ្ណោះ តែអាចជាបច្ច័យដល់ចក្ខុវិញ្ញាណ ឈ្មោះថា **អបរិភិន្ន** គឺ មិនបែកធ្លាយទៅ ។ បទថា **ពាហិរា ច រូបា** បានដល់ រូប ដែលមានសមុដ្ឋាន ៤ ខាងក្រៅ ។ បទថា **តជ្ជោ សមន្នាហារោ** បានដល់ អាស្រ័យចក្ខុនោះ និងរូប ត្រិះរិះដល់ភវង្គ ហើយកើតមនសិការៈ អធិប្បាយថា កិរិយា-មនោធាតុចិត្ត ក្នុងចក្ខុទ្វារ អាចគិតដល់ភវង្គ កិរិយាមនោធាតុចិត្តនោះមិនអាចសូម្បីដល់អ្នកបញ្ជូនចិត្តទៅក្នុងទីដទៃ ព្រោះរូបារម្មណ៍មិនប្រាកដ ។ បទថា **តជ្ជស្ស** បានដល់ សមគួរដល់ចិត្តនោះ ។ បទថា **វិញ្ញាណភាគស្ស** បានដល់ ចំណែកនៃ វិញ្ញាណ ។ លោកសម្តែងសច្ចៈ ៤ ដោយអាការ ១២ ក្នុងពាក្យថា **យថាភូតស្ស** ជាដើម ។ បណ្តាបទទាំងនោះ បទថា **តថាភូតស្ស** សេចក្តីថា កើតព្រមដោយចក្ខុវិញ្ញាណ គឺ បរិបូរណ៍ដោយចក្ខុវិញ្ញាណ ។ បទថា **រូបំ** សេចក្តីថា រូបដែលមានសមុដ្ឋាន ៣ រមែងបានក្នុងខណៈចក្ខុវិញ្ញាណ ព្រោះចក្ខុវិញ្ញាណជាតួធ្វើឲ្យរូបកើត សូម្បីរូបដែលមានសមុដ្ឋាន ៤ រមែងបានក្នុងខណៈចិត្តតពីនោះ ។ បទថា **សង្គហំ**

**គច្ឆតិ** ប្រែថា ដល់ការរាប់ ។ ចេតសិកធម៌ មានវេទនាជាដើម ក៏សម្បយុត្ត ដោយចក្ខុវិញ្ញាណដូចគ្នា ។ វិញ្ញាណ ក៏គឺ ចក្ខុវិញ្ញាណនោះឯង ។ លោក ពោលចេតនាថា **សង្ខារ** ទុកពាក្យនេះ ។ បទថា **សង្គហោ** ប្រែថា រួមគ្នា ។ បទថា **សន្និបាតោ** ប្រែថា មកព្រមគ្នា ។ បទថា **សមវាយោ** បានដល់ ពួក ។ បទថា **យោ បដិច្ចសមុប្បាទំ បស្សតិ** បានដល់ អ្នកណាឃើញ បច្ច័យទាំងឡាយ ។ បទថា **សោ ធម្មំ បស្សតិ** បានដល់ អ្នកនោះឈ្មោះថា ឃើញបដិច្ចសមុប្បាទធម៌ ។ ពាក្យទាំងពួង មានឆន្ទៈជាដើម ជាវេវចនៈ របស់តណ្ហានោះឯង ។ ពិតហើយ តណ្ហាលោកហៅថា ឆន្ទៈ ព្រោះធ្វើ សេចក្ដីពេញចិត្ត ហៅថា **អាល័យ** ព្រោះធ្វើសេចក្ដីមិននឹងនំ ហៅថា **អនុនយ** ព្រោះធ្វើសេចក្ដីត្រេកអរ ហៅថា **អជ្ឈោសាន** ព្រោះដាក់ចុះលេបទុក ។ ពាក្យថា **ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ** ជាឈ្មោះព្រះនិព្វានទាំងអស់ ។ ក្នុងព្រះបាលីមកសច្ចៈ ៣ ប៉ុណ្ណោះ គួរយកមគ្គសច្ចៈមករួមទុកផង ដោយ ប្រការដូច្នោះ ។ ក្នុងឋានៈ ៣ ពួកនេះ **ទិដ្ឋិសង្កប្ប វាចាកម្មន្ត អាជីវ វាយាម សតិ សមាធិ ភាវនា បដិវេធ** នេះ ឈ្មោះថា **មគ្គ** ។ បទថា **ពហុកតំ ហោតិ** សេចក្ដីថា សូម្បីអធិប្បាយត្រឹមប៉ុណ្ណោះ ក៏ជាការធ្វើតាម ពាក្យប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ជាច្រើន ។ សូម្បីក្នុងភារៈ

មានជាអាទិថា **អជ្ឈត្តិកំ ចេ អាវុសោ សោតំ** ក៏ន័យនេះដូចគ្នា ។ ចំណែកក្នុងមនោទ្វារ ភវង្គចិត្ត ឈ្មោះថា ចិត្តខាងក្នុង ភវង្គចិត្តនោះ សូម្បីរលត់ទៅហើយ មិនអាចជាបច្ច័យរបស់អាវជ្ជនចិត្តបាន ភវង្គចិត្តដែលមានកម្លាំងខ្សោយសូម្បីកំពុងប្រព្រឹត្តទៅ ក៏ឈ្មោះថា បែកធ្លាយហើយ ដែលអាចជាបច្ច័យរបស់អាវជ្ជនចិត្ត ឈ្មោះថា មិនបែកធ្លាយ ។ ពាក្យថា **ពាហិរា ច ធម្មា ។បេ។ នេវ តាវ តជ្ជស្ស** នេះ លោកពោលទុកដោយសម័យភង្គចិត្តប៉ុណ្ណោះ ។ ក្នុងវារៈទី ២ លោកពោលសំដៅយកភិក្ខុអ្នកបញ្ជូនចិត្តទៅក្នុងទីដទៃ ដោយពិចារណាឈាន ដែលស្ទាត់ជំនាញធ្វើទុកក្នុងចិត្តនូវកម្មដ្ឋានដែលស្ទាត់ជំនាញ ឬទន្ទេញព្រះពុទ្ធវចនៈដែលជំនាញជាដើម ។ រូប សូម្បីមានសមុដ្ឋាន ៤ ក៏បានឈ្មោះថា រូប ក្នុងវារៈនេះ ។ ព្រោះមនោវិញ្ញាណ រមែងឲ្យរូបកើតឡើង ។ ចេតសិកធម៌ មានវេទនាជាដើម ក៏សម្បយុត្តដោយមនោវិញ្ញាណ ។ វិញ្ញាណ ក៏គឺ មនោវិញ្ញាណនោះឯង ។ តែក្នុងទីនេះ សង្ខារទាំងឡាយ លោកកាន់យកដោយផស្សចេតនាដូចគ្នា ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។

ដូច្នោះ ព្រះមហាថេរៈ កាលពិចារណាចំពោះឯកទេសក្នុងកាលមុន ទើបយកមកតាំងទុកក្នុងទីនេះ ហើយសម្តែងចែកទេសនាដែលមិនសម្បូរណ៍

*ទាំងអស់ក្នុងកាលមុនទុកដោយអំណាចទ្វារ ចប់ព្រះសូត្រទៅតាមលំដាប់អនុសន្ធិ ។*

( ចប់ អដ្ឋកថា មហាហត្ថិបទោបមសូត្រ ទី៨ )

# អដ្ឋកថា

## មហាសារោបមសូត្រទី ៩

(៨៥-៨៧) *មហាសារោបមសូត្រផ្ដើមឡើងថា ខ្ញុំម្ចាស់បានស្ដាប់មក ហើយយ៉ាងនេះ គប្បីជ្រាបវិនិច្ឆ័យ ក្នុងមហាសារោបមសូត្រនោះដូចតទៅនេះ ៖*

*បទថា* ***អចិរបក្កន្តេ*** *សេចក្ដីថា កាលទេវទត្តបំបែកសង្ឃ ញ៉ាំងលោហិតុប្បាទកម្ម ធ្វើព្រះលោហិតឲ្យពុះពង ចៀសចេញទៅមិនយូរប៉ុន្មាន ក៏នាំបក្សពួក បំបែកគ្នាទៅតាមភេទដើមរបស់ខ្លួន ។ ក្នុងពាក្យថា* ***ឥធ ភិក្ខវេ ឯកច្ចោ កុលបុត្តោ*** *លោកមិនបានកំណត់ថា កុលបុត្រ ឈ្មោះឯណោះ សូម្បីយ៉ាងនេះ ពាក្យនេះគប្បីជ្រាបថា លោកពោលសំដៅយកចំពោះទេវទត្ត ប៉ុណ្ណោះ ។ ព្រោះទេវទត្ត ឈ្មោះថា ជាកុលបុត្រដោយជាតិ ព្រោះកើតក្នុងវង្សព្រះបាទឱក្កាករាជ តាមខ្សែស្រឡាយ មហាសម្បត្តិរាជ្យដែលមិនលាយឡំវង្សដទៃ ។ បទថា* ***ឱតិណ្ណោ*** *បានដល់ ជាតិរបស់អ្នកណា នៅខាងក្នុងអ្នកនោះ ឈ្មោះថា អ្នកត្រូវជាតិគ្របសង្កត់ហើយ ។ សូម្បីក្នុងជរាជាដើម ក៏មានន័យនេះដូចគ្នា ។ បច្ច័យ ៤ ឈ្មោះថា* ***លាភ*** *ក្នុងពាក្យថា លាភនិងសក្ការៈជាដើម ។*

បទថា **សក្ការោ** បានដល់ បច្ច័យ ៤ ទាំងនោះ ដែលគេចាត់ទុកល្អហើយ ។ បទថា **សិលោកោ** បានដល់ ការនិយាយសរសើរ ។ បទថា **អភិនិព្វត្តេតិ** បានដល់ ឲ្យកើត ។ បទថា **អប្បញ្ញាតា** សេចក្ដីថា មិនប្រាកដក្នុងស្ថាន ដែលជនទាំងពីរស្ថិតនៅ រមែងមិនបានសូម្បីគ្រាន់តែអាហារ និងគ្រឿងស្លៀកដណ្ដប់ ។ បទថា **អប្បេសក្ខា** បានដល់ ពួកដែលមិនមានបរិវារ មិនមានមនុស្សហោមរោមនៅខាងមុខ ឬខាងក្រោយ ។ បទថា **សារេន សារករណីយំ** បានដល់ របស់ណាមួយ មានក្លៀកង់ ទឹម និងនង្គ័លជាដើម ដែលធ្វើដោយឈើខ្លឹម ។ បទថា **សាខាបលាសំ អគ្គហេសិ ព្រហ្មចរិយស្ស** សេចក្ដីថា បច្ច័យ ៤ ឈ្មោះថា មែកឈើ ស្លឹកស្រស់ នៃសាសនព្រហ្មចរិយៈ ដែលមានមគ្គផលជាសារៈ បានកាន់យកតែមែកឈើស្លឹកស្រស់នោះ ។ បទថា **តេន ច វោសានំ អាបាទិ** សេចក្ដីថា ក៏ដោយហេតុនោះឯង ព្រះទេវទត្តនោះ ទើបបញ្ឈប់ ដោយយល់ថា ប៉ុណ្ណឹងល្មមហើយ យើងជួបសារៈហ្នឹងហើយ ។

(៨៨-៨៩) បទថា **ញាណទស្សនំ អភិនិព្វត្តេតិ** សេចក្ដីថា ព្រះទេវទត្តបានអភិញ្ញា ៥ គឺ ទិព្វចក្ខុនៅទីបំផុតរបស់អភិញ្ញា ៥ , ទិព្វចក្ខុនោះ លោកពោលថា ញាណទស្សនៈ ក្នុងព្រះសូត្រនេះ ។ បទថា **អជានំ អបស្ស**

**វិហរន្តិ** សេចក្ដីថា ភិក្ខុទាំងឡាយមិនដឹងសុខុមរូបណាៗ ដោយទីបំផុត សូម្បីបិសាចប្រឡាក់ធូលី ក៏មិនឃើញ ។ បទថា **អសមយវិមោក្ខំ អារាធេតិ** សេចក្ដីថា កុលបុត្ររមែងត្រេកអរ រមែងឲ្យដល់ព្រម រមែងបាន នូវលោកុត្តរធម៌ ៩ ដែលលោកពោលទុកយ៉ាងនេះ **អសមយវិមោក្ខ** តើ ដូចម្ដេច ? គឺ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ នេះឈ្មោះថា **អសមយវិមោក្ខ** ។ ព្រោះសមាបត្តិដែលជាលោកិយៈ រមែងផុតចាកធម៌ ដែលជាសត្រូវក្នុងខណៈដែលដល់អប្បនានោះឯង ព្រោះដូច្នោះ លោកិយ-សមាបត្តិនោះ ទើបលោកពោលថា ជាសមយវិមោក្ខយ៉ាងនេះ **សមយ-វិមោក្ខ** តើដូចម្ដេច ? គឺ រូបាវចរសមាបត្តិ ៤ អរូបាវចរសមាបត្តិ ៤ នេះ ហៅថា សមយវិមោក្ខ ចំណែកលោកុត្តធម៌ រមែងផុតបានគ្រប់កាល ព្រោះ មគ្គចិត្ត ផលចិត្ត ដែលរួចផុតមួយខណៈ ក៏ជាការរួចផុតហើយ និព្វាន ក៏រួចផុតហើយជាសមុច្ឆេទ ពីសព្វកិលេសតែម្យ៉ាង ព្រោះដូច្នោះ ធម៌ទាំង ៩ នេះ ទើបលោកពោលថា **អសមយវិមោក្ខ** ។

(៩០) បទថា **អកុប្បា ចេតោវិមុត្តិ** បានដល់ វិមុត្តិសម្បយុត្តដោយ អរហត្តផល ។ ប្រយោជន៍នៃព្រហ្មចរិយៈនោះមាន ព្រោះដូច្នោះ ព្រហ្ម-ចរិយនោះ ទើបឈ្មោះថា **ឯតទត្ថ** គឺ ព្រហ្មចរិយៈ មានព្រះអរហត្តផល

នោះជាប្រយោជន៍ លោកអធិប្បាយថា នេះជាប្រយោជន៍ នៃព្រហ្មចរិយៈនោះ ។ បទថា **ឯតំ សារំ** សេចក្ដីថា អរហត្តមគ្គ និងអរហត្តផល នេះជាសារៈនៃព្រហ្មចរិយៈ ។ បទថា **ឯតំ បរិយោសានំ** សេចក្ដីថា អរហត្តផលនេះ ជាទីបំផុតនៃព្រហ្មចរិយៈ ។ នេះជាទីបំផុត មិនមានផលដែលនឹងគប្បីសម្រេចក្រៃលែងជាងនេះ ព្រោះដូច្នោះ ទើបលោកបញ្ចប់ទេសនាតាមអនុសន្ធិយ៉ាងនេះឯង ។

( ចប់ អដ្ឋកថា មហាសារោបមសូត្រ ទី ៩ )

# អដ្ឋកថា

##ចូឡសារោបមសូត្រ ទី ១០

(៩១-៩៨) ចូឡសារោបមសូត្រ ផ្ដើមឡើងថា ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងចូឡសារោបមសូត្រនោះ ដូចតទៅនេះ ។

បទថា **បិង្គលកោច្ឆោ** បានដល់ ព្រាហ្មណ៍អ្នកមានធាតុលឿង ក៏ពាក្យថា **កោច្ឆោ** នេះ ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ព្រោះដូច្នោះ ព្រាហ្មណ៍នោះ ទើបលោកហៅថា បិង្គលកោច្ឆៈ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សង្ឃិនោ** ជាដើម សមណព្រាហ្មណ៍ឈ្មោះថា **សង្ឃិនោ** ព្រោះមានពួក ពោលគឺ ប្រជុំនៃអ្នកបួស ។ ឈ្មោះថា **គណិនោ** ព្រោះមានគណៈនោះឯង ។ ឈ្មោះថា **គណាចរិយា** ព្រោះជាអាចារ្យនៃគណៈដោយអំណាចអាចារសិក្ខាបទ ។ បទថា **ញាតា** បានដល់ អ្នកដែលស្គាល់គ្នាទូទៅ គឺ អ្នកប្រាកដ បានដល់ ដែលគេលើកតំកើង ដោយន័យមានជាអាទិ៍ថា ជាអ្នកប្រាថ្នាតិច សន្ដោស មិនស្ញៀកដណ្ដប់នូវសំពត់ ព្រោះជាអ្នកប្រាថ្នាតិច ។ ឈ្មោះថា **យសស្សិនោ** ព្រោះជា អ្នកមានយស ។ បទថា **តិត្ថករា** ប្រែថា ម្ចាស់លទ្ធិ ។ បទថា **សាធុសម្មតា** បានដល់ ដែលគេសន្មតយ៉ាងនេះថា មនុស្សទាំងនេះ ជាមនុស្សមានប្រយោជន៍ ជា

មនុស្សល្អ ជាសប្បុរស ។ បទថា **ពហុជនស្ស** បានដល់ អ្នកមិនបាន ស្តាប់ ដែលជាបុថុជ្ជនអន្ធពាល ។

ឥឡូវនេះ កាលទ្រង់នឹងសម្តែងមនុស្សទាំងនោះ ទើបត្រាស់ថា **សេយ្យថីទំ បូរណោ** យ៉ាងនេះជាដើម ។ បណ្តាបទទាំងនោះ បទថា **បូរណោ** ជាឈ្មោះរបស់ម្ចាស់លទ្ធិនោះ ដែលប្រកាសខ្លួនថាជាសាស្តា ។ ពាក្យថា **កស្សបោ** ជាគោត្រ ។ បានឮថា ម្ចាស់លទ្ធិឈ្មោះបូរណៈ នោះ ជាមនុស្សគម្រប់ទីមួយរយគត់ របស់ត្រកូលមួយដែលមានទាសៈ ៩៩ នាក់ ។ ដោយហេតុនោះ ទើបមនុស្សទាំងឡាយហៅគេថា បូរណោ ។ ក៏ព្រោះគេជា ទាសមង្គល ទើបមិនមានអ្នកពោលថា គេធ្វើកិច្ចដែលធ្វើបានដោយលំបាក ឬមិនធ្វើកិច្ចដែលអ្នកណាគេមិនធ្វើ ។ គេគិតថា យើងនឹងនៅទីនេះធ្វើអ្វី ហើយក៏គេចចេញទៅ ។ លំដាប់នោះ ពួកចោរបានដណ្តើមយកសំពត់ របស់គេទៅ ។ គេមិនមានការបិទបាំងសូម្បីដោយស្លឹកឈើ ឬស្មៅ ក៏ ចូលទៅដល់ភូមិមួយទាំងដែលអាក្រាតកាយនោះឯង ។ ពួកមនុស្សឃើញ គាត់ ហើយគិតថា សមណៈនេះ ជាព្រះអរហន្ត ជាអ្នកប្រាថ្នាតិច មិនមាន អ្នកណាស្មើនឹងសមណៈនេះទេ ទើបកាន់យកបង្អែម និងចំអាបជាដើមចូល ទៅរក ។ គេគិតថា រឿងនេះកើតឡើង ព្រោះយើងមិនស្លៀកសំពត់ តាំង

ពីនោះមកសូម្បីបានសំពត់ ក៏មិនស្លៀក គេបានកាន់យកការមិនស្លៀកសំពត់នោះ នោះឯងជាបព្វជ្ជា ។ សូម្បីមនុស្សដទៃ ៗ ប្រមាណ ៥០០ នាក់ ក៏បួសក្នុងសម្នាក់របស់ខ្លួន លោកសំដៅយកម្ចាស់លទ្ធិនោះឯង ទើបពោលថា បូរណកស្សបៈ ។ ពាក្យថា **មក្ខលិ** ជាឈ្មោះរបស់ម្ចាស់លទ្ធិនោះ ។ ពាក្យថា **គោសាលោ** ជាឈ្មោះទី ២ ព្រោះកើតក្នុងរោងគោ ។ បានឮថា គេកាន់ថ្នាំងប្រេងកំពុងដើរទៅលើដីដែលមានភក់ ចៅហ្វាយនាយប្រាប់ថា ប្រយ័ត្នរអិល ។ គេរអិលដួលដោយសេចក្ដីធ្វេសប្រហែស ហើយផ្ដើមនឹងគេចរត់ទៅ ព្រោះខ្លាចចៅហ្វាយ ។ ចៅហ្វាយរត់ទៅចាប់ជាយសំពត់ទាន់ ។ គេបោលសំពត់ រត់ទៅទាំងគ្មានសំពត់ជាប់ខ្លួន ។ ពាក្យដ៏សេសដូចគ្នានឹងម្ចាស់លទ្ធិបូរណៈនោះដែរ ។ ពាក្យថា **អជិត** ជាឈ្មោះរបស់ម្ចាស់លទ្ធិនោះ ។ គេឈ្មោះថា **កេសកម្ពល** ។ ព្រោះស្លៀកសំពត់ធ្វើពីសក់មនុស្ស ។ ហេតុនោះ ទើបគេរួមទាំងពីរហៅថា **អជិតកេសកម្ពល** ។ ក្នុងពាក្យនោះ សំពត់កម្ពលដែលគេធ្វើដោយសក់មនុស្ស ឈ្មោះថា កេស-កម្ពល ។ ដែលឈ្មោះថា សំពត់ដ៏អាក្រក់ជាងសំពត់កេសកម្ពលនោះ មិនមាន ។ ដូចដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ដែលជាសំពត់ដាន ដោយអំបោះប្រភេទណាមួយ សំពត់កម្ពល លោកពោលថា អាក្រក់ជាង

សំពត់ទាំងនោះ ម្នាលភិក្ខុទាំងឡាយ សំពត់កេសកម្ពល កាលត្រជាក់ក៏ត្រជាក់ កាលណាក្តៅក៏ក្តៅ មានពណ៌អាក្រក់ មានក្លិនស្អុយ និងមានសម្ផស្សមិនសប្បាយ ។ ពាក្យថា **បកុធោ** ជាឈ្មោះរបស់ម្ចាស់លទ្ធិនោះ ។ ពាក្យថា **កច្ចាយនោ** ជាគោត្រ ។ លោករួមទាំងនាម និងគោត្រហៅថា **បកុធកច្ចាយនៈ** ។ ម្ចាស់លទ្ធិនោះ ជាអ្នកហាមទឹកត្រជាក់ សូម្បីនឹងបន្ទោរបង់ឧច្ចារៈ ក៏មិនប្រើទឹក ។ បានទឹកក្តៅ ឬទឹកបាយទើបប្រើ ។ គេដើរឆ្លងស្ទឹង ឬទឹកតាមផ្លូវ ក៏គិតថា យើងដាច់សីល ហើយពូនខ្សាច់ជាស្តូប អធិដ្ឋានសីល ទើបដើរទៅ បកុធកច្ចាយនៈនេះ ជាម្ចាស់លទ្ធិដែលមិនមានយសសក្តិបែបនេះ ។ ពាក្យថា **សញ្ជយោ** ជាឈ្មោះរបស់ម្ចាស់លទ្ធិនោះ ។ ឈ្មោះថា **វេលដ្ឋបុត្រ** ព្រោះជាបុត្ររបស់វេលដ្ឋៈ ។ ម្ចាស់លទ្ធិឈ្មោះថា **និគន្ថ** ដោយបាននាម ព្រោះនិយាយយ៉ាងនេះថា ពួកយើងមិនមានកិលេសជាគ្រឿងរួបរឹត មិនមានកិលេសពពាក់ពពូនថា ពួកយើងវៀរចាកគ្រឿងរួបរឹត គឺ កិលេស ។ ឈ្មោះថា **នាដ្ឋបុត្រ** ព្រោះជាបុត្ររបស់នាដ្ឋកៈ អ្នករបាំ ។ បទថា **អព្ភញ្ញឹសុ** សេចក្តីថា សមណ-ព្រាហ្មណ៍ដឹងមិនដឹងក៏ដោយ ដែលពួកគេប្រកាសទុក ។ លោកពោលអធិប្បាយទុកថា បើការប្រកាសរបស់ពួកគេនោះ ជានិយ្យានិកៈមែន គេ

ទាំងអស់ក៏ដឹង បើមិនជានិយ្យានិកៈមែន ពួកគេក៏មិនដឹង ព្រោះដូច្នោះ សេចក្តីនេះទើបមានយ៉ាងនេះថា ការប្រកាសរបស់ពួកគេ ជានិយ្យានិកៈ ឬជាអនិយ្យានិកៈ ។

លំដាប់នោះព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បដិសេធថា ល្មមហើយ ព្រោះមិនមានប្រយោជន៍ ដោយការពោលប្រកាស ដែលជាអនិយ្យានិកៈ របស់ម្ចាស់លទ្ធិនោះ កាលណានឹងប្រកាសបទដែលមានប្រយោជន៍ ដោយឧបមា ដើម្បីទ្រង់នឹងសម្តែងចំពោះធម៌ ទើបទ្រង់ត្រាស់ពាក្យថា ព្រាហ្មណ៍ តថាគតនឹងសម្តែងធម៌ដល់អ្នកយ៉ាងនេះជាដើម ។

(៩៦) បណ្តាបទទាំងនោះ បទថា **សច្ឆិកិរិយាយ** ប្រែថា ដើម្បីធ្វើឲ្យច្បាស់ ។ បទថា **ន ឆន្ទំ ជនេតិ** សេចក្តីថា មិនឲ្យកើតសេចក្តីពេញចិត្ត ចង់នឹងធ្វើ ។ បទថា **ន វាយមតិ** បានដល់ មិនធ្វើសេចក្តីព្យាយាម សេចក្តីឧស្សាហ៍ ។ បទថា **ឱលីនវុត្តិកោ ច ហោតិ** បានដល់ ជាអ្នកមានអធ្យាស្រ័យថោកទាប ។ បទថា **សាថិលិកោ** បានដល់ អ្នកកាន់សាសនាធូរៗ គឺ កាន់យកសាសនាធូររលុង គឺ មិនមុឹងម៉ាត់ ។

(៩៧) បទថា **ឥធ ព្រាហ្មណ ភិក្ខុ វិវេច្ចេវ កាមេហិ** សួរថា ធម៌មានបឋមជ្ឈាន ជាដើមទាំងនេះ នឹងប្រសើរជាងញាណទស្សនៈបានយ៉ាង

ណា ។ ឆ្លើយថា ព្រោះធម៌ទាំងឡាយ មានបឋមជ្ឈានជាដើម ជាបាទរបស់ វិបស្សនា ឈ្មោះថា ទាបជាង ព្រោះធ្វើឲ្យជាបាទនៃនិរោធ ធម៌ទាំងនេះ ឈ្មោះថា ជាបាទនៃនិរោធ ព្រោះដូច្នោះគប្បីជ្រាបថា ញាណទស្សនៈនោះ ប្រសើរជាង ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បញ្ចប់ព្រះសូត្រនេះ តាម អនុសន្ធិដោយប្រការដូច្នេះ ។ ក្នុងវេលាបញ្ចប់ទេសនា ព្រាហ្មណ៍ក៏តាំង ក្នុងសរណៈនោះ ។

( ចប់ អដ្ឋកថា ចុល្លសារោបមសូត្រ ទី ១០ )

ការពណ៌នាសេចក្តីនៃមជ្ឈិមនិកាយ មូលបណ្ណាសកៈ
ដែលមាន ១០ សូត្រ ក៏ចប់ស្រេចហើយដែរ ។
បបញ្ចសូទនី អដ្ឋកថា មជ្ឈិមនិកាយ បឋមភាគ

**លេខ ២១**

រួមព្រះសូត្រដែលមានក្នុងវគ្គនេះគឺ
កកចូបមសូត្រ ១ អលគទ្ទូបមសូត្រ ២ វម្មិកសូត្រ ៣ រថវិនីតសូត្រ ៤ និវាបសូត្រ ៥
ចាសរាសិសូត្រ ៦ ចុល្លហត្ថិបទោបមសូត្រ ៧ មហាហត្ថិបទោបមសូត្រ ៨
មហាសារោបមសូត្រ ៩ ចុល្លសារោបមសូត្រ ១០ ។


នត្ថិ សន្តិ បរំ សុខំ
ព្រះរាជាណាចក្រកម្ពុជា